ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្រ្តជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ឆ្នាំ ២០១៩-២០២៣

រៀបចំដោយ

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

រាជធានីភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០១៨

# បុព្វកថា

សេចក្ដីសម្រេចលេខ ១៣៩ សសរ ស្ដីពីសូចនាករតាមដានរួមគ្នា ឆ្នាំ២០១៤-២០១៨ ដើម្បីបង្កើនប្រសិទ្ធភាព និងផ្ដល់សមត្ថភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានដាក់បញ្ចូលការបង្កើតយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ដែលជាធាតុចេញមួយនៃសូចនាករ។ យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិសម្រេចបានជោគជ័យពីផែនការមេស្ថិតិ ឆ្នាំ២០០៨-២០១៥ ដែលបាននាំមកនូវសមិទ្ធិផលគួរឱ្យកត់សម្គាល់ក្នុងប្រព័ន្ធស្ថិតិជាតិតាមរបាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០១២ ប៉ុន្តែក៏នៅមានចំណុចខ្សោយមួយចំនួនដែលត្រូវដោះស្រាយតាមរយៈយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិនេះ។

ប្រព័ន្ធស្ថិតិជាតិត្រូវបានប្រឈមនឹងកង្វះខាតគួរឱ្យកត់សម្គាល់អំពីធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ទោះបីមានតម្រូវការកើនឡើងសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការតាមដានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក៏ដោយ។ ជំរឿន និងអង្កេតសំខាន់ៗមួយចំនួនដែលនឹងត្រូវធ្វើក្នុងរយៈពេលប្រាំឆ្នាំខាងមុខនេះ ដូចជាជំរឿនប្រជាជន ជំរឿនកសិកម្ម ជំរឿនសេដ្ឋកិច្ច អង្កេតសេដ្ឋកិច្ចសង្គមកិច្ចប្រចាំឆ្នាំ និងអង្កេតសំខាន់ដទៃទៀត។ អង្គភាពស្ថិតិដែលបានចាត់តាំងត្រូវបានស្នើសុំឱ្យផ្ដល់សូចនាករបន្ថែមទៀត ដែលបានមកពីប្រព័ន្ធព័ត៌មានគ្រប់គ្រង និងកំណត់ត្រារដ្ឋបាលរបស់ពួកគេ។

យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិនឹងផ្ដល់នូវផែនទីបង្ហាញផ្លូវ ដើម្បីគាំទ្រដល់តម្រូវការផលិតស្ថិតិដោយចីរភាព និងធានាដល់ការអនុវត្តគោលដៅរបស់ប្រព័ន្ធស្ថិតិជាតិប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ និងតាមដានគោលនយោបាយអភិវឌ្ឍន៍កម្ពុជា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ក៏ជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយក្នុងការស្វែងយល់ពីស្ថានភាពក្នុងការប្រតិបត្តិស្ថិតិ ការអភិវឌ្ឍសមត្ថភាព និងការបង្កើនគុណភាពទិន្នន័យ ដើម្បីផ្ដល់ទិន្នន័យមានគុណភាពសម្រាប់ការធ្វើផែនការ គោលនយោបាយ និងធ្វើសេចក្ដីសម្រេច និងកម្មវិធីស្ថិតិនានារបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលផងដែរ។

ខ្ញុំសូមអំពាវនាវដល់ក្រុមប្រឹក្សាស្ថិតិ គណៈកម្មាធិការសម្របសម្រួលស្ថិតិ បណ្ដាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ជាពិសេសអង្គភាពស្ថិតិដែលបានចាត់តាំង និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ដោយមានការដឹកនាំពីវិទ្យាស្ថានជាតិស្ថិតិ ដើម្បីអនុវត្តផែនការសកម្មភាព និងសម្រេចគោលដៅ និងគោលបំណងដែលបានលើកឡើងក្នុងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិនេះ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់ធនាគារពិភពលោក ចំពោះការបន្តគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងប្រព័ន្ធស្ថិតិជាតិ ជាពិសេសវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនៃរាជរដ្ឋាភិបាលកម្ពុជា។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

# អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបានប្រគល់ភារកិច្ចសម្របសម្រួលឆ្លើយតបទៅនឹងគោលដៅជាតិទាំងអស់ក្រោមសូចនាករតាមដានរួម និងបង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃមួយប្រកបដោយប្រសិទ្ធភាព មានស្ថិតិគ្រប់គ្រាន់ និងទាន់ពេលវេលាដែលត្រូវផលិតជាប្រចាំ ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ធ្វើផែនការយុទ្ធសាស្ត្រ និងសេចក្តីសម្រេច។ លទ្ធផលមួយក្នុងចំណោមលទ្ធផលនានា គឺយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។

ព័ត៌មានក្នុងយុទ្ធសាស្ត្រនេះត្រូវបានប្រមូលពីបណ្តាក្រសួង ស្ថាប័ន ក្រុមប្រឹក្សា លេខាធិការដ្ឋាន ធនាគារជាតិនៃកម្ពុជា ចំនួន២៧ ដែលទទួលខុសត្រូវលើស្ថិតិផ្លូវការដែលបានចាត់តាំង។ ក្រុមការងារនៃទីប្រឹក្សា GOPA រួមមានលោក Richard Roberts លោក Tomas Africa និងលោក So Dane ត្រូវបានគាំទ្រដោយវិទ្យាស្ថានជាតិស្ថិតិ ដើម្បីជួយដល់អ្នកពាក់ព័ន្ធទាំងអស់ពីរដ្ឋាភិបាល វិស័យឯកជន បណ្ឌិតសភា អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ តាមរយៈកិច្ចប្រជុំ បញ្ជីសំណួរ និងសិក្ខាសាលា (ផ្តល់សុពលភាព និងកិច្ចប្រជុំខ្លីៗ/ការបណ្តុះបណ្តាល)។ កិច្ចខិតខំប្រឹងប្រែងគួរឱ្យកត់សម្គាល់ក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងនេះ គឺដើម្បីបង្កើនភាពជាម្ចាស់ និងការប្តេជ្ញាចិត្តចំពោះយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។

យើងខ្ញុំសូមអរគុណដល់សមាជិកនៃគណៈកម្មាធិការសម្របសម្រួលស្ថិតិ និងក្រុមប្រឹក្សាស្ថិតិ រួមជាមួយអង្គភាពស្ថិតិដែលបានចាត់តាំង ចំពោះការគាំទ្រ និងកិច្ចសហប្រតិបត្តិការពេញលេញ ក្នុងការបង្កើតយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិដែលបានឆ្លើយតបនឹងសំណូមពរជាមួយការប្តេជ្ញាចិត្ត និងការជឿជាក់ ដើម្បីពង្រឹងតួនាទីរបស់ប្រព័ន្ធស្ថិតិជាតិនៅក្នុងដំណើរការអភិវឌ្ឍន៍ជាតិ។

យើងខ្ញុំមានសំណាង ដែលបានធនាគារពិភពលោកជួយគាំទ្រនូវបំណងប្រាថ្នារបស់យើងខ្ញុំ ក្នុងការកសាងសមត្ថភាពបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការបង្កើតឡើងនូវស្ថិតិមានគុណភាពខ្ពស់ដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ហង់ លីណា**

# សង្ខេបរួម

ការប្រមូលទិន្នន័យស្ថិតិនៅកម្ពុជា មានប្រវត្តិសាស្រ្តយូរអង្វែងតាំងពីទសវត្សរ៍ឆ្នាំ១៨០០ ហើយប្រព័ន្ធស្ថិតិជាតិបានឆ្លងកាត់ការផ្លាស់ប្តូរដោយសារតែស្ថានភាពនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច នៅក្នុងឆ្នាំបន្តបន្ទាប់។ ក្នុងពេលថ្មីៗនេះ ប្រព័ន្ធស្ថិតិជាតិបានដំណើរការក្រោមផែនការមេស្ថិតិ ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៥។ ផែនការមេស្ថិតិគឺជាផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍រយៈពេលមធ្យម រយៈពេលវែងសម្រាប់ប្រព័ន្ធស្ថិតិជាតិកម្ពុជា រួមមានវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំងនៅក្នុងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា ។ វាបានផ្តល់នូវផែនការយុទ្ធសាស្រ្តសម្រាប់សកម្មភាពស្ថិតិផ្លូវការ និងការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធ។

សមិទ្ធិផលគួរឱ្យកត់សម្គាល់ត្រូវបានសម្រេចនៅក្រោមផែនការមេស្ថិតិ ហើយក្រោយមកទៀតទាំងនេះបានដាក់បញ្ចូលតាមលំដាប់ជំរឿន និងអង្កេតសំខាន់ៗ និងបង្កើនការប្រើប្រាស់កំណត់ត្រារដ្ឋបាល និងប្រព័ន្ធព័ត៌មានគ្រប់គ្រងដែលបាននាំមកនូវស្ថិតិសំខាន់ៗ គ្របដណ្តប់លើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន។ ច្បាប់ស្ថិតិថ្មីត្រូវបានអនុម័តនៅឆ្នាំ២០១៥។ សកម្មភាពស្ថិតិសំខាន់ៗទាំងនេះ រួមជាមួយនឹងភារកិច្ចផ្សេងៗទៀតក្នុងប្រព័ន្ធស្ថិតិជាតិបានរួមចំណែកដ៏ទូលំទូលាយក្នុងការអភិវឌ្ឍគួរឱ្យកត់សម្គាល់ក្នុងប្រព័ន្ធស្ថិតិជាតិ។

ការវាយតម្លៃជាទូទៅថ្មីៗជាច្រើន ត្រូវបានធ្វើឡើងរវាងឆ្នាំ២០១២ និង ២០១៦។ វាក៏បានផ្តោតលើការវាយតម្លៃស្ថិតិសំខាន់ៗផងដែរ សម្រាប់ធ្វើសមាហរណកម្មសេដ្ឋកិច្ចនៃបណ្តាប្រទេសនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។ ការវាយតម្លៃដទៃទៀតបានគ្របដណ្តប់លើសមត្ថភាព ដើម្បីផលិតនូវសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ប្រព័ន្ធគ្រប់គ្រង ការផ្តល់មូលនិធិនៃការងារស្ថិតិ និងការពង្រឹងសមត្ថភាពស្ថិតិសេដ្ឋកិច្ច។ ការវាយតម្លៃទាំងនេះបានទទួលស្គាល់នូវសមិទ្ធិផលរបស់ប្រព័ន្ធស្ថិតិជាតិ ប៉ុន្តែក៏បានរកឃើញនូវបញ្ហា និងបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីចាប់ផ្តើមឱ្យមាននិរន្តរភាព និងរីកចម្រើនទៅមុខ។

ដោយផ្អែកលើចំណុចទាំងនេះ គោលដៅនៃកិច្ចការនេះគឺដើម្បីគាំទ្រវិទ្យាស្ថានជាតិស្ថិតិ ដើម្បីធ្វើការវាយតម្លៃតាមវិស័យនៃស្ថិតិសង្គមកិច្ច សេដ្ឋកិច្ច និងធនធានធម្មជាតិ និងដើម្បីបង្កើតយុទ្ធសាស្រ្តជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិសម្រាប់ប្រទេសកម្ពុជា។ ការងារនេះនឹងបង្ហាញពីលទ្ធភាព និងគុណភាពនៃទិន្នន័យដែលអ្នកប្រើប្រាស់ត្រូវការ និងនាំទៅរកការរៀបចំឱ្យប្រសើរឡើងនូវប្រព័ន្ធស្ថិតិ។ ដំណើរការល្អនៃយុទ្ធសាស្រ្តជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិនឹងផ្តល់ទិន្នន័យដល់អ្នកធ្វើសេចក្តីសម្រេច ប្រជាជន អ្នកសិក្សា និងសង្គមស៊ីវិល។ យុទ្ធសាស្រ្តជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិនឹងអនុវត្តតាមការណែនាំដែលចេញដោយលេខាធិការដ្ឋាន PARIS21 សម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច និងមានសកម្មភាពសំខាន់ៗដូចខាងក្រោម ៖

**ទីមួយ** ការផ្សព្វផ្សាយយុទ្ធសាស្រ្តជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិដែលភ្ជាប់ទៅនឹងសកម្មភាពនានា មានបំណងបង្ហាញលម្អិតអំពីរបៀប និងវិធីសាស្រ្ត ដើម្បីបង្កើតយុទ្ធសាស្រ្តជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ក៏ដូចជាការពិនិត្យឡើងវិញនូវផែនទីបង្ហាញផ្លូវនៃយុទ្ធសាស្រ្តជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ដែលបានរៀបចំដោយក្រុម PARIS21។

**ទីពីរ** ការវាយតម្លៃស្ថិតិតាមវិស័យ បានផ្តល់នូវទិដ្ឋភាពទូទៅនៃប្រព័ន្ធស្ថិតិជាតិនៅកម្ពុជា និងបានចង្អុលបង្ហាញនូវភាពខ្សោយ និងភាពខ្លាំង ដែលត្រូវពិចារណានៅក្នុងយុទ្ធសាស្រ្តជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។

**ទីបី** ពីលទ្ធផលនៃការវាយតម្លៃស្ថិតិតាមវិស័យ ចក្ខុវិស័យ បេសកកម្ម និងគោលដៅយុទ្ធសាស្ត្ររបស់យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ រួមទាំងប្រព័ន្ធតាមដាន និងវាយតម្លៃ និងផែនការសកម្មភាពនិងចំណាយក្នុងរយៈពេលប្រាំឆ្នាំ ត្រូវបានរៀបចំឡើងដោយសហការយ៉ាងជិតស្និទ្ធ និងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។

**ចុងក្រោយ** ការចាត់តាំង និងលទ្ធផលចម្បងរបស់វា គឺយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិត្រូវបានបញ្ចប់ដោយការបង្ហាញ និងការអនុម័តក្នុងចំណោមភាគីពាក់ព័ន្ធ។

យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិជាសង្ខេប ៖

## ចក្ខុវិស័យ

ស្ថិតិនៃប្រព័ន្ធស្ថិតិជាតិគាំទ្រដល់សកម្មភាពនៃកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់ទាំងអស់គ្នានៅកម្ពុជា។

## បេសកកម្ម

បេសកកម្មនៃប្រព័ន្ធស្ថិតិជាតិ គឺដើម្បីសម្របសម្រួល ប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយស្ថិតិផ្លូវការប្រកបដោយគុណភាពខ្ពស់ និងមិនលំអៀង ដើម្បីជួយដល់ការធ្វើសេចក្តីសម្រេច ការជជែកវែកញែក និងការពិភាក្សាក្នុងរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ខេត្ត ស្រុក និងឃុំ ធុរៈកិច្ច និងប្រព័ន្ធផ្សព្វផ្សាយ ក៏ដូចជាសហគមន៍កម្ពុជា និងអន្តរជាតិដ៏ទូលំទូលាយ[១] ។

## តម្លៃស្នូល

គោលបំណងជាក់លាក់អ្នកប្រើប្រាស់ វិជ្ជាជីវៈ សុចរិតភាព គុណភាព និរន្តរភាព ភាពជាដៃគូការគ្រប់គ្រងល្អ ។

## គោលដៅយុទ្ធសាស្ត្រ

គោលដៅយុទ្ធសាស្ត្រ ១. អភិវឌ្ឍ អនុវត្ត និងថែរក្សានូវសំណុំទិន្នន័យស្នូលដែលមានគុណភាពខ្ពស់[២] ដោយគ្រប់ស្ថាប័នទាំងអស់នៃប្រព័ន្ធស្ថិតិជាតិក្រោមការដឹកនាំរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការស្ថិតិនៃកិច្ចដំណើរការអភិវឌ្ឍន៍ដែលកើតចេញពីការប្តេជ្ញានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការយុទ្ធសាស្ត្រអាស៊ានតាមផ្នែក និងតម្រូវការរបស់អ្នកប្រើប្រាស់ដទៃទៀត។

គោលដៅយុទ្ធសាស្ត្រ ២. បន្តពង្រឹងច្បាប់ស្ថិតិ ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន រចនាសម្ព័ន្ធចាត់តាំង ឯករាជ្យភាពនៃវិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការ ហិរញ្ញវត្ថុ និងរដ្ឋបាលនៃប្រព័ន្ធស្ថិតិជាតិ ដើម្បីគាំទ្រដល់ការផលិត និងការអភិវឌ្ឍស្ថិតិ។

---

[១] ជាសេចក្តីថ្លែងអំពីបេសកកម្មនៃផែនការមេស្ថិតិ (SMP) ឆ្នាំ២០០៨-២០១៥ លើកលែងតែ “ប្រព័ន្ធស្ថិតិជាតិ” ត្រូវបានប្រើជំនួស “វិទ្យាស្ថានជាតិស្ថិតិ”។

[២] ភាពសំខាន់ ភាពទាន់ពេលវេលា ភាពគួរទុកចិត្តបាន ភាពទទួលបាន។

គោលដៅយុទ្ធសាស្ត្រ ៣. អភិវឌ្ឍ និងអនុវត្តការកសាងសមត្ថភាពមនុស្សក្នុងការរៀបចំជ្រើសរើសបុគ្គលិក ការបណ្ដុះបណ្ដាល និងកម្មវិធីលើកទឹកចិត្តមន្ត្រីក្នុងប្រព័ន្ធស្ថិតិជាតិ។

គោលដៅយុទ្ធសាស្ត្រ ៤. អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រ និងផែនការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដើម្បីផ្ដល់នូវសមត្ថភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដោយគាំទ្រគ្រប់ទិដ្ឋភាពទាំងអស់នៃការប្រមូល ការកែច្នៃ ការវិភាគ ការថែរក្សា និងការផ្សព្វផ្សាយស្ថិតិ។

គោលដៅយុទ្ធសាស្ត្រ ៥. អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយ យុទ្ធសាស្ត្រគាំទ្រ និងចំណេះដឹងផ្នែកស្ថិតិ ដើម្បីផ្ដល់ការទទួលបានឱ្យកាន់តែប្រសើរឡើងដល់អ្នកប្រើប្រាស់ទាំងអស់ និងបង្កើនសេចក្ដីត្រូវការសម្រាប់ស្ថិតិ។

គោលដៅយុទ្ធសាស្ត្រ ៦. ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិ ដើម្បីលុបបំបាត់ជម្លោះទិន្នន័យ (Data Conflicts) និងផលិតស្ថិតិអាចប្រៀបធៀបបាន ទាន់ពេលវេលាក្នុងប្រព័ន្ធស្ថិតិជាតិប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។

គោលដៅយុទ្ធសាស្ត្រ ៧. ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងការងារ និងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីធានានូវការគាំទ្រការព្យាករណ៍ ការបន្ត និងការរួមបញ្ចូលគ្នាទៅនឹងសកម្មភាពអាទិភាពរបស់ប្រព័ន្ធស្ថិតិជាតិ ក៏ដូចជាការផ្ទេរជំនាញពេញលេញ និងចំណេះធ្វើ។

គោលដៅយុទ្ធសាស្ត្រ ៨. ជំរុញស្ថិរភាព និងកំណើននៃការគាំទ្រថវិកាសម្រាប់ប្រព័ន្ធស្ថិតិជាតិពីប្រភពក្នុងស្រុក និងអន្តរជាតិ ដើម្បីអាចធ្វើផែនការ និងអនុវត្តកម្មវិធីស្ថិតិអាទិភាពប្រកបដោយប្រសិទ្ធភាព។

ចេញពីគោលដៅទាំងនេះ សកម្មភាពយុទ្ធសាស្ត្រសំខាន់ៗត្រូវបានរៀបចំ សម្រាប់ប្រព័ន្ធស្ថិតិជាតិទាំងមូល ដើម្បីបន្តក្នុងការរៀបចំគោលនយោបាយ និងការអនុវត្តកម្មវិធី។ សកម្មភាពយុទ្ធសាស្ត្រទាំងនេះមានក្នុងជំពូក ៤ (ផែនការសកម្មភាព) ឧបសម្ព័ន្ធ ១ (កាលវិភាគសូចនាករសម្រាប់ជំរឿន និងអង្កេត ឆ្នាំ២០១៩-២០២៣) និង ឧបសម្ព័ន្ធ ២ (ផែនការអនុវត្ត ឆ្នាំ២០១៩-២០២៣)។ សកម្មភាពអាទិភាព (២០១៩-២០២៣) មាននៅក្នុងផ្នែក ៤.២ បានរៀបចំការកំណត់គោលនយោបាយ និងកម្មវិធី ការកសាងសមត្ថភាពចាត់តាំង មនុស្ស រចនាសម្ព័ន្ធ និងយន្តការសម្របសម្រួល ក្រៅពីការអនុវត្តស្ថិតិតាមកាលវិភាគ។

ថវិកាសរុបរបស់ប្រព័ន្ធស្ថិតិជាតិត្រូវបានប៉ាន់ស្មានប្រមាណ ៥៨,៨ លានដុល្លារអាមេរិក ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។ វិទ្យាស្ថានជាតិស្ថិតិមានប្រមាណ ៧៦,៥ ភាគរយ នៃចំនួនសរុបនេះ។ ការប៉ាន់ស្មានទាំងនេះមាននៅក្នុងឧបសម្ព័ន្ធ ៣ ដោយផ្អែកតាមរបាយការណ៍ប្រចាំឆ្នាំស្ដីពីការគាំទ្រដល់ស្ថិតិ (CRESS) ដែលបានរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ និង PARIS21 នៅខែឧសភា ឆ្នាំ២០១៧ និងពីចម្លើយក្នុងបញ្ជីសំណួរដែលបានផ្ញើទៅបណ្ដាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។[៣]

[៣] ការប៉ាន់ស្មានទាំងនេះដែលបានបង្ហាញ និងភាពមិនច្បាស់លាស់ និងកង្វះភាពហ្មត់ចត់ គឺស្ថិតក្នុងចំណោមបញ្ហាជាច្រើនទៀត ដោយសារតែជាទូទៅគ្មានព័ត៌មានជាក់លាក់ដែលអាចរកបានលើសកម្មភាពផ្សេងៗ ដែលបានអនុវត្តនៅក្នុងប្រព័ន្ធស្ថិតិជាតិ (NSS) នៃការផលិតស្ថិតិ ឬវិធីគណនាជាលក្ខណៈស្តង់ដារ និងរបាយការណ៍ចំណាយអំពីបៀវត្សរ៍ ការប្រមូលទិន្នន័យ និងការប្រើប្រាស់ទិន្នន័យរដ្ឋបាល ការវិភាគ និងការផ្សព្វផ្សាយ ។ល។ ការរៀបចំកញ្ចប់ថវិកាសម្រាប់ស្ថាប័ន (មាត្រា ២១ ច្បាប់ស្ដីពីស្ថិតិ) នឹងបានល្អប្រសើរនូវដំណើរការថវិកា និងការប៉ាន់ស្មានសកម្មភាពប្រព័ន្ធស្ថិតិជាតិ។

ថវិកាប៉ាន់ស្មានសម្រាប់វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០១៩-២០២៣ ប៉ាន់ស្មានប្រមាណ ៥៥,៧ លានដុល្លារអាមេរិក ដោយបានបែងចែកតាមឆ្នាំដូចតទៅ ៖ ឆ្នាំ២០១៩ ប្រមាណ ១៩,៩០៣,៩០០ដុល្លារអាមេរិក ឆ្នាំ២០២០ ប្រមាណ ៧,១៧៧,៦០០ដុល្លារអាមេរិក ឆ្នាំ២០២១ ប្រមាណ ៩,០២០,៩០០ដុល្លារអាមេរិក ឆ្នាំ២០២២ ប្រមាណ ៤,៨១០,៦០០ដុល្លារអាមេរិក និងឆ្នាំ២០២៣ ប្រមាណ ៨,៧៨៦,២០០ ដុល្លារអាមេរិក។

ថវិកាប៉ាន់ស្មានសម្រាប់ការធ្វើជំរឿនប្រជាជនឆ្នាំ២០១៩ មាន ៨,៧លានដុល្លារអាមេរិក និងជំរឿនសេដ្ឋកិច្ចឆ្នាំ២០២១ មានប្រមាណ ៤,៥លានដុល្លារអាមេរិក និងជំរឿនកសិកម្មឆ្នាំ២០២៣ ប្រមាណ ៦លានដុល្លារអាមេរិក។ ថវិកាជំរឿនប្រជាជនឆ្នាំ២០១៩ មាន ៨,៧លានដុល្លារអាមេរិក រួមមានចំណាយលើសកម្មភាពរៀបចំ ១,៣លានដុល្លារអាមេរិក នៅឆ្នាំ២០១៨ និងប្រតិបត្តិការជំរឿននៅឆ្នាំ២០១៩ ចំណាយ ៧,៤លានដុល្លារអាមេរិក។

ថវិការអង្កេតរួមមាន ៖ អង្កេតសេដ្ឋកិច្ចសង្គមកិច្ច (ឆ្នាំ២០១៩-២០២៣) ចំណាយ ៤,៧លានដុល្លារអាមេរិក អង្កេតប្រជាសាស្ត្រ និងសុខភាព (ឆ្នាំ២០២០) ចំណាយ ៥,៧លានដុល្លារអាមេរិក អង្កេតចន្លោះជំរឿនកសិកម្ម (ឆ្នាំ២០១៩) ចំណាយ ១,៧លានដុល្លារអាមេរិក អង្កេតសេដ្ឋកិច្ចប្រចាំឆ្នាំចំណាយ ៦០០ពាន់ដុល្លារអាមេរិក អង្កេតពិការភាពថ្នាក់ជាតិ (ឆ្នាំ២០២១) ចំណាយ ៦៥៣ពាន់ដុល្លារអាមេរិក អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារ (ឆ្នាំ២០១៩ ២០២៣) ចំណាយ ៩០០ពាន់ដុល្លារអាមេរិក អង្កេតអំពើហឹង្សាលើរាងកាយកុមារ (ឆ្នាំ២០២១) ចំណាយ ៤៥០ពាន់ដុល្លារអាមេរិក អង្កេតប្រជាជនអាយុចាស់ (ឆ្នាំ២០២១) ចំណាយ ៣៩០ពាន់ដុល្លារអាមេរិក និងអង្កេតថ្នាំជក់ទូទៅថ្នាក់ជាតិ (ឆ្នាំ២០១៩) ចំណាយ ៣៦០ពាន់ដុល្លារអាមេរិក។

លើសពីនេះទៀត ថវិកាប្រចាំឆ្នាំប្រមាណ ៤៥០ពាន់ដុល្លារអាមេរិក ត្រូវបានស្នើឡើងសម្រាប់ការកសាងសមត្ថភាពរបស់ប្រព័ន្ធស្ថិតិជាតិស្តីពីការវាស់វែងសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ការតាមដាន ការរាយការណ៍ និងការផ្សព្វផ្សាយ។ សកម្មភាពស្ថិតិ និងការផលិតស្ថិតិដទៃទៀតរបស់វិទ្យាស្ថានជាតិស្ថិតិត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ ៦ ។

បន្ទាប់ពីពិចារណាលើធាតុចូល ម៉ោងការងារ មូលនិធិ អន្តរកម្ម និងការពិគ្រោះយោបល់ ដែលឈានទៅការបង្កើតយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ការអនុវត្តទាំងនេះត្រូវបានផ្តោតទៅលើនិរន្តរភាព។ ជំពូក ៦ បង្ហាញអំពីបញ្ហា និងហានិភ័យប្រឈមនានាដែលត្រូវដោះស្រាយ សំណើរៀបចំអភិបាលកិច្ច និងផ្តល់ក្របខ័ណ្ឌតាមដានដើម្បីណែនាំការតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។

មានបញ្ហាជាក់លាក់មួយចំនួនដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្លាំង។បញ្ហាទី១ ការរៀបចំបញ្ជីសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ បញ្ហាទី២ លើកសំណួរអំពីការចំណាយរបស់រាជរដ្ឋាភិបាលសម្រាប់សកម្មភាពស្ថិតិ។ បញ្ហាទី៣ ស្នើឱ្យមានទស្សនៈប្រាកដប្រជាមួយថាតើប្រព័ន្ធស្ថិតិជាតិគួរតែឆ្ពោះទៅរកការប្រមូលផ្តុំឬទេ។

# មាតិកា


ទំព័រ

**ជំពូក ១ សេចក្តីផ្តើម** ............ ១

១.១ គោលបំណង ............ ១

១.១.១ ទស្សនៈនៃយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ............ ១

១.១.២ ផែនការមេស្ថិតិ ............ ២

១.២ សាវតារ ............ ៣

១.២.១ ព័ត៌មានទូទៅ ............ ៣

១.២.២ ផែនការអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ............ ៤

**ជំពូក ២ ការវាយតម្លៃលើប្រព័ន្ធស្ថិតិជាតិ** ............ ៧

២.១ ប្រព័ន្ធស្ថិតិជាតិ ............ ៧

២.១.១ ប្រវត្តិសង្ខេបនៃប្រព័ន្ធស្ថិតិជាតិ ............ ៧

២.១.២ វិទ្យាស្ថានជាតិស្ថិតិ ............ ៨

២.១.៣ អង្គភាពស្ថិតិដែលបានចាត់តាំង ............ ១០

២.២ ការវាយតម្លៃប្រព័ន្ធស្ថិតិជាតិ ............ ១១

២.២.១ ប្រវត្តិនៃការវាយតម្លៃ ............ ១១

២.២.២ របាយការណ៍ពាក់កណ្តាលអាណត្តិ ............ ១១

២.៣ ការវិភាគយុទ្ធសាស្ត្រនៃប្រព័ន្ធស្ថិតិជាតិ និងតម្រូវការអភិវឌ្ឍន៍ ............ ១៣

២.៣.១ ការបំពេញសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ ............ ១៤

២.៣.២ ស្ថិតិក្នុងគោលនយោបាយអភិវឌ្ឍន៍ជាតិ ............ ២១

២.៣.៣ ច្បាប់ និងក្របខ័ណ្ឌស្ថាប័ន ............ ២២

២.៣.៤ ធនធានមនុស្ស ............ ២៥

២.៣.៥ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា (ICT) ............ ៣០

២.៣.៦ ការផ្សព្វផ្សាយ និងការគាំទ្រ ............ ៣៣

២.៣.៧ ការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ ............ ៣៧

២.៣.៨ ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ............ ៣៩

២.៣.៩ ការផ្តល់ហិរញ្ញប្បទានប្រព័ន្ធស្ថិតិជាតិ ............ ៤២

**ជំពូក ៣ យុទ្ធសាស្ត្រសម្រាប់ប្រព័ន្ធស្ថិតិជាតិ** ............ ៤៥

៣.១ ចក្ខុវិស័យ និងបេសកកម្ម ............ ៤៥

៣.២ តម្លៃស្នូល ............ ៤៥

៣.៣ គោលដៅយុទ្ធសាស្ត្រ ............ ៤៦

៣.៣.១ តម្រូវការអ្នកប្រើប្រាស់ ............ ៤៦

៣.៣.២ ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ............ ៤៧

៣.៣.៣ ធនធានមនុស្ស........................................................................................ ៤៧
៣.៣.៤ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា........................................................ ៤៧
៣.៣.៥ ការផ្សព្វផ្សាយ និងការគាំទ្រ........................................................................ ៤៧
៣.៣.៦ ការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ................................................................ ៤៧
៣.៣.៧ ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍.................................................................. ៤៨
៣.៣.៨ ហិរញ្ញប្បទានប្រព័ន្ធស្ថិតិជាតិ........................................................................ ៤៨

**ជំពូក ៤ ផែនការសកម្មភាព**.................................................................................. ៤៩
៤.១ ភារកិច្ចចាំបាច់.......................................................................................... ៤៩
៤.១.១ បំពេញតាមតម្រូវការនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងអាស៊ាន និងអ្នកប្រើប្រាស់ដទៃទៀត.......................................................... ៥០
៤.១.២ ពង្រឹងច្បាប់ និងក្របខ័ណ្ឌស្ថាប័ន.................................................................. ៥៣
៤.១.៣ ធ្វើឱ្យប្រសើរឡើងនូវធនធានមនុស្ស.............................................................. ៥៤
៤.១.៤ ធ្វើសនិទានកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា....................................... ៥៦
៤.១.៥ បង្កើនការផ្សព្វផ្សាយ និងការគាំទ្រ.............................................................. ៥៦
៤.១.៦ បង្កើនប្រសិទ្ធភាពការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ........................................ ៥៨
៤.១.៧ ធ្វើសនិទានកម្មផ្សារភ្ជាប់ជាមួយដៃគូអភិវឌ្ឍន៍.................................................. ៥៩
៤.១.៨ ផ្តល់ហិរញ្ញប្បទានប្រព័ន្ធស្ថិតិជាតិ.................................................................. ៦០
៤.២ សកម្មភាពអាទិភាព (ឆ្នាំ២០១៧-២០១៨)......................................................... ៦០

**ជំពូក ៥ ហិរញ្ញប្បទាន**........................................................................................ ៦៣
៥.១ ការប៉ាន់ស្មានថវិកា មុនឆ្នាំ២០១៧............................................................... ៦៣
៥.១.១ ផែនការមេស្ថិតិ ខែតុលា ឆ្នាំ២០០៥.............................................................. ៦៣
៥.១.២ ផែនការមេស្ថិតិ-របាយការណ៍ពាក់កណ្តាលអាណត្តិ ខែវិច្ឆិកា ឆ្នាំ២០១២................ ៦៤
៥.១.៣ របាយការណ៍ប្រព័ន្ធស្ថិតិជាតិប្រចាំឆ្នាំ២០១៥ ដោយវិទ្យាស្ថានជាតិស្ថិតិ ខែធ្នូ ឆ្នាំ២០១៦............... ៦៥
៥.២ ការប៉ាន់ស្មានថវិកា ឆ្នាំ២០១៩ - ២០២៣....................................................... ៦៥
៥.៣ ប្រតិទិននៃសកម្មភាព និងថវិការបស់វិទ្យាស្ថានជាតិស្ថិតិ.................................... ៦៥

**ជំពូក ៦ និរន្តរភាព**............................................................................................ ៦៧
៦.១ បញ្ហា និងហានិភ័យ.................................................................................. ៦៧
៦.២ ការរៀបចំអភិបាលកិច្ចសម្រាប់យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ....................... ៧០
៦.៣ ការតាមដាន និងវាយតម្លៃ............................................................................ ៧២

ឯកសារយោង................................................................................................ ៨១

# ឧបសម្ព័ន្ធ


| | | ទំព័រ |
|---|---|---|
| ឧបសម្ព័ន្ធ ១ | កាលវិភាគសូចនាករ សម្រាប់ជំរឿន និង អង្កេត ឆ្នាំ២០១៩ - ២០២៤.............................. | ៨៣ |
| ឧបសម្ព័ន្ធ ២ | ផែនការអនុវត្តន៍ ឆ្នាំ២០១៩ - ២០២៣.................................................................. | ៨៥ |
| ឧបសម្ព័ន្ធ ៣ | ការប៉ាន់ស្មានថវិការបស់ប្រព័ន្ធស្ថិតិជាតិ ឆ្នាំ២០១៩ - ២០២៣.................................... | ៩១ |
| ឧបសម្ព័ន្ធ ៤ | ចំណាយផ្ទាល់សម្រាប់សកម្មភាពស្ថិតិអាទិភាព ឆ្នាំ២០០៦ - ២០១៥ (ពីផែនការមេស្ថិតិ)........ | ៩៥ |
| ឧបសម្ព័ន្ធ ៥ក | ចំណាយផ្ទាល់សម្រាប់សកម្មភាពស្ថិតិរបស់ប្រព័ន្ធស្ថិតិជាតិ ឆ្នាំ២០០៦ - ២០១៥ (ពីផែនការមេស្ថិតិ)........................................................................................... | ៩៧ |
| ឧបសម្ព័ន្ធ ៥ខ | ចំណាយផ្ទាល់សម្រាប់សកម្មភាពស្ថិតិរបស់ប្រព័ន្ធស្ថិតិជាតិ ឆ្នាំ២០០៦ - ២០១៥ (ពីផែនការមេស្ថិតិ)........................................................................................... | ១០១ |
| ឧបសម្ព័ន្ធ ៦ | ប្រតិទិននៃសកម្មភាព និងថវិការបស់វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០១៩ - ២០២៣................... | ១០៥ |
| ឧបសម្ព័ន្ធ ៧ | មន្ត្រីស្ថិតិ ចំនួនថ្លូវការ និងបំពេញមុខងារ តាមក្រសួង/ស្ថាប័ន ឆ្នាំ២០១៣ - ២០១៦............. | ១០៩ |
| ឧបសម្ព័ន្ធ ៨ | បមាណភាគនៃការបែងចែកចំណាយរបស់រាជរដ្ឋាភិបាលសម្រាប់ស្ថិតិ ធៀបនឹង ការចំណាយសរុបរបស់ក្រសួង/ស្ថាប័ន................................................................. | ១១៣ |


# រូប


| | | ទំព័រ |
|---|---|---|
| រូប១ | ក្របខ័ណ្ឌរចនាសម្ព័ន្ធរបស់ប្រព័ន្ធស្ថិតិជាតិកម្ពុជា............................................................... | ៧១ |
| រូប២ | ការរៀបចំសំណើអភិបាលកិច្ចសម្រាប់ការអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ................... | ៧១ |

# ជំពូក ១ សេចក្តីផ្តើម

## ១.១ គោលបំណង

### ១.១.១ ទស្សនៈនៃយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ[៤]

ស្ថិតិល្អបានផ្តល់នូវព័ត៌មានអំពីសេដ្ឋកិច្ចរបស់ប្រទេសមួយ និងប្រជាជន បរិស្ថានធម្មជាតិ និងធនធាន ដែលជាតម្រូវការចាំបាច់សម្រាប់រាជរដ្ឋាភិបាលក្នុងការធ្វើសេចក្តីសម្រេចផ្អែកលើភស្តុតាង បង្កើតគោលនយោបាយផ្អែកលើការពិត និងយុទ្ធសាស្ត្រនានានៃការអភិវឌ្ឍជាអាទិភាពសម្រាប់ជាប្រយោជន៍ដល់ប្រជាជន។ ស្ថិតិទាំងនេះ ៖

- ផ្តល់ភស្តុតាងជាអាទិភាពរបស់រាជរដ្ឋាភិបាលដែលត្រូវកំណត់លើគ្រប់វិស័យតាមភូមិសាស្ត្រ (ទីប្រជុំជន-ជនបទ ខេត្ត) និងផ្តោតលើក្រុមប្រជាជនជាក់លាក់ ដូចជាកុមារ យុវវ័យ មនុស្សចាស់ អ្នកគ្មានការងារធ្វើ និងអ្នកក្រ
- ផ្តល់នូវគោលដៅគ្រឹះសម្រាប់គោលនយោបាយ យុទ្ធសាស្ត្រ និងអន្តរាគមន៍រួមនានា ជាទិន្នន័យគោល (ពណ៌នាស្ថានភាពបច្ចុប្បន្ន) ក៏ដូចជាគោលដៅពិតប្រាកដនៃគោលនយោបាយ និងផែនការជាក់លាក់មួយដែលត្រូវសម្រេចឱ្យបាន
- តាមរយៈទិន្នន័យគោលទាំងនេះ និងការប្រមូលជាទៀងទាត់នូវស្ថិតិមូលដ្ឋាន អនុញ្ញាតឱ្យអ្នកធ្វើផែនការ និងអ្នកឯកទេសតាមវិស័យ ដើម្បីតាមដានវឌ្ឍនភាព និងប្រាប់ឱ្យដឹងមុនដល់អ្នកធ្វើគោលនយោបាយនៅពេលសូចនាករសំខាន់ៗត្រូវបានតាមដាន ធ្វើការស៊ើបអង្កេតភ្លាមៗដើម្បីរៀបចំគោលនយោបាយឡើងវិញ និងកែសម្រួលកម្មវិធីឱ្យបានលទ្ធផលល្អប្រសើរ និង
- ចុងក្រោយ ជួយធានាថាធនធានដែលមានកម្រិតកំណត់ត្រូវបានប្រើប្រាស់ ក្នុងការងារមួយដែលមានភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព និងលើកឡើងពីតម្រូវការធនធានបន្ថែម។

ច្បាប់ស្តីពីស្ថិតិបច្ចុប្បន្នមានលក្ខណៈច្បាស់លាស់អំពីការផ្សារភ្ជាប់គ្នារវាងទិន្នន័យ និងការបង្កើតផែនការអភិវឌ្ឍន៍ និងការអនុវត្ត ដែលនឹងត្រូវពិនិត្យលម្អិតឡើងវិញ។ អ្វីដែលខ្វះខាតគឺការណែនាំ ដែលជួយដល់ការបកស្រាយ ឬប្រតិបត្តិច្បាប់ដែលទាក់ទងទៅនឹងការប្រមូលស្ថិតិ តាមគោលបំណងជាក់លាក់ទទួលលទ្ធផលដែលចង់បាន។ នេះហើយជាលទ្ធផលដែល *យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ* កំពុងព្យាយាមសម្រេចឱ្យបាន។

ការបង្កើតយុទ្ធសាស្ត្រជាតិនេះ ក៏ស្របទៅនឹងកិច្ចប្រជុំតុមូលអន្តរជាតិលើកទីពីរស្តីពីការគ្រប់គ្រងសម្រាប់លទ្ធផលអភិវឌ្ឍន៍ ដែលបានប្រារព្ធនៅម៉ារ៉ាកិច ប្រទេសម៉ារ៉ុក នៅខែកុម្ភៈ ឆ្នាំ២០០៤។ ផែនការសកម្មភាពម៉ារ៉ាកិចសម្រាប់ស្ថិតិបានកំណត់គោលដៅសម្រាប់បណ្តាប្រទេសដែលមានប្រាក់ចំណូលទាបទាំងអស់ឱ្យរៀបចំយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ជាមួយគោលបំណងធ្វើឱ្យមានគុណភាពខ្ពស់នូវទិន្នន័យស្ថិតិផលិតក្នុងស្រុក ដើម្បីតាមដានវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ នៅឆ្នាំ២០១៥។

---

[៤] សម្រង់ពីសេចក្តីព្រាងផែនទីបង្ហាញផ្លូវ សម្រាប់យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (NSDS) របស់រដ្ឋសហព័ន្ធមីក្រូនេស៊ី ដោយ Gerald Haberkorn ទីប្រឹក្សា PARIS21 ។

ដូចគ្នានេះដែរ សារៈសំខាន់នៃស្ថិតិដែលគាំទ្រដល់អភិបាលកិច្ចល្អ និងការធ្វើសេចក្ដីសម្រេច បានបញ្ជាក់ជាថ្មីម្ដងទៀតនៅវេទិកាកម្រិតខ្ពស់លើកទីបួនឆ្នាំ២០១១ ស្ដីពីប្រសិទ្ធភាពជំនួយ នៅប៊ូសាន ប្រទេសកូរ៉េ បានលើកឡើងពីសារៈសំខាន់នៃ "ភាពជាដៃគូដើម្បីអនុវត្តផែនការសកម្មភាពសកលសម្រាប់ស្ថិតិ ដើម្បីបង្កើនសមត្ថភាពសម្រាប់ស្ថិតិ ក្នុងការតាមដានវឌ្ឍនភាព វាយតម្លៃផលប៉ះពាល់ ធានាភាពត្រឹមត្រូវ ការគ្រប់គ្រងវិស័យសាធារណៈផ្ដោតលើលទ្ធផល និងលើកឡើងពីបញ្ហាយុទ្ធសាស្ត្រសម្រាប់ការសម្រេចគោលនយោបាយ។"

នៅឆ្នាំ២០១៦ របៀបវារៈសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ អំពាវនាវឱ្យមាន "បដិវត្តន៍ទិន្នន័យ" ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពស្ថិតិ និងព័ត៌មានដែលមានស្រាប់ដល់ប្រជាជន និងរាជរដ្ឋាភិបាល ដើម្បីធានាថា *"គ្មាននរណាម្នាក់ត្រូវបានបោះបង់ចោល"*។ យោងតាមការយល់ព្រម និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលដើម្បីសម្រេចបាននូវរបៀបវារៈនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទំហំសូចនាករស្ថិតិដែលត្រូវការសម្រាប់ព័ត៌មានគោល និងតាមដានវឌ្ឍនភាពសូចនាករគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទាំងឡាយណាដែលមិនទាន់សម្រេចបានជួយដល់ការបង្កើតយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិបានទាន់ពេលវេលា និងផ្ដល់មូលដ្ឋានចាំបាច់ដល់រាជរដ្ឋាភិបាល ដើម្បីបំពេញការតាមដានជាទៀងទាត់ និងរាយការណ៍តាមកាលកំណត់។

ហើយថ្មីៗនេះ នៅទីក្រុង Cape Town ខែមករា ឆ្នាំ២០១៧ ផែនការសកម្មភាពពិភពលោក Cape Town សម្រាប់ទិន្នន័យអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលរៀបចំដោយក្រុមការងារជាន់ខ្ពស់សម្រាប់ភាពជាដៃគូ ការសម្របសម្រួល និងការកសាងសមត្ថភាពស្ថិតិ សម្រាប់របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព បានអំពាវនាវឱ្យអ្នកដឹកនាំគោលនយោបាយ "សម្រេចបាននូវកតិកាសញ្ញាពិភពលោក ឬសម្ព័ន្ធភាពដែលទទួលស្គាល់ការផ្ដល់មូលនិធិដល់កិច្ចខិតខំប្រឹងប្រែងទំនើបភាវូបនីយកម្មរបស់ប្រព័ន្ធស្ថិតិជាតិ គឺជាការចាំបាច់ចំពោះការអនុវត្តពេញលេញនៃរបៀបវារៈឆ្នាំ២០៣០" ។

## ១.១.២ ផែនការមេស្ថិតិ

ប្រព័ន្ធស្ថិតិជាតិបានដំណើរការក្រោមផែនការមេស្ថិតិ ពីឆ្នាំ២០០៨-២០១៥ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាស្ថិតិនៅខែមេសា ឆ្នាំ២០០៧។ ផែនការមេស្ថិតិគឺជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលមធ្យម រយៈពេលវែងសម្រាប់ប្រព័ន្ធស្ថិតិជាតិដែលមានវិសាលភាពគ្របដណ្ដប់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំងនៅក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល រួមទាំងធនាគារជាតិនៃកម្ពុជា។ វាបានផ្ដល់ប្លង់យុទ្ធសាស្ត្រសម្រាប់សកម្មភាពស្ថិតិផ្លូវការ និងការអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធ។ វាក៏បានផ្ដល់នូវផែនការហិរញ្ញវត្ថុរយៈពេលមធ្យមផងដែរ ដើម្បីគាំទ្រដល់សកម្មភាព ស្ថិតិចាំបាច់ និងកសាងសមត្ថភាព រួមទាំងជំនួយក្រៅប្រទេសសម្រាប់ស្ថិតិ។

ផែនការមេស្ថិតិបានកំណត់ចក្ខុវិស័យ និងគោលដៅសម្រាប់ប្រព័ន្ធស្ថិតិជាតិតាមរយៈប្រាំគោលការណ៍គឺ ៖ ភាពសំខាន់ ភាពសុច្ចរិត ភាពទទួលបាន ភាពវិជ្ជាជីវៈ និងភាពទុកចិត្ត។ ផែនការមេស្ថិតិមានបំណងសម្រាប់ ៖

១. សម្របសម្រួល និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធស្ថិតិជាតិរបស់ព្រះរាជាណាចក្រកម្ពុជា

២. ប្រព័ន្ធស្ថិតិជាតិត្រូវមានភាពទាន់ពេលវេលា មានភាពសំខាន់ ភាពឆ្លើយតប និងការគោរពចំពោះសុចរិតភាព និងគុណភាពរបស់វា

៣. ផ្ដល់ព័ត៌មាន និងបង្កើនការប្រើប្រាស់ស្ថិតិផ្លូវការ

៤.	អ្នកចូលរួមសកម្មក្នុងសកម្មភាពស្ថិតិអន្តរជាតិ មានសារៈសំខាន់ដល់ព្រះរាជាណាចក្រកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍
៥.	ស្ថាប័នដែលលើកទឹកចិត្តដល់ការសិក្សា ការច្នៃប្រឌិត និងការអនុវត្តខ្ពស់ក្នុងគ្រប់សកម្មភាព និងការអភិវឌ្ឍស្ថិតិរបស់ខ្លួន
៦.	ជឿទុកចិត្ត និងកិច្ចសហប្រតិបត្តិការដល់អ្នកផ្តល់ទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ
៧.	ការទទួលស្គាល់ និងការគាំទ្រខ្លាំងដល់ស្ថិតិ។

ផែនការមេស្ថិតិមានបំណងពង្រឹងបន្ថែមទៀតនូវក្របខ័ណ្ឌច្បាប់ និងបន្តកសាងរចនាសម្ព័ន្ធស្ថិតិសម្រាប់ស្ថិតិតាមរយៈការអភិវឌ្ឍធនធាន និងធ្វើឱ្យប្រសើរឡើងនូវកិច្ចប្រតិបត្តិការស្ថិតិ។ កម្មវិធីការងារផ្តោតលើសកម្មភាពដើម្បីដោះស្រាយលើវិស័យអាទិភាពសំខាន់ៗដូចខាងក្រោម ៖

១.	រក្សាទុកស្ថិតិសេដ្ឋកិច្ច និងប្រជាសាស្ត្រ សង្គមសំខាន់ៗ
២.	ដំណើរការ និងធ្វើឱ្យប្រសើរឡើងដល់ការធ្វើជំរឿន និងអង្កេតតាមកាលកំណត់
៣.	កសាង និងរក្សាទុកបញ្ជីសម្រាប់គោលបំណងស្ថិតិ
៤.	លើកកម្ពស់ប្រភពទិន្នន័យរដ្ឋបាល
៥.	បង្កើតប្រព័ន្ធសូចនាករ
៦.	ពង្រឹងសមត្ថភាព និងប្រព័ន្ធសម្រាប់ការវិភាគទិន្នន័យ ធ្វើរបាយការណ៍ និងការផ្សព្វផ្សាយ។

ផែនការមេស្ថិតិក៏មានបំណងបម្រើជាក្របខ័ណ្ឌមួយ សម្រាប់សម្របសម្រួលគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំងនៅក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាសម្រាប់រៀបចំជំនួយបច្ចេកទេសដោយដៃគូអភិវឌ្ឍន៍។

សមិទ្ធិផលគួរឱ្យកត់សម្គាល់បានសម្រេចនៅក្រោមផែនការមេស្ថិតិ។

## ១.២ សាវតារ[៥]

### ១.២.១ ព័ត៌មានទូទៅ

កម្ពុជាត្រូវបានស្គាល់ជាផ្លូវការថាជា **ព្រះរាជាណាចក្រកម្ពុជា** ជាប្រទេសមួយស្ថិតនៅភាគខាងត្បូងនៃឧបទ្វីបឥណ្ឌូចិននៅអាស៊ីអាគ្នេយ៍។ ប្រទេសមានផ្ទៃក្រឡា ១៨១.០៣៥ គីឡូម៉ែតក្រឡា មានព្រំប្រទល់ជាប់នឹងប្រទេសថៃនៅទិសពាយព្យ ប្រទេសឡាវនៅទិសឦសាន ប្រទេសវៀតណាមនៅទិសខាងកើត និងឈូងសមុទ្រថៃនៅទិសនិរតី។ ទិដ្ឋភាពរបស់ប្រទេសកម្ពុជាមានលក្ខណៈជាតំបន់ទំនាបកណ្តាលដែលព័ទ្ធជុំវិញដោយតំបន់ខ្ពង់រាប និងភ្នំ ហើយរួមទាំងទន្លេសាប និងតំបន់ខាងលើនៃដីសណ្តទន្លេមេគង្គ។ តំបន់ទំនាបដ៏មានមនុស្សច្រើនរស់នៅនេះដែលដាំដំណាំស្រូវវស្សា គឺជាបេះដូងនៃប្រទេសកម្ពុជា។

---

[៥] ឯកសារយុទ្ធសាស្ត្រកម្ពុជា។ ផ្អែកលើក្របខ័ណ្ឌយុទ្ធសាស្ត្រដែលបានអនុម័តដោយការិយាល័យ UOS នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦។ VLIR-UOS ក្រុមការងារអន្តរទ្វីប Flemish - University Cooperation for Development ។

កម្ពុជាត្រូវបានចាត់ទុកជាប្រទេសមានសេដ្ឋកិច្ចលូតលាស់លឿនបំផុត ទីដប់ប្រាំបួនលើពិភពលោក ដោយយោងតាមរបាយការណ៍ស្តីពីទស្សនវិស័យសេដ្ឋកិច្ចពិភពលោករបស់ធនាគារពិភពលោក (ឆ្នាំ២០១៤)។ កម្ពុជាស្ថិតក្នុងលំដាប់ទី៤ ក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅលើពិភពលោកក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ បើយោងតាមសន្ទស្សន៍វឌ្ឍនភាពគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDG Progress Index) (ឆ្នាំ២០១៣) របស់មជ្ឈមណ្ឌលសម្រាប់ការអភិវឌ្ឍសកល។ ប្រទេសនេះមានលទ្ធភាពទ្រទ្រង់កំណើនសេដ្ឋកិច្ចខ្ពស់ ទោះបីមានការធ្លាក់ចុះសេដ្ឋកិច្ចសកល ក៏មានការកាត់បន្ថយភាពក្រីក្រគួរឱ្យកត់សម្គាល់ និងមានភាពប្រសើរឡើងនូវសូចនាករសង្គមសំខាន់ៗ ក្នុងវិស័យសុខាភិបាល និងអប់រំ[៦] ។

## ១.២.២ ផែនការអភិវឌ្ឍរបស់រាជរដ្ឋាភិបាល

យុទ្ធសាស្ត្រចតុកោណសម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ត្រូវបានផ្សព្វផ្សាយនៅឆ្នាំ២០០៤ ហើយណែនាំអំពីការអនុវត្តរបៀបវារៈគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា។ អភិបាលកិច្ចល្អគឺជាស្នូលក្នុងយុទ្ធសាស្ត្រចតុកោណ។ រីឯផ្នែកដទៃទៀតនៃយុទ្ធសាស្ត្រចតុកោណគឺការជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍកសិកម្ម ការស្តារឡើងវិញ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍវិស័យឯកជន ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ខែកញ្ញា ឆ្នាំ២០១៣ គឺជាត្រីវិស័យជួយដល់រាជរដ្ឋាភិបាលធ្វើការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព សមធម៌ ការងារ និងកំណើនសេដ្ឋកិច្ច។ ការកំណត់គោលដៅ ក៏ដូចជាការតាមដានវឌ្ឍនភាពឆ្ពោះទៅការសម្រេចបាននូវលទ្ធផលនៃគោលដៅអភិវឌ្ឍន៍យុទ្ធសាស្ត្រចតុកោណ តម្រូវឱ្យមានព័ត៌មានស្ថិតិទាន់ពេលវេលា និងមានគុណភាពល្អអាចទទួលយកបាន ដែលប្រព័ន្ធស្ថិតិជាតិរំពឹងថានឹងផ្តល់ជូន។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានរៀបចំជាឯកសារផែនការសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តចក្ខុវិស័យដែលបានកំណត់ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ។ សូចនាករក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាគន្លឹះកំណត់ដ៏សំខាន់នៃព័ត៌មាន ដើម្បីបរិយាយអំពីស្ថានភាពបច្ចុប្បន្ន និងផ្លូវឆ្ពោះទៅមុខ ដើម្បីអភិវឌ្ឍសង្គមកម្ពុជាយោងតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

ការសម្របសម្រួលស្ថិតិ និងសូចនាករប្រកបដោយគុណភាពខ្ពស់ មានសារៈសំខាន់ណាស់សម្រាប់អ្នកនយោបាយ នៅពេលដំណើរការឆ្ពោះទៅរកការរីកចម្រើននិរន្តរភាព និងសុខុមាលភាពសម្រាប់សង្គមកម្ពុជា។ យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិមានសារៈសំខាន់ នៅពេលនិយាយអំពីព័ត៌មានដែលត្រូវការចាំបាច់ និងបង្ហាញអំពីអង្កេត និងជំរឿននានាដែលត្រូវតែមាន។ យុទ្ធសាស្ត្រនេះក៏ចង្អុលបង្ហាញផងដែរនូវដែនកំណត់ ដើម្បីបំពេញស្ថិតិដែលបានគ្រោងទុកដោយសារតម្រូវការរបស់អ្នកប្រើប្រាស់ ដែលជាគម្លាតហិរញ្ញវត្ថុដ៏ធំនៅក្នុងការផ្តល់មូលនិធិរបស់រាជរដ្ឋាភិបាល។

តួអង្គសំខាន់នៅក្នុងប្រព័ន្ធស្ថិតិជាតិ គឺវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស្ថាប័ន និងធនាគារជាតិនៃកម្ពុជា។ ក្រសួងមួយចំនួនបង្កើតផែនការប្រាំឆ្នាំ សម្រាប់ធុរៈកិច្ច និងប្រតិបត្តិការរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ

---

[៦] យុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សហគមន៍អឺរ៉ុបសម្រាប់កម្ពុជា ឆ្នាំ២០១៤-២០១៨ (European Development Cooperation Strategy for Cambodia 2014-2018)។

ផែនការនេះជាញឹកញាប់ឆ្លុះបញ្ចាំងអំពីមហិច្ឆតាខ្ពស់ជាងអ្វីដែលធនធានមានកំណត់ ទាំងមន្ត្រី ទាំងហិរញ្ញវត្ថុដែលមាន។ ការសម្របសម្រួលនៅមានកម្រិតរវាងផែនការរយៈពេលវែង និងរយៈពេលខ្លីរបស់ក្រសួងនានា។ នេះត្រូវធ្វើឱ្យប្រសើរឡើង ដើម្បីផលិតស្ថិតិតាមវិធីប្រសិទ្ធិភាពធនធានជាងមុន។

ក្រសួងផែនការទទួលខុសត្រូវចំពោះផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយវិទ្យាស្ថានជាតិស្ថិតិទទួលខុសត្រូវលើការផ្តល់ស្ថិតិសម្រាប់ការតាមដានប្រចាំឆ្នាំ។

# ជំពូក ២ ការវាយតម្លៃលើប្រព័ន្ធស្ថិតិជាតិ

## ២.១ ប្រព័ន្ធស្ថិតិជាតិ

### ២.១.១ ប្រវត្តិសង្ខេបនៃប្រព័ន្ធស្ថិតិជាតិ

ការប្រមូលទិន្នន័យស្ថិតិនៅកម្ពុជាមានប្រវត្តិយូរយារណាស់មកហើយ តាំងពីឆ្នាំ១៨០០ មកម្លេះ។ ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ១៩៤៨ ប្រព័ន្ធស្ថិតិជាតិបានចាប់ផ្តើមលេចរូបរាងពិតប្រាកដ។ ប្រព័ន្ធស្ថិតិជាតិបានឆ្លងកាត់ការផ្លាស់ប្តូរដោយសារកាលៈទេសៈនយោបាយ សេដ្ឋកិច្ច និងសង្គមក្នុងឆ្នាំបន្តបន្ទាប់។ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩) សកម្មភាពស្ថិតិដែលមានស្រាប់ត្រូវបានបំផ្លាញ។ បន្ទាប់មកនៅឆ្នាំ១៩៧៩ នាយកដ្ឋានស្ថិតិត្រូវបានបង្កើត (ដោយគ្មានអ្នកស្ថិតិឆ្លងការបណ្តុះបណ្តាល) ស្ថិតនៅក្រោមក្រសួងហិរញ្ញវត្ថុ ហើយត្រូវបានប្តូរមកក្រសួងផែនការ នៅឆ្នាំ១៩៨១។ ពេលនោះ នាយកដ្ឋានត្រូវបានប្តូរឈ្មោះទៅជាវិទ្យាស្ថានជាតិស្ថិតិ នៅឆ្នាំ១៩៩៤ ហើយត្រូវបានប្តូរឋានៈជាអគ្គនាយកដ្ឋានមួយរបស់ក្រសួងផែនការ នៅឆ្នាំ១៩៩៧។

ច្បាប់ស្តីពីស្ថិតិ ឆ្នាំ២០០៥ ត្រូវបានធ្វើវិសោធនកម្មនៅខែធ្នូ ឆ្នាំ២០១៥ ដោយបានកំណត់ "ប្រព័ន្ធស្ថិតិជាតិ" ឱ្យកាន់តែរឹងមាំសំដៅដល់ "សមាហរណកម្មនៃស្ថិតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិ រួមបញ្ចូលទាំងទិន្នន័យស្ថិតិផ្លូវការ និងកម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធស្ថិតិ និងអង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត" (មាត្រា៤)។ អង្គភាពស្នូលនៃប្រព័ន្ធស្ថិតិ គឺជាស្ថាប័នធ្វើគោលនយោបាយស្ថិតិផ្លូវការ និងភ្នាក់ងារប្រមូលទិន្នន័យបឋម (វិទ្យាស្ថានជាតិស្ថិតិ)។ ការិយាល័យ និងផ្នែកស្ថិតិនៅក្នុងនាយកដ្ឋានផែនការ និងស្ថិតិនៃបណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ព្រមទាំងការិយាល័យស្ថិតិនៅក្នុងមន្ទីរផែនការរាជធានី ខេត្ត ស្រុកខ័ណ្ឌ មានរួមបញ្ចូលប្រព័ន្ធស្ថិតិផ្សេងទៀត។ ប្រព័ន្ធស្ថិតិជាតិបានជ្រើសយករចនាសម្ព័ន្ធវិមជ្ឈការ ដែលកម្មវិធីស្ថិតិត្រូវបានគ្រប់គ្រង និងប្រតិបត្តិដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាលផ្សេងគ្នា។ ជាក់ស្តែងមានស្ថាប័នចំនួន ២៩ រួមមានវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំងនៅតាមបណ្តាក្រសួង និងស្ថាប័ន (វិទ្យាស្ថានជាតិស្ថិតិ ក្រសួង ស្ថាប័នរាជរដ្ឋាភិបាលចំនួន ២៧ និងធនាគារជាតិនៃកម្ពុជា) រួមគ្នាផលិតស្ថិតិផ្លូវការដែលបានចាត់តាំង ដែលបង្កើតជាប្រព័ន្ធស្ថិតិជាតិវិមជ្ឈការពេញលេញមួយ។

ទិន្នន័យមួយចំនួនបានមកពីប្រព័ន្ធរដ្ឋបាល និងផ្សេងទៀត និងបានមកពីអង្កេតស្ថិតិ។ មួយភាគធំនៃព័ត៌មាននេះត្រូវបានប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ការរៀបចំគោលនយោបាយ និងកម្មវិធី ធ្វើផែនការ និងតាមដាន សិក្សាស្រាវជ្រាវ និងវិភាគ។ ស្ថាប័នកណ្តាលនៃប្រព័ន្ធស្ថិតិជាតិ គឺវិទ្យាស្ថានជាតិស្ថិតិនៅក្រសួងផែនការ។ ក្រសួងសំខាន់ៗដទៃទៀតសម្រាប់ស្ថិតិសេដ្ឋកិច្ច សង្គម ប្រជាសាស្ត្រ និងបរិស្ថាន គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម និងក្រសួងទេសចរណ៍។ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលមួយចំនួនទៀតក៏ប្រមូល ប្រើប្រាស់ និងផ្តល់ព័ត៌មានស្ថិតិផងដែរ និងបង្កើតជាផ្នែកមួយរបស់ប្រព័ន្ធស្ថិតិជាតិ។ ស្ថាប័នសំខាន់ផ្សេងទៀត ដែលចូលរួមក្នុងការផលិត និងប្រើប្រាស់ស្ថិតិសេដ្ឋកិច្ច គឺធនាគារជាតិនៃកម្ពុជា។

### ២.១.២ វិទ្យាស្ថានជាតិស្ថិតិ

នៅក្នុងក្របខ័ណ្ឌដែលបានពណ៌នាខាងលើ និងច្បាប់ស្តីពីស្ថិតិ វិទ្យាស្ថានជាតិស្ថិតិគឺជាស្ថាប័នធ្វើគោលនយោបាយស្ថិតិផ្លូវការ ជាអ្នកសម្របសម្រួល និងជាអ្នកផលិតទិន្នន័យស្ថិតិសំខាន់ៗ។

ភារកិច្ចរបស់វិទ្យាស្ថានជាតិស្ថិតិបានកំណត់យ៉ាងច្បាស់ នៅក្នុងច្បាប់ស្តីពីស្ថិតិ ឆ្នាំ២០១៥ ដូចខាងក្រោម ៖

- ធ្វើជំរឿន (ប្រជាជន កសិកម្ម និងសេដ្ឋកិច្ច) - (សហការជាមួយស្ថាប័នពាក់ព័ន្ធ (មាត្រា៧))
- បង្កើតបញ្ជីពាណិជ្ជកម្ម ឬគ្រោងសំណាកគំរូសម្រាប់អង្កេតគ្រួសារ ដើម្បីរក្សាទុក និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ (មាត្រា១០)
- ធ្វើសៀវភៅវាយឈ្មោះ និងទីតាំងរបស់ប្រភពទិន្នន័យស្ថិតិ និងរដ្ឋបាលដែលត្រូវថែរក្សា និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ (មាត្រា១១)
- ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិគ្រឹះតាមការធ្វើជំរឿន អង្កេត និងប្រើប្រាស់ប្រភពទិន្នន័យរដ្ឋបាល (មាត្រា១២)
- ចងក្រងគណនេយ្យជាតិកម្ពុជា និងសន្ទស្សន៍ថ្លៃ ក៏ដូចជាសូចនាករសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រ (មាត្រា១២)
- កសាងគោលនយោបាយស្ថិតិផ្លូវការ ក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័ន (មាត្រា១៤) និង
- បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិដែលបានផលិតជូនអ្នកប្រើប្រាស់ទាំងអស់ បោះពុម្ពសៀវភៅស្ថិតិប្រចាំឆ្នាំ និងរក្សាឃ្លាំងទិន្នន័យទាំងឡាយដែលមានទិន្នន័យផ្ដុំអាចឱ្យសាធារណជនទូទៅរកបានតាមប្រព័ន្ធអ៊ីនធឺណិត (មាត្រា២៣)

ក្នុងកិច្ចការទាំងនេះ វិទ្យាស្ថានជាតិស្ថិតិត្រូវ (មាត្រា១៥) ៖

- ដំណើរការយន្តការសម្របសម្រួលសម្រាប់ធានាការគ្រប់គ្រងដែលមានសមត្ថភាព និងប្រសិទ្ធភាពនៃប្រព័ន្ធស្ថិតិជាតិ
- ធ្វើការសម្របសម្រួលក្នុងសកម្មភាពនៃកិច្ចអភិវឌ្ឍស្ថិតិរួម និងការបណ្តុះបណ្តាលជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងវិស័យឯកជន
- ធ្វើកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពស្ថិតិ ជាមួយអង្គការអន្តរជាតិ អង្គភាពស្ថិតិជាតិនៃប្រទេសនានា និងវិស័យឯកជន នានាទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន និង
- កំណត់បទដ្ឋានស្ថិតិជាតិដែលទាក់ទងនឹងចំណាត់ថ្នាក់ ទស្សនទាន និយមន័យ និងអង្គពិនិត្យពិចារណាស្ថិតិ។

វិទ្យាស្ថានជាតិស្ថិតិត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីប្រព័ន្ធស្ថិតិជាតិទៅរដ្ឋមន្ត្រីក្រសួងផែនការ ហើយធ្វើរបាយការណ៍ប្រចាំឆ្នាំនេះជូនទីស្តីការគណៈរដ្ឋមន្ត្រីជារៀងរាល់ឆ្នាំ[៧]។ របាយការណ៍ប្រចាំឆ្នាំដែលត្រូវរាយការណ៍ជូន

---

[៧] អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ មាត្រា១០។

រដ្ឋមន្ត្រីក្រសួងផែនការនៅមិនទាន់ពេលវេលាឡើយ ដាក់ស្តែងរបាយការណ៍ប្រចាំឆ្នាំ២០១៥ ត្រូវបានកំណត់កាលបរិច្ឆេទខែធ្នូ ឆ្នាំ២០១៦។

នៅឆ្នាំ២០១៥ ច្បាប់ស្តីពីស្ថិតិត្រូវបានធ្វើបច្ចុប្បន្នកម្ម អគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិជា **ប្រធានមន្ត្រីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាការអភិវឌ្ឍនៃការផ្តល់អគ្គនាយកនូវតំណែងមួយ មានអំណាចក្នុងការនិយាយអំពីស្ថិតិនៅកម្រិតខ្ពស់បំផុតក្នុងរដ្ឋាភិបាល (វាក៏មានការពាក់ព័ន្ធទៅនឹងឯករាជ្យភាពរបស់វិទ្យាស្ថានជាតិស្ថិតិផងដែរ)។

បច្ចុប្បន្ន វិទ្យាស្ថានជាតិស្ថិតិមានឯករាជ្យភាពពេញលេញរបស់ខ្លួនលើបញ្ហាបច្ចេកទេស។ វាបានបង្កើនឯករាជ្យភាពលើកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុ ប៉ុន្តែនៅមានខ្វះឯករាជ្យភាពក្នុងវិស័យពីរ គឺការកំណត់អាទិភាពសកម្មភាពស្ថិតិ និងការអភិវឌ្ឍរដ្ឋបាល និងធនធានមនុស្ស។

វិទ្យាស្ថានជាតិស្ថិតិមានឯករាជ្យភាពបច្ចេកទេស និងមានសេរីភាពពេញលេញដល់ការសម្រេចបច្ចេកទេសរបស់ខ្លួន តាមរយៈការប្រើប្រាស់វិធីសាស្ត្រប្រកបដោយវិជ្ជាជីវៈ ដូចដែលបានគាំទ្រយ៉ាងពេញទំហឹងនៅក្នុងច្បាប់ស្តីពីស្ថិតិ ឆ្នាំ២០១៥ (មាត្រា៥)។ ស្ថិតិផ្លូវការមិនអាចទៅដល់រាជរដ្ឋាភិបាលកម្ពុជា មុនពេលធ្វើការចេញផ្សាយ និងការផ្សព្វផ្សាយក្នុងពេលជាមួយគ្នាសម្រាប់អ្នកប្រើប្រាស់ទិន្នន័យទាំងអស់ឡើយ។ ច្បាប់ស្តីពីស្ថិតិ ឆ្នាំ២០១៥ បានប្រគល់សិទ្ធិឱ្យអគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិ ក្នុងការធ្វើអត្ថាធិប្បាយ ពន្យល់កែតម្រូវលើការបកស្រាយមិនត្រឹមត្រូវ និងការប្រើប្រាស់ស្ថិតិខុស ទោះជាជននោះ ឬស្ថាប័ននោះជាម្ចាស់ដើមនៃស្ថិតិនោះក៏ដោយ (មាត្រា២៨) ដែលជាការបង្ហាញគួរឱ្យកត់សម្គាល់ពីឯករាជ្យភាពបច្ចេកទេសរបស់វិទ្យាស្ថានជាតិស្ថិតិ។ ទោះជាយ៉ាងណាក៏ដោយ វិទ្យាស្ថានជាតិស្ថិតិហាក់ដូចជាកម្រធ្វើបែបនេះឡើយ ដោយសារសមត្ថភាពរបស់វិទ្យាស្ថានជាតិស្ថិតិមិនអាចអនុវត្តតួនាទីដូចនេះបាន។ វិទ្យាស្ថានជាតិស្ថិតិនៅមិនទាន់ធ្វើការប្រកាសប្រតិទិនចេញផ្សាយទិន្នន័យជាមុនឡើយ មូលហេតុមួយនៃការវាស់វែងឯករាជ្យភាពបច្ចេកទេសគឺដោយសារគ្មានសមត្ថភាពគ្រប់គ្រាន់ និងការត្រួតពិនិត្យទៅលើពេលវេលានៃការចេញផ្សាយទិន្នន័យ។ ទោះជាយ៉ាងណាក៏ដោយ វិទ្យាស្ថានជាតិស្ថិតិបានផ្តល់ព័ត៌មានតាមកាលបរិច្ឆេទចេញផ្សាយរំពឹងទុកនូវសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងគណនេយ្យជាតិ។ វិទ្យាស្ថានជាតិស្ថិតិមានកាលវិភាគគ្រោងទុកសម្រាប់ការបោះពុម្ពផ្សាយនីមួយៗពីជំរឿន និងអង្កេត ឧទាហរណ៍លទ្ធផលនៃអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាគួរតែបោះពុម្ពផ្សាយ (តាមរយៈសិក្ខាសាលា) ប្រហែលដប់ខែ បន្ទាប់ពីការប្រមូលទិន្នន័យត្រូវបានបញ្ចប់។ គម្រោងកាលបរិច្ឆេទចេញផ្សាយ ក៏ត្រូវបានដាក់បញ្ចូលក្នុងផែនការប្រចាំឆ្នាំរបស់វិទ្យាស្ថានជាតិស្ថិតិផងដែរ។ លិខិតអញ្ជើញ ឬដំណឹងត្រូវបានផ្ញើចេញបាន ១-២ សប្តាហ៍ មុនពេលសិក្ខាសាលា។

ការចាប់ផ្តើមនៃថវិកាកម្មវិធីក្នុងថវិកាជាតិឆ្នាំ២០១៧ រួមបញ្ចូលទាំងថវិកាសម្រាប់ស្ថិតិ បានបង្ហាញពីការបោះជំហ៊ានដ៏ធំមួយទៅរកឯករាជ្យភាពហិរញ្ញវត្ថុសម្រាប់វិទ្យាស្ថានជាតិស្ថិតិ។ ការផ្តួចផ្តើមនេះនឹងអនុញ្ញាតឱ្យវិទ្យាស្ថានជាតិស្ថិតិស្នើសុំថវិការបស់ខ្លួន និងបានគ្រប់គ្រងលើការចំណាយនេះ រួមទាំងការធ្វើចំណាយដោយឡែក (ផ្អែកលើច្បាប់ថវិកា)។

អគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិមានអំណាចចាត់មន្ត្រីឡើងវិញក្នុងការិយាល័យរបស់វិទ្យាស្ថានជាតិស្ថិតិ និងអាចចាត់ពួកគេឱ្យធ្វើការនៅការិយាល័យថ្នាក់ខេត្ត ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងផែនការ។ ជម្រើសក្នុង

ការគ្រប់គ្រងមន្ត្រីស្ថិតិ ដូចជាវិញ្ញាបនបត្រសម្រាប់កម្រិតជំនាញស្ថិតិផ្តល់ជូនរង្វាន់តាមកម្រិតនីមួយៗនៅវិទ្យាស្ថានជាតិស្ថិតិ នៅមិនទាន់អនុវត្តបាន។

### ២.១.៣ អង្គភាពស្ថិតិដែលបានចាត់តាំង

នៅក្នុងក្របខ័ណ្ឌដូចបានពណ៌នាខាងលើ ច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងអង្គភាពស្ថិតិដែលបានចាត់តាំងនៅបណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលត្រូវអនុវត្តសកម្មភាពប្រមូលទិន្នន័យតាមវិស័យជាក់លាក់ និងផ្តល់ស្ថិតិដែលបានចាត់តាំងតាមផ្នែក។ ប្រព័ន្ធនៃស្ថិតិដែលបានចាត់តាំងត្រូវបានចាត់ទុកជាយន្តការសារវន្តមួយ សម្រាប់ធានានូវភាពទូលំទូលាយ និងចរិតលក្ខណៈនៃប្រព័ន្ធស្ថិតិជាតិ។

នៅក្នុងច្បាប់ស្តីពីស្ថិតិ ឆ្នាំ២០១៥ អង្គភាពស្ថិតិដែលបានចាត់តាំងត្រូវ ៖

- ប្រមូលទិន្នន័យតាមផ្នែកដោយខ្លួនឯង ឬដោយសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ តាមរយៈការធ្វើអង្កេត និងការប្រមូលទិន្នន័យស្ថិតិពីការកត់ត្រារដ្ឋបាល (មាត្រា១៣) និង
- បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិដែលបានផលិតជូនអ្នកប្រើប្រាស់ទាំងអស់ (មាត្រា២៣ក)។

អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងប្រគល់អាណត្តិឱ្យក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលត្រូវបម្រើសេចក្តីត្រូវការព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយ អ្នកធ្វើសេចក្តីសម្រេច និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ (មាត្រា២) ហើយអនុក្រឹត្យបានបញ្ជាក់ពីស្ថិតិដែលត្រូវប្រមូល ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយដោយអង្គភាពស្ថិតិដែលបានចាត់តាំងនីមួយៗ (មាត្រា៦) អនុក្រឹត្យក៏បានបញ្ជាក់ផងដែរពីកម្រិតនៃប្រភពទិន្នន័យដែលអង្គភាពស្ថិតិដែលបានចាត់តាំងត្រូវបានផ្តល់សិទ្ធឱ្យប្រើប្រាស់ ដូចជាទិន្នន័យរដ្ឋបាល ឬទិន្នន័យអង្កេតតាមវិស័យដែលបានប្រមូលដោយបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សមាគម និងសង្គមស៊ីវិល ទិន្នន័យថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ និងសង្កាត់ និងទិន្នន័យចេញផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ (មាត្រា៧)។

ក្របខ័ណ្ឌគតិយុត្តនេះ ផ្តល់ឱ្យអង្គភាពស្ថិតិដែលបានចាត់តាំងនូវភាពច្បាស់លាស់ក្នុងការទទួលខុសត្រូវរបស់ខ្លួន និងផ្តល់ពួកគេនូវអំណាចទូលំទូលាយក្នុងការប្រមូលទិន្នន័យសម្រាប់គោលបំណងស្ថិតិ។ រដ្ឋមន្ត្រីក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលជាធម្មតាត្រូវពិនិត្យ និងយល់ព្រមលើស្ថិតិ មុនពេលបោះពុម្ពផ្សាយ។

ដូចបានបង្ហាញនៅក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិ មានបញ្ហាប្រឈមសំខាន់ៗនៅក្នុងការផលិតស្ថិតិផ្លូវការដែលបានចាត់តាំង ជាពិសេសនៅបណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។ ទន្ទឹមនឹងតម្រូវការទិន្នន័យមួយចំនួនធំត្រូវតែមាន ទាន់ពេលវេលាសម្រាប់តាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏មានការធានាតិចតួចនូវគុណភាពទិន្នន័យដែលបានរាយការណ៍ផងដែរ។ មានតែក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលមួយចំនួនតូចប៉ុណ្ណោះដែលមានប្រព័ន្ធទិន្នន័យរដ្ឋបាលល្អ ខណៈដែលកិច្ចសម្របសម្រួលផ្ទៃក្នុងផ្សេងៗរវាងអង្គភាពស្ថិតិដែលបានចាត់តាំង និងសមាសភាពផលិតស្ថិតិនៃអង្គភាពប្រតិបត្តិនៅខ្សោយនៅឡើយ។

អង្គភាពស្ថិតិដែលបានចាត់តាំងជាច្រើនខ្វះថវិកាគ្រប់គ្រាន់ និងមន្ត្រីមានជំនាញចាំបាច់ ដើម្បីគ្រប់គ្រងការប្រមូលទិន្នន័យ និងធានាថាបទដ្ឋានគុណភាពត្រូវបានអនុវត្ត។ អង្គភាពទាំងនេះបានបាត់បង់អាទិភាពផ្សេងៗ ក្នុងការផ្តល់ ឬចាត់ចែងធនធាន រួមមានធនធានមនុស្ស បច្ចេកវិទ្យា និងធនធានហិរញ្ញវត្ថុ។ រាជរដ្ឋាភិបាលកំពុងរៀបចំកែ

ទម្រង់បៀវត្សរ៍ ទាំងមន្ត្រីនៅវិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីរដ្ឋាភិបាលផ្សេងទៀត ព្រមទាំងអ្នកធ្វើការស្ថិតិនៅតាមអង្គភាពស្ថិតិដែលបានចាត់តាំងដទៃទៀត។

បច្ចុប្បន្ននេះ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលទទួលបានតែជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ជាសេវាទីប្រឹក្សាបច្ចេកទេស និងវគ្គបណ្តុះបណ្តាលប៉ុណ្ណោះ។

## ២.២ ការវាយតម្លៃប្រព័ន្ធស្ថិតិជាតិ

### ២.២.១ ប្រវត្តិនៃការវាយតម្លៃ

គន្លឹះក្នុងការវាយតម្លៃគឺការរកឃើញ និងអនុសាសន៍នានានៃរបាយការណ៍ពាក់កណ្តាលអាណត្តិនៃផែនការមេស្ថិតិកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០១២ ការត្រួតពិនិត្យប្រព័ន្ធស្ថិតិជាតិកម្ពុជា នៅខែមិថុនា ឆ្នាំ២០១៥ និងផែនទីបង្ហាញផ្លូវនៃយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ខែកុម្ភៈ ឆ្នាំ២០១៦។

ទាំងអស់នេះក៏ផ្តោតលើការវាយតម្លៃស្ថិតិ ដែលមានសារៈសំខាន់ដល់សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ដូចជាស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ ស្ថិតិពាណិជ្ជកម្មអន្តរជាតិខាងសេវាកម្ម ស្ថិតិវិនិយោគផ្ទាល់ពីបរទេស និងស្ថិតិដឹកជញ្ជូន។ ការវាយតម្លៃផ្សេងទៀត "បង្កើនសមត្ថភាពស្ថិតិជាតិ ដើម្បីវាស់វែង តាមដាន វាយតម្លៃ និងរាយការណ៍អំពីវឌ្ឍនភាពលើការសម្រេចបានក្រោយឆ្នាំ២០១៥ លើគោលដៅ និងចំណុចដៅសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (ក្នុងប្រទេសកម្ពុជា)" ផ្នែកស្ថិតិសហប្រជាជាតិ និងវិទ្យាស្ថានជាតិស្ថិតិ របាយការណ៍លើកទីមួយអំពីបេសកកម្ម ថ្ងៃទី៩-១៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងរបាយការណ៍លើកទីពីរអំពីបេសកកម្ម ថ្ងៃទី៩-១៣ ខែឧសភា ឆ្នាំ២០១៦ (របាយការណ៍សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ផ្នែកស្ថិតិសហប្រជាជាតិ និងវិទ្យាស្ថានជាតិស្ថិតិ)។ FIDES Services Cambodia ការវាយតម្លៃប្រព័ន្ធត្រួតពិនិត្យប្រតិបត្តិការផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្មរបស់វិទ្យាស្ថានជាតិស្ថិតិ (ខែមីនា ឆ្នាំ២០១៧) (របាយការណ៍របស់ FIDES) និងរបាយការណ៍ប្រទេសស្តីពីការគាំទ្រដល់ស្ថិតិកម្ពុជា (CRESS) របស់ PARIS21/វិទ្យាស្ថានជាតិស្ថិតិ ខែឧសភា ឆ្នាំ២០១៧ និងការពង្រឹងសមត្ថភាពស្ថិតិសេដ្ឋកិច្ចដែលបានរាយការណ៍ក្នុងកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ (ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧)។

### ២.២.២ របាយការណ៍ពាក់កណ្តាលអាណត្តិ

ការវាយតម្លៃដ៏ទូលំទូលាយមួយ គឺរបាយការណ៍ពាក់កណ្តាលអាណត្តិបានឱ្យដឹងពីការសម្រេចបានជាច្រើនក្នុងអំឡុងពេលត្រួតពិនិត្យឡើងវិញ។ ការសម្រេចបានគួរឱ្យកត់សម្គាល់ទាំងនោះ រួមមាន ៖

ក. ការបង្កើតក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ ជាយន្តការអន្តរស្ថាប័នកម្រិតខ្ពស់ដែលអាចជួយពង្រឹងទំនាក់ទំនងគ្នារវាងគោលនយោបាយ និងស្ថិតិ និងសម្របសម្រួលស្ថាប័នស្ថិតិ។

ខ. ការរៀបចំការងារស្ថាប័នបានល្អសម្រាប់វិស័យស្ថិតិជាក់លាក់។

គ. ការបង្ហាញក្រមប្រតិបត្តិ[៨] ក្នុងស្ថិតិឆ្ពោះទៅការធ្វើឱ្យប្រសើរឡើងនូវគុណភាព។

---

[៨] ក្រមប្រតិបត្តិរបស់ប្រព័ន្ធស្ថិតិសហគមន៍អាស៊ាន ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២។

ឃ. បង្កើនសមត្ថភាពរបស់វិទ្យាស្ថានជាតិស្ថិតិក្នុងការគ្រប់គ្រង និងធ្វើសកម្មភាពស្ថិតិ ក៏ដូចជាអនុវត្តបទដ្ឋានអនុសាសន៍អន្តរជាតិឆ្ពោះទៅភាពប្រសើរឡើងនៃគុណភាពស្ថិតិ។
ង. បង្កើនការបណ្តុះបណ្តាល និងជំនួយបច្ចេកទេស សម្រាប់បណ្តាក្រសួង ស្ថាប័ន និងអង្គភាពស្ថិតិដែលបានចាត់តាំង។
ច. ធ្វើឱ្យប្រសើរឡើងនូវការផ្សព្វផ្សាយស្ថិតិ តាមរយៈវេបសាយ និងការបោះពុម្ពផ្សាយនៃរបាយការណ៍ស្ថិតិ។
ឆ. បន្តការអនុវត្តល្អក្នុងការផ្តល់ទិន្នន័យ និងការសម្របសម្រួលសម្រាប់តាមដានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។
ជ. ធ្វើជំរឿន និងអង្កេតសំខាន់ៗ និងសកម្មភាពស្ថិតិសំខាន់ផ្សេងទៀត ជាមួយនឹងការបង្កើនមូលនិធិពីរាជរដ្ឋាភិបាល។
ឈ. កំណើននៃការប្រើប្រាស់ស្ថិតិក្នុងរាជរដ្ឋាភិបាល។

ទន្ទឹមនឹងវឌ្ឍនភាពក្នុងវិស័យខាងលើ របាយការណ៍ពាក់កណ្តាលអាណត្តិក៏បានរកឃើញនូវបញ្ហា និងការប្រឈមមួយចំនួនដែលត្រូវការដោះស្រាយ ដើម្បីបន្តនិរន្តភាព និងធ្វើឱ្យប្រសើរឡើងថែមទៀត ៖

ក. គម្លាតហិរញ្ញវត្ថុដ៏ធំ ដើម្បីអនុវត្តសកម្មភាពអាទិភាពជាច្រើននៅក្នុងផែនការមេស្ថិតិ។ ហិរញ្ញប្បទានដល់ការផលិតស្ថិតិផ្លូវការក្នុងអំឡុងឆ្នាំ២០០៩-២០១១ រាជរដ្ឋាភិបាលបានបង្កើនថវិការបស់វិទ្យាស្ថានជាតិស្ថិតិដោយពង្រីកប្រមាណនៃចំណាយសរុបពី១/៥ ទៅ ១/៣។ ទោះជាយ៉ាងណាក៏ដោយ ជំនួយពីដៃគូនៅតែមានចំនួន ២/៣ នៃមូលនិធិសរុប។ ការផ្តល់មូលនិធិនៅមានកម្រិតបានកើតមានឡើងនៅក្រសួងមួយចំនួន។ ដូច្នេះ យុទ្ធសាស្ត្រហិរញ្ញប្បទានប្រសើជាងនេះ គួរតែត្រូវបានពិចារណា។
ខ. ទន្ទឹមនឹងក្របខ័ណ្ឌគតិយុត្តបានពង្រឹងមុខងារ និងតួនាទីរបស់វិទ្យាស្ថានជាតិស្ថិតិ ក៏នៅមានផ្នែកមួយចំនួនត្រូវធ្វើឱ្យប្រសើរឡើង រួមមានភាពច្បាស់លាស់ ភាពទូលំទូលាយ និងសង្គតិភាពក្នុងការទទួលខុសត្រូវនិយមន័យ និងកម្រិតលម្អិត។
គ. ត្រូវពង្រឹងទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ ក្នុងការធ្វើផែនការ ការសម្របសម្រួល និងគោលបំណងប្រឹក្សាយោបល់
ឃ. បន្តការខិតខំកំណត់បទដ្ឋានគុណភាព និងបង្កើនការអនុវត្តបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាក្នុងដំណើរការកិច្ចការស្ថិតិ និងប្រព័ន្ធព័ត៌មាន ប៉ុន្តែមានផ្នែកមួយចំនួនទៀតត្រូវធ្វើឱ្យប្រសើរឡើងថែមទៀត។
ង. នៅមានគម្លាតជំនាញបច្ចេកទេសសូម្បីនៅវិទ្យាស្ថានជាតិស្ថិតិ ប៉ុន្តែគម្លាតនេះកាន់តែធំនៅក្នុងក្រសួងនានា។ សកម្មភាពបណ្តុះបណ្តាលត្រូវការសម្របសម្រួលបានល្អ និងរួមបញ្ចូលគ្នា សម្រាប់កសាងសមត្ថភាពប្រកបដោយចីរភាពថែមទៀតនៃប្រព័ន្ធស្ថិតិជាតិ។
ច. ត្រូវធ្វើឱ្យប្រសើរឡើងនូវកិច្ចសម្របសម្រួលនៃការផលិតទិន្នន័យស្ថិតិនៅតាមក្រសួង ស្ថាប័ន និងរាងការិយាល័យថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត។
ឆ. កម្រិតប្រាក់បៀវត្សរ៍ទាបរបស់មន្ត្រីស្ថិតិនៅតែជាបញ្ហាលំបាក ប៉ុន្តែអ្វីដែលត្រូវដោះស្រាយនោះ ទាល់តែប្រព័ន្ធស្ថិតិជាតិកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងការពង្រីកតម្រូវការទិន្នន័យ។

ជ. មានវឌ្ឍនភាពខ្ពស់ក្នុងការផ្សព្វផ្សាយស្ថិតិផ្លូវការ ប៉ុន្តែការផ្តល់ចំណេះដឹងបន្ថែមអំពីការប្រើប្រាស់ និងសារប្រយោជន៍នៃទិន្នន័យ គួរបង្កើនថែមទៀតនូវការប្រើប្រាស់ស្ថិតិក្នុងគោលនយោបាយ និងគោលបំណងផ្សេងទៀត។

ឈ. ទោះជាស្ថិតិមួយចំនួនធំត្រូវការសម្រាប់តាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានផលិតក៏ដោយ ក៏នៅមិនទាន់មានការយល់ព្រមច្បាស់លាស់ ក្នុងការផ្តល់អាទិភាពដល់សកម្មភាពស្ថិតិនៅក្នុងផែនការមេស្ថិតិរវាងអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យ។

ញ. ពង្រឹងយន្តការស្ថាប័នថែមទៀតសម្រាប់សម្របសម្រួលជំនួយបច្ចេកទេស តាមតម្រូវការស្ថិតិរវាងវិទ្យាស្ថានជាតិស្ថិតិ និងដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយនានា ដើម្បីធានាថាធនធានខាងក្រៅដែលនឹងអាចថយចុះនាពេលអនាគត ត្រូវបានបង្កើនប្រសិទ្ធភាព និងប្រើប្រាស់សម្រាប់ដោះស្រាយគម្លាតទិន្នន័យសំខាន់ៗ និងសមត្ថភាព។

គំហើញខាងលើបានបញ្ជាក់ឡើងវិញនូវការសន្និដ្ឋានមួយចំនួនពីការវាយតម្លៃថ្មីៗនេះ គឺរបាយការណ៍សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ផ្នែកស្ថិតិសហប្រជាជាតិ និងវិទ្យាស្ថានជាតិស្ថិតិ របាយការណ៍ប្រទេសស្តីពីការគាំទ្រដល់ស្ថិតិកម្ពុជា (CRESS) របស់ PARIS21/វិទ្យាស្ថានជាតិស្ថិតិ និងកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ (ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧)។

## ២.៣ ការវិភាគយុទ្ធសាស្ត្រនៃប្រព័ន្ធស្ថិតិជាតិ និងតម្រូវការអភិវឌ្ឍន៍

ការវាយតម្លៃតាមវិស័យនៃស្ថិតិសេដ្ឋកិច្ច សង្គម និងធនធានធម្មជាតិនេះ គឺជាដំណាក់កាលមួយក្នុងចំណោមពីរដំណាក់កាលដែលគ្របដណ្តប់នៅក្នុងគម្រោងនេះ[៩] ។ ដំណាក់កាលផ្សេងទៀត គឺជាការរៀបចំប្រព័ន្ធស្ថិតិជាតិ ដែលនឹងកសាងផ្អែកលើលទ្ធផលវាយតម្លៃ។

ការវិភាគរួមមានការពិនិត្យឡើងវិញ និងការវាយតម្លៃដូចខាងក្រោម ៖

១. ប្រព័ន្ធស្ថិតិតាមវិស័យ ដោយផ្តោតលើប្រព័ន្ធប្រមូលទិន្នន័យ និងគ្រប់គ្រងព័ត៌មានដែលមានស្រាប់ និងភាពអាចរកបាននៃសូចនាករស្ថិតិដែលត្រូវការ សម្រាប់ធ្វើសេចក្តីសម្រេចផ្អែកលើភស្តុតាង និងការតាមដានវឌ្ឍនភាពនៃការអភិវឌ្ឍ។

២. រចនាសម្ព័ន្ធអភិបាលកិច្ច រួមមានច្បាប់ ការបង្កើតស្ថាប័ន និងអង្គការចាត់តាំង និងអនុសាសន៍សម្រាប់ធ្វើឱ្យប្រសើរឡើង ប្រសិនបើចាំបាច់។

៣. ការជ្រើសរើសមន្ត្រី ជំនាញ និងការអភិវឌ្ឍផែនការបណ្តុះបណ្តាល។

៤. ហេដ្ឋារចនាសម្ព័ន្ធស្ថិតិ រួមមានគុណភាព និងការប្រើប្រាស់ក្របខ័ណ្ឌសំណាកគំរូបានត្រឹមត្រូវ និងវិធីសាស្ត្រជ្រើសសំណាកគំរូ ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ។ល។

---

[៩] ការវាយតម្លៃតាមវិស័យនៃស្ថិតិសេដ្ឋកិច្ច សង្គម និងធនធានធម្មជាតិ និងការរៀបចំយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិកម្ពុជា គឺជាការវាយតម្លៃមួយមានសមាសភាពបី ក្រោមគម្រោងបង្កើនសមត្ថភាពវិភាគភាពក្រីក្រ Enhancement of Poverty Analysis Capacity Project EPACP/2016/CF/001 Grant No. TF0A0113 ។

៥. គុណភាព និងភាពអាចរកបាននៃសូចនាករគន្លឹះ នៅក្នុងវិស័យស្ថិតិសំខាន់ៗ។
៦. សកម្មភាពអតីតកាល និងកំពុងប្រតិបត្តិរបស់ភ្នាក់ងារម្ចាស់ជំនួយ ក្នុងការកសាងសមត្ថភាពស្ថិតិ និងផលប៉ះពាល់លើការកសាងសមត្ថភាពស្ថិតិ និងការសិក្សា។

ផ្នែកបន្ទាប់បានបង្ហាញគំហើញ និងអនុសាសន៍នានាស្តីពីរបៀបដោះស្រាយបញ្ហាប្រឈមស្ថិតិ ផ្តោះទៅការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទិន្នន័យមូលដ្ឋានតាមវិស័យ និងប្រព័ន្ធគ្រប់គ្រងព័ត៌មានដែលមានស្រាប់តាមវិស័យ។

### ២.៣.១ ការបំពេញសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់

សកម្មភាពស្ថិតិសំខាន់ៗផ្សារភ្ជាប់ជាមួយការអនុវត្តដទៃទៀត បានរួមចំណែកដ៏ទូលំទូលាយដល់ការអភិវឌ្ឍដែលត្រូវពិចារណានៅក្នុងប្រព័ន្ធស្ថិតិជាតិ។ ហេតុដូច្នេះ ស្ថានភាពស្ថិតិបច្ចុប្បន្នបានប្រសើរឡើងគួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងស្ថានភាពនៃដំណាក់កាលចាប់ផ្តើមរបស់ផែនការមេស្ថិតិ។

#### ស្ថិតិ និងសូចនាករ

ទិន្នន័យ និងសូចនាករសំខាន់ៗ ដែលបានផលិតនៅប្រទេសកម្ពុជាបច្ចុប្បន្ន រួមមានគណនេយ្យជាតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសន្ទស្សន៍ថ្លៃអ្នកផលិត ផលិតផលកសិកម្ម ទេសចរណ៍ ប្រជាសាស្ត្រ កំណើតនិងមរណភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្ថិតិការងារ កម្លាំងពលកម្ម សង្គមកិច្ច និងភាពក្រីក្រ ព្រមទាំងទិន្នន័យគោលប្រជាជនសម្រាប់វិស័យអប់រំ និងសុខាភិបាល។ ទិន្នន័យក៏ត្រូវបានប្រមូលផងដែរ សម្រាប់ជញ្ជីងទូទាត់ ពាណិជ្ជកម្មអន្តរជាតិខាងទំនិញ និងសេវាកម្ម និងស្ថានភាពវិនិយោគអន្តរជាតិ។ ទិន្នន័យតាមវិស័យត្រូវបានប្រមូលសម្រាប់អប់រំ សុខាភិបាល ឧស្សាហកម្ម សំណង់ ដឹកជញ្ជូន និងវិនិយោគ។

ទន្ទឹមនឹងស្ថិតិសេដ្ឋកិច្ច បរិស្ថាន និងហិរញ្ញវត្ថុ រួមមានគណនេយ្យជាតិ ជញ្ជីងទូទាត់ និងពាណិជ្ជកម្មទំនិញអន្តរជាតិ ជាទូទៅអាចរកបានជាទៀងទាត់ និងបានធ្វើឱ្យប្រសើរឡើងតាមឆ្នាំក៏ដោយ ក៏ត្រូវមានការខិតខំបន្ថែមទៀតដើម្បីផលិតស្ថិតិទាំងនេះឱ្យបានទាន់ពេលវេលា មានគុណភាពល្អជាងមុន និងកាន់តែមានភាពសំខាន់។

ខណៈដែលមានការរីកចម្រើនខ្លាំងក្នុងការផលិតស្ថិតិភាពក្រីក្រ និងស្ថិតិសង្គមកិច្ចសំខាន់ផ្សេងទៀតនៅក្នុងប្រទេសក៏ដោយ ក៏នៅមានវិស័យសំខាន់មួយចំនួនត្រូវកែលម្អ ដូចជាការផលិតទិន្នន័យបន្ថែមទៀតសម្រាប់សូចនាករសង្គមកិច្ច និងភាពទាន់ពេលវេលា និរន្តរភាព ភូមិសាស្ត្រលម្អិត និងគុណភាពរួមនៃស្ថិតិ រួមទាំងទិន្នន័យដែលផលិតដោយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

#### ជំរឿន និងអង្កេត

លទ្ធផលស្ថិតិពីជំរឿន និងអង្កេតសំខាន់ៗដែលផលិតសម្រាប់វិស័យទាំងអស់នៃស្ថិតិ បានធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ។ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលក៏ផលិតស្ថិតិដែលគ្របដណ្តប់លើវិស័យរបស់ខ្លួន ជាលទ្ធផលដាច់ដោយឡែក (ភាគច្រើនជាប្រចាំឆ្នាំ ប៉ុន្តែមួយចំនួនប្រចាំឆមាស និងប្រចាំខែ) ឬជាសមាសភាពនៃរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

ជំរឿនសំខាន់ៗមួយចំនួនត្រូវបានធ្វើក្នុងរយៈពេល ១០ ឆ្នាំកន្លងមក។ នៅឆ្នាំ២០០៨ វិទ្យាស្ថានជាតិស្ថិតិ បានធ្វើជំរឿនទូទៅប្រជាជនកម្ពុជា។ ក្នុងប្រវត្តិសាស្ត្រដំបូង កម្ពុជាបានធ្វើជំរឿនសេដ្ឋកិច្ចនៅឆ្នាំ២០១១។ នៅឆ្នាំ ២០១៣ កម្ពុជាបានធ្វើជំរឿនកសិកម្មលើកទីមួយ។

អង្កេតទ្រង់ទ្រាយធំធ្វើដោយវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ព្រមទាំងស្ថាប័នរាជរដ្ឋាភិបាល រួមមាន[១០] ៖

| អង្កេត | ដោយ/ធ្វើនៅឆ្នាំ |
|---|---|
| អង្កេតចន្លោះជំរឿនប្រជាជនកម្ពុជា (CIPS) | ២០០៤ ២០១៣ |
| អង្កេតចន្លោះជំរឿនសេដ្ឋកិច្ចកម្ពុជា (CIES) | ២០១៤ |
| អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (CSES) | រៀងរាល់ឆ្នាំតាំងពីឆ្នាំ២០០៧។ នៅឆ្នាំ២០១៤ បានពង្រីកទំហំ និងវិសាលភាព។ |
| អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) | ជាមួយក្រសួងសុខាភិបាល ឆ្នាំ២០០៥ ២០១០ ២០១៤។ |
| អង្កេតម្លាំងពលកម្ម និងពលកម្មកុមារ (២០១២) | ២០១២ |
| ការចុះបញ្ជីសហគ្រាសទូទាំងប្រទេស (២០០៩) | ២០០៩ |
| អង្កេតពីសាលាទៅការងារ (២០១២ ២០១៤) | ២០១២ ២០១៤ |
| អង្កេតកសិកម្ម (បសុសត្វ ការប្រមូលផល ទីសត្វឃាត កិនស្រូវ ទិន្នផលដំណាំ ការចំណាយផលិតកម្ម ថ្លៃទីផ្សារកសិកម្ម) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| អំពើហឹង្សាលើកុមារ | ក្រសួងសុខាភិបាល ឆ្នាំ២០១៣។ |
| អង្កេតគោលស្តីពីអគ្រានុកូលដ្ឋាន | ក្រសួងមហាផ្ទៃ |
| អង្កេតការវិនិយោគផ្ទាល់ពីបរទេស | ធនាគារជាតិនៃកម្ពុជា |

ទោះជាមានការអង្កេតរៀបរាប់ខាងលើធ្វើដោយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលក៏ដោយ ជាទូទៅក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលមិនបានធ្វើអង្កេតឡើយ ប៉ុន្តែប្រើប្រាស់កំណត់ត្រារដ្ឋបាល។

លទ្ធផលអង្កេត ជាទូទៅត្រូវបានរក្សាទុកក្នុងទិន្នន័យមូលដ្ឋាន។ ទិន្នន័យលម្អិតពីអង្កេតត្រូវបានផ្សព្វផ្សាយ តាមរយៈប័ណ្ណសារទិន្នន័យជាតិ National Data Archive (NADA)[១១] ។

## កំណត់ត្រារដ្ឋបាល

វិទ្យាស្ថានជាតិស្ថិតិ ព្រមទាំងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលបានប្រើប្រាស់កំណត់ត្រារដ្ឋបាល សម្រាប់ គោលបំណងស្ថិតិដូចមានចែងក្នុងមាត្រា ៦ ១១ និង ១២ នៃច្បាប់ស្តីពីស្ថិតិ ឆ្នាំ២០១៥។ កំណត់ត្រារដ្ឋបាល និង ប្រព័ន្ធព័ត៌មានគ្រប់គ្រងត្រូវបានទាញយកមកសម្រាប់ការផលិតស្ថិតិ ប៉ុន្តែមានវិសាលភាពខុសគ្នារវាងវិទ្យាស្ថាន ជាតិស្ថិតិ ព្រមទាំងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។ វិទ្យាស្ថានជាតិស្ថិតិប្រើប្រាស់កំណត់ត្រារដ្ឋបាលតិចតួច ដោយផ្ទាល់ និងពឹងផ្អែកជាសំខាន់លើទិន្នន័យជំរឿន និងអង្កេតនានា ប៉ុន្តែក៏ពឹងផ្អែកលើស្ថិតិពីបណ្តាក្រសួង និងស្ថា ប័នរាជរដ្ឋាភិបាលផងដែរ ដែលជាចម្បងផ្អែកលើកំណត់ត្រារដ្ឋបាល និងប្រព័ន្ធព័ត៌មានគ្រប់គ្រង។

---

[១០] ការពណ៌នា និងការផ្តល់យោបល់លើអង្កេតជាច្រើនដែលមាននៅក្នុងរបាយការណ៍លើកទីមួយនៃសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់ ផ្នែកស្ថិតិសហប្រជាជាតិ/វិទ្យាស្ថានជាតិស្ថិតិ។

[១១] http://nada-nis.gov.kh/index.php/home NADA គឺជាប្រព័ន្ធ web-based repository system ស្តីពីទិន្នន័យអង្កេតដែលធ្វើដោយវិទ្យាស្ថានជាតិ ស្ថិតិនៅកម្ពុជា។ វាបានអភិវឌ្ឍឡើង ដើម្បីរក្សាទុកជាប្រព័ន្ធមួយ និងអាចទាញទិន្នន័យស្ថិតិ រួមមានកំណត់ត្រាអង្កេត និងវិធីសាស្ត្ររបស់វា ទស្សនទាន និងម៉េតាទិន្នន័យផ្សេងទៀត។

ឧទាហរណ៍នៃកំណត់ត្រារដ្ឋបាលដែលបានប្រើប្រាស់ដោយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល និងស្ថិតិផ្អែកលើកំណត់ត្រារដ្ឋបាល ព្រមទាំងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល រួមមាន ៖

| ស្ថិតិពីកំណត់ត្រារដ្ឋបាល | ប្រភព |
|---|---|
| របាយការណ៍ប្រចាំឆ្នាំ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងធម្មការ និងសាសនា |
| របាយការណ៍ស្តីពីផលិតផលកសិកម្ម | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| បញ្ជីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ | ក្រសួងព័ត៌មាន |
| ស្ថិតិសំណង់មានប័ណ្ណអនុញ្ញាត និងរបាយការណ៍តម្លៃសំណង់តាមវិញ្ញាបនប័ត្របញ្ជាក់គោលបំណងកាន់កាប់ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ចំនួននិយោជិត រួមទាំងចំនួនស្ត្រី និងមូលធន | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| សំណុំព័ត៌មានក្រុមហ៊ុន ចំនួននិយោជិត ការនាំចូល និងការនាំចេញ | ក្រសួងពាណិជ្ជកម្ម |
| ស្ថិតិ និងសូចនាករអប់រំ ប្រចាំឆ្នាំ | ក្រសួងអប់រំ យុវជន និងកីឡា |
| ស្ថិតិសុខាភិបាល ប្រចាំឆ្នាំ | ក្រសួងសុខាភិបាល |
| ស្ថិតិកុមារកំព្រា និងកុមារងាយរងគ្រោះនៅក្នុងមណ្ឌលថែទាំ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| មន្ត្រីរាជការស៊ីវិលជាអ្នកគ្រប់គ្រង | ក្រសួងកិច្ចការនារី |
| ទិន្នន័យគយ ទិន្នន័យទេសចរណ៍ ទិន្នន័យធនាគារពាណិជ្ជកម្ម | ធនាគារជាតិនៃកម្ពុជា |

ប្រព័ន្ធព័ត៌មានគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា និងប្រព័ន្ធព័ត៌មានជាតិក្រសួងសុខាភិបាល គឺជាការចូលរួមចម្បងដល់ការផលិតស្ថិតិ។

មន្ត្រីជាន់ខ្ពស់របស់វិទ្យាស្ថានជាតិស្ថិតិគិតថាកំណត់ត្រារដ្ឋបាល និងប្រព័ន្ធព័ត៌មានគ្រប់គ្រងដែលមាននៅតាមក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលហាក់ដូចជាមិនទាន់គ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការរៀបចំស្ថិតិមានគុណភាពល្អ។ បញ្ហាមួយចំនួនត្រូវបានបង្ហាញរួមមាន ៖ កំណត់ត្រារដ្ឋបាលដែលប្រើប្រាស់ក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលអាចមិនត្រូវបានសម្របសម្រួលជាមួយតម្រូវការរបស់វិទ្យាស្ថានជាតិស្ថិតិ ពោលគឺខ្វះមន្ត្រីមានសមត្ថភាពធ្វើការជាមួយកំណត់ត្រារដ្ឋបាល ហើយនិងការបណ្តុះបណ្តាលដែលជាតម្រូវការរបស់វិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលអំពីការប្រើប្រាស់កំណត់ត្រារដ្ឋបាលសម្រាប់គោលបំណងស្ថិតិ។ ការចាត់ចែងស្ថិតិនៅតាមក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលមួយចំនួនត្រូវការធ្វើឱ្យប្រសើរឡើង។ ថវិកាមានកម្រិតមានឥទ្ធិពលដល់ការប្រើប្រាស់កំណត់ត្រារដ្ឋបាលដែលមានស្រាប់។

ទិន្នន័យទូលាយ (Big data)[១២] បង្កើតឡើងជាប្រភពបន្ថែមមួយសម្រាប់ស្ថិតិផ្លូវការ។ វាត្រូវបានទទួលស្គាល់ជាផ្លូវការថាជាប្រភពដ៏សំខាន់មួយ ក្នុងបរិបទសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ មន្ត្រីជាន់ខ្ពស់របស់វិទ្យាស្ថានជាតិស្ថិតិបានយល់ដឹងប្រភពដ៏មានសក្តានុពលនេះ និងបន្តយល់ដឹងពីការអភិវឌ្ឍ។

---

[១២] https://unstats.un.org/unsd/bigdata/conferences/2016/ការប្រើប្រាស់ទូរស័ព្ទចល័តប្រចាំថ្ងៃ និងបណ្តាញសង្គម ក៏ដូចជាការពិនិត្យឧបករណ៍ជាប្រចាំ ដូចជារថយន្ត ឬរបស់ប្រើប្រាស់ក្នុងផ្ទះ និងការទាញបន្តពីបណ្តាញទិន្នន័យអេឡិចត្រូនិក។ ប្រភពទិន្នន័យទាំងនេះ ជារួមសំដៅដល់ទិន្នន័យទូលាយ (Big Data) អាចមានសក្តានុពលប្រើប្រាស់ក្នុងការចងក្រងស្ថិតិផ្លូវការ សម្រាប់គោលបំណងនៃការធ្វើសេចក្តីសម្រេចផ្អែកលើភស្តុតាង។ ហេតុដូច្នេះ គណៈកម្មាធិការស្ថិតិសហប្រជាជាតិបានបង្កើតក្រុមការងារសកលមួយ នៅឆ្នាំ២០១៤ ដែលមានសិទ្ធិអំណាចក្នុងការផ្តល់ចក្ខុវិស័យជាយុទ្ធសាស្ត្រ

នៅឆ្នាំ២០១៣ វិទ្យាស្ថានជាតិស្ថិតិបានបង្កើតនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ ដើម្បីចងក្រងកំណត់ត្រារដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងចំណោមប្រភពកំណត់ត្រារដ្ឋបាលនៅកម្ពុជា គឺទិន្នន័យមូលដ្ឋានឃុំសង្កាត់ (CDB) ដែលបានផ្ទុកនូវទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច ជាង ១,៦០០ ឃុំសង្កាត់ទូទាំងប្រទេស។ ភាពអាចជឿបាន និងភាពស៊ីគ្នារបស់ទិន្នន័យមូលដ្ឋានឃុំសង្កាត់ ជាមួយលទ្ធផលអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា គឺជារឿងដែលត្រូវពិចារណា។ វិទ្យាស្ថានជាតិស្ថិតិអាចមានតួនាទីសំខាន់ក្នុងការរក្សាទុក និងធ្វើឱ្យប្រសើរឡើងនូវទិន្នន័យមូលដ្ឋាននេះ។

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) អាស៊ាន (ASEAN)

កម្ពុជាមានប្រសិទ្ធភាពខ្ពស់ក្នុងការប្រមូល ការប៉ាន់ស្មាន និងរាយការណ៍ទិន្នន័យស្ដីពីសូចនាករគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដោយរួមបញ្ចូលគ្នានូវក្របខ័ណ្ឌតាមដានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទៅក្នុងក្របខ័ណ្ឌតាមដាន និងវាយតម្លៃគោលនយោបាយជាតិ ជាពិសេសតាមរយៈការតាមដានយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ។ នៅដើមឆ្នាំ២០១០ រាជរដ្ឋាភិបាលបានធ្វើការវាយតម្លៃប្រចាំឆ្នាំលើវឌ្ឍនភាពក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ របាយការណ៍ឆ្នាំ២០១៣[១៣] រួមបញ្ចូលការពិភាក្សាលើស្ថានភាពគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាថ្នាក់ក្រោមជាតិ ដែលជួយបង្ហាញនូវវិសមភាពក្នុងការសម្រេចបាននូវគោលដៅ និងចំណុចដៅក្នុងទូទាំងប្រទេស។ របាយការណ៍ពាក់កណ្ដាលអាណត្តិបានបញ្ជាក់ថា ច្រើនជាងពីរភាគបីនៃសូចនាករគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា មានយ៉ាងហោចណាស់ទិន្នន័យពីរគ្រាវវាងឆ្នាំ១៩៩០ និងឆ្នាំ២០១១ ដែលមានភាពប្រសើរជាងប្រទេសមួយចំនួនធំ។ របាយការណ៍ចុងក្រោយស្ដីពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាមានសូចនាករតាមប្រភេទសម្បូរបែប ដែលត្រូវការសម្រាប់តាមដានការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពអាចបង្ហាញថា មានការប្រឈមកាន់តែខ្លាំងសម្រាប់កម្ពុជាចំពោះវិសាលភាពដ៏ទូលំទូលាយរបស់ខ្លួន។ ជាមួយ ១៧ គោលដៅ និង ១៦៩ ចំណុចដៅ ដែលបានយល់ព្រមជាផ្លូវការដោយមហាសន្និបាតសហប្រជាជាតិនៅខែកញ្ញា ឆ្នាំ២០១៥ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនាំមកនូវក្របខ័ណ្ឌតាមដានកាន់តែទូលំទូលាយមួយ ដែលទាមទារឱ្យមានវិសាលភាពទិន្នន័យកាន់តែធំ ហើយក៏អាចជាសម្ពាធកាន់ធ្ងន់លើប្រព័ន្ធស្ថិតិជាតិ។ បច្ចុប្បន្នមាន ២០៣ សូចនាករ ក្នុងចំណោម ២៣០ ដែលបានយល់ព្រមបានចាត់ទុកថាអាចអនុវត្តបាននៅកម្ពុជា[១៤] ។ ស្របពេលដែលកម្ពុជាស្ថិតក្នុងដំណើរការធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឱ្យស្របទៅនឹងតម្រូវការអភិវឌ្ឍន៍អាទិភាពរបស់ខ្លួន អាចថែមសូចនាករមួយចំនួនទៀត។

ការដឹកនាំ និងការសម្របសម្រួលលើការប្រើប្រាស់ទិន្នន័យទូលាយសម្រាប់ស្ថិតិផ្លូវការ។ ក្រុមការងារសកលលើកកម្ពស់ការអនុវត្តនៃការប្រើប្រាស់ទិន្នន័យទូលាយ ការកសាងសមត្ថភាព និងការចែករំលែកនូវបទពិសោធន៍ ទន្ទឹមនឹងការស្វែងរកនូវដំណោះស្រាយញ្ហាប្រឈមរួម។

[១៣] របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៣ ៖ ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក្រសួងផែនការ ខែមេសា ឆ្នាំ២០១៤។

[១៤] របាយការណ៍សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់ផ្នែកស្ថិតិសហប្រជាជាតិ/វិទ្យាស្ថានជាតិស្ថិតិ ខែវិច្ឆិកា ឆ្នាំ២០១៥ និងខែឧសភា ឆ្នាំ២០១៦។

ការវាយតម្លៃសមត្ថភាពចងក្រង ១៤៤ សូចនាករ ក្នុងនោះមាន ៤៥ សូចនាករ ឬ ៣១ ភាគរយ បានចងក្រងរួចរាល់ ឬអាចធ្វើបានងាយស្រួល (វាតំណាងឱ្យ ២២ ភាគរយ នៃ ២០៣ សូចនាករអនុវត្តន៍បាន[១៥]) ៧១ សូចនាករផ្សេងទៀតអាចអនុវត្តបានដោយការខិតខំខ្លាំង និង ២៩ សូចនាករផ្សេងទៀតមិនអាចអនុវត្ត ទោះបីមានការខិតខំខ្លាំងយ៉ាងណាក៏ដោយ[១៦] ។

កម្រិតខ្ពស់នៃវិមជ្ឈការនៃប្រព័ន្ធស្ថិតិជាតិ ធ្វើឱ្យការសម្របសម្រួលនៃការផលិតទិន្នន័យស្ថិតិតាមក្រសួង និងរាងការិយាល័យថ្នាក់ជាតិ និងថ្នាក់ខេត្ត ជាបញ្ហាប្រឈមកណ្តាលមួយសម្រាប់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីដឹកនាំការងារ និងការអភិវឌ្ឍស្ថិតិសម្រាប់ចងក្រងសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ការយកចិត្តទុកដាក់ជាពិសេសគួរផ្តល់ឱ្យថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត និងស្រុកខ័ណ្ឌ)។ ស្ថិតិថ្នាក់ក្រោមជាតិ ជាតម្រូវការសម្រាប់ការធ្វើផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ និងត្រូវបានបញ្ចូលក្នុងសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងបរិបទ "គ្មាននរណាម្នាក់ត្រូវបានបោះបង់ចោល" ។

បច្ចុប្បន្ន ទិន្នន័យជាទៀងទាត់ដែលបានផ្តល់ទៅការិយាល័យស្ថិតិអាស៊ាន រួមមានស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិដែលប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថិតិពាណិជ្ជកម្មអន្តរជាតិខាងសេវាកម្ម និងស្ថិតិវិនិយោគផ្ទាល់ពីបរទេសបានប្រមូល ក្រោមកិច្ចសហប្រតិបត្តិការជាមួយផ្នែកស្ថិតិជញ្ជីងទូទាត់នៃធនាគារជាតិកម្ពុជា និងស្ថិតិដទៃទៀត។ ស្ថាប័នចូលរួមផ្សេងទៀតក្នុងប្រព័ន្ធស្ថិតិជាតិត្រូវបានគាំទ្រដោយដៃគូអភិវឌ្ឍន៍ ដើម្បីលើកម្ពស់គុណភាពទិន្នន័យ ទាន់ពេលវេលា និងអាចប្រៀបធៀបបាននៃស្ថិតិទាំងនេះដែលមានសារៈសំខាន់សម្រាប់តាមដាន និងវាយតម្លៃនៃការវាស់វែងសមាហរណកម្មអាស៊ាន។

## គុណភាព

បទដ្ឋាន និងវិធីសាស្ត្រស្ថិតិបច្ចុប្បន្នដែលអនុវត្តនៅក្នុងប្រព័ន្ធស្ថិតិជាតិ បានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ ប៉ុន្តែវានៅមានបញ្ហាប្រឈមដែលតម្រូវឱ្យមានការផ្លាស់ប្តូរទាំងអស់ និងផ្តល់អនុសាសន៍។

ជាគោលការណ៍ ប្រព័ន្ធស្ថិតិជាតិបានខិតខំអនុវត្តតាមបទដ្ឋាន ចំណាត់ថ្នាក់ និងក្របខ័ណ្ឌវិធីសាស្ត្រអន្តរជាតិ។ គោលការណ៍ទាំងនោះបច្ចុប្បន្នបានអនុវត្តនៅក្នុងប្រព័ន្ធស្ថិតិជាតិ រួមមានប្រព័ន្ធគណនេយ្យជាតិឆ្នាំ ១៩៩៣ (អនុវត្តដោយផ្នែក) (វិទ្យាស្ថានជាតិស្ថិតិ) ចំណាត់ថ្នាក់បទដ្ឋានសកម្មភាពសេដ្ឋកិច្ចអន្តរជាតិ ជំនាន់៤ (ISIC4)[១៧] (វិទ្យាស្ថានជាតិស្ថិតិ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម) សេចក្តីណែនាំរបស់អង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) សេចក្តីណែនាំស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលនៃអង្គការមូល និធិរូបិយ

---

[១៥] ដោយសន្មតថា (i) សូចនាករ ១០ ក្នុងចំណោម ៥៩ ដែលមិនត្រូវបានវាយតម្លៃអាចធ្វើបានងាយស្រួល និង (ii) ប្រហែល ១០% (៧) នៃសូចនាករ ៧១ ដែលអាចអនុវត្តបានដោយការខិតខំខ្លាំង អាចនឹងមាន (អាស្រ័យលើកម្រិតខ្លាំងនៃការខិតខំ ដើម្បីចងក្រងវា) សូចនាករ ៦១ ឬ ៣០% នៃសូចនាករ ២០៣ ដែលអាចអនុវត្តបាន អាចត្រូវបានផលិតក្នុងរយៈពេលខ្លីទៅរយៈពេលមធ្យម។

[១៦] ការវាយតម្លៃនាពេលក្រោយដែលបានរាយការណ៍នៅក្នុងកំណត់ហេតុនៃក្រុមការងារបច្ចេកទេស TWG-PPR សម្រាប់ទិន្នន័យសម្រាប់ការអភិវឌ្ឍនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ បានបង្ហាញថាសម្រាប់សូចនាករ ១៤៥ ដែលបានវាយតម្លៃ មាន ២១ ដែលបានចងក្រង ឬភាពគ្រប់គ្រាន់នៃទិន្នន័យសម្រាប់ចងក្រងសូចនាករទាំងនេះអាចរកបាន មាន ៣៨ សម្រាប់សូចនាករមិនត្រូវបានចងក្រង ប៉ុន្តែទិន្នន័យពាក់ព័ន្ធមួយចំនួនអាចរកបាន និង ៨៦ សម្រាប់ទិន្នន័យមិនពាក់ព័ន្ធអាចរកបាន។ ទាំងនេះបម្លែងទៅជា ២៩% នៃសូចនាករអនុវត្តបាននឹងត្រូវចងក្រង ឬភាពគ្រប់គ្រាន់នៃទិន្នន័យសម្រាប់ការចងក្រងអាចរកបាន ឬសូចនាករមិនត្រូវបានចងក្រង ប៉ុន្តែទិន្នន័យពាក់ព័ន្ធមួយចំនួនអាចរកបាន។

[១៧] ចំណាត់ថ្នាក់បទដ្ឋានសកម្មភាពសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០១២ ផ្អែកតាមចំណាត់ថ្នាក់បទដ្ឋានសកម្មភាពសេដ្ឋកិច្ចអន្តរជាតិ ( ISIC)។

វត្ថុអន្តរជាតិ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ចំណាត់ថ្នាក់បទដ្ឋានមុខរបរអន្តរជាតិ (ISCO-88) ចំណាត់ថ្នាក់បទដ្ឋានពាណិជ្ជកម្មអន្តរជាតិ (SITC) ចំណាត់ថ្នាក់បទដ្ឋានអប់រំអន្តរជាតិ (ISCED) និងសេចក្ដីណែនាំជញ្ជីងទូទាត់របស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ បោះពុម្ពលើកទី៥ (ធនាគារជាតិនៃកម្ពុជា)។

សេចក្ដីណែនាំផ្ទៃក្នុងដើម្បីធានាគុណភាពទិន្នន័យ ត្រូវបានរៀបចំដើម្បីគាំទ្រដល់ការធ្វើជំរឿនដែលឧបត្ថម្ភដោយដៃគូអភិវឌ្ឍន៍នានា។ សេចក្ដីណែនាំនេះត្រូវបានរៀបចំជាមួយការគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន សម្រាប់ជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០០៨ និងជំរឿនសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០១១ និងមានតែមួយសម្រាប់សកម្មភាពជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយ វិទ្យាស្ថានជាតិស្ថិតិមិនបានអនុវត្តការត្រួតពិនិត្យគុណភាពស្ថិតិតាមកាលកំណត់ (លើកលែងតែក្នុងករណីពិសេស) ដោយសារតែចំនួនមន្ត្រី និងកម្រិតជំនាញចាំបាច់របស់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិនៅមានកម្រិតដើម្បីធ្វើការងារទាំងនេះ ក៏ដូចជាសេចក្ដីត្រូវការដទៃទៀតសម្រាប់មន្ត្រីជំនាញឯកទេស។

កម្ពុជាជាសមាជិកអាស៊ានបានយល់ព្រមក្រមអនុវត្តន៍នៃប្រព័ន្ធស្ថិតិសហគមន៍អាស៊ាន នៅខែកញ្ញា ឆ្នាំ២០១២ ដែលបច្ចុប្បន្នកំពុងអនុវត្ត។

អ្នកប្រើប្រាស់ដែលត្រូវបានពិគ្រោះយោបល់បានលើកឡើងថា ពួកគេមិនដឹងពីភាពខុសគ្នារវាងតួលេខដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ និងអ្នកផលិតផ្សេងទៀតឡើយ។ មន្ត្រីវិទ្យាស្ថានជាតិស្ថិតិបានបញ្ជាក់ពីភាពខុសគ្នានៃស្ថិតិប្រជាជនពីប្រភពខុសគ្នា រួមមានវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងមហាផ្ទៃ។ ធនាគារជាតិនៃកម្ពុជារាយការណ៍ភាពខុសគ្នារវាងទិន្នន័យរបស់ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិអំពីការនាំចូល និងការនាំចេញ។

មន្ត្រីជាន់ខ្ពស់នៃវិទ្យាស្ថានជាតិស្ថិតិបានវាយតម្លៃល្អប្រសើរលើស្ថិតិរបស់វិទ្យាស្ថានជាតិស្ថិតិ ហើយបានបំពេញគ្រប់គ្រាន់លើប្រាំពីរគោលការណ៍គុណភាព រួមមាន ៖ វិធីសាស្ត្រអនុវត្តន៍ត្រឹមត្រូវ នីតិវិធីស្ថិតិសមស្របក្នុងការប្រមូលទិន្នន័យ សុពលភាព ការកែច្នៃទិន្នន័យ ។ល។ មានភាពត្រូវគ្នាជាមួយទិន្នន័យផ្សេងទៀត ភាពត្រឹមត្រូវ និងគួរឱ្យជឿជាក់ ទាន់ពេលវេលា និងទៀងទាត់ពេលវេលា ការផ្សព្វផ្សាយ (លទ្ធភាពទទួលបាន) និងភាពច្បាស់លាស់ និងស្ថិតិណាដែលអ្នកប្រើប្រាស់ចង់បាន និងបំពេញតាមតម្រូវការរបស់ពួកគេ។

ការខិតខំនានាដើម្បីឆ្ពោះទៅកែលម្អគុណភាពគួរតែបំពេញបន្ថែម ដោយការអភិវឌ្ឍ និងការអនុវត្តក្របខ័ណ្ឌធានាគុណភាពឱ្យបានទូលំទូលាយ។

ម៉េតាទិន្នន័យសម្រាប់ជំរឿន និងអង្កេតត្រូវបានបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍អង្កេត និងនៅលើវេបសាយប័ណ្ណសារទិន្នន័យជាតិ (NADA)។ ម៉េតាទិន្នន័យត្រូវបានបោះពុម្ពផ្សាយជាមួយសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងគណនេយ្យជាតិ ប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo)) និងនៅមានកម្រិតនៅឡើយសម្រាប់សៀវភៅស្ថិតិប្រចាំឆ្នាំរបស់វិទ្យាស្ថានជាតិស្ថិតិ។ មន្ត្រីជាន់ខ្ពស់វាយតម្លៃថាម៉េតាទិន្នន័យមានគ្រប់គ្រាន់តែនៅមិនទាន់គ្រប់ជ្រុងជ្រោយ។

ច្បាប់ស្ដីពីស្ថិតិតម្រូវឱ្យវិទ្យាស្ថានជាតិស្ថិតិបង្កើតសៀវភៅវាយឈ្មោះរដ្ឋបាល និងប្រភពទិន្នន័យស្ថិតិ (មាត្រា១១) ព្រមទាំងរក្សាទុក និងធ្វើបច្ចុប្បន្នកម្មប្រកបដោយប្រសិទ្ធភាព[១៨] អង្គភាពស្ថិតិដែលបានចាត់តាំងត្រូវប្រមូលទិន្នន័យតាមវិស័យដោយឯករាជ្យ ឬសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិ (មាត្រា១៣)។ សៀវភៅ

[១៨] អនុក្រឹត្យស្ដីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ មាត្រា២០ និងអនុក្រឹត្យស្ដីពីស្ថិតិផ្លូវការដែលបានចាត់តាំង មាត្រា១២។

រាយឈ្មោះនេះមិនទាន់បានបោះពុម្ពផ្សាយ ប៉ុន្តែវាជាឧបករណ៍ដ៏មានតម្លៃដើម្បីគាំទ្រការអភិវឌ្ឍបន្ថែមទៀតដល់កំណត់ត្រារដ្ឋបាល ដើម្បីបំពេញចន្លោះខ្វះខាតទិន្នន័យ និងរួមចំណែកធ្វើឱ្យប្រសើរឡើងដល់ការសម្របសម្រួលសកម្មភាពស្ថិតិ។

អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងតម្រូវឱ្យ ៖ (i) អង្គភាពស្ថិតិដែលបានចាត់តាំងត្រូវចុះបញ្ជីការប្រមូលទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតរបស់ខ្លួនជាមួយវិទ្យាស្ថានជាតិស្ថិតិ និងរក្សាទុកបញ្ជីធ្វើបច្ចុប្បន្នកម្ម (មាត្រា៨) (ii) ក្រសួងផែនការត្រូវពិនិត្យឡើងវិញនូវផែនការសម្រាប់ការប្រមូលទិន្នន័យរដ្ឋបាល និងជំរឿន និងអង្កេត និងលុបបំបាត់ការជាន់គ្នា (មាត្រា៩) (iii) ក្រសួងផែនការត្រូវបញ្ជូនបញ្ជីនៃរាល់ការប្រមូលទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតដែលមានស្រាប់ទៅទីស្តីការគណៈរដ្ឋមន្ត្រី និងធ្វើបច្ចុប្បន្នកម្មវាជារៀងរាល់ឆ្នាំ ដើម្បីបញ្ចូលការប្រមូលទិន្នន័យថ្មី (មាត្រា១០) (iv) អង្គភាពស្ថិតិដែលបានចាត់តាំងត្រូវបញ្ជូនរាល់ព័ត៌មាន និងទិន្នន័យស្ថិតិទាំងអស់ដែលបានផលិតជាទម្រង់អេឡិចត្រូនិក និងជាសៀវភៅទៅវិទ្យាស្ថានជាតិស្ថិតិ (មាត្រា១១) និង (v) វិទ្យាស្ថានជាតិស្ថិតិត្រូវបង្កើត និងរក្សាទុកបញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាល និងស្ថិតិ និងបញ្ជីឈ្មោះម៉េតាទិន្នន័យ (មាត្រា១២)។ ទោះជាយ៉ាងណាក៏ដោយ តម្រូវការទាំងនេះមិនត្រូវបានអនុវត្តឡើយ។

សេចក្តីណែនាំ ឬការណែនាំដែលមានស្រាប់សម្រាប់អង្កេត និងការប្រតិបត្តិស្ថិតិដទៃទៀតរួមទាំងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ជួនកាលសេចក្តីណែនាំនេះមិនច្បាស់លាស់ ឬពេញលេញឡើយ។ សេចក្តីណែនាំម៉េតាទិន្នន័យមិនទាន់បានរៀបចំឡើយ ទោះយ៉ាងណាក៏ដោយ ម៉េតាទិន្នន័យសម្រាប់ជំរឿន និងអង្កេតត្រូវបានបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍ជំរឿន និងអង្កេត និងម៉េតាទិន្នន័យត្រូវបានបោះពុម្ពផ្សាយជាមួយសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងគណនេយ្យជាតិ និងក្នុងប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo)។

វិទ្យាស្ថានជាតិស្ថិតិរក្សាការរៀបចំចាត់ចែងការងារ សម្រាប់អង្កេតនៅកម្រិតរាជធានីខេត្ត។ គុណភាពនៃធាតុផ្សំទាំងនេះរបស់ហេដ្ឋារចនាសម្ព័ន្ធត្រូវបានវាយតម្លៃវាងល្អប្រសើរ និងគ្រប់គ្រាន់ ដោយមន្ត្រីជាន់ខ្ពស់របស់វិទ្យាស្ថានជាតិស្ថិតិ។

## ការសម្ងាត់

ច្បាប់ស្តីពីស្ថិតិបានរួមបញ្ចូលបទបញ្ញត្តិមួយ សម្រាប់ធានារក្សាការសម្ងាត់នូវរាល់ព័ត៌មានបុគ្គលទាំងឡាយដែលទទួលបានពីអ្នកឆ្លើយ (ដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង) និងតម្រូវឱ្យព័ត៌មានដែលប្រមូលបានក្រោមច្បាប់ស្តីពីស្ថិតិ ត្រូវប្រើប្រាស់តែក្នុងគោលដៅស្ថិតិតែប៉ុណ្ណោះ (មាត្រា៣០)។ ច្បាប់នេះបញ្ជាក់ពីការពិន័យចំពោះអ្នករំលោភបំពានផងដែរ (មាត្រា៣៤)។ អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ តម្រូវឱ្យមន្ត្រីប្រតិបត្តិការងារស្ថិតិត្រូវចុះហត្ថលេខាលើកិច្ចសន្យា ដើម្បីធានារក្សាការសម្ងាត់នៃទិន្នន័យបុគ្គល និងប្រើប្រាស់សម្រាប់តែក្នុងគោលដៅស្ថិតិប៉ុណ្ណោះ (មាត្រា២៤)។ ទាំងនេះគឺជាបទបញ្ញត្តិដ៏រឹងមាំសម្រាប់ធានារក្សាការសម្ងាត់។

មាត្រាទី២៧ នៃច្បាប់ស្តីពីស្ថិតិអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទទួលបានមីក្រូទិន្នន័យ សម្រាប់គោលបំណងស្រាវជ្រាវ ប៉ុន្តែក្រោមលក្ខខណ្ឌការពារអត្តសញ្ញាណរូបវន្តបុគ្គល ឬក្រុមហ៊ុន សហគ្រាស និងស្ថាប័នដោយផ្ទាល់ ឬដោយប្រយោល។ លក្ខខណ្ឌនៃការប្រើប្រាស់តម្រូវឱ្យអ្នកប្រើប្រាស់ទិន្នន័យចុះហត្ថលេខាលើកិច្ចព្រមព្រៀងបទដ្ឋាន

មួយជាមួយក្រសួងផែនការ ដើម្បីការពារសំណុំទិន្នន័យដែលបានផ្តល់សម្រាប់គោលបំណងសិក្សាស្រាវជ្រាវ (http://nada-nis.gov.kh/index.php/home)។

ចំពោះមន្ត្រីខេត្តដែលបានចូលរួមយ៉ាងជិតស្និទ្ធជាមួយការប្រមូលទិន្នន័យពីអ្នកឆ្លើយ ភាគច្រើននៃអ្នកឆ្លើយបានទុកចិត្តលើការធានារក្សាការសម្ងាត់នៃការងារស្ថិតិ។

## ការចុះបញ្ជីស្ថិតិ

ភាពត្រឹមត្រូវនៃអង្កេត អាស្រ័យលើបញ្ជីនៃឯកតាសាកលរបស់អាជ្ញាធរដែលត្រូវជ្រើសសំណាកគំរូ ដូចជាបញ្ជីអាជីវកម្ម និង/ឬគ្រួសារ។ ជាមួយការផ្តល់មូនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) វិទ្យាស្ថានជាតិស្ថិតិបានចាប់ផ្តើមទទួលស្គាល់កាលានុវត្តភាពប្រើប្រាស់កំណត់ត្រារដ្ឋបាលសម្រាប់អភិវឌ្ឍន៍បញ្ជីអាជីវកម្មស្ថិតិ ឆ្នាំ២០១៤។ ការទទួលបានទិន្នន័យចុះបញ្ជីសារពើពន្ធនៅមានកម្រិត ទោះបីមានឯកសារយោងល្អដើម្បីបង្កើតបញ្ជីអាជីវកម្មស្ថិតិសម្រាប់កម្ពុជាក៏ដោយ។ បញ្ជីសំណួរត្រូវបានបង្កើតឡើងដោយការប្រើប្រាស់ទិន្នន័យពីជំរឿនសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០១១។ សិក្ខាសាលាត្រូវបានរៀបចំជាមួយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធ ជាពិសេសអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ខែកុម្ភៈ ឆ្នាំ២០១៧) ក៏ត្រូវបានស្នើសុំផ្តល់ទិន្នន័យថែមទៀតផងដែរ។

បញ្ជីគ្រួសារដែលមានស្រាប់ផ្អែកលើជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០០៨ និងការធ្វើបច្ចុប្បន្នកម្មនៃការសិក្សាពិសេសនៅឆ្នាំ២០១៣ ត្រូវបានប្រើប្រាស់សម្រាប់រៀបចំអង្កេតសំណាកគំរូ។

## ២.៣.២ ស្ថិតិក្នុងគោលនយោបាយអភិវឌ្ឍន៍ជាតិ

របៀបវារៈនៃការអភិវឌ្ឍបច្ចុប្បន្នរបស់រាជរដ្ឋាភិបាល ត្រូវបានណែនាំដោយយុទ្ធសាស្រ្តចតុកោណ សម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី៣ ខែកញ្ញា ឆ្នាំ២០១៣។ យុទ្ធសាស្រ្តចតុកោណត្រូវបានបំពេញបន្ថែមដោយផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ (ខែកក្កដា ឆ្នាំ២០១៤)។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ ពឹងផ្អែកកាន់តែច្រើនលើសំណុំសូចនាករស្ថិតិ ដែលមាន ៧៣ សូចនាករស្នូល ក្នុងនោះ ២៦ បានមកពីការអង្កេតរបស់វិទ្យាស្ថានជាតិស្ថិតិ។ សូចនាករបន្ថែម ៨២ ត្រូវបានកំណត់អត្តសញ្ញាណ ទោះជាយ៉ាងណាក៏ដោយ គ្មានសូចនាករណាមួយពីការអង្កេតរបស់វិទ្យាស្ថានជាតិស្ថិតិឡើយ។ ផែនការអភិវឌ្ឍន៍ជាតិកន្លងមកឆ្នាំ២០០៩-២០១៣ ក៏បានប្រើប្រាស់ស្ថិតិ និងសូចនាករស្នូលតិចតួច ប៉ុន្តែបញ្ជីសូចនាករតិចជាងសម្រាប់ផែនការ ឆ្នាំ២០១៤-២០១៨។

ស្ថិតិត្រូវបានលើកឡើងជាច្រើននៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ ប៉ុន្តែមិនបានផ្តោតលើការពិភាក្សាអំពីតម្រូវការកសាងសមត្ថភាពស្ថិតិនៅវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង និងស្ថាប័នឡើយ។ ការពិភាក្សាដ៏ទូលំទូលាយភាគច្រើនពាក់ព័ន្ធនឹងផែនការរបស់ក្រសួងផែនការ ដើម្បីអភិវឌ្ឍប្រព័ន្ធតាមដាន និងវាយតម្លៃសម្រាប់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។ ការពិភាក្សាមួយចំនួននៃសេចក្តីត្រូវការក៏បានលើកឡើងអំពីសមត្ថភាពស្ថិតិពីគ្រប់ក្រសួងផងដែរ។ ទោះជាយ៉ាងណាក៏ដោយ វិទ្យាស្ថានជាតិស្ថិតិដែលជាទីភ្នាក់ងារស្នូល មិនត្រូវបានលើកឡើងក្នុងបរិបទទោះបីប្រព័ន្ធតាមដាន និងវាយតម្លៃ ឬការកសាងសមត្ថភាពស្ថិតិ។ នេះគឺជាការធ្វេសប្រហែស

ដែលគួរឱ្យស្តាយ បើមូលដ្ឋានគ្រឹះនៃប្រព័ន្ធតាមដាន និងវាយតម្លៃល្អ ធ្វើឱ្យប្រព័ន្ធស្ថិតិជាតិខ្លាំងក្រោមការដឹកនាំរបស់វិទ្យាស្ថានជាតិស្ថិតិ។

រាជរដ្ឋាភិបាលកម្ពុជាបានបន្តការពឹងផ្អែកខ្ពស់លើស្ថិតិ ជាពិសេសមកពីវិទ្យាស្ថានជាតិស្ថិតិ សម្រាប់ធ្វើផែនការ និងតាមដានសកម្មភាព ដូចបានបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងកិច្ចព្រមព្រៀងអន្តរជាតិ និងតំបន់ ដូចជាការតាមដានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការចងក្រងសូចនាករអាស៊ាន។ ទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជាមិនទាន់បានផ្តោតទៅលើការអភិវឌ្ឍស្ថិតិនៅឡើយដែលជាគោលដៅជាតិដ៏សំខាន់ ដែលអាចឆ្លុះបញ្ចាំងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងថវិកាជាតិបានល្អប្រសើរជាពិសេសជាមួយការអនុវត្តរបៀបវារៈសកលស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ដែលបច្ចុប្បន្នកំពុងដំណើរការ។

### ២.៣.៣ ច្បាប់ និងក្របខ័ណ្ឌស្ថាប័ន

អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ វិទ្យាស្ថានជាតិស្ថិតិដឹកនាំដោយអគ្គនាយកដែលតែងតាំងដោយព្រះរាជក្រឹត្យ។ អគ្គនាយកមានអាណត្តិដឹកនាំ និងត្រួតពិនិត្យការរៀបចំ និងកិច្ចដំណើរការរបស់វិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធស្ថិតិជាតិ (មាត្រា៧)។ អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិមានជំនួយការជាអគ្គនាយករងដប់ពីររូប មានមុខងារទទួលខុសត្រូវផ្នែកសំខាន់ៗនៃកិច្ចដំណើរការក្នុងវិទ្យាស្ថានជាតិស្ថិតិ។

វិទ្យាស្ថានជាតិស្ថិតិមានប្រាំបីនាយកដ្ឋាន ដែលនាយកដ្ឋាននីមួយៗទទួលខុសត្រូវការងារសំខាន់ៗនៃការអភិវឌ្ឍ និងប្រតិបត្តិការស្ថិតិ រួមមាន ៖ នាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិកាស្ថិតិ នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច នាយកដ្ឋានស្ថិតិសង្គមកិច្ច នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត នាយកដ្ឋានបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានវិទ្យា នាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិ នាយកដ្ឋានគណនេយ្យជាតិ និងនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ។ នាយកដ្ឋាននីមួយៗមានការិយាល័យ ៤-៥ ដែលអនុវត្តមុខងារជាក់លាក់ រួមមាន រដ្ឋបាល គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស និងប្រតិបត្តិការស្ថិតិ។ ការពិពណ៌នាមានស្រាប់ជាផ្លូវការនូវតួនាទី និងការទទួលខុសត្រូវរបស់រចនាសម្ព័ន្ធនីមួយៗ។

អគ្គនាយករង ១២ រូប មានមុខងារទទួលខុសត្រូវលើ ៨ នាយកដ្ឋានដែលធ្វើឱ្យរចនាសម្ព័ន្ធកំពូលមានអ្នកគ្រប់គ្រងច្រើនគួរឱ្យកត់សម្គាល់ ដោយមានអគ្គនាយករងពីររូបនៅពីលើទទួលបន្ទុកនាយកដ្ឋានមួយចំនួនហាក់ដូចជាមិនមានភាពចាំបាច់ឡើយ។ អគ្គនាយករងមួយរូបគួរតែទទួលបន្ទុកលើប្រធាននាយកដ្ឋាននីមួយៗ ហើយអគ្គនាយករងបួនរូបទៀតគួរជួយការងាររបស់វិទ្យាស្ថានជាតិស្ថិតិឱ្យកាន់តែល្អប្រសើរ ជាមួយការងារពិសេសជាទីប្រឹក្សាឱ្យអគ្គនាយកអំពីបញ្ហាមួយចំនួន ដូចជាការផ្សព្វផ្សាយ ការពង្រីកការប្រើប្រាស់កំណត់ត្រារដ្ឋបាលក្នុងប្រព័ន្ធស្ថិតិជាតិ ការធានាគុណភាព និងការងារផ្សេងទៀត។

សូមកត់សម្គាល់ថា គ្មាននាយកដ្ឋានណាមួយដែលមានភារកិច្ចទទួលខុសត្រូវជាក់លាក់សម្រាប់ការផ្សព្វផ្សាយឡើយ ដែលការទទួលខុសត្រូវនេះគួរត្រូវបានបន្ថែមទៅនាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិ ឬនាយកដ្ឋានបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (បច្ចេកវិទ្យានឹងជាធាតុបង្កើននៃការផ្សព្វផ្សាយ) និងជម្រើសផ្សេងទៀត ការទទួលខុសត្រូវទាំងមូលសម្រាប់ការផ្សព្វផ្សាយគួរចាត់ឱ្យអគ្គនាយករងមួយរូប ជាតំណែងពិសេសមួយ។

ការិយាល័យមជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិក៏ស្ថិតនៅក្រោមនាយកដ្ឋានមួយដូចបានរៀបរាប់ខាងលើ ដែលការគ្រប់ដណ្តប់របស់វាហួសឆ្ងាយពីភាពសមស្រប ដែលបច្ចុប្បន្នស្ថិតនៅក្រោមនាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត។ ការទទួលខុសត្រូវសម្រាប់ប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo) ស្ថិតនៅក្រោមការគ្រប់គ្រងធនធានមនុស្ស និងការិយាល័យប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo)ហាក់ដូចជាមិនសមហេតុផល គួរតែស្ថិតក្រោមបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានវិទ្យា ឬជាមួយការផ្សព្វផ្សាយដូចដែលបានរៀបរាប់ខាងលើ ទើបសមស្របជាង។

វិទ្យាស្ថានជាតិស្ថិតិមានការអនុវត្តគ្រប់គ្រងល្អប្រសើរមួយចំនួននៅនឹងកន្លែង។ វិទ្យាស្ថានជាតិស្ថិតិមានផែនការយុទ្ធសាស្ត្របួនឆ្នាំ (២០១៤-២០១៨) ដែលបានបង្កើតឡើងជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រក្រសួងផែនការ[១៩] និងមាននៅក្នុងគេហទំព័រក្រសួងផែនការ។ វិទ្យាស្ថានជាតិស្ថិតិមានផែនការការងារប្រចាំឆ្នាំដែលជាផ្នែកមួយនៃផែនការការងារដ៏ធំរបស់ក្រសួងផែនការ ហើយផែនការនេះត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ២០១៦[២០] ប៉ុន្តែមិនយូរឡើយសម្រាប់ឆ្នាំ២០១៧។ វិទ្យាស្ថានជាតិស្ថិតិបានបោះពុម្ពរបាយការណ៍ប្រព័ន្ធស្ថិតិជាតិប្រចាំឆ្នាំ តាំងពីឆ្នាំ ២០១០ និងមានជាសាធារណៈក្នុងគេហទំព័រវិទ្យាស្ថានជាតិស្ថិតិ[២១]។ របាយការណ៍ចុងក្រោយសម្រាប់ឆ្នាំ២០១៥ បានបោះពុម្ពផ្សាយនៅខែវិច្ឆិកា ឆ្នាំ២០១៦ (ប៉ុន្តែមិនទាន់បានដាក់ក្នុងគេហទំព័រវិទ្យាស្ថានជាតិស្ថិតិ)។ ប្រព័ន្ធស្ថិតិជាតិក៏មានកិច្ចដំណើរការនៅក្រោមផែនការមេស្ថិតិ ឆ្នាំ២០០៨-២០១៥ ដែលជាឧបករណ៍គ្រប់គ្រងដ៏មានប្រសិទ្ធភាពមួយ។ ហេតុការណ៍ដែលផែនការទាំងនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈជាវិជ្ជមាន គឺដើម្បីចង់ផ្តល់នូវតម្លាភាពក្នុងការប្រតិបត្តិរបស់វិទ្យាស្ថានជាតិស្ថិតិ ការផ្សព្វផ្សាយជាសាធារណៈសម្រាប់សកម្មភាពស្ថិតិ និងជាមូលដ្ឋានសម្រាប់គណនេយ្យភាព និងការត្រួតពិនិត្យជាសាធារណៈ។

## រចនាសម្ព័ន្ធក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធ

បណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលតម្រូវឱ្យបង្កើតអង្គភាពស្ថិតិនៅក្នុងស្ថាប័នរបស់ខ្លួន សម្រាប់គោលបំណងស្ថិតិ (មាត្រា១៨ នៃច្បាប់ស្តីពីស្ថិតិ)។ អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង (មាត្រា៤) តម្រូវឱ្យក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលគួរតែបង្កើតអង្គភាពស្ថិតិកណ្តាលមួយ ដើម្បីទទួលខុសត្រូវការផលិតស្ថិតិផ្លូវការដែលបានចាត់តាំង។ រចនាសម្ព័ន្ធភាគច្រើនជាក់ស្តែងដែលមានស្រាប់ ចូលរួមក្នុងអង្គភាពស្ថិតិ “កណ្តាល” ប៉ុន្តែស្ថិតិមួយចំនួនក៏ត្រូវបានផលិតដោយនាយកដ្ឋានប្រតិបត្តិដែរ។ ក្រសួងមួយចំនួនគ្មានអង្គភាពស្ថិតិ “កណ្តាល” (ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន) ហើយស្ថិតិត្រូវបានផលិតក្នុងនាយកដ្ឋានប្រតិបត្តិប៉ុណ្ណោះ។ ឧទាហរណ៍ជាក់លាក់មួយចំនួន ដូចជានាយកដ្ឋានស្ថិតិកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រមូលនិងចងក្រងស្ថិតិអំពីផលិតផលដំណាំ ប៉ុន្តែទិន្នន័យអំពីព្រៃឈើ នេសាទ និងបសុសត្វត្រូវបានប្រមូល ចងក្រង និងផ្សព្វផ្សាយ ដោយនាយកដ្ឋានផ្សេងៗគ្នានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា ប្រមូល ចងក្រង និងផ្សព្វផ្សាយ តែស្ថិតិអប់រំតាមមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ខណៈដែលស្ថិតិអប់រំក្នុងប្រព័ន្ធ និងឧត្តមសិក្សាមិនស្ថិតនៅក្រោមការ

---

[១៩] បច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រក្រសួងផែនការ ២០១៤-២០១៨ ខែមករា២០១៤។

[២០] ផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៦ នៃផែនការយុទ្ធសាស្ត្រក្រសួងផែនការ (MPSP) ២០១៤-២០១៨។

[២១] បច្ចុប្បន្នថ្មីបំផុត របាយការណ៍ប្រចាំឆ្នាំ២០១៥ ប្រព័ន្ធស្ថិតិជាតិកម្ពុជា បោះពុម្ពផ្សាយខែធ្នូ ឆ្នាំ២០១៦។

ទទួលខុសត្រូវផ្ទាល់ឡើយ។ ធនាគារជាតិនៃកម្ពុជាមាននាយកដ្ឋានស្ថិតិទទួលខុសត្រូវរាល់ស្ថិតិទាំងអស់របស់ធនាគារជាតិនៃកម្ពុជា។

ការខុសគ្នាទាំងនេះមាននៅក្នុងស្ថាប័នស្ថិតិ ទោះបីបានកំណត់ក្នុងច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងក៏ដោយ។ ការអនុវត្តពេញលេញនៃគោលបំណងនៃច្បាប់ និងអនុក្រឹត្យនឹងមានអត្ថប្រយោជន៍។

វចនាសម្ព័ន្ធបែបនេះមាននៅក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលជាច្រើន ដែលមាននៅរហូតដែលគេហៅថា "បំពង់ផ្សែងចង្ក្រាន" នៃដំណើរការស្ថិតិ ដែលបង្កើតនូវភាពគ្មានប្រសិទ្ធភាពនៅក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលខ្លួនឯង និងបង្អាក់ដល់ការសម្របសម្រួលនៃកិច្ចដំណើរការប្រព័ន្ធស្ថិតិជាតិ ដូចជាវិទ្យាស្ថានជាតិស្ថិតិដែរដែលមិនមានអ្នកទំនាក់ទំនងតែមួយតាមក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលមួយចំនួន ហើយត្រូវធ្វើអន្តរកម្មជាមួយអង្គភាពផ្សេងៗរបស់ពួកគេក្នុងដំណើរការការងារធម្មតា ដូចជាដើម្បីទទួលបានទិន្នន័យដែលបានចាត់តាំង ឬដើម្បីពិភាក្សា/បញ្ជាក់ពីបញ្ហាម៉េតាទិន្នន័យជាដើម។ ការសម្របសម្រួលស្ថិតិនៅក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលគឺមានសារៈសំខាន់ណាស់។

របាយការណ៍ពាក់កណ្តាលអាណត្តិបានសង្កេតឃើញថា ការរៀបចំការងារស្ថាប័នល្អសម្រាប់វិស័យស្ថិតិពិតប្រាកដមួយចំនួនត្រូវបានបង្ហាញ។ ការធ្វើឱ្យប្រសើរឡើងថែមទៀតបានកើតឡើងបន្ទាប់ពីឆ្នាំ២០១២ និងមានច្រើនទៀតក្នុងដំណាក់កាលធ្វើផែនការ ឧទាហរណ៍ ក្រសួងអប់រំ យុវជន និងកីឡាកំពុងពិចារណាបង្កើតអង្គភាពស្ថិតិ "កណ្តាល" មួយ។

## ការសម្របសម្រួល

ច្បាប់ស្តីពីស្ថិតិតាក់តែងជំពូកមួយ ដើម្បីសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ (ជំពូក៤ មាត្រា១៤ ដល់១៩)។ វាផ្តល់នូវការទទួលខុសត្រូវរបស់វិទ្យាស្ថានជាតិស្ថិតិ សម្រាប់ធ្វើគោលនយោបាយក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ការទទួលខុសត្រូវសម្រាប់ការសម្របសម្រួលទាក់ទងនឹងការគ្រប់គ្រងប្រព័ន្ធស្ថិតិជាតិប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព ការអភិវឌ្ឍស្ថិតិ រួមទាំងការបណ្តុះបណ្តាល ការរៀបចំជាមួយអង្គការអន្តរជាតិ និងស្ថាប័នដទៃទៀត និងបទដ្ឋានស្ថិតិជាតិទាក់ទងនឹងចំណាត់ថ្នាក់ ទស្សនទាន និយមន័យ និងអង្គពិនិត្យពិចារណាស្ថិតិ។ ជំពូកនេះបានបង្កើតក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ តម្រូវឱ្យអង្គភាពស្ថិតិដែលបានចាត់តាំងបង្កើតអង្គភាពស្ថិតិ ផ្តល់ឱ្យអគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិមានឋានៈជាប្រធានស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា និងតម្រូវឱ្យអង្គភាពស្ថិតិដែលបានចាត់តាំងផ្ញើទិន្នន័យស្ថិតិដែលពួកគេបានផលិតទៅវិទ្យាស្ថានជាតិស្ថិតិ។

ការសម្របសម្រួលត្រូវបានអនុវត្តភាគច្រើន តាមរយៈក្រុមប្រឹក្សាស្ថិតិ (កិច្ចប្រជុំចុងក្រោយបំផុតនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧) គណៈកម្មាធិការសម្របសម្រួលស្ថិតិ (កិច្ចប្រជុំចុងក្រោយបំផុតនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧) និងអនុក្រុមបច្ចេកទេសនៃក្រុមការងារបច្ចេកទេស ផែនការ និងកាត់បន្ថយភាពក្រីក្រ (TWG-PPR) ស្តីពីទិន្នន័យសម្រាប់ការអភិវឌ្ឍ (កិច្ចប្រជុំចុងក្រោយបំផុតនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨)។ វិទ្យាស្ថានជាតិស្ថិតិជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាស្ថិតិ។ អគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិជាប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ ហើយដូច្នេះមានលទ្ធភាពទទួលបានពីក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលទាំងអស់នៅតាមកម្រិតសមស្របក្នុងនាមជាសមាជិកគណៈកម្មាធិការ។ នេះបានផ្តល់ឱកាសដល់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីពង្រឹងកិច្ចសហការលើបញ្ហា

សម្របសម្រួលទាំងស្រុង។ ក៏មានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកប្រើប្រាស់ទិន្នន័យ/ភាគីពាក់ព័ន្ធ/ដៃគូអភិវឌ្ឍន៍ សម្រាប់ជំរឿន និងអង្កេតនីមួយៗដែលធ្វើដោយវិទ្យាស្ថានជាតិស្ថិតិ ឧទាហរណ៍ ដំណើរការថ្មីៗចុងក្រោយបំផុតគឺថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨ ស្តីពីជំរឿនទូទៅប្រជាជន ឆ្នាំ២០១៩។ កិច្ចប្រជុំដទៃទៀតជាមួយស្ថាប័នរបស់ប្រព័ន្ធស្ថិតិជាតិ ត្រូវបានធ្វើឡើងនៅពេលចាំបាច់។ វិទ្យាស្ថានជាតិស្ថិតិផលិតរបាយការណ៍ប្រចាំឆ្នាំស្តីពីប្រព័ន្ធស្ថិតិជាតិ។

### ការផ្តល់ថវិកា

ផ្អែកតាមច្បាប់ស្តីពីស្ថិតិថ្មី គួរតែមានបន្ទាត់ថវិកាមួយសម្រាប់ការអនុវត្តសកម្មភាពសេដ្ឋកិច្ចដែលធ្វើដោយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលនីមួយៗ រួមមានការកសាងសមត្ថភាព និងការស្រាវជ្រាវទ្រង់ទ្រាយតូច។ នៅពេលដែលការអនុវត្តកាន់តែរីកចម្រើនតាមការរំពឹងទុក។

ច្បាប់ស្តីពីស្ថិតិ ឆ្នាំ២០១៥ ផ្តល់នីតិវិធីសម្រាប់ធ្វើឱ្យប្រសើរឡើងសម្រាប់ការផ្តល់ថវិកាស្ថិតិ ជាពិសេសអង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលត្រូវរៀបចំផែនការសកម្មភាពនៃសកម្មភាពស្ថិតិរបស់ខ្លួន និងរៀបចំផែនការថវិកាប្រចាំឆ្នាំ ដើម្បីបញ្ចូលក្នុងកញ្ចប់ថវិការបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ (មាត្រា២១)។ នៅពេលអនុវត្តន៍ វានឹងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពទូទៅនៃការគាំទ្រថវិកាសម្រាប់ស្ថិតិ នៅក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

### ២.៣.៤ ធនធានមនុស្ស

គិតត្រឹមឆ្នាំ២០១១ មន្ត្រីស្ថិតិមាន ៦២៥ នាក់ ក្នុងនោះវិទ្យាស្ថានជាតិស្ថិតិមាន ៣១៣ នាក់ នៅវិទ្យាស្ថានជាតិស្ថិតិ និង ៣១៥ នាក់ នៅការិយាល័យផែនការខេត្ត និងខណ្ឌស្រុក។ នៅក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលមានមន្ត្រីស្ថិតិប្រមាណ ២៩០ នាក់ ដែលមានមូលដ្ឋាននៅអង្គភាពស្ថិតិដែលបានចាត់តាំង និង ៩១០ នាក់ ជាមន្ត្រីផែនការ និងស្ថិតិខេត្ត។

គិតត្រឹមឆ្នាំ២០១៦ មន្ត្រីស្ថិតិមាន ១,០៧៣ នាក់ ក្នុងនោះវិទ្យាស្ថានជាតិស្ថិតិមាន ៣១៥ នាក់ នៅវិទ្យាស្ថានជាតិស្ថិតិ (ប្រុស ២០៨ នាក់ និងស្ត្រី ១០៧ នាក់) និង ៧៥៨ នាក់ នៅការិយាល័យផែនការខេត្ត និងខណ្ឌស្រុក។ ការិយាល័យផែនការខេត្តមានអនុប្រធានមួយទទួលបន្ទុកផែនការ និងស្ថិតិ និងប្រធានការិយាល័យមួយទទួលបន្ទុកការិយាល័យស្ថិតិ។ លើសពីនេះទៀត មានមន្ត្រីផែនការ និងស្ថិតិមួយចំនួននៅថ្នាក់ស្រុក។ នៅក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល មានមន្ត្រីស្ថិតិ ៣៧១ នាក់ ដែលមានមូលដ្ឋាននៅអង្គភាពស្ថិតិដែលបានចាត់តាំង (រួមទាំងស្ត្រី ៩៩ នាក់) និងគ្មានទិន្នន័យអំពីមន្ត្រីផែនការ និងស្ថិតិខេត្តឡើយ។

នៅឆ្នាំ២០១៦ ប្រមាណ ៧៤ ភាគរយ នៃមន្ត្រីវិទ្យាស្ថានជាតិស្ថិតិមានកម្រិតបរិញ្ញាបត្រ ឬខ្ពស់ជាងនេះ។ ចំពោះក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលមានលំដាប់ថ្នាក់ភាគរយ ពី ៤០ ភាគរយ ទៅ ១០០ ភាគរយ ជាមួយមធ្យមភាគប្រមាណ ៧៣ ភាគរយ។

របាយការណ៍ពាក់កណ្តាលអាណត្តិបានកត់សម្គាល់ថា កម្រិតប្រាក់បៀវត្សរ៍របស់មន្ត្រីស្ថិតិនៅតែបន្តជាបញ្ហាលំបាកមួយហើយចាំបាច់ត្រូវដោះស្រាយ ប្រសិនបើប្រព័ន្ធស្ថិតិជាតិមានប្រសិទ្ធភាព និងឆ្លើយតបទៅនឹងការពង្រីកតម្រូវការទិន្នន័យ។ សំណាងល្អ ប្រាក់បៀវត្សរ៍រដ្ឋាភិបាលបានកើនឡើងប្រហែល ២០ ភាគរយ ក្នុងមួយឆ្នាំ ក្នុង

រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ[២២] កម្រិតនៅតែត្រូវបានពិនិត្យឡើងវិញជាមួយការខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យប្រសើរឡើងថែមទៀត។ ទោះជាយ៉ាងណាក៏ដោយ អត្រាប្រាក់បៀវត្សរ៍នៅទាបនៅឡើយ ហើយស្ថិតនៅក្នុងកម្រិតទាបបំផុតនៅក្នុងតំបន់អាស៊ាន។

ការលើកទឹកចិត្តសម្រាប់ការសិក្សាក៏មិនខ្លាំងក្លាដែរ វាគួរតែជំរុញប្រសិនបើនិស្សិតបញ្ចប់ការសិក្សាត្រូវបានសាកល្បង និងបញ្ជាក់ជំនាញស្ថិតិតាមកម្រិតពិតប្រាកដ ហើយទទួលបានប្រាក់បៀវត្សរ៍បំប៉ន។ ទោះជាយ៉ាងណាក៏ដោយ វិទ្យាស្ថានជាតិស្ថិតិបច្ចុប្បន្នខ្វះសិទ្ធិអំណាច ដើម្បីបង្កើតប្រព័ន្ធលើកទឹកចិត្តឯករាជ្យ។

ការអនុវត្តការគ្រប់គ្រងផ្សេងៗទៀតរួមមាន ៖ មន្ត្រីទាំងអស់មានការពិពណ៌នាការងារ និងការត្រួតពិនិត្យអនុវត្តន៍ការងារមន្ត្រី ត្រូវបានធ្វើឡើងរៀងរាល់ពីរឆ្នាំ។ ការអនុវត្តនៃការត្រួតពិនិត្យរៀងរាល់ពីរឆ្នាំម្តង អាចនឹងធ្វើឱ្យប្រសើរឡើងដល់ការត្រួតពិនិត្យប្រចាំឆ្នាំ។ វិទ្យាស្ថានជាតិស្ថិតិបានបង្កើតផែនការអភិវឌ្ឍន៍ធនធានមនុស្សមួយ ប៉ុន្តែវាមិនត្រូវបានអនុវត្តឡើយ។ ការគ្រប់គ្រង និងការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំមិនត្រូវបានផ្តល់ការយកចិត្តទុកដាក់ខ្ពស់ឡើយ។

## ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព

របាយការណ៍ពាក់កណ្តាលអាណត្តិបានកត់សម្គាល់ថា ចំនួននៃការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសសម្រាប់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលបានកើនឡើង។ វាក៏បានកត់សម្គាល់ផងដែរថា គម្លាតនៃជំនាញបច្ចេកទេសនៅតែមានទោះបីនៅក្នុងវិទ្យាស្ថានជាតិស្ថិតិ ប៉ុន្តែគម្លាតកាន់តែធំនៅក្នុងក្រសួង។ របាយការណ៍បានផ្តល់អនុសាសន៍ថាសកម្មភាពបណ្តុះបណ្តាលត្រូវបានសម្របសម្រួលបានល្អ និងរួមបញ្ចូលគ្នាសម្រាប់ការកសាងសមត្ថភាពប្រកបដោយនិរន្តរភាពនៃប្រព័ន្ធស្ថិតិជាតិ។

ក្រសួងផែនការមានមជ្ឈមណ្ឌលបណ្តុះបណ្តាលមួយដែលផ្តល់កម្មវិធីរួមគ្នាពីរឆ្នាំ សម្រាប់ផែនការ និងស្ថិតិ។ សិស្សគឺជាអនាគតនិយោជិត និងជានិយោជិតថ្មីរបស់ក្រសួងផែនការ ពួកគេទទួលបានការបណ្តុះបណ្តាលរួមគ្នាពីរឆ្នាំ។ ស្ថិតិមានប្រហែល ៦០ ភាគរយ នៃកម្មវិធីសិក្សា សម្រាប់និស្សិតដែលមានជំនាញខាងស្ថិតិ។ កម្មវិធីនៃក្រសួងផែនការរួមមានសេចក្តីផ្តើមនៃស្ថិតិសម្រាប់មន្ត្រីកម្រិតទាប ទ្រឹស្តីស្ថិតិ ស្ថិតិសេដ្ឋកិច្ច ការអង្កេតគំរូ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ គណនេយ្យជាតិ និងស្ថិតិសម្រាប់ឧស្សាហកម្ម សំណង់ និងដឹកជញ្ជូន ប៉ុន្តែមិនមានមុខជំនាញសំខាន់ៗ ដូចជាស្ថិតិបឋម ប្រជាសាស្ត្រ និងកម្មវិធីស្ថិតិ (SPSS[២៣] STATA[២៤] និងកម្មវិធីប្រើប្រាស់ SAS[២៥]) ឡើយ។

[២២] បញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗដែលរំខានដល់ប្រព័ន្ធស្ថិតិជាតិ គឺប្រាក់បៀវត្សរ៍ទាបសម្រាប់មន្ត្រីរដ្ឋាភិបាល ដែលធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តការងារ។ អាស្រ័យហេតុនេះ មន្ត្រីស្ថិតិជាច្រើនទៅធ្វើការងារបន្ថែម បន្ទាប់ពីម៉ោងធ្វើការ។ រហូតមកដល់ឆ្នាំ២០១២ ដៃគូអភិវឌ្ឍន៍បានអនុវត្តកម្មវិធីមួយសម្រាប់បំពេញប្រាក់បៀវត្សរ៍របស់មន្ត្រីថ្នាក់ខ្ពស់នៅក្នុងស្ថាប័នទាំងអស់ ដើម្បីជំរុញលើកទឹកចិត្តមន្ត្រីទាំងនោះឱ្យផ្តោតលើការងាររបស់ខ្លួន ដោយចៀសវាងការប្រកួតប្រជែងរវាងម្ចាស់ជំនួយ។ គម្រោងបំពេញប្រាក់បៀវត្សរ៍ដែលស្រដៀងគ្នានេះ បន្ទាប់មកត្រូវបានរាជរដ្ឋាភិបាលកម្ពុជាទទួលយក ហើយបានផ្តល់អត្ថប្រយោជន៍ដល់មន្ត្រី ៧០ នាក់ ដែលត្រូវបានបន្តនៅក្នុងឆ្នាំ២០១២ និង ២០១៣ ប៉ុន្តែត្រូវបានបញ្ចប់ដោយភ្ជាប់ជាមួយការតម្លើងប្រាក់បៀវត្សរ៍រដ្ឋាភិបាល។

[២៣] SPSS (Statistical Package for the Social Sciences) គឺជាកម្មវិធីសម្រាប់វិភាគស្ថិតិ។

[២៤] STATA (Statistics and data) គឺជាកម្មវិធីសម្រាប់គោលបំណងទូទៅនៃស្ថិតិ។

[២៥] SAS (Statistical Analysis System) គឺជាកម្មវិធីសម្រាប់ការវិភាគកម្រិតខ្ពស់ ការវិភាគចម្រុះ ភាពវៃឆ្លាតខាងធុរៈកិច្ច ការគ្រប់គ្រងទិន្នន័យ និងការវិភាគទស្សន៍ទាយ។

ប្រមាណ ៤០ ទៅ ៥០ ភាគរយ នៃមន្ត្រីវិទ្យាស្ថានជាតិស្ថិតិបច្ចុប្បន្នបានបញ្ចប់កម្មវិធី។ មានតែកម្មវិធីសិក្សាស្ថិតិនេះទេ ដែលកំពុងដំណើរការនៅកម្ពុជា។ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA) ក៏បានឧបត្ថម្ភដល់ការបណ្តុះបណ្តាលស្ថិតិសម្រាប់មន្ត្រីក្រសួងផែនការនៅតាមខេត្តជាភាសាខ្មែរ ហើយគម្រោងនេះត្រូវបានរំពឹងថានឹងបន្តក្នុងគម្រោងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA)។

ស្ថិតិមិនទាន់ត្រូវបានផ្តល់ឱ្យទៅមហាវិទ្យាល័យ ឬសាកលវិទ្យាល័យណាមួយនៅកម្ពុជា ជាកម្មវិធីកម្រិតមហាវិទ្យាល័យ ឬក្រោយមហាវិទ្យាល័យទៀតឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅខែតុលា ឆ្នាំ២០១៥ ថ្នាក់គ្រប់គ្រងក្រសួងផែនការ និងវិទ្យាស្ថានជាតិស្ថិតិបានឈានដល់កិច្ចព្រមព្រៀងមួយជាមួយសាកលវិទ្យាល័យកូរ៉េ អំពីការពង្រីកនាយកដ្ឋានគណិតវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ទៅជានាយកដ្ឋានគណិតវិទ្យា និងស្ថិតិនាពេលអនាគត ដោយមានជំនួយពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)។ កិច្ចព្រមព្រៀងនេះ គឺសំដៅកាត់បន្ថយកង្វះខាតជំនាញស្ថិតិ។ កិច្ចព្រមព្រៀងនេះនៅតែមិនទាន់ត្រូវបានអនុវត្តនៅឡើយ។

## វិទ្យាស្ថានជាតិស្ថិតិ

ទោះជាយ៉ាងណាក៏ដោយ មន្ត្រីជាន់ខ្ពស់នៃវិទ្យាស្ថានជាតិស្ថិតិបានវាយតម្លៃថា មន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិបានទទួលការបណ្តុះបណ្តាលយ៉ាងពេញលេញសម្រាប់ការងារដែលពួកគេកំពុងធ្វើ។ ប៉ុន្មានឆ្នាំមកនេះ មន្ត្រីមួយចំនួននៃវិទ្យាស្ថានជាតិស្ថិតិ រួមទាំងមន្ត្រីថ្នាក់ខ្ពស់នៅវិទ្យាស្ថានជាតិស្ថិតិបានចូលរួមក្នុងឱកាសកសាងសមត្ថភាពស្ថិតិរយៈពេលខ្លី និងរយៈពេលវែង ដើម្បីជំរុញចំណេះដឹង និងជំនាញតាមរយៈ ៖

- សញ្ញាប័ត្រក្រោយឧត្តមសិក្សាខាងស្ថិតិ ឬវគ្គសិក្សាដែលទាក់ទងបានផ្តល់ឱ្យនៅបរទេស (តាមរយៈអាហារូបករណ៍ ឬកម្មវិធីផ្លាស់ប្តូរស្ថាប័នដែលផ្តល់ថវិកាដោយដៃគូអភិវឌ្ឍន៍មួយចំនួន)។ នៅចុងទសវត្សរ៍ ១៩៩០ និងទសវត្សរ៍ ២០០០ មន្ត្រីវិទ្យាស្ថានជាតិស្ថិតិប្រាំបីនាក់បានសិក្សាវគ្គសិក្សាស្ថិតិនៅប្រទេសហ្វីលីពីន និងទទួលបានសញ្ញាបត្រអនុបណ្ឌិត។ ពួកគេនៅតែនៅវិទ្យាស្ថានជាតិ ហើយបច្ចុប្បន្នបានបង្កើតភាពជាអ្នកដឹកនាំដ៏វៃឆ្លាតនៃវិទ្យាស្ថានជាតិស្ថិតិ។
- កម្មវិធីបណ្តុះបណ្តាលមានសញ្ញាបត្រ ឬគ្មានកម្រិតបានផ្តល់ជូនដោយវិទ្យាស្ថានបណ្តុះបណ្តាលអន្តរជាតិ (ឧទាហរណ៍ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) វិទ្យាស្ថានស្ថិតិសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (SIAP) សាកលវិទ្យាល័យកាល់គូតា រដ្ឋាភិបាលឥណ្ឌា ជប៉ុន ស៊ុយអែត និងវៀតណាម)។
- វគ្គបណ្តុះបណ្តាលក្នុងស្រុកទាក់ទងនឹងសកម្មភាពស្ថិតិសំខាន់ៗ (ឧទាហរណ៍ អំពីជំរឿន និងអង្កេត)។

មន្ត្រីជាសមាជិកបានទទួលការបណ្តុះបណ្តាលក្រៅប្រទេសនៅសិក្ខាសាលា និងកិច្ចប្រជុំអន្តរជាតិនានាតាមរយៈជំនួយរបស់ដៃគូអភិវឌ្ឍន៍។ ទន្ទឹមនឹងនេះដែរ ការបណ្តុះបណ្តាលស្ថិតិក៏ត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍ លើវិស័យជាក់លាក់ ការវិភាគទិន្នន័យ និងការប្រើប្រាស់ទិន្នន័យសម្រាប់ផ្នែកផែនការ និងការគ្រប់គ្រង។

មន្ត្រីជាន់ខ្ពស់ក៏បានចូលរួមសិក្ខាសាលាគ្រប់គ្រងស្ថិតិប្រចាំឆ្នាំរបស់វិទ្យាស្ថានស្ថិតិសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (SIAP) សម្រាប់ប្រធានការិយាល័យស្ថិតិ និងអនុប្រធានការិយាល័យស្ថិតិ សម្រាប់ការអភិវឌ្ឍជំនាញគ្រប់គ្រង និងភាពជាអ្នកដឹកនាំ។ បន្ថែមពីនេះទៀត គម្រោងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA) ដែលកំពុងដំណើរ

ការនៅវិទ្យាស្ថានជាតិស្ថិតិ បានផ្តល់ការប្រឹក្សាយោបល់ស្តីពីជំនាញគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ការគ្រប់គ្រងធនធានមនុស្ស និងឧបករណ៍សម្រាប់អ្នកគ្រប់គ្រងវិទ្យាស្ថានជាតិស្ថិតិ (កម្រិតខ្ពស់ កម្រិតមធ្យម) អស់រយៈពេលជាច្រើនឆ្នាំ។

ដោយមានការគាំទ្រពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA) វិទ្យាស្ថានជាតិស្ថិតិបានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីស្ថិតិមូលដ្ឋាន និងស្ថិតិកម្រិតខ្ពស់ដល់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល បន្ថែមដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងការិយាល័យខេត្តនៃក្រសួងផែនការ[២៦] ផងដែរ។

## ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល

ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលមួយចំនួនបានទទួលអត្ថប្រយោជន៍ពីការបណ្តុះបណ្តាល និងជំនួយការពីវិទ្យាស្ថានជាតិស្ថិតិ និងដៃគូអភិវឌ្ឍន៍ ដូចជា ៖

| ទទួលបានការបណ្តុះបណ្តាល (ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល) | វិស័យ |
|---|---|
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ទស្សនកិច្ចសិក្សាវិនិយោគផ្ទាល់ពីបរទេស នៅធនាគារនៃប្រទេសឥណ្ឌូណេស៊ី ការផ្សព្វផ្សាយ |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | វិធីសាស្ត្រ ការប្រមូលទិន្នន័យ ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រអង្កេត ការជ្រើសសំណាកគំរូ ការវិភាគ រួមទាំងការបណ្តុះបណ្តាលមួយចំនួននៅថ្នាក់ខេត្ត |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | វិធីសាស្ត្រស្ថិតិ និងការកែច្នៃទិន្នន័យ |
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo) អង្កេតមូលដ្ឋាន |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ទស្សនទានមូលដ្ឋាននៃស្ថិតិ |
| ក្រសួងបរិស្ថាន | វគ្គសិក្សាកម្មវិធី STATA និងប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo) |
| ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | វគ្គសិក្សាខ្លីស្តីពីស្ថិតិមូលដ្ឋាន និងការស្រាវជ្រាវ |
| ក្រសួងមហាផ្ទៃ | ការតាមដាន និងវាយតម្លៃ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | វគ្គបណ្តុះបណ្តាលស្ថិតិមូលដ្ឋាន |
| ក្រសួងកិច្ចការនារី | ស្ថិតិយេនឌ័រ ការវិភាគទិន្នន័យ (SPSS និង STATA) គម្រោងយេនឌ័រក្នុងវ័យបន្តពូជ និងការគ្រប់គ្រង |
| ក្រសួងអភិវឌ្ឍន៍ជនបទ | អង្កេត ការវាយបញ្ចូលទិន្នន័យ និងការវិភាគ ទិន្នន័យមូលដ្ឋាន ការតាមដាន និងវាយតម្លៃ |
| ធនាគារជាតិនៃកម្ពុជា | ស្ថិតិជញ្ជីងទូទាត់ ស្ថិតិរូបិយវត្ថុ និងហិរញ្ញវត្ថុ |

ថ្វីបើមានសកម្មភាពបណ្តុះបណ្តាលទាំងនេះក៏ដោយ ក៏កម្រិតនៃជំនាញស្ថិតិត្រូវបានចាត់ទុកជាទូទៅថាមានកម្រិតទាប។

[២៦] វិទ្យាស្ថានជាតិស្ថិតិបានផ្តល់វគ្គបណ្តុះបណ្តាលចំនួនពីរ (ស្ថិតិមូលដ្ឋាន និងស្ថិតិកម្រិតខ្ពស់) ៖ ស្ថិតិមូលដ្ឋាន (ការិយាល័យខេត្តកោះកុង ព្រៃវែង បន្ទាយមានជ័យ សៀមរាប កំពង់ចាម និងព្រះសីហនុ) ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល និងវិទ្យាស្ថានជាតិស្ថិតិ ហើយនិងស្ថិតិកម្រិតខ្ពស់ (ការិយាល័យខេត្តសៀមរាប) និងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

## តម្រូវការបណ្តុះបណ្តាល

ជារួម ការបន្តលើកកម្ពស់សមត្ថភាព និងជំនាញរបស់មន្ត្រីស្ថិតិនៅវិទ្យាស្ថានជាតិស្ថិតិចាំបាច់ណាស់សម្រាប់ការងារស្ថិតិដែលកំពុងដំណើរការ និងជាពិសេសសម្រាប់ផលិតសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ហើយគួរយកចិត្តទុកដាក់ជាពិសេសនៅថ្នាក់ក្រោមជាតិ (តាមខេត្ត និងស្រុក)។ វិស័យខាងក្រោមនៃការបណ្តុះបណ្តាល និងការអភិវឌ្ឍ (មានចំនួននៅក្នុងវង់ក្រចក) ត្រូវបានកំណត់ដូចខាងក្រោម ៖

| តម្រូវការបណ្តុះបណ្តាល និងការកសាងសមត្ថភាព នៅវិទ្យាស្ថានជាតិស្ថិតិ |
|---|
| ការគ្រប់គ្រងធនធានមនុស្ស (៥) |
| ស្ថិតិទូទៅ (កម្រិតមូលដ្ឋាន និងកម្រិតខ្ពស់) (១៥) |
| ការរៀបចំ ដំណើរការ និងការវិភាគជំរឿន និងអង្កេត (១៥) |
| ការវិភាគទិន្នន័យស្ថិតិ និងសរសេររបាយការណ៍ (៣-៥) |
| ការកែច្នៃទិន្នន័យស្ថិតិ/របៀបធ្វើតារាងស្ថិតិ និងប្រើប្រាស់កម្មវិធីស្ថិតិ ដូចជាកម្មវិធី SPSS (៥-១០) ជ្រើសសំណាកគំរូ និងគណនាមេគុណសមាត្រទម្ងន់ (៥-១០) |
| ការរចនាវេបសាយ (៥-១០) |
| ការរចនាបញ្ជីសំណួរ (១០) |
| ការប្រើប្រាស់សម្ភាសន៍ផ្ទាល់ខ្លួនដោយកុំព្យូទ័រ (CAPI) សម្រាប់ការប្រមូលទិន្នន័យ |
| ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) |
| ប្រព័ន្ធព័ត៌មានគ្រប់គ្រង (MIS) |
| ការបណ្តុះបណ្តាលតាមប្រធានបទអំពីគណនេយ្យជាតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងប្រធានបទដទៃទៀត |
| ការប្តូរឆ្នាំគោល និងរបៀបយកគណនីសេដ្ឋកិច្ចផ្លាស់ប្តូរក្នុងការរៀបចំប្រមូលទិន្នន័យ |
| ការបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាពមន្ត្រីក្នុងភាសាអង់គ្លេស |
| ការពិនិត្យគុណភាពស្ថិតិ |
| ការអភិវឌ្ឍសូចនាករ ការប្រមូលទិន្នន័យ ការវិភាគ និងការបកស្រាយទិន្នន័យ |

តម្រូវការបណ្តុះបណ្តាលនៅបណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល រួមមាន ៖

| ទទួលបានការបណ្តុះបណ្តាល (ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល) | វិស័យ |
|---|---|
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ការប្រមូលទិន្នន័យ ការវិភាគ និងរបៀបភ្ជាប់ទៅជញ្ជីងទូទាត់នៃមូលនិធិរូបិយវត្ថុអន្តរជាតិ បោះពុម្ពលើកទី៦ (BPM6) |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អង្កេតគំរូ និងការវិភាគ |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ការប្រមូលទិន្នន័យ ស្ថិតិកម្រិតខ្ពស់ ប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo) |
| ក្រសួងធម្មការ និងសាសនា | ការប្រមូលទិន្នន័យ និងការវិភាគ |
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | កម្មវិធី SPSS ប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo) កម្មវិធី Access ការវិភាគទិន្នន័យ |
| ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | របៀបគ្រប់គ្រងស្ថិតិ |
| ក្រសួងរ៉ែ និងថាមពល | ការវិភាគស្ថិតិ |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | កម្មវិធី SPSS ប្រព័ន្ធកែច្នៃជំរឿន និងអង្កេត (CSPro) ការស្រាវជ្រាវ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា និងការគ្រប់គ្រងចំណេះដឹង |
| ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ការបណ្តុះបណ្តាលតាមរយៈការងារ និងសិក្ខាសាលាស្តីពីស្ថិតិ |

| | |
|---|---|
| ក្រសួងមហាផ្ទៃ | ការវិភាគទិន្នន័យជាមួយកម្មវិធីវិភាគ ការប្រមូលទិន្នន័យ និងអង្កេត |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ការបង្កើតបញ្ជីសំណួរ ការចងក្រង ការវិភាគ |
| ក្រសួងកិច្ចការនារី | ការគ្រប់គ្រងទិន្នន័យមូលដ្ឋាន ការវិភាគស៊ីជម្រៅ ការប្រមូលទិន្នន័យ និង ការបកស្រាយ ការផលិតស្ថិតិ ការធ្វើផែនការស្ថិតិ រួមទាំងវិធីសាស្ត្រ |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ការវិភាគទិន្នន័យ និងការវាយបញ្ចូលទិន្នន័យ |
| ធនាគារជាតិនៃកម្ពុជា | ការប្រមូលទិន្នន័យ ជញ្ជីងទូទាត់ប្រើប្រាស់សៀវភៅណែនាំជញ្ជីងទូទាត់ បោះពុម្ពលើកទី៦ (BPM6) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងស្ថិតិរូបិយវត្ថុ និងហិរញ្ញវត្ថុ។ |

បញ្ហាមួយ គឺជាលទ្ធផលនៃការយល់ដឹងរួមពីដៃគូអភិវឌ្ឍន៍មុនៗ ដែលបានផ្តល់ឱកាសសម្រាប់កម្មវិធីបណ្តុះបណ្តាល។ ការលើកទឹកចិត្ត និងភាសាជាហេតុផលចម្បងពីរដែលធ្វើឱ្យការបណ្តុះបណ្តាលភាគច្រើនត្រូវបានចាត់ទុកថាមិនទទួលបានជោគជ័យ។ ឯកសារបណ្តុះបណ្តាល និងមធ្យោបាយណែនាំជាភាសាអង់គ្លេស។ បញ្ហានេះបានបង្កឱ្យមានបញ្ហាដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិជាច្រើន ដែលខ្វះខាតខាងការយល់ដឹងភាសាអង់គ្លេសបានល្អ ហើយពិបាកយល់មេរៀន។ ដោយយោងទៅតាមការពិបាកនេះ កម្មវិធីបណ្តុះបណ្តាលជាភាសាខ្មែរប្រហែលជានឹងសមស្របជាងសម្រាប់ប្រព័ន្ធស្ថិតិជាតិ។ វិសាលភាពនៃការបណ្តុះបណ្តាលអាចត្រូវបានកំណត់ ដោយការប្រើប្រាស់ឯកសារមេរៀនជាភាសាខ្មែរ ប៉ុន្តែបច្ចុប្បន្នឯកសារមេរៀនដែលមានស្រាប់ទាំងនេះ ភាគច្រើនត្រូវបានសរសេរដោយក្រុមគ្រូស្ថិតិបង្រៀនក្រៅម៉ោងនៃវិទ្យាស្ថានជាតិស្ថិតិដែលមានសញ្ញាបត្រអនុបណ្ឌិតពីប្រទេសហ្វីលីពីន។ ឯកសារថ្មីៗអាចត្រូវបានបន្ថែមពីពេលមួយទៅពេលមួយ។ សទ្ទានុក្រមនៃពាក្យបច្ចេកទេសជាភាសាអង់គ្លេសអាចត្រូវបានបង្រៀនផងដែរ។ ការបង្រៀនភាគច្រើនអាចធ្វើឡើងដោយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ។

### ២.៣.៥ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា (ICT)

តម្លៃនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យានៅក្នុងនីតិវិធីស្ថិតិត្រូវបានទទួលស្គាល់យ៉ាងពេញលេញ។

#### វិទ្យាស្ថានជាតិស្ថិតិ

វិទ្យាស្ថានជាតិស្ថិតិមានប្រព័ន្ធបណ្តាញមូលដ្ឋានមួយ (LAN) នៃកុំព្យូទ័រប្រមាណ ១០០ គ្រឿង ជាមួយ កុំព្យូទ័រមានសមត្ថភាពខ្ពស់ ៣ គ្រឿងជាម៉ាស៊ីនបម្រើ ប្រមាណ ៥០ គ្រឿងគ្មានប្រព័ន្ធបណ្តាញ។ ការប្រើប្រាស់អ៊ីនធឺណិត (ល្បឿន ៦០ មេហ្គាបៃ) ត្រូវបានផ្តល់ជូនជាច្រើន ប៉ុន្តែមិនមែនគ្រប់មន្ត្រីទាំងអស់សុទ្ធតែជួយពួកគេក្នុងការបំពេញភារកិច្ចឡើយ។ វិទ្យាស្ថានជាតិស្ថិតិរក្សាទុកវេបសាយមួយ។ គោលដៅដំបូងជាមួយវេបសាយរបស់វិទ្យាស្ថានជាតិស្ថិតិគឺផ្តល់របាយការណ៍សម្រាប់ទាញយក មានអ្នកប្រើប្រាស់ប្រមាណ ២០០ នាក់ ដែលចូលប្រើវេបសាយនេះ។

បច្ចុប្បន្ននៅវិទ្យាស្ថានជាតិស្ថិតិ ទិន្នន័យត្រូវបានរក្សាទុកក្នុងទីតាំងផ្សេងៗគ្នានៅលើបណ្តាញ ក៏ដូចជានៅលើកុំព្យូទ័រលើតុ។ សំណុំឯកសារទិន្នន័យច្រើនតែស្ថិតនៅក្នុងកុំព្យូទ័រផ្ទាល់ខ្លួន (PCs) របស់មន្ត្រីសមាជិកដែលមិនមានការត្រួតពិនិត្យត្រឹមត្រូវ។ ការរក្សាទុកទិន្នន័យនេះធ្វើឱ្យមានហានិភ័យដល់គុណភាពទិន្នន័យ និងអាចផ្តល់លទ្ធផលមិនអាចទាយទុកមុនបាន នៅពេលធ្វើតារាងទិន្នន័យ និងវិភាគទិន្នន័យ។ នាយកដ្ឋានបច្ចេកវិទ្យាទូរគមនាគមន៍

និងព័ត៌មានវិទ្យានៃវិទ្យាស្ថានជាតិស្ថិតិ ជំរុញខ្លាំងដល់ការបង្កើតទិន្នន័យមូលដ្ឋានទាក់ទងក្នុងគ្រប់វិស័យនៃស្ថិតិ និងចំណាត់ថ្នាក់។

ទ្រង់ទ្រាយផ្ទុកផ្សេងគ្នាកំពុងប្រើប្រាស់ ឧទាហរណ៍ កម្មវិធី Access ឆ្នាំ៩៥/៩៧/២០០០ Microsoft SQL Server និងប្រព័ន្ធអាស្រ័យលើសំណុំឯកសារមួយចំនួន។ ទិន្នន័យមួយចំនួនក៏ត្រូវបានរក្សាទុកក្នុងទ្រង់ទ្រាយ SPSS/STATA ប៉ុន្តែបន្ទាប់មកត្រូវបានគណនាបន្ថែម និងធ្វើឱ្យប្រសើរឡើងតាមវិធីផ្សេងៗគ្នា។ ភាពខុសគ្នាធំបំផុតរវាងវិធីផ្ទុកទាំងនេះ គឺជាកន្លែង និងរបៀបរក្សាទុកទិន្នន័យ និងកម្រិតនៃសុវត្ថិភាពទិន្នន័យ។

កម្មវិធីដែលបានប្រើប្រាស់រួមមាន ៖ កម្មវិធីស្ថិតិ-STATA SPSS ឧបករណ៍ធ្វើតារាងទិន្នន័យ និងការផ្សព្វផ្សាយ – CSPro Super CROSS[២៧] កម្មវិធីការិយាល័យ – Microsoft ឬ Open Office ឧបករណ៍អភិវឌ្ឍន៍កម្មវិធី – CSPro, Access Visual Basic 6 ឬ Net programming language, Window 7, 10/Windows server 2008, Antivirus (អាជ្ញាប័ណ្ណឥតគិតថ្លៃ)។ មានបញ្ហាមួយដែលមិនស្របគ្នានៃប្រព័ន្ធកម្មវិធីមួយចំនួន ដែលបានប្រើប្រាស់នៅវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

គ្រឿងបរិក្ខាភាគច្រើនដែលបានប្រើប្រាស់សម្រាប់ស្ថិតិ (ឧទាហរណ៍ ផ្នែករឹង ម៉ាស៊ីនបម្រើ និងកម្មវិធី) ត្រូវបានផ្តល់ហិរញ្ញប្បទានតាមរយៈការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍។ ការគាំទ្របច្ចុប្បន្នដោយថវិកាក្នុងស្រុកសម្រាប់ការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាមិនទាន់បានរៀបចំឱ្យបានល្អនៅឡើយ។ គោលនយោបាយរយៈពេលវែងនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាក៏មិនទាន់មាន។

លទ្ធភាពនៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យារបស់មន្ត្រីនៅមិនទាន់គ្រប់គ្រាន់ឡើយ។ ពួកគេត្រូវការផ្នែករឹង និងផ្នែកទន់ដែលត្រូវធ្វើបច្ចុប្បន្នកម្ម និងបង្កើន រួមទាំងកុំព្យូទ័រផ្ទាល់ខ្លួន កុំព្យូទ័រយួរដៃ ម៉ាស៊ីនបម្រើ ម៉ាស៊ីនបោះពុម្ព ម៉ាស៊ីនបញ្ចាំង ជំនួយកត់ត្រាផ្ទាល់ខ្លួន (Personal Digital Assistants) និងបណ្តាញ។ ពួកគេត្រូវការកម្មវិធីស្ថិតិថ្មីៗសម្រាប់វិភាគស្ថិតិ និងការងារប្រក្រតី។ វេបសាយថេរមួយក៏ត្រូវការ និងការថែរក្សាជាទៀងទាត់នូវឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា គឺត្រូវការជាចាំបាច់ដើម្បីបន្តការងារ។

នៅក្នុងការវាយតម្លៃរបស់ក្រុមហ៊ុន FIDES Services នៅកម្ពុជាអំពីទិដ្ឋភាពជាច្រើននៃការគ្រប់គ្រងរបស់វិទ្យាស្ថានជាតិស្ថិតិដែលបានអនុវត្តនៅឆ្នាំ២០១៧ ធាតុផ្សំមួយចំនួននៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ត្រូវបានរាប់បញ្ចូល។ ធាតុផ្សំទាំងនេះគឺ ៖

- បង្កើតផែនការរយៈពេលវែង និងខ្លីសម្រាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា (ភាពងាយរងហានិភ័យទាប បច្ចុប្បន្នត្រូវបានផ្អាកដោយសារខ្វះហិរញ្ញប្បទាន និងធនធាន វិទ្យាស្ថានជាតិស្ថិតិនឹងព្យាយាមអនុវត្ត)
- ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋានដែលអាចគ្រប់គ្រងការបង្កើត ការថែរក្សា និងការប្រើប្រាស់ទិន្នន័យមូលដ្ឋាន និងចៀសវាងការគ្រប់គ្រងលទ្ធផលនៃគម្រោងនីមួយៗនៅក្នុងកុំព្យូទ័រតែមួយ (ភាពងាយរងហានិភ័យមធ្យម មិនទាន់បានអនុវត្តដោយសារលទ្ធភាពថវិកា និងធនធានមនុស្ស)។

[២៧] Super CROSS គឺជាឧបករណ៍កម្មវិធីទាញតារាងទិន្នន័យឥតគិតថ្លៃមួយដែលត្រូវបានប្រើប្រាស់ដោយអ្នកស្ថិតិ សម្រាប់ទាញតារាងទិន្នន័យរួម និងទិន្នន័យខ្វែងពីអង្កេត។

- ថែរក្សាទីតាំងបិទ (off-site) ក្នុងទីកន្លែងសុវត្ថិភាព សំណុំឯកសារទាញយកវិញនៃគ្រប់ទិន្នន័យអង្កេតទាំងអស់ និងទិន្នន័យដំណើរការចុងក្រោយពីអ្នកផ្តល់ជំនួយខុសៗគ្នា (ភាពងាយរងហានិភ័យមធ្យម មិនទាន់បានអនុវត្ត ដោយសារលទ្ធភាពថវិកា និងធនធានមនុស្ស វិទ្យាស្ថានជាតិស្ថិតិនឹងព្យាយាមអនុវត្ត)។
- បង្កើតគោលនយោបាយ និងនីតិវិធីសុវត្ថិភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាផ្លូវការ សម្រាប់ការប្រើប្រាស់មុខងារបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាដែលទាក់ទងនឹងប្រតិបត្តិការប្រចាំថ្ងៃនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ផ្តល់បច្ចេកវិទ្យាដល់មន្ត្រី និងផ្តល់ការបណ្តុះបណ្តាល និងកម្មវិធីការយល់ដឹង។ ភាពងាយរងហានិភ័យទាប (បានអនុវត្តមុនអនុសាសន៍ដែលនឹងបង្កើត ត្រូវការធ្វើបច្ចុប្បន្នកម្មអាស្រ័យលើលទ្ធភាពថវិកា និងធនធានមនុស្ស វិទ្យាស្ថានជាតិស្ថិតិនឹងព្យាយាមអនុវត្ត)។
- បង្កើតឃ្លាំងទិន្នន័យដើម្បីរក្សាទុកទិន្នន័យពីប្រភពច្រើនដែលបានផ្លាស់ប្តូរទៅក្នុងទីតាំងទូទៅមួយ គំរូទិន្នន័យពហុមាត្រសម្រាប់ការស្រាវជ្រាវ និងការវិភាគប្រកបដោយប្រសិទ្ធភាព (ភាពងាយរងហានិភ័យទាប មិនទាន់បានអនុវត្តដោយសារលទ្ធភាពថវិកា និងធនធានមនុស្ស វិទ្យាស្ថានជាតិស្ថិតិនឹងព្យាយាមអនុវត្ត)។

ប្រព័ន្ធរួមនៃការចែករំលែកទិន្នន័យអាចត្រូវបានសម្រួល និងរៀបចំជាផ្លូវការ ជាពិសេសធ្វើឱ្យប្រសើរឡើងនូវការរៀបចំ និងគ្រប់គ្រងទិន្នន័យមូលដ្ឋាន និងអនុញ្ញាតឱ្យមានទំនាក់ទំនងអន្តរទិន្នន័យមូលដ្ឋាន នៅក្នុង/ចំណោមស្ថាប័នទាំងអស់នៃប្រព័ន្ធស្ថិតិជាតិ[២៨]។

## ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល

ជារួម នៅក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលមានការខ្វះខាតសម្ភារៈកុំព្យូទ័រ ដើម្បីទ្រទ្រង់ប្រតិបត្តិការស្ថិតិរបស់ពួកគេ។ កម្រិតនៃសម្ភារៈ និងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាមានភាពខុសគ្នាដែលគួរពិចារណាក្នុងចំណោមក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ពីគួរសមទៅល្អស្ទើរតែមិនមាន។ ឧទាហរណ៍មួយចំនួនគឺ ៖

| ក្រសួង | ស្ថានភាព |
|---|---|
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | គ្មានសម្ភារៈបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាសម្រាប់គាំទ្រដល់ការងារស្ថិតិ |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | កម្មវិធីចាស់ ហួសសម័យ និងមានសមត្ថភាពទាប រួមទាំងកុំព្យូទ័រផ្ទាល់ខ្លួន និងម៉ាស៊ីនបោះពុម្ព ត្រូវការគ្រឿងបរិក្ខា និងកម្មវិធីបន្ថែមទៀត ប្រើប្រាស់កម្មវិធី Excel និង Access ប្រព័ន្ធបច្ចុប្បន្នផ្អែកលើក្រដាស និងការប្រមូលទិន្នន័យដោយសំបុត្រ ឬតេឡេក្រាមដែលធ្វើឱ្យយឺតយ៉ាវ ចង់ប្រើប្រាស់កុំព្យូទ័រតូច (tablet) សម្រាប់ការប្រមូលទិន្នន័យចល័ត ដើម្បីឱ្យការងារលឿនជាងមុន |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | គ្មានកុំព្យូទ័រយួរដៃ គ្មានអ៊ីនធឺណិត គ្មានថវិកា |
| ក្រសួងធម្មការ និងសាសនា | គ្មានកុំព្យូទ័រ អ៊ីនធឺណិតយឺត គ្មានសុវត្ថិភាព |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | មានបញ្ហាជាមួយប្រព័ន្ធបណ្តាញមូលដ្ឋាន (LAN) អ៊ីនធឺណិតគ្មានស្ថេរភាព ការការពារមេរោគទូរស័ព្ទមិនត្រូវបានភ្ជាប់ បានបង្កើត DEVInfo[២៩] តាមតម្រូវការ ដើម្បីបង្កើតទិន្នន័យមូលដ្ឋាន MEFInfo ផ្ទាល់របស់ក្រសួង និងទិន្នន័យមូលដ្ឋានដទៃទៀតកំពុងត្រូវបានបង្កើត |

[២៨] របាយការណ៍វេទិកាជាតិស្តីពីការបង្កើតយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦។

[២៩] DevInfo គឺជាប្រព័ន្ធទិន្នន័យមូលដ្ឋានមួយដែលបង្កើតឡើងក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ និងបានគាំទ្រដោយក្រុមអភិវឌ្ឍន៍អង្គការសហប្រជាជាតិ សម្រាប់តាមដានការអភិវឌ្ឍន៍មនុស្សជាមួយគោលបំណងជាក់លាក់ក្នុងការតាមដានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ DevInfo គឺជាឧបករណ៍មួយសម្រាប់រៀបចំ រក្សាទុក និងបង្ហាញទិន្នន័យតាមរបៀបដូចគ្នា ដើម្បីជួយសម្រួលដល់ការចែករំលែកទិន្នន័យនៅកម្រិតប្រទេស ដោយឆ្លងកាត់នាយកដ្ឋានរដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍។

| ក្រសួង | ស្ថានភាព |
|---|---|
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | គ្មានសម្ភារៈគ្រប់គ្រាន់ក្នុងផ្នែកបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាទាំងផ្នែករឹង និងផ្នែកទន់ គ្មានប្រព័ន្ធវេបសាយ គ្មានម៉ាស៊ីនបម្រើដើម្បីប្រមូលព័ត៌មានបានឆាប់រហ័ស ទម្រង់ធ្វើជាប្រព័ន្ធ ផ្អែកលើក្រដាសសម្រាប់បំពេញមានការយឺតយ៉ាវ ទិន្នន័យមិនត្រូវគ្នា ពិបាកក្នុងការត្រួតពិនិត្យ មន្ត្រីមិនសូវដឹងពីបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រើប្រាស់កម្មវិធី Excel ការទំនាក់ទំនងជាមួយខេត្តគឺតាមរយៈអ៊ីមែល និងក្រដាស |
| ក្រសួងពាណិជ្ជកម្ម | មានភាពយុត្តិធម៌ក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ការចុះបញ្ជីអនឡាញសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម សញ្ញាពាណិជ្ជកម្ម និងវិញ្ញាបនបត្រដើម នឹងស្ថាបនាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាសម្រាប់ផលិតស្ថិតិអំពីអាជីវកម្ម និងការវិនិយោគ |
| ក្រសួងអប់រំ យុវជន និងកីឡា | មានប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យមូលដ្ឋាន វាបង្កើតស្ថិតិក្នុង Excel និងចម្លងចូលថាសស៊ីឌី |
| ក្រសួងមហាផ្ទៃ | មូលដ្ឋានទិន្នន័យកំពុងត្រូវបានបង្កើតឡើង ដើម្បីធ្វើសមកាលកម្មរវាងខេត្ត និងក្រសួង ប្រើប្រាស់កម្មវិធី Excel និងផ្ញើទិន្នន័យតាមអ៊ីមែល |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | គ្មានទិន្នន័យមូលដ្ឋាន កុំព្យូទ័រ អ៊ីនធឺណិត និងគ្រឿងបរិក្ខាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា |
| ក្រសួងកិច្ចការនារី | គ្មានប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាន (DBMS) ម៉ាស៊ីនបម្រើ ផ្នែកទន់ ការការពារមេរោគ ការថែទាំ |
| ក្រសួងអភិវឌ្ឍន៍ជនបទ | មិនទាន់មានគ្រឿងបរិក្ខា ប្រើប្រាស់អ៊ីមែល តេឡេក្រាម និងរបាយការណ៍សម្រាប់ទំនាក់ទំនងទិន្នន័យ |
| ធនាគារជាតិនៃកម្ពុជា | ការគាំទ្រទាំងអស់ដោយនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ថ្នាក់គ្រប់គ្រងមានកុំព្យូទ័រយួរដៃ និងស្មាតហ្វូន ដើម្បីសម្រួលដល់ការងារបន្ទាន់ និងសកម្មភាពចាត់តាំងផ្សេងៗ |

### ២.៣.៦ ការផ្សព្វផ្សាយ និងការគាំទ្រ

ជារួម ការរីកចម្រើនត្រូវបានសម្រេចដោយផ្អែកលើទិន្នន័យដែលអាចរកបាននៅក្នុងប្រព័ន្ធស្ថិតិជាតិ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ កម្រិតដ៏ធំទូលាយនៃទិន្នន័យអាចរកបាននៅក្នុងប្រព័ន្ធស្ថិតិ សម្រាប់បំពេញតម្រូវការអ្នកប្រើប្រាស់ជាមូលដ្ឋាន ដែលភាគច្រើនត្រូវបានដាក់នៅវិទ្យាស្ថានជាតិស្ថិតិ។ ទោះបីមានមធ្យោបាយផ្សព្វផ្សាយទិន្នន័យក៏ដោយ ក៏ការប្រើប្រាស់ស្ថិតិនៅកម្ពុជានៅមានកម្រិត និងការចូលប្រើប្រាស់មានការលំបាក។ ធនធានដែលមាន និងស្ថិតិទាន់សម័យមិនងាយស្រួលចូលប្រើប្រាស់ដោយអ្នកប្រើប្រាស់ទិន្នន័យសំខាន់ៗ ដូចជាក្រុមហ៊ុនអាជីវកម្ម ភ្នាក់ងារស្រាវជ្រាវ ក្រុមជំនាញការ និងសាធារណជនទូទៅ។

### វិទ្យាស្ថានជាតិស្ថិតិ

មិនទាន់បានធ្វើឱ្យទាន់សម័យនូវគោលនយោបាយផ្សព្វផ្សាយទិន្នន័យនៅកម្ពុជាឡើយ។ “គោលនយោបាយផ្សព្វផ្សាយ និងថ្លៃ” បានរៀបចំឡើងនៅឆ្នាំ២០០២ ដោយមានជំនួយទីប្រឹក្សានៃអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប៉ុន្តែគោលនយោបាយនេះត្រូវបានដំណើរការតែមួយផ្នែកប៉ុណ្ណោះ ហើយត្រូវធ្វើបច្ចុប្បន្នកម្មឱ្យសមស្របនឹងស្ថានភាពបច្ចុប្បន្ននៅក្នុងប្រព័ន្ធស្ថិតិជាតិ។ នាយកដ្ឋាននីមួយៗនៅវិទ្យាស្ថានជាតិស្ថិតិត្រូវទទួលខុសត្រូវដោយការពិចារណាសម្រាប់ការផ្សព្វផ្សាយ និងការគាំទ្រទិន្នន័យរបស់ខ្លួនឯង។ វិទ្យាស្ថានជាតិស្ថិតិចេញសេចក្តីប្រកាសព័ត៌មាន (press release) ទាំងតាមការបោះពុម្ព និងអនឡាញ ដើម្បីប្រកាសពីលទ្ធភាពថ្មីនៃអង្កេត ឬជំរឿន ឬដើម្បីជូនដំណឹងអំពីព្រឹត្តិការណ៍សំខាន់ៗ។ ទោះបីជាយ៉ាងណាក៏ដោយ សេចក្តីប្រកាសព័ត៌មានកម្រនឹងមានការ

វិភាគទិន្នន័យ ដូច្នេះមហាជនមិនចាប់អារម្មណ៍ខ្លាំងពីប្រព័ន្ធផ្សព្វផ្សាយឡើយ។ ការធ្វើសិក្ខាសាលាក៏ត្រូវបានរៀបចំសម្រាប់ទិន្នន័យថ្មីៗ អ្នកសារព័ត៌មានចូលរួម ហើយរាយការណ៍ជាបន្តបន្ទាប់នៅលើប្រព័ន្ធផ្សព្វផ្សាយរបស់ពួកគេ (សារព័ត៌មាន វិទ្យុ ទូរទស្សន៍)។ ប្រព័ន្ធផ្សព្វផ្សាយសង្គមក៏ត្រូវបានប្រើប្រាស់ដោយវិទ្យាស្ថានជាតិស្ថិតិផងដែរ ទំព័រហ្វេសប៊ុករបស់វិទ្យាស្ថានជាតិស្ថិតិ បង្ហាញពីព្រឹត្តិការណ៍នៃវិទ្យាស្ថានជាតិស្ថិតិ ដូចជាការប្រជុំជាដើម។

ការផ្សព្វផ្សាយទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិតាមរយៈការបោះពុម្ពផ្សាយ ព្រឹត្តិប័ត្រ សន្លឹកប័ណ្ណ ថាសស៊ីឌី សេចក្តីប្រកាសព័ត៌មានតាមអនឡាញយូរៗម្តង អ៊ីមែល និងនៅលើវេបសាយរបស់វិទ្យាស្ថានជាតិស្ថិតិ។ ក្រុមចល័តត្រូវបានបញ្ជូនទៅខេត្តនានា ដើម្បីផ្សព្វផ្សាយព្រឹត្តិការណ៍ស្ថិតិសំខាន់ៗ ដូចជាជំរឿន អង្កេតសំខាន់ៗ (អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា អង្កេតចន្លោះជំរឿនប្រជាជនកម្ពុជា)។ សំណុំទិន្នន័យសំខាន់ៗជាច្រើនអាចមានតែនៅក្នុងសៀវភៅបោះពុម្ពផ្សាយប៉ុណ្ណោះ។ នេះបានដាក់កំហិតយ៉ាងខ្លាំងដល់អ្នកប្រើប្រាស់ក្នុងការទទួលបានទិន្នន័យ (រួមទាំងអ្នកប្រើប្រាស់នៅក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផងដែរ)។

វិទ្យាស្ថានជាតិស្ថិតិគ្រប់គ្រងប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo)។ បច្ចុប្បន្ន[៣០] CAMInfo ត្រូវបានធ្វើបច្ចុប្បន្នកម្មជាមួយទិន្នន័យសម្រាប់ ៦៥៥ សូចនាករ ដែលចំណាត់ថ្នាក់ជាវិស័យ និងគោលដៅអភិវឌ្ឍន៍ រួមមានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍/គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សូចនាករស្នូល និងបន្ថែមសម្រាប់ការតាមដាន និងវាយតម្លៃ។

មីក្រូទិន្នន័យពីអង្កេតត្រូវបានផ្សព្វផ្សាយ តាមរយៈប័ណ្ណសារទិន្នន័យជាតិ (NADA)[៣១] ។

វិទ្យាស្ថានជាតិស្ថិតិរក្សាវេបសាយ[៣២] ដែលបង្ហាញទិន្នន័យស្ថិតិ ក៏ដូចជាព័ត៌មានអំពីវិទ្យាស្ថានជាតិស្ថិតិ។ បច្ចុប្បន្ន វេបសាយមិនទាន់បានរចនា និងដំណើរការបានល្អប្រសើរដើម្បីបម្រើដល់អ្នកប្រើប្រាស់ឡើយ។ វាផ្តល់ជូននូវរបាយការណ៍ជំរឿននានា និងអង្កេតសំខាន់ៗ និងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ គណនេយ្យជាតិ និងសៀវភៅស្ថិតិប្រចាំឆ្នាំចុងក្រោយ។ វាផ្តល់បញ្ជាប់ទៅប័ណ្ណសារទិន្នន័យជាតិ (NADA)។ វាផ្តល់បញ្ជាប់ទៅប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo) ប៉ុន្តែបញ្ជាប់គ្មានដំណើរការឡើយ។ វាផ្តល់បញ្ជាប់ទៅបណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលដែលចងក្រងស្ថិតិ ប៉ុន្តែបញ្ជាប់មិនដំណើរការឡើយ។ វេបសាយនេះមិនបានធ្វើបច្ចុប្បន្នកម្មជាទៀងទាត់ឡើយ។ វាគ្មានប្រព័ន្ធផ្លូវការសម្រាប់តាមដានការប្រើប្រាស់ស្ថិតិឡើយ ទោះបីចុចលើទំព័រមេនីមួយៗនៃវេបសាយវិទ្យាស្ថានជាតិស្ថិតិក៏ដោយ ក៏មិនត្រូវបានរាប់ឡើយ។ វេបសាយមិនផ្តល់ឱ្យអ្នកប្រើប្រាស់ផ្តល់អនុសាសន៍/សំណួរតាមអនឡាញ (ប៉ុន្តែអនុសាសន៍/សំណួរតាមអ៊ីមែល ទូរស័ព្ទ ឬលិខិតត្រូវបានស្វាគមន៍)។

មជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិកំពុងដំណើរការ ដែលសម្រួលដល់ការផ្សព្វផ្សាយស្ថិតិផ្លូវការ រួមបញ្ចូលទាំងស្ថិតិផលិតដោយវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលដល់អ្នកប្រើប្រាស់ទិន្នន័យ និងសាធារណជន។ គ្មានកំណត់ត្រាជាផ្លូវការនៃការប្រើប្រាស់របស់មជ្ឈមណ្ឌលត្រូវបានរក្សាទុកឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងនៃការប្រើប្រាស់សេវាកម្មមជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិត្រូវបានសង្កេតដោយមន្ត្រីវិទ្យា

---

[៣០] កំណត់ហេតុនៃគណៈកម្មាធិការសម្របសម្រួលស្ថិតិ ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៧។

[៣១] http://nada-nis.gov.kh/index.php/home NADA គឺជាប្រព័ន្ធទុកដាក់តាមវេបសាយអំពីទិន្នន័យអង្កេតដែលបានបង្កើតដោយវិទ្យាស្ថានជាតិស្ថិតិនៅកម្ពុជា។ វាត្រូវបានបង្កើតឡើង ដើម្បីអភិរក្ស ប្រមូលទុកតាមប្រព័ន្ធ និងទាញយកទិន្នន័យស្ថិតិ រួមទាំងកំណត់ត្រាអង្កេត និងវិធីសាស្ត្រ ទស្សនទាន និងម៉េតាទិន្នន័យផ្សេងៗរបស់វា។

[៣២] www.nis.gov.kh

ស្ថានជាតិស្ថិតិ។ មជ្ឈមណ្ឌលគួរតែរក្សាទុកកំណត់ត្រាភ្ញៀវទៅកាន់មជ្ឈមណ្ឌល និងប្រភេទនៃការប្រើប្រាស់ និងការស្នើសុំ។ ភាគច្រើននៃអ្នកប្រើប្រាស់ដែលបានពិគ្រោះយោបល់ក្នុងអំឡុងពេលវាយតម្លៃ មិនបានដឹងថាមានមជ្ឈមណ្ឌល ហើយភាគច្រើនពឹងផ្អែកតែលើវេបសាយវិទ្យាស្ថានជាតិស្ថិតិ ដើម្បីពិនិត្យមើលព័ត៌មានទិន្នន័យដែលបានធ្វើបច្ចុប្បន្នកម្មចុងក្រោយបំផុត។

វិទ្យាស្ថានជាតិស្ថិតិចេញផ្សាយទិន្នន័យជាច្រើន ប៉ុន្តែក្នុងករណីភាគច្រើនវាមិនត្រូវបានធ្វើតាមការវិភាគសមស្របឡើយ។ កិច្ចខិតខំប្រឹងប្រែងមួយចំនួនត្រូវបានអនុវត្ត ដោយចាប់ផ្តើមសរសេរការវិភាគសម្រាប់លទ្ធផលឆ្នាំ២០១៤ នៃអង្កេតសេដ្ឋកិច្ច សង្គមសេដ្ឋកិច្ចកម្ពុជា ដោយមានការចូលរួមពីអ្នកពិគ្រោះយោបល់ពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA)។

កម្ពុជាបានយល់ព្រមទទួលប្រព័ន្ធផ្សព្វផ្សាយទិន្នន័យទូទៅ (GDDS)[៣៣] របស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។ កម្ពុជាអនុលោមទៅតាមអនុសាសន៍របស់ប្រព័ន្ធផ្សព្វផ្សាយទិន្នន័យទូទៅ (GDDS) លើការផ្សព្វផ្សាយតាមពេលកំណត់ និងទាន់ពេលវេលា។ ធាតុចូលសម្រាប់កម្ពុជាលើវេបសាយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) មានលក្ខណៈហួសសម័យខ្លាំង (ខែសីហា ឆ្នាំ២០០៧)។

គោលនយោបាយមួយត្រូវបានអនុវត្ត សម្រាប់ការផ្សព្វផ្សាយមីក្រូទិន្នន័យ[៣៤]។ ការទទួលបានគឺធ្វើតាមរយៈការស្នើសុំ និងត្រូវបានផ្តល់ជូនតែអ្នកប្រើប្រាស់ទិន្នន័យ/អ្នកស្រាវជ្រាវដែលជាទីភ្នាក់ងារគាំទ្របានចុះបញ្ជីស្របច្បាប់ (សាកលវិទ្យាល័យ ក្រុមហ៊ុន មជ្ឈមណ្ឌលស្រាវជ្រាវ អង្គការជាតិ ឬអន្តរជាតិ។ល។)។ មានលក្ខខណ្ឌមួយចំនួនដែលអ្នកប្រើប្រាស់ត្រូវតែគោរពតាម ដើម្បីទទួលបានដំណើរការ។ អ្នកប្រើប្រាស់ដែលមានការអនុញ្ញាតតម្រូវឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលបានមីក្រូទិន្នន័យស្របច្បាប់។

## ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល

សម្រាប់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ច្រកសម្រាប់ការផ្សព្វផ្សាយទិន្នន័យមានលក្ខណៈខុសៗគ្នា ហើយមិនត្រូវបានបញ្ជាប់ក្នុងប្រព័ន្ធជាប់ទាក់ទងគ្នាឡើយ។ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលបោះពុម្ពផ្សាយសៀវភៅស្ថិតិ សន្លឹកប័ណ្ណ ថាសស៊ីឌី និងការប្រើប្រាស់ហ្វេសប៊ុក។ ស្ថិតិត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលមួយចំនួនដាក់ស្ថិតិនៅលើវេបសាយរបស់ខ្លួន ប៉ុន្តែរបៀបនៃការផ្សព្វផ្សាយនេះមិនត្រូវបានប្រើប្រាស់ទូលំទូលាយឡើយ។ ការផ្សព្វផ្សាយក៏ត្រូវបានធ្វើឡើង តាមរយៈមជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិនៃវិទ្យាស្ថានជាតិស្ថិតិ។ បញ្ជាប់តាមរយៈវេបសាយវិទ្យាស្ថានជាតិស្ថិតិដូចបានពិពណ៌នាខាងលើ ក៏ផ្តល់នូវច្រកមួយ (សក្តានុពល) សម្រាប់ការផ្សព្វផ្សាយផងដែរ។

---

[៣៣] http://dsbb.imf.org/Pages/GDDS/CtyCtgList.aspx?ctycode=KHM

[៣៤] http://nada-nis.gov.kh/index.php/policies-and-procedures

## ការទទួលបាន និងការប្រើប្រាស់ទិន្នន័យ

ជាទូទៅ ការចូលរួមរបស់អ្នកប្រើប្រាស់ទិន្នន័យនៅខ្សោយ និងគ្មានយន្តការស្ថាប័នសម្រាប់ការផ្ដល់មតិយោបល់របស់អ្នកប្រើប្រាស់ជាទៀងទាត់ លើលទ្ធផលស្ថិតិ ផលិតផល និងសេវាកម្មស្ថិតិនៅក្នុងប្រព័ន្ធស្ថិតិជាតិ។

មានការពិគ្រោះយោបល់តិចតួចជាមួយអ្នកប្រើប្រាស់ទិន្នន័យនៅក្រៅរដ្ឋាភិបាល រួមមានអ្នកមកពីបណ្ឌិតសភា ប្រព័ន្ធផ្សព្វផ្សាយ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ឬសាធារណជនទូទៅ។ វេទិកាជាតិលើកទីមួយស្ដីពីការគាំទ្រដើម្បីស្ថិតិ - http://www.paris21.org/node/1661 – វេទិកាអ្នកប្រើប្រាស់ និងអ្នកផលិតទិន្នន័យដែលរៀបចំដោយក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ និងអង្គការភាពជាដៃគូក្នុងស្ថិតិសម្រាប់ការអភិវឌ្ឍក្នុងសតវត្សរ៍ទី២១ (PARIS21) បានប្រារព្ធធ្វើឡើងនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ មានអ្នកប្រើប្រាស់ជាង ១០០ នាក់ និងអ្នកផលិតមកពីរាជរដ្ឋាភិបាល វិស័យឯកជន បណ្ឌិតសភា សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយបានជួបជុំគ្នា ដើម្បីពិភាក្សាអំពីបញ្ហាស្ថិតិ។ មានការពេញចិត្តយ៉ាងខ្លាំងពីភាគីពាក់ពន្ធ័ដែលបានចូលរួម (វិស័យឯកជន /អាជីវកម្ម អ្នកតំណាងរាស្ត្រ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយ) ហើយពួកគេបានយល់ស្របលើតម្រូវសម្រាប់ការចូលរួមបន្ត ដើម្បីពិភាក្សាលើបញ្ហាស្ថិតិ និងសារៈសំខាន់របស់វានៅក្នុងអភិបាលកិច្ច និងសង្គម[៣៥] ។

## ការគាំទ្រ

ការបោះពុម្ពផ្សាយ សេចក្ដីប្រកាសព័ត៌មាន (press release) និងវេបសាយផ្ដល់ព័ត៌មានអំពីលទ្ធផលជំរឿន ឬអង្កេតថ្មីៗ ក៏ដូចជាព័ត៌មានស្ដីពីវឌ្ឍនភាពនៃគម្រោងកំពុងដំណើរការ ឬការប្រតិបត្តិស្ថិតិសំខាន់ៗ ធ្វើដូច្នេះវាផ្ដល់នូវមធ្យោបាយមួយនៃការគាំទ្រស្ថិតិសម្រាប់ប្រព័ន្ធស្ថិតិជាតិ ប៉ុន្តែប្រព័ន្ធស្ថិតិជាតិគ្មានកម្មវិធីគាំទ្រស្ថិតិសកម្មឡើយ។ សកម្មភាពនានាជុំវិញការប្រារព្ធទិវាស្ថិតិ (សារពីនាយករដ្ឋមន្ត្រី សៀវភៅតូច ផ្ទាំងរូបភាព ពាក្យស្លោក និងបាវចនា) ផ្ដល់នូវកញ្ចប់គាំទ្រជាវិជ្ជមាន។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានលើកឡើងអំពីសារៈសំខាន់នៃការអភិវឌ្ឍសមត្ថភាពស្ថិតិនៅគ្រប់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ប៉ុន្តែមិនបានអំពាវនាវឱ្យមានប្រព័ន្ធស្ថិតិជាតិមួយរឹងមាំ ក្រោមការដឹកនាំរបស់វិទ្យាស្ថានជាតិស្ថិតិឡើយ។

មតិយោបល់របស់អ្នកប្រើប្រាស់ត្រូវបានផ្ដល់ឱ្យ និងកត់សម្គាល់ពីពេលមួយទៅពេលមួយលើលទ្ធផលជំរឿន និងបានដាក់បញ្ចូលទៅក្នុងការត្រួតពិនិត្យគុណភាពនៃជំរឿនប្រជាជន និងសេដ្ឋកិច្ច។ អ្នកប្រើប្រាស់ដែលត្រូវបានពិគ្រោះយោបល់បាននិយាយថា ពួកគេមិនបានដឹងអំពីភាពខុសគ្នា/ការប៉ះទង្គិចគ្នារវាងតួលេខដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ និងអ្នកផលិតផ្សេងទៀត។ មន្ត្រីវិទ្យាស្ថានជាតិស្ថិតិបានបង្ហាញពីភាពខុសគ្នានៃស្ថិតិប្រជាជនពីប្រភពផ្សេងៗគ្នា ដូចជាវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងមហាផ្ទៃ។ ធនាគារជាតិនៃកម្ពុជាបានរាយការណ៍ពីភាពខុសគ្នារវាងតួលេខរបស់ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិស្ដីពីការនាំចូល និងការនាំចេញ។

ក្រុមអ្នកប្រើប្រាស់ដែលត្រូវបានពិគ្រោះយោបល់ ពួកគេ ៖

[៣៥] សូមមើលរបាយការណ៍នៃវេទិកានៅ http://www.paris21.org/newsletter/fall2013/user-producer-dialogueshttp://www.paris21.org/newsletter/fall2013/user-producer-dialogues

១. បានពិពណ៌នាខ្លួនឯងថាបានប្រើប្រាស់ស្ថិតិជាញឹកញាប់ ឬពីពេលមួយទៅពេលមួយ
២. បានពិពណ៌នាទូលំទូលាយអំពីភាពអាចរកបាន គុណភាព និងទាន់ពេលវេលានៃស្ថិតិនៅកម្ពុជាដែលមានភាពប្រសើរឡើង និង
៣. បានថ្លែងថាពួកគេជឿទុកចិត្តមួយផ្នែក (បើប្រៀបធៀបទៅនឹងការជឿទុកចិត្តពេញលេញ) និងពេញចិត្តមួយផ្នែក (បើប្រៀបធៀបទៅនឹងការពេញចិត្តខ្លាំង) រួមគ្នាដោយស្ថិតិផ្លូវការ។

ចាំបាច់ត្រូវការសន្ទនាជាទៀងទាត់ និងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងនេះ ដើម្បីទទួលបានមតិយោបល់ និងទស្សនវិស័យរបស់ពួកគេអំពីលទ្ធផល និងសេវាកម្មស្ថិតិដែលបានផលិតនៅក្នុងប្រព័ន្ធស្ថិតិជាតិ។

### ២.៣.៧ ការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ

កម្រិតខ្ពស់នៃវិមជ្ឈការរបស់ប្រព័ន្ធស្ថិតិជាតិធ្វើឱ្យមានការសម្របសម្រួលមួយ ក្នុងចំណោមបញ្ហាប្រឈមសំខាន់ៗសម្រាប់វិទ្យាស្ថានជាតិស្ថិតិ សម្រាប់ការងារស្ថិតិ និងការអភិវឌ្ឍជាទូទៅ ហើយជាពិសេសសម្រាប់ការចងក្រងសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ របាយការណ៍ពាក់កណ្តាលអាណត្តិបានកត់សម្គាល់ថា មានតម្រូវការកែលម្អការសម្របសម្រួលការផលិតទិន្នន័យស្ថិតិនៅតាមបណ្តាក្រសួង និងរាជរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ខេត្ត។

## ច្បាប់ស្តីពីស្ថិតិ/អនុក្រឹត្យ

ច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យមានចំណុចសំខាន់ៗជាច្រើនដែលអាចជួយដល់ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពគឺ ៖

ច្បាប់ស្តីពីស្ថិតិបានផ្តល់នូវជំពូកពេញលេញមួយទាក់ទងនឹងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ (ជំពូក៤ មាត្រា១៤ ដល់ ១៩)។ វាផ្តល់នូវការទទួលខុសត្រូវរបស់វិទ្យាស្ថានជាតិស្ថិតិ ក្នុងការកសាងគោលនយោបាយក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ការទទួលខុសត្រូវសម្រាប់ការសម្របសម្រួលទាក់ទងនឹងការគ្រប់គ្រងប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃប្រព័ន្ធស្ថិតិជាតិ ការអភិវឌ្ឍស្ថិតិ រួមមានការបណ្តុះបណ្តាល ការរៀបចំជាមួយអង្គការអន្តរជាតិ និងស្ថាប័នដទៃទៀត និងបទដ្ឋានស្ថិតិជាតិទាក់ទងនឹងចំណាត់ថ្នាក់ ទស្សនទាន និយមន័យ និងអង្គពិនិត្យពិចារណាស្ថិតិ។ ជំពូកនេះបានបង្កើតក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ តម្រូវឱ្យអង្គភាពស្ថិតិដែលបានចាត់តាំងបង្កើតអង្គភាពស្ថិតិ ផ្តល់ឱ្យអគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិមានឋានៈជាប្រធានមន្ត្រីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា ហើយតម្រូវឱ្យអង្គភាពស្ថិតិដែលបានចាត់តាំងផ្ញើទិន្នន័យស្ថិតិដែលពួកគេផលិតទៅវិទ្យាស្ថានជាតិស្ថិតិ។

អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំងតម្រូវឱ្យ ៖ (i) អង្គភាពស្ថិតិដែលបានចាត់តាំងត្រូវចុះបញ្ជីការប្រមូលទិន្នន័យរដ្ឋបាល ជំរឿន និងអង្កេតរបស់ខ្លួនជាមួយវិទ្យាស្ថានជាតិស្ថិតិ និងរក្សាទុកបញ្ជីធ្វើបច្ចុប្បន្នកម្ម (មាត្រា៨) (ii) ក្រសួងផែនការត្រូវពិនិត្យឡើងវិញនូវផែនការសម្រាប់ការប្រមូលទិន្នន័យរដ្ឋបាល និងជំរឿន និងអង្កេត និងលុបបំបាត់ការជាន់គ្នា (មាត្រា៩) (iii) ក្រសួងផែនការត្រូវបញ្ជូនបញ្ជីនៃរាល់ការប្រមូលទិន្នន័យរដ្ឋបាល

ជំរឿន និងអង្កេតដែលមានស្រាប់ទៅទីស្តីការគណៈរដ្ឋមន្ត្រី និងធ្វើបច្ចុប្បន្នកម្មវាជារៀងរាល់ឆ្នាំ ដើម្បីបញ្ចូលការប្រមូលថ្មី (មាត្រា១០) (iv) អង្គភាពស្ថិតិដែលបានចាត់តាំងត្រូវបញ្ជូនរាល់ព័ត៌មាន និងទិន្នន័យស្ថិតិទាំងអស់ដែលបានផលិតជាទម្រង់អេឡិចត្រូនិក និងជាសៀវភៅទៅវិទ្យាស្ថានជាតិស្ថិតិ (មាត្រា១១) និង (v) វិទ្យាស្ថានជាតិស្ថិតិត្រូវបង្កើត និងរក្សាទុកបញ្ជីឈ្មោះប្រភពទិន្នន័យរដ្ឋបាល និងស្ថិតិ និងបញ្ជីឈ្មោះម៉េតាទិន្នន័យ (មាត្រា១២)។ ទោះជាយ៉ាងណាក៏ដោយ តម្រូវការទាំងនេះមិនត្រូវបានអនុវត្តឡើយ។

អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិបានកំណត់តួនាទីរបស់ក្រុមប្រឹក្សាស្ថិតិ (មាត្រា១៣-១៦) និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ (មាត្រា១៧-២១) រួមទាំងតួនាទីរបស់ពួកគេលើការសម្របសម្រួលផងដែរ។

ការសម្របសម្រួលត្រូវបានអនុវត្តភាគច្រើន តាមរយៈក្រុមប្រឹក្សាស្ថិតិ (កិច្ចប្រជុំចុងក្រោយបំផុតនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧) គណៈកម្មាធិការសម្របសម្រួលស្ថិតិ (កិច្ចប្រជុំចុងក្រោយបំផុតនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧) និងអនុក្រុមបច្ចេកទេសនៃក្រុមការងារបច្ចេកទេស ផែនការ និងកាត់បន្ថយភាពក្រីក្រ (TWG-PPR) ស្តីពីទិន្នន័យសម្រាប់ការអភិវឌ្ឍ (កិច្ចប្រជុំចុងក្រោយបំផុតនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨)។ វិទ្យាស្ថានជាតិស្ថិតិជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាស្ថិតិ។ អគ្គនាយកនៃវិទ្យាស្ថានជាតិស្ថិតិជាប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ ហើយដូច្នេះមានលទ្ធភាពទទួលបានពីក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលទាំងអស់នៅតាមកម្រិតសមស្របក្នុងនាមជាសមាជិកគណៈកម្មាធិការ។ ក៏មានកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកប្រើប្រាស់ទិន្នន័យ/ភាគីពាក់ព័ន្ធ/ដៃគូអភិវឌ្ឍន៍សម្រាប់ជំរឿន និងអង្កេតនីមួយៗដែលធ្វើដោយវិទ្យាស្ថានជាតិស្ថិតិ ឧទាហរណ៍ ដំណើរការថ្មីៗចុងក្រោយបំផុតគឺថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៨ ស្តីពីជំរឿនទូទៅប្រជាជន ឆ្នាំ២០១៩។ កិច្ចប្រជុំដទៃទៀតជាមួយស្ថាប័នរបស់ប្រព័ន្ធស្ថិតិជាតិ ត្រូវបានធ្វើឡើងនៅពេលចាំបាច់។ វិទ្យាស្ថានជាតិស្ថិតិផលិតរបាយការណ៍ប្រចាំឆ្នាំស្តីពីប្រព័ន្ធស្ថិតិជាតិ។

មន្ត្រីជាន់ខ្ពស់នៃវិទ្យាស្ថានជាតិស្ថិតិបានវាយតម្លៃអំពីប្រសិទ្ធភាពនៃការសម្របសម្រួល នៅចន្លោះកម្រិតល្អ និងគ្រប់គ្រាន់។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅតែមានភាពខ្សោយក្នុងការសម្របសម្រួលការងារស្ថិតិនៅក្នុងប្រព័ន្ធស្ថិតិជាតិ ឧទាហរណ៍ ក្នុងការសម្របសម្រួលនៃការអនុវត្តបទដ្ឋានស្ថិតិ និងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ការវាយតម្លៃ និងការតាមដានការត្រួតជាន់គ្នាក្នុងការប្រមូលទិន្នន័យរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល នៅមិនទាន់ត្រូវបានអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិឡើយ។

ចំនួនទិន្នន័យសំខាន់ៗត្រូវបានចែករំលែកក្នុងចំណោមស្ថាប័ននានានៅក្នុងប្រព័ន្ធស្ថិតិជាតិ ដោយឈរលើមូលដ្ឋានច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យ[៣៦]។ វិទ្យាស្ថានជាតិស្ថិតិចាត់ទុកថាការអនុវត្តន៍នៅនឹងកន្លែង វាផ្តល់នូវលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានទិន្នន័យដែលត្រូវការ។ ទោះជាយ៉ាងណាក៏ដោយ ការបញ្ជូនទិន្នន័យនៅមិនទាន់ពេលវេលា និងផលប៉ះពាល់មិនល្អដល់ការផលិតលទ្ធផលស្ថិតិរបស់វិទ្យាស្ថានជាតិស្ថិតិ ឧទាហរណ៍ សៀវភៅស្ថិតិប្រចាំឆ្នាំ និងគណនេយ្យជាតិ។ ការបង្កើតអនុស្សរណៈនៃការយោគយល់ (MOU) រវាងវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលនីមួយៗនឹងធ្វើឱ្យប្រសើរឡើងនូវការចែករំលែកទិន្នន័យ។

---

៣៦ ប្រភពដ៏មានសក្តានុពលនៃទិន្នន័យប្រជាជន គឺជាទិន្នន័យមូលដ្ឋានប្រជាជនដែលគ្រប់គ្រងដោយនាយកដ្ឋានស្ថិតិប្រជាជនដែលទើបបង្កើតថ្មី ស្ថិតនៅក្រោមក្រសួងមហាផ្ទៃ។ មន្ត្រីនៃនាយកដ្ឋានជឿជាក់ថា បច្ចុប្បន្នពួកគេមានទិន្នន័យពី ៨០% ទៅ ៩០% នៃប្រជាជន។

កំណត់ត្រារដ្ឋបាល/ស្ថិតិបន្ថែមដែលមានប្រយោជន៍ដល់វិទ្យាស្ថានជាតិស្ថិតិត្រូវបានបង្ហាញ ៖ ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ (CDB) ស្ថិតិចុះបញ្ជីស៊ីវិល និងអត្រានុកូលដ្ឋានពីក្រសួងមហាផ្ទៃ និងទិន្នន័យមូលដ្ឋានប្រជាជនផ្អែកលើអត្តសញ្ញាណប័ណ្ណ។

ការរៀបចំចាត់ចែងសម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង ក៏រារាំងដល់ការសម្របសម្រួលរបស់ប្រព័ន្ធស្ថិតិជាតិដូចវិទ្យាស្ថានជាតិស្ថិតិផងដែរ ដែលក្នុងរាល់ករណីទាំងអស់មិនមានអ្នកទំនាក់ទំនងតែមួយនៅតាមក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល និងត្រូវធ្វើអន្តរកម្មជាមួយអង្គភាពផ្សេងៗ ដើម្បីទទួលបានទិន្នន័យដែលបានចាត់តាំង ឬដើម្បីពិភាក្សា/បញ្ជាក់មេតាទិន្នន័យ និងបញ្ហាផ្សេងទៀត។

### ២.៣.៨ ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍

ដៃគូអភិវឌ្ឍន៍បានគាំទ្រសកម្មភាពស្ថិតិសំខាន់ៗក៏ដូចជាការកសាងសមត្ថភាពស្ថិតិ និងការបង្កើនគុណភាពនៅក្នុងដំណើរការស្ថិតិ និងលទ្ធផលនៅក្នុងប្រព័ន្ធស្ថិតិជាតិ។ ពួកគេបានធានានូវការប្រើប្រាស់បទដ្ឋាន ចំណាត់ថ្នាក់ និងក្របខ័ណ្ឌវិធីសាស្ត្រអន្តរជាតិ ក្នុងគម្រោង/អង្កេតដែលពួកគេបានចូលរួម។

ប្រព័ន្ធស្ថិតិជាតិមានប្រវត្តិយូរអង្វែងនៃភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍។ ក្នុងចំណោមអង្គការអន្តរជាតិដំបូងដែលផ្តល់ជំនួយបច្ចេកទេសទូលំទូលាយ រួមមានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។ ស្ថាប័នតំបន់ដទៃទៀត (អាស៊ាន គណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (ESCAP) និងវិទ្យាស្ថានស្ថិតិសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (SIAP)) បានរួមចំណែកយ៉ាងសំខាន់។ ទីភ្នាក់ងារអន្តរជាតិដទៃទៀត ដូចជាអង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ (FAO) ភាពជាដៃគូក្នុងស្ថិតិសម្រាប់ការអភិវឌ្ឍក្នុងសតវត្សរ៍ទី២១ (PARIS 21) មូលនិធិប្រជាជនសហប្រជាជាតិ (UNFPA) មូលនិធិកុមារសហប្រជាជាតិ (UNICEF) ធនាគារពិភពលោក (WB) និងទីភ្នាក់ងារជាតិ ដូចជាទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ/រដ្ឋាភិបាលអូស្ត្រាលី រដ្ឋាភិបាលជប៉ុន និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA) នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស (DFID) ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងមជ្ឈមណ្ឌលពិនិត្យ និងការពារជម្ងឺសហរដ្ឋអាមេរិក/កម្មវិធីហ៊ីវ/អេដស៍សកល) និងចំណោមដទៃទៀតក៏បានផ្តល់ការគាំទ្រដល់ទំនាក់ទំនងស្ថិតិទូទៅ វិស័យស្ថិតិពិសេស ការធ្វើជំរឿន និងអង្កេត ការផ្តួចផ្តើមកសាងសមត្ថភាពមនុស្ស និងស្ថាប័ន និងសកម្មភាពអភិវឌ្ឍន៍ស្ថិតិដទៃទៀត និងផែនការយុទ្ធសាស្ត្រ។

ក្រុមប្រឹក្សាស្ថិតិមានការទទួលខុសត្រូវក្នុងការផ្តល់ប្រឹក្សាដល់ក្រសួងផែនការ អំពីអាទិភាពស្ថិតិនៃវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង (ក្រោមអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ (មាត្រា១៦))។ ទោះជាយ៉ាងណាក៏ដោយ ដៃគូអភិវឌ្ឍន៍នៅតែរួមចំណែកដ៏សំខាន់ក្នុងការផ្តល់ថវិកាដល់សកម្មភាពស្ថិតិសំខាន់ៗនៅកម្ពុជា និងការទិញគ្រឿងបរិក្ខាដើម្បីគាំទ្រដល់ប្រតិបត្តិការស្ថិតិ។ ដូច្នេះ អាទិភាពស្ថិតិជាច្រើនត្រូវបានជះឥទ្ធិពលដោយលទ្ធភាពថវិកា និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍។ នៅក្នុងអាទិភាពកំណត់នេះ ត្រូវបានកំណត់ជាក់ស្តែងស្របតាមគោលដៅរបស់វិទ្យាស្ថានជាតិស្ថិតិ និងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

ជំនួយក្រៅប្រទេសត្រូវមានការសម្របសម្រួលឱ្យបានត្រឹមត្រូវ នៅពេលដែលដៃគូអភិវឌ្ឍន៍នីមួយៗដើរតាមកម្មវិធីការងាររបស់ខ្លួន និងក្នុងការទំនាក់ទំនងតាមក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។ នេះនាំឱ្យមានការងារមួយចំនួនជាន់គ្នានៅក្នុងប្រព័ន្ធស្ថិតិជាតិ[៣៧]។ អនុក្រុមបច្ចេកទេសនៃក្រុមការងារបច្ចេកទេស ផែនការ និងកាត់បន្ថយភាពក្រីក្រ (TWG-PPR) ស្តីពីទិន្នន័យសម្រាប់ការអភិវឌ្ឍអាចផ្តល់នូវយន្តការសម្រាប់ការសម្របសម្រួលឱ្យកាន់តែប្រសើរឡើងជាមួយដៃគូអភិវឌ្ឍន៍។

## ការផ្តល់ជំនួយបច្ចេកទេស

សារៈសំខាន់នៃការផ្តល់ហិរញ្ញប្បទានក្រៅប្រទេសត្រូវបានបង្ហាញតាមទំហំ និងលំដាប់នៃគម្រោងដែលពាក់ព័ន្ធនឹងហិរញ្ញប្បទានក្រៅប្រទេស ឆ្នាំ២០១៣-២០១៦ ដូចបានបង្ហាញដោយ ១៧ គម្រោង[៣៨] ក្នុងតារាងខាងក្រោមដោយផ្អែកតាមរបាយការណ៍ប្រទេសស្តីពីការគាំទ្រដល់ស្ថិតិ (CRESS)។

គម្រោងគាំទ្រដោយដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៣-២០១៦ ដូចបានរាយការណ៍ដោយប្រព័ន្ធស្ថិតិជាតិ

| | គម្រោងស្ថិតិ | ឆ្នាំ យោង/ អនុវត្តន៍ | ការគាំទ្រ ហិរញ្ញប្បទាន (១០០០ ដុល្លារ អាមេរិក) | ក្រសួង/ស្ថាប័ន ទទួល | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| ១ | អង្កេតចន្លោះជំរឿនប្រជាជនកម្ពុជា | ២០១៣ | ៨២៥ | វិទ្យាស្ថានជាតិស្ថិតិ | រដ្ឋាភិបាលជប៉ុន/ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន<br>មូលនិធិប្រជាជនសហប្រជាជាតិ |
| ២ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | ២០១៣ | ៦៧៩ | វិទ្យាស្ថានជាតិស្ថិតិ | រដ្ឋាភិបាលស៊ុយអែដ/ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ |
| ៣ | ជំរឿនកសិកម្ម | ២០១៣ | ៣.៨៧៧ | វិទ្យាស្ថានជាតិស្ថិតិ | អង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ<br>រដ្ឋាភិបាលអូស្ត្រាលី/នាយកដ្ឋានការបរទេស និងពាណិជ្ជកម្ម<br>រដ្ឋាភិបាលស៊ុយអែដ/ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ<br>ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| ៤ | បង្កើនការប្រមូលផ្តុំ លទ្ធភាព និងការផ្សព្វផ្សាយសូចនាករអភិវឌ្ឍន៍ជាតិ រួមទាំងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ | ២០១៣ | ៤៧ | វិទ្យាស្ថានជាតិស្ថិតិ | ការិយាល័យស្ថិតិសហប្រជាជាតិ/នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ (ចក្រភពអង់គ្លេស) |
| ៥ | អង្កេតឧស្សាហកម្ម និងសេដ្ឋកិច្ចកម្ពុជា | ២០១៤ | ២១២ | វិទ្យាស្ថានជាតិស្ថិតិ | រដ្ឋាភិបាលជប៉ុន/ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន<br>មូលនិធិប្រជាជនសហប្រជាជាតិ |
| ៦ | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា | ២០១៤ | ១.២៧៧ | វិទ្យាស្ថានជាតិស្ថិតិ | មូលនិធិប្រជាជនសហប្រជាជាតិ<br>រដ្ឋាភិបាលអូស្ត្រាលី/នាយកដ្ឋានការបរទេស និងពាណិជ្ជកម្ម<br>រដ្ឋាភិបាលជប៉ុន/ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន<br>រដ្ឋាភិបាលកូរ៉េ/ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ |
| ៧ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | ២០១៤ | ៥៣២ | វិទ្យាស្ថានជាតិស្ថិតិ | រដ្ឋាភិបាលស៊ុយអែដ/ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ |
| ៨ | អគ្គរកម្មស្ថិតិ និងការអភិវឌ្ឍសមត្ថភាពតាមដាន និងវាយតម្លៃ ក្នុងការគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ | ២០១៤ | ១០ | ក្រសួងផែនការ | ធនាគារពិភពលោក |

[៣៧] របាយការណ៍សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ការិយាល័យស្ថិតិសហប្រជាជាតិ/វិទ្យាស្ថានជាតិស្ថិតិ របាយការណ៍ដំបូង ខែធ្នូ ឆ្នាំ២០១៥ កថាខ័ណ្ឌ១០។

[៣៨] ខណៈដែលគម្រោងចំនួន ១៧ ត្រូវបានរាយការណ៍ដោយប្រព័ន្ធស្ថិតិជាតិ សម្រាប់ឆ្នាំ២០១៣-២០១៦ ហើយ ៣៦ ត្រូវបានរាយការណ៍ដោយដៃគូអភិវឌ្ឍន៍សម្រាប់រយៈពេលដូចគ្នា (របាយការណ៍ប្រទេសស្តីពីការគាំទ្រដល់ស្ថិតិ CRESS ទំព័រ ១៩)។

| | គម្រោងស្ថិតិ | ឆ្នាំ យោង/ អនុវត្តន៍ | ការគាំទ្រ ហិរញ្ញប្បទាន (១០០០ ដុល្លារ អាមេរិក) | ក្រសួង/ស្ថាប័ន ទទួល | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| | ជាតិ/គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងទីប្រឹក្សាប្រព័ន្ធតាមដាន និងវាយតម្លៃតាមវិស័យ | | | | |
| ៩ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | ២០១៥ | ១៧២ | វិទ្យាស្ថានជាតិស្ថិតិ | រដ្ឋាភិបាលស៊ុយអែដ/ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ |
| ១០ | គម្រោងមិនបានបញ្ជាក់ស្តីពីស្ថិតិអប់រំ | ២០១៥ | ៨៨ | ក្រសួងអប់រំ យុវជន និងកីឡា | មិនបានប្រាប់ |
| ១១ | គម្រោងបង្កើនសម្ថភាពវិភាគគោលនយោបាយ | ២០១៥ | ៣៥០ | វិទ្យាស្ថានជាតិស្ថិតិ | ធនាគារពិភពលោក |
| ១២ | ការចុះបញ្ជីពាណិជ្ជកម្មស្ថិតិ | ២០១៥ | ១៥ | វិទ្យាស្ថានជាតិស្ថិតិ | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ១៣ | ស្ថិតិយេនឌ័រ | ២០១៣-២០១៥ | ៣០ | ក្រសួងកិច្ចការនារី | រដ្ឋាភិបាលជប៉ុន/ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| ១៤ | អង្កេតថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតរបស់ស្ត្រីនៅកម្ពុជា | ២០១៤-២០១៥ | ២០០ | ក្រសួងកិច្ចការនារី | អង្គការសុខភាពពិភពលោក<br>ស្ត្រីសហប្រជាជាតិ |
| ១៥ | អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា | ២០១៦ | ១៨៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សហភាពអឺរ៉ុប |
| ១៦ | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា | ២០១៦ | ៣៤៦ | វិទ្យាស្ថានជាតិស្ថិតិ | រដ្ឋាភិបាលស៊ុយអែដ/ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ |
| ១៧ | ការពង្រឹងស្ថិតិអប់រំ | ២០១៣-២០១៦ | ៧០០ | ក្រសួងអប់រំ យុវជន និងកីឡា | មូលនិធិកុមារសហប្រជាជាតិ<br>រដ្ឋាភិបាលស៊ុយអែដ/ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ<br>អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌សហប្រជាជាតិ |
| | តម្លៃសរុប | | ៩.៥៤៥ | | |

ជំនួយបន្ថែមត្រូវបានរាយការណ៍ដោយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលមួយចំនួន ដូចខាងក្រោម ៖

| អ្នកទទួលផល | ជំនួយបច្ចេកទេស/ដៃគូរអភិវឌ្ឍន៍ |
|---|---|
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ ធនាគារពិភពលោក សហភាពអឺរ៉ុប |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ធនាគាពិភពលោក |
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ការគាំទ្របច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ក៏មានជំនួយពីសហភាពអឺរ៉ុប សិង្ហបុរី និងជប៉ុនលើអាជ្ញាប័ណ្ណចុះបញ្ជីកម្មសិទ្ធិបញ្ញាផងដែរ |
| ក្រសួងមហាផ្ទៃ | ការគាំទ្រការតាមដាន និងវាយតម្លៃពីមូលនិធិកុមារសហប្រជាជាតិ និងធនាគារអភិវឌ្ឍន៍អាស៊ី |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | មូលនិធិកុមារសហប្រជាជាតិ អំពីទិន្នន័យមូលដ្ឋានត្រួតពិនិត្យមជ្ឈមណ្ឌលថែទាំលំនៅដ្ឋាន |
| ក្រសួងកិច្ចការនារី | ថវិកាសម្រាប់ស្ថិតិយេនឌ័រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ពីអង្គការសុខភាពពិភពលោក និងមូលនិធិកុមារសហប្រជាជាតិ-អង្កេតស្រោមអនាម័យ អំពើហឹង្សាប្រឆាំងនារី ឆ្នាំ ២០១៤ មូលនិធិប្រជាជនសហប្រជាជាតិអំពីការវិភាគស៊ីជម្រៅលើអំពើហឹង្សាប្រឆាំងស្ត្រីតាមរយៈការដកស្រង់ពីអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០១៤ |
| ធនាគារជាតិនៃកម្ពុជា | ជញ្ជីងទូទាត់ពីមូលនិធិរូបិយវត្ថុអន្តរជាតិ ស្ថិតិវិនិយោគផ្ទាល់ពីបរទេសពីសហភាពអឺរ៉ុប-អាស៊ាន និងស្ថិតិពាណិជ្ជកម្មអន្តរជាតិខាងសេវាកម្មពីសហភាពអឺរ៉ុប-អាស៊ាន |

### ២.៣.៩ ការផ្តល់ហិរញ្ញប្បទានប្រព័ន្ធស្ថិតិជាតិ

រាល់ការវាយតម្លៃថវិកាសម្រាប់ស្ថិតិនៅកម្ពុជា បានយល់ព្រមដូចគ្នាថាកម្រិតនៃការផ្តល់ថវិកាសម្រាប់ស្ថិតិគឺមិនគ្រប់គ្រាន់ឡើយ។ ការគាំទ្របញ្ជីនៃសកម្មភាពស្ថិតិសំខាន់ៗ និងការអភិវឌ្ឍត្រូវបានពន្យារពេល ឬលុបចោល ដូចបានរាយការណ៍ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់វិទ្យាស្ថានជាតិស្ថិតិស្តីពីប្រព័ន្ធស្ថិតិជាតិ ឧទាហរណ៍ក្នុងរបាយការណ៍ឆ្នាំ២០១៥ (របាយការណ៍ចុងក្រោយបំផុត) របស់វិទ្យាស្ថានជាតិស្ថិតិ ៖ "មានសន្ទស្សន៍មួយចំនួន អង្កេតសេដ្ឋកិច្ច បរិស្ថាន និងធនធានធម្មជាតិប្រចាំឆ្នាំ និងកម្រងស្ថិតិដែលវិទ្យាស្ថានជាតិស្ថិតិមិនអាចអនុវត្តបានដោយសារខ្វះខាតធនធាន។ ក្រៅពីស្ថិតិដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិ មាន ៩៥ ស្ថិតិដែលប្រមូលទិន្នន័យដោយអង្គភាពស្ថិតិនៅក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា។ ស្ថិតិភាគច្រើនត្រូវបានផលិត និងផ្សព្វផ្សាយដល់សាធារណជន យោងតាមអនុក្រឹត្យលេខ៧០ អនក្រ.បក ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង។ ស្ថិតិមួយចំនួនតូចមិនត្រូវបានប្រមូលឡើយសម្រាប់ពេលខ្លះ ឬមិនស្របតាមពេលកំណត់ក្នុងអនុក្រឹត្យនេះ" ។

ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលបានរាយការណ៍ថាកម្រិតកំណត់ថវិកាគឺជាបញ្ហាចម្បងមួយ និងជាពិសេសសម្រាប់មន្ត្រី សម្រាប់ការប្រមូលទិន្នន័យ សិក្ខាសាលា និងការបោះពុម្ពផ្សាយ។ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលចាត់ទុកការគាំទ្រថវិកាថាមិនគ្រប់គ្រាន់ ឬតិចតួចបំផុត។

ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលត្រូវបានតម្រូវឱ្យរៀបចំផែនការសម្រាប់សកម្មភាពស្ថិតិរបស់ខ្លួន និងរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីបញ្ចូលក្នុងកញ្ចប់ថវិការបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីជាមូលដ្ឋានសម្រាប់ការគាំទ្រថវិកាសម្រាប់សកម្មភាពស្ថិតិប្រចាំឆ្នាំរបស់ខ្លួន (ច្បាប់ស្តីពីស្ថិតិ មាត្រា២១)។

វិទ្យាស្ថានជាតិស្ថិតិមានបំពាក់ឧបករណ៍យ៉ាងល្អជាមួយហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានអគារផ្ទាល់ខ្លួនដែលហាក់ដូចជាគ្រប់គ្រាន់សម្រាប់ចំនួនមន្ត្រីបច្ចុប្បន្ន។ ប៉ុន្តែគ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារជាទូទៅមិនគ្រប់គ្រាន់ និងត្រូវការការជំនួស។ លទ្ធភាព និងភាពងាយស្រួលរបស់យានយន្តសម្រាប់ការងារស្ថិតិ (ការប្រមូលទិន្នន័យ និងការប្រើប្រាស់ផ្សេងទៀត) ក៏មិនគ្រប់គ្រាន់ផងដែរ។

ផែនការដើម្បីណែនាំថវិកាកម្មវិធីនៅក្នុងថវិកាជាតិ រួមទាំងថវិកាសម្រាប់ស្ថិតិនៅឆ្នាំ២០១៧ បង្ហាញពីជំហានវិជ្ជមានមួយសម្រាប់ការប្រតិបត្តិស្ថិតិ និងការអភិវឌ្ឍ។ គំនិតផ្តួចផ្តើមនេះនឹងអនុញ្ញាតឱ្យវិទ្យាស្ថានជាតិស្ថិតិគ្រប់គ្រងលើការចំណាយរបស់ខ្លួន រួមទាំងការបែងចែកការចំណាយឡើងវិញ (នៅក្នុងច្បាប់ថវិកា)។

## ជំនួយក្រៅប្រទេស

របាយការណ៍ប្រទេសស្តីពីការគាំទ្រដល់ស្ថិតិកម្ពុជា (CRESS Report)[៣៩] ខែឧសភា ឆ្នាំ២០១៧ ដោយវិទ្យាស្ថានជាតិស្ថិតិ និងអ្នកជំនាញការក្រៅប្រទេស និងផ្តល់មូលនិធិដោយ PARIS21 គឺជាកិច្ចខិតខំប្រឹងប្រែងក្នុងការចងក្រងព័ត៌មានស្តីពីហិរញ្ញប្បទានដល់ស្ថិតិនៅកម្ពុជា។ របាយការណ៍បានបង្ហាញព័ត៌មានដូចខាងក្រោមដោយផ្អែកលើព័ត៌មានដែលផ្តល់ដោយប្រព័ន្ធស្ថិតិជាតិថា "ការផ្តល់ហិរញ្ញប្បទានសរុបសម្រាប់ស្ថិតិដែលបានរាយការណ៍

[៣៩] (សេចក្តីព្រាង) របាយការណ៍ប្រទេសស្តីពីការគាំទ្រដល់ស្ថិតិកម្ពុជា អង្គការភាពជាដៃគូក្នុងស្ថិតិសម្រាប់ការអភិវឌ្ឍក្នុងសតវត្សរ៍ទី២១ (PARIS21) នៅខែឧសភា ឆ្នាំ២០១៧។ របាយការណ៍ទទួលស្គាល់ថាការសិក្សានេះមានដែនកំណត់ច្រើន។ វិសាលភាពតិចតួចនៃស្ថាប័ន និងអត្រាឆ្លើយតបតិចតួចរួមជាមួយទិន្នន័យមិនពេញលេញអាចជាទូទៅជាលទ្ធផលនៃការប៉ាន់ស្មានស្ទើរនៃការផ្តល់ហិរញ្ញប្បទានសម្រាប់ស្ថិតិពីប្រភពទាំងក្នុងស្រុក និងក្រៅប្រទេស។

ដោយម្កៃក្រសួង និងស្ថាប័នមាន ៣៥,៨ លានដុល្លារអាមេរិកសម្រាប់រយៈពេលបួនឆ្នាំ ២០១៣-២០១៦។ ទឹកប្រាក់ ២៦,៣ លានដុល្លារអាមេរិក (៧៣ ភាគរយ) បានផ្តល់ដោយរាជរដ្ឋាភិបាល ខណៈដែល ៩,៥ លានដុល្លារអាមេរិក (២៧ ភាគរយ) បានទទួលពីប្រភពខាងក្រៅ។”[៤០]

ក្តីបារម្ភសំខាន់ពីរនាពេលបច្ចុប្បន្ន គឺផែនការថវិការបស់វិទ្យាស្ថានជាតិស្ថិតិដែលស្នើសុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៧ ត្រូវបានកាត់បន្ថយ ហើយការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍សម្រាប់ជំរឿនទូទៅប្រជាជនឆ្នាំ២០១៩ មិនច្បាស់លាស់ និងមិនមានការសន្យា ដែលវិទ្យាស្ថានជាតិស្ថិតិបានស្នើសុំឱ្យដៃគូអភិវឌ្ឍន៍បន្តគាំទ្រការផលិតស្ថិតិនៅវិទ្យាស្ថានជាតិស្ថិតិ ។[៤១]

[៤០] ទំព័រទី១០ មានភាពខុសគ្នា (របាយការណ៍ CRESS ទំព័រ១៩) ព័ត៌មានពីដៃគូអភិវឌ្ឍន៍អន្តរជាតិចំនួន ៧ បង្ហាញជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសសរុប ២១,៣ លានដុល្លារអាមេរិក ដែលបានផ្តល់ក្នុងអំឡុងឆ្នាំ២០១៣-២០១៦។ ចំនួនទឹកប្រាក់នេះមាន ១១,៨ លានដុល្លារអាមេរិក ច្រើនជាងកម្រិតនៃការផ្តល់ថវិកាក្រៅប្រទេសដែលបានរាយការណ៍ដោយស្ថាប័នរាជរដ្ឋាភិបាល។ ការប្រើប្រាស់ទិន្នន័យដែលបានរាយការណ៍ដោយដៃគូអភិវឌ្ឍន៍អន្តរជាតិ ការផ្តល់ថវិកាសរុបសម្រាប់ស្ថិតិនៅកម្ពុជាអាចមានដល់ ៤៧,៦ លានដុល្លារអាមេរិក ជំនួសឱ្យ ៣៥,៨ លានដុល្លារអាមេរិក ដែលបានរាយការណ៍ដោយរាជរដ្ឋាភិបាល។ បមាណភាគនៃហិរញ្ញប្បទានក្រៅប្រទេសសម្រាប់ឆ្នាំ២០១៣-២០១៦ ក៏នឹងកើនឡើងដល់ ៤៤,៨ ភាគរយ ពី ២៦,៧ ភាគរយ ផ្អែកលើទិន្នន័យរបស់រាជរដ្ឋាភិបាល។ ភាពខុសគ្នានេះត្រូវតែដោះស្រាយ ដើម្បីឱ្យមានទិន្នន័យគ្រប់គ្រាន់សម្រាប់ការវិភាគ និងការគាំទ្រ។

[៤១] កំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាស្ថិតិ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦។

# ជំពូក ៣ យុទ្ធសាស្ត្រសម្រាប់ប្រព័ន្ធស្ថិតិជាតិ

## ៣.១ ចក្ខុវិស័យ និងបេសកកម្ម

**ចក្ខុវិស័យ**

ស្ថិតិនៃប្រព័ន្ធស្ថិតិជាតិគាំទ្រដល់សកម្មភាពនៃកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់ទាំងអស់គ្នានៅកម្ពុជា។

**បេសកកម្ម**

បេសកកម្មនៃប្រព័ន្ធស្ថិតិជាតិ គឺដើម្បីសម្របសម្រួល ប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយស្ថិតិផ្លូវការប្រកបដោយគុណភាពខ្ពស់ និងមិនលំអៀង ដើម្បីជួយដល់ការធ្វើសេចក្តីសម្រេច ការជជែកវែកញែក និងការពិភាក្សាក្នុងរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ខេត្ត ស្រុក និងឃុំ ធុរៈកិច្ច និងប្រព័ន្ធផ្សព្វផ្សាយ ក៏ដូចជាសហគមន៍កម្ពុជា និងអន្តរជាតិដ៏ទូលំទូលាយ[៤២] ។

## ៣.២ តម្លៃស្នូល

អ្នកប្រើប្រាស់គោលដៅ - ធានាថាតម្រូវការរបស់អ្នកប្រើប្រាស់ត្រូវបានឆ្លើយតបជាមួយលទ្ធផលស្ថិតិ តាមរយៈការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញ។

វិជ្ជាជីវៈ - លើកកម្ពស់កម្រិតបទដ្ឋានខ្ពស់បំផុតនៃជំនាញបច្ចេកទេស និងក្រមសីលធម៌វិជ្ជាជីវៈក្នុងការផលិត ការសម្របសម្រួល និងការផ្សព្វផ្សាយទិន្នន័យស្ថិតិដែលមានគុណភាព - ប្រកាន់ខ្ជាប់នូវគោលការណ៍យុត្តិធម៌ និងស្មើភាព - ថែរក្សាប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងចំណេះដឹងថ្នាក់ជាតិតាមបទដ្ឋានខ្ពស់បំផុត - តម្លាភាព។

សុចរិតភាព - រឹងមាំខាងក្នុង និងក្រៅ - ប្តេជ្ញារក្សាការសម្ងាត់ក្នុងការប្រមូលទិន្នន័យ និងព័ត៌មានស្ថិតិ - ខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីធ្វើឱ្យប្រាកដថាបន្ទុករបស់អ្នកឆ្លើយមានភាពសមហេតុផល។

គុណភាព - ធានាស្ថិតិមានស្ថិរភាព អាចទុកចិត្តបាន និងទៀងទាត់ដើម្បីទាំងអស់គ្នា - ការប្រមូល ការកែច្នៃ និងការផ្សព្វផ្សាយទិន្នន័យ និងព័ត៌មានទាន់ពេលវេលា។

និរន្តរភាព - អភិវឌ្ឍប្រព័ន្ធស្ថិតិជាតិប្រកបដោយចីរភាព ស្របតាមតម្រូវការរបស់អ្នកពាក់ព័ន្ធទាំងអស់។

ភាពជាដៃគូ - រួមគ្នាតែមួយ - រក្សាការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងទំនាក់ទំនងការងារជាមួយអ្នកពាក់ព័ន្ធទាំងអស់ - តស៊ូមតិ និងអប់រំអំពីការប្រើប្រាស់ព័ត៌មានស្ថិតិសម្រាប់ការធ្វើសេចក្តីសម្រេចដ៏ល្អ - ប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពនូវប្រព័ន្ធផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយស្ថិតិ និងកសាងសមត្ថភាពចំណេះដឹងផ្នែកស្ថិតិ។

ការគ្រប់គ្រងល្អ - ប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធាន។

---

[៤២] ជាសេចក្តីថ្លែងអំពីបេសកកម្មនៃផែនការមេស្ថិតិ (SMP) ឆ្នាំ២០០៨-២០១៥ លើកលែងតែ “ប្រព័ន្ធស្ថិតិជាតិ” ត្រូវបានប្រើជំនួស “វិទ្យាស្ថានជាតិស្ថិតិ”។

## ៣.៣ គោលដៅយុទ្ធសាស្ត្រ

| | គោលដៅយុទ្ធសាស្ត្រ |
|---|---|
| គោលដៅយុទ្ធសាស្ត្រ១ | អភិវឌ្ឍ អនុវត្ត និងថែរក្សានូវសំណុំទិន្នន័យស្នូលដែលមានគុណភាពខ្ពស់[៤៣] ដោយគ្រប់ស្ថាប័នទាំងអស់នៃប្រព័ន្ធស្ថិតិជាតិក្រោមការដឹកនាំរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការស្ថិតិនៃកិច្ចដំណើរការអភិវឌ្ឍន៍ដែលកើតចេញពីការប្តេជ្ញានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការយុទ្ធសាស្ត្រអាស៊ានតាមផ្នែក និងតម្រូវការរបស់អ្នកប្រើប្រាស់ដទៃទៀត។ |
| គោលដៅយុទ្ធសាស្ត្រ២ | បន្តពង្រឹងច្បាប់ស្តីពីស្ថិតិហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន រចនាសម្ព័ន្ធចាត់តាំង ឯករាជ្យភាពនៃវិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការ ហិរញ្ញវត្ថុ និងរដ្ឋបាលនៃប្រព័ន្ធស្ថិតិជាតិ ដើម្បីគាំទ្រដល់ការផលិត និងការអភិវឌ្ឍស្ថិតិ។ |
| គោលដៅយុទ្ធសាស្ត្រ៣ | អភិវឌ្ឍ និងអនុវត្តការកសាងសមត្ថភាពមនុស្សក្នុងការរៀបចំជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាល និងកម្មវិធីលើកទឹកចិត្តមន្ត្រីក្នុងប្រព័ន្ធស្ថិតិជាតិ។ |
| គោលដៅយុទ្ធសាស្ត្រ៤ | អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រ និងផែនការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដើម្បីផ្តល់នូវសមត្ថភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដោយគាំទ្រគ្រប់ទិដ្ឋភាពទាំងអស់នៃការប្រមូល ការកែច្នៃ ការវិភាគ ការថែរក្សា និងការផ្សព្វផ្សាយស្ថិតិ។ |
| គោលដៅយុទ្ធសាស្ត្រ៥ | អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយ យុទ្ធសាស្ត្រគាំទ្រ និងចំណេះដឹងផ្នែកស្ថិតិ ដើម្បីផ្តល់ការទទួលបានឱ្យកាន់តែប្រសើរឡើងដល់អ្នកប្រើប្រាស់ទាំងអស់ និងបង្កើនសេចក្តីត្រូវការសម្រាប់ស្ថិតិ។ |
| គោលដៅយុទ្ធសាស្ត្រ៦ | ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិ ដើម្បីលុបបំបាត់ជម្លោះទិន្នន័យ (Data Conflicts) និងផលិតស្ថិតិអាចប្រៀបធៀបបាន ទាន់ពេលវេលាក្នុងប្រព័ន្ធស្ថិតិជាតិប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។ |
| គោលដៅយុទ្ធសាស្ត្រ៧ | ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងការងារ និងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីធានានូវការគាំទ្រការព្យាករណ៍ ការបន្ត និងការរួមបញ្ចូលគ្នាទៅនឹងសកម្មភាពអាទិភាពរបស់ប្រព័ន្ធស្ថិតិជាតិ ក៏ដូចជាការផ្ទេរជំនាញពេញលេញ និងចំណេះធ្វើ។ |
| គោលដៅយុទ្ធសាស្ត្រ៨ | ជំរុញស្ថិរភាព និងកំណើននៃការគាំទ្រថវិកាសម្រាប់ប្រព័ន្ធស្ថិតិជាតិពីប្រភពក្នុងស្រុក និងអន្តរជាតិ ដើម្បីអាចធ្វើផែនការ និងអនុវត្តកម្មវិធីស្ថិតិអាទិភាពប្រកបដោយប្រសិទ្ធភាព។ |

ទាំងនេះត្រូវបានបញ្ជាក់បន្ថែមនៅក្នុងគោលបំណងជាក់លាក់ ដូចខាងក្រោម។

### ៣.៣.១ តម្រូវការអ្នកប្រើប្រាស់

**គោលដៅយុទ្ធសាស្ត្រ ១.** អភិវឌ្ឍ អនុវត្ត និងថែរក្សានូវសំណុំទិន្នន័យស្នូលដែលមានគុណភាពខ្ពស់ដោយគ្រប់ស្ថាប័នទាំងអស់នៃប្រព័ន្ធស្ថិតិជាតិក្រោមការដឹកនាំរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការស្ថិតិនៃកិច្ចដំណើរការអភិវឌ្ឍន៍ដែលកើតចេញពីការប្តេជ្ញានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការយុទ្ធសាស្ត្រអាស៊ានតាមផ្នែក និងតម្រូវការរបស់អ្នកប្រើប្រាស់ដទៃទៀត។

៣.៣.១.១ ភ្ជាប់ប្រតិបត្តិការប្រព័ន្ធស្ថិតិជាតិ ទៅនឹងគោលនយោបាយអភិវឌ្ឍន៍

៣.៣.១.២ កែលម្អគោលនយោបាយទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិ

៣.៣.១.៣ គាំទ្រការចងក្រងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

៣.៣.១.៤ បន្តកែលម្អស្ថិតិសេដ្ឋកិច្ច សង្គមកិច្ច

[៤៣] ភាពសំខាន់ ភាពទាន់ពេលវេលា ភាពគួរទុកចិត្តបាន ភាពទទួលបាន។

### ៣.៣.២ ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន

**គោលដៅយុទ្ធសាស្ត្រ ២.** បន្តពង្រឹងច្បាប់ស្ដីពីស្ថិតិហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន រចនាសម្ព័ន្ធចាត់តាំង ឯករាជ្យភាពនៃវិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការ ហិរញ្ញវត្ថុ និងរដ្ឋបាលនៃប្រព័ន្ធស្ថិតិជាតិ ដើម្បីគាំទ្រដល់ការផលិត និងការអភិវឌ្ឍស្ថិតិ។

៣.៣.២.១ រៀបចំប្រព័ន្ធស្ថិតិជាតិ ដូចមានចែងក្នុងច្បាប់ស្ដីពីស្ថិតិ និងអនុក្រឹត្យ

៣.៣.២.២ ផ្ដល់នូវស្វ័យភាព និងការទទួលខុសត្រូវបន្ថែមទៀតក្នុងការគ្រប់គ្រងវិទ្យាស្ថានជាតិស្ថិតិ

៣.៣.២.៣ បង្កើតអាណត្តិរបស់អង្គភាពស្ថិតិដែលបានចាត់តាំងក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល

### ៣.៣.៣ ធនធានមនុស្ស

**គោលដៅយុទ្ធសាស្ត្រ ៣.** អភិវឌ្ឍ និងអនុវត្តការកសាងសមត្ថភាពមនុស្សក្នុងការរៀបចំជ្រើសរើសបុគ្គលិក ការបណ្ដុះបណ្ដាល និងកម្មវិធីលើកទឹកចិត្តមន្ត្រីក្នុងប្រព័ន្ធស្ថិតិជាតិ។

៣.៣.៣.១ ធ្វើការផ្លាស់ប្ដូរថ្មីនូវគោលនយោបាយ និងការគ្រប់គ្រងធនធានមនុស្ស

៣.៣.៣.២ អភិវឌ្ឍ និងបន្តកម្មវិធីបណ្ដុះបណ្ដាលទូលំទូលាយក្នុងប្រព័ន្ធស្ថិតិជាតិ

### ៣.៣.៤ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា

**គោលដៅយុទ្ធសាស្ត្រ ៤.** អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រ និងផែនការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដើម្បីផ្ដល់នូវសមត្ថភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដោយគាំទ្រគ្រប់ទិដ្ឋភាពទាំងអស់នៃការប្រមូល ការកែច្នៃ ការវិភាគ ការថែរក្សា និងការផ្សព្វផ្សាយស្ថិតិ។

៣.៣.៤.១ ប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាជាយុទ្ធសាស្ត្រ ជាមួយការកាត់បន្ថយជាអប្បបរមានៃកម្លាំងពលកម្ម

### ៣.៣.៥ ការផ្សព្វផ្សាយ និងការគាំទ្រ

**គោលដៅយុទ្ធសាស្ត្រ ៥.** អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយ យុទ្ធសាស្ត្រគាំទ្រ និងចំណេះដឹងផ្នែកស្ថិតិ ដើម្បីផ្ដល់ការទទួលបានឱ្យកាន់តែប្រសើរឡើងដល់អ្នកប្រើប្រាស់ទាំងអស់ និងបង្កើនសេចក្ដីត្រូវការសម្រាប់ស្ថិតិ។

៣.៣.៥.១ ការគាំទ្រដល់ការប្រើប្រាស់ស្ថិតិតាមគោលនយោបាយ និងផែនការ

៣.៣.៥.២ ផ្សព្វផ្សាយ និងធ្វើអន្តរកម្មប្រកបដោយប្រសិទ្ធភាពទៅអ្នកប្រើប្រាស់ដ៏ទូលំទូលាយ

### ៣.៣.៦ ការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ

**គោលដៅយុទ្ធសាស្ត្រ ៦.** ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិ ដើម្បីលុបបំបាត់ជម្លោះទិន្នន័យ និងផលិតស្ថិតិអាចប្រៀបធៀបបាន ទាន់ពេលវេលាក្នុងប្រព័ន្ធស្ថិតិជាតិប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។

៣.៣.៦.១ ពង្រីកវិសាលភាព និងយន្តការនៃការសម្របសម្រួលនៅក្នុងប្រព័ន្ធស្ថិតិជាតិ

### ៣.៣.៧ ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍

**គោលដៅយុទ្ធសាស្ត្រ ៧.** ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងការងារ និងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីធានានូវការគាំទ្រការព្យាករណ៍ ការបន្ត និងការរួមបញ្ចូលគ្នា ដល់សកម្មភាពអាទិភាពនៃប្រព័ន្ធស្ថិតិជាតិ និងការផ្ទេរពេញលេញនូវជំនាញ និងចំណេះធ្វើ។

៣.៣.៧.១ ធ្វើឱ្យស្របគ្នានូវតម្រូវការរបស់ប្រទេសជាមួយដៃគូអភិវឌ្ឍន៍

### ៣.៣.៨ ហិរញ្ញប្បទានប្រព័ន្ធស្ថិតិជាតិ

**គោលដៅយុទ្ធសាស្ត្រ ៨.** ជំរុញឱ្យមានស្ថិរភាព និងកំណើននៃការគាំទ្រថវិកាសម្រាប់ប្រព័ន្ធស្ថិតិជាតិទាំងពីប្រភពក្នុងស្រុក និងអន្តរជាតិ ដើម្បីអាចធ្វើផែនការ និងអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកម្មវិធីស្ថិតិអាទិភាព។

៣.៣.៨.១ អនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីស្ថិតិ ទាក់ទងនឹងនីតិវិធីកែលម្អសម្រាប់ហិរញ្ញប្បទាន

# ជំពូក ៤ ផែនការសកម្មភាព

## ៤.១ ភារកិច្ចចាំបាច់

របាយការណ៍ពាក់កណ្តាលអាណត្តិនៃផែនការមេស្ថិតិបានបង្ហាញសមិទ្ធផលជាច្រើន ដែលមុនគេបង្អស់គឺការកែលម្អលើការផលិតទិន្នន័យ និងអាចផ្តល់ធាតុចូលក្នុងការតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ទាំងនេះចេញមកពីការធ្វើជំរឿន និងអង្កេតសំខាន់ៗ និងសកម្មភាពស្ថិតិសំខាន់ដទៃទៀត ជាមួយការកើនឡើងនៃហិរញ្ញប្បទានក្នុងស្រុកពីសំណាក់រាជរដ្ឋាភិបាល ដែលបានកំពុងលើកទឹកចិត្ត។

ការកសាងសមត្ថភាពមួយចំនួនរបស់វិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល (ទោះបីមានវិសាលភាពតិចតួច) បានសង្កេតជាក់ស្តែងឃើញថាមានក្របខ័ណ្ឌច្បាប់ប្រសើរជាងមុន ដោយមានការបង្កើតក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ។ អនុក្រឹត្យបន្តបន្ទាប់ក៏អាចជួយពង្រឹងទំនាក់ទំនងរវាងគោលនយោបាយ និងស្ថិតិ និងការសម្របសម្រួលស្ថាប័នស្ថិតិផងដែរ។

ឱកាសជាច្រើនសម្រាប់បង្កើនការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសសម្រាប់ក្រសួងពាក់ព័ន្ធ និងស្ថាប័នដែលបានចាត់តាំងដទៃទៀត បានបន្ថែមសមត្ថភាពនៃប្រព័ន្ធស្ថិតិជាតិក្នុងការគ្រប់គ្រង និងដំណើរការសកម្មភាពស្ថិតិក៏ដូចជាការអនុវត្តតាមបទដ្ឋានដែលបានណែនាំជាអន្តរជាតិឆ្ពោះទៅរកស្ថិតិមានគុណភាពកាន់តែប្រសើរឡើង។

ការខិតខំប្រឹងប្រែងទាំងនេះ ដើម្បីទទួលបានវិធីសាស្ត្រ និងការអនុវត្តប្រកបដោយគុណភាព និងដើម្បីកែលម្អការផ្សព្វផ្សាយស្ថិតិតាមវេបសាយ និងការបោះពុម្ពផ្សាយរបាយការណ៍ស្ថិតិ ដែលបច្ចុប្បន្ននេះមានការកើនឡើងនូវការប្រើប្រាស់ស្ថិតិក្នុងរាជរដ្ឋាភិបាល។

ទោះជាដូច្នេះក្តី ការអភិវឌ្ឍទាំងនេះគ្រាន់តែអាចបង្ហាញពីដំណាក់កាលដំបូងទៅដំណាក់កាលកណ្តាលនៃការអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិប៉ុណ្ណោះ។ ការខិតខំធ្វើឱ្យមានបន្ថែមនូវមន្ត្រីជំនាញ និងធនធានគ្រប់គ្រាន់ត្រូវបានជំនួសឱ្យគ្មាននរណាម្នាក់ក្នុងអំឡុងពេលមួយទសវត្សរ៍កន្លងមកនេះ។ បន្ថែមនឹងនេះ ការកើនឡើងនូវតម្រូវការស្ថិតិមានគុណភាពបានទៅលឿនជាងហួសពីសមត្ថភាពរបស់ប្រព័ន្ធស្ថិតិជាតិ ដើម្បីផ្តល់តម្រូវការនេះ។

បញ្ជីសកម្មភាពសំខាន់ៗចាប់ពីឆ្នាំ២០១៩-២០២៣ រួមជាមួយការធ្វើអង្កេត ជំរឿន និងដំណើរការរដ្ឋបាលផ្តោតលើការបង្កើត និងធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ដោយដាក់ឱ្យមានរចនាសម្ព័ន្ធសម្របសម្រួលដែលមានប្រសិទ្ធភាព និងយន្តការទំនាក់ទំនងដែលពាក់ព័ន្ធនឹងគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចតាមរយៈលទ្ធផលល្អប្រសើរ និងទទួលបានការគាំទ្រពីភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីផ្តល់នូវធាតុចូលចាំបាច់សម្រាប់ពង្រឹងវិទ្យាស្ថានជាតិស្ថិតិជាពិសេស និងប្រព័ន្ធស្ថិតិជាតិជាទូទៅ។

### ៤.១.១ បំពេញតាមតម្រូវការនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងអាស៊ាន និងអ្នកប្រើប្រាស់ដទៃទៀត

តម្រូវការនៃទិន្នន័យត្រូវតែមានការគ្រប់គ្រង។ ការសំខាន់ដំបូងគេ គឺផ្តល់សេវាតាមតម្រូវការទៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ អន្តរជាតិ (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ប្រព័ន្ធផ្សព្វផ្សាយទិន្នន័យទូទៅ) និងថ្នាក់តំបន់ (អាស៊ាន គណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (ESCAP))។ តម្រូវការក្នុងការផ្តល់ថវិកាដល់សកម្មភាពស្ថិតិ និងកសាងធនធានសម្រាប់ផលិតលទ្ធផលដែលមានអត្ថន័យ សម្រាប់ភាពជោគជ័យនៃគំនិតផ្តួចផ្តើមគន្លឹះដែលអនុម័តដោយរាជរដ្ឋាភិបាល គឺជាភាពជាក់ស្តែងតាំងពីដំបូង។ ជំរឿន អង្កេត និងដំណើរការទិន្នន័យរដ្ឋបាលគួរតែត្រូវបានរៀបចំ និងអនុវត្ត ដើម្បីបំពេញសេចក្តីត្រូវការនេះ។ គោលបំណង និងគោលដៅដែលត្រូវបានកំណត់ឱ្យសង្គម និងសេដ្ឋកិច្ចកាន់តែប្រសើរឡើង និងលទ្ធផលពីវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលគួរតែមានគុណភាពខ្ពស់បំផុតលើមូលដ្ឋាននៃការខិតខំប្រឹងប្រែងដ៏ល្អបំផុត ពោលគឺតាមកម្រិតធនធាន និងកាលៈទេសៈដែលមានស្រាប់។ ប្រភពជម្រើស ដូចជាទិន្នន័យទូលាយ (Big Data) និងព័ត៌មានវិស័យឯកជននឹងត្រូវបានវាយតម្លៃជាយថាហេតុ សម្រាប់ការទទួលស្គាល់ និងប្រើប្រាស់ជាផ្លូវការ។

| យុទ្ធសាស្ត្រ/<br>គោលដៅជាក់លាក់ | សកម្មភាព | ការិយាល័យ<br>ទទួលខុសត្រូវ | លទ្ធផល | អាចត្រូវការ<br>ជំនួយការ<br>បច្ចេកទេស |
|---|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រ ១. អភិវឌ្ឍ អនុវត្ត និងថែរក្សានូវសំណុំទិន្នន័យស្នូលដែលមានគុណភាពខ្ពស់[៤៤] ដោយគ្រប់ស្ថាប័នទាំងអស់នៃប្រព័ន្ធស្ថិតិជាតិក្រោមការដឹកនាំរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការស្ថិតិនៃកិច្ចដំណើរការអភិវឌ្ឍន៍ដែលកើតចេញពីការប្តេជ្ញានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការយុទ្ធសាស្ត្រអាស៊ានតាមផ្នែក និងតម្រូវការរបស់អ្នកប្រើប្រាស់ដទៃទៀត។ | | | | |
| • ភ្ជាប់ប្រតិបត្តិការប្រព័ន្ធស្ថិតិជាតិទៅនឹងគោលនយោបាយអភិវឌ្ឍន៍<br>• កែលម្អគោលនយោបាយអំពីស្ថិតិដែលបានចាត់តាំង និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិ<br>• គាំទ្រការចងក្រងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព<br>• បន្តកែលម្អស្ថិតិសេដ្ឋកិច្ច សង្គមកិច្ច | ១. រួមបញ្ចូលយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ | ក្រុមប្រឹក្សាស្ថិតិ/<br>គណៈកម្មាធិការ<br>សម្របសម្រួលស្ថិតិ | ជំពូកសំខាន់/ផ្នែកសម្រាប់ស្ថិតិក្នុងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ | |
| | ២. ដឹកនាំការស្វែងរកគ្រប់លទ្ធភាពទាំងអស់សម្រាប់ពង្រីកការប្រើប្រាស់កំណត់ត្រារដ្ឋបាលប្រព័ន្ធព័ត៌មានគ្រប់គ្រង និងធាតុនៃទិន្នន័យទូលាយ (Big Data) ជាប្រភពនៃទិន្នន័យសម្រាប់គោលបំណងស្ថិតិ ដើម្បីបំពេញចន្លោះខ្វះខាត និងជាពិសេសជាប្រភពសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងទិន្នន័យបំបែក (តាម ភេទ ក្រុមអាយុ ពិការភាព និងថ្នាក់ក្រោមជាតិ)។ | វិទ្យាស្ថានជាតិស្ថិតិ | ការបំបែកបន្ថែមទៅលើសំណុំទិន្នន័យ | បាទ |
| | ៣. ធ្វើផែនការវាយតម្លៃ សម្របសម្រួល និងធ្វើឱ្យស្របច្បាប់នូវសំណុំទិន្នន័យពីអង្គការផ្សេងៗ ដូចជាអង្គការវិស័យឯកជន វិទ្យាស្ថានស្រាវជ្រាវ សមាគមវិជ្ជាជីវៈ និងអង្គការមិនមែនរដ្ឋាភិបាល។ | វិទ្យាស្ថានជាតិស្ថិតិ | វាយតម្លៃគុណភាពនៃសំណុំទិន្នន័យពីប្រភពមិនមែនរដ្ឋាភិបាល | |

[៤៤] ភាពសំខាន់ ភាពទាន់ពេលវេលា ភាពគួរទុកចិត្តបាន ភាពទទួលបាន។

| យុទ្ធសាស្ត្រ/ គោលដៅជាក់លាក់ | សកម្មភាព | ការិយាល័យ ទទួលខុសត្រូវ | លទ្ធផល | អាចត្រូវការ ជំនួយការ បច្ចេកទេស |
|---|---|---|---|---|
| | ៤. បង្កើតបញ្ជីវាយឈ្មោះករណីដែលបទដ្ឋាន និងចំណាត់ថ្នាក់អន្តរជាតិមិនត្រូវបានអនុវត្តក្នុងប្រព័ន្ធស្ថិតិជាតិ និងបង្កើតផែនការសម្រាប់ការអនុវត្តរបស់វា។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ | ផែនការសម្រាប់ការយល់ព្រមតាមបទដ្ឋាន និងចំណាត់ថ្នាក់អន្តរជាតិ | បាទ |
| | ៥. អភិវឌ្ឍ និងយល់ព្រមតាមក្របខ័ណ្ឌធានាគុណភាពទិន្នន័យ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ | អនុម័តក្របខ័ណ្ឌធានាគុណភាពទិន្នន័យ (DQAF) | បាទ |
| | ៦. ផលិតម៉េតាទិន្នន័យសមស្របសម្រាប់វិស័យទាំងអស់នៃស្ថិតិ និងធ្វើវាឱ្យបានទៅអ្នកប្រើប្រាស់។ | វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | អនុម័តការណែនាំអនុវត្តន៍សម្រាប់ផ្តល់ម៉េតាទិន្នន័យដល់លទ្ធផលចេញផ្សាយ | បាទ |
| | ៧. បង្កើតសេចក្តីណែនាំគោលនយោបាយច្បាស់លាស់មួយ និងកម្មវិធីសម្រាប់អភិវឌ្ឍន៍ស្ថិតិថ្នាក់ក្រោមជាតិ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ | អនុម័តកម្មវិធីសម្រាប់ស្ថិតិថ្នាក់ក្រោមជាតិ | បាទ |
| | ៨. បញ្ជ្រាបសូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ទៅក្នុងសកម្មភាពស្ថិតិថ្នាក់ជាតិ វិស័យ និងថ្នាក់ក្រោមជាតិតាមរយៈ អនុក្រុមការងារបច្ចេកទេសផែនការ និងកាត់បន្ថយភាពក្រីក្រ (TWG-PPR) អំពីទិន្នន័យសម្រាប់ការអភិវឌ្ឍ ឬក្រុមការងារបច្ចេកទេសសមស្របដទៃទៀតដែលត្រូវបានបង្កើតដោយក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ | ការបង្កើតក្រុមការងារបច្ចេកទេសដើម្បីទទួលខុសត្រូវលើការបញ្ជ្រាបសូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងសកម្មភាពស្ថិតិ | |
| | ៩. អភិវឌ្ឍ និងអនុវត្តផែនការជាក់លាក់[៩៥] ដើម្បីកែលម្អស្ថិតិសេដ្ឋកិច្ច បរិស្ថាន និងហិរញ្ញវត្ថុ រួមទាំងគណនេយ្យជាតិ ថ្លៃ ជញ្ជីងទូទាត់ និងស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ ដើម្បីធ្វើវាកាន់តែទាន់ពេលវេលា គុណភាពជាងមុន និងភាពសំខាន់ជាងមុន។<br>៩.១. អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាប្រចាំឆ្នាំ<br>៩.២. អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា<br>៩.៣. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថ្នាក់ខេត្ត និងថ្នាក់ជាតិសាកល្បង[៩៦] | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | ធ្វើអង្កេត | បាទ |

[៩៥] ដកស្រង់ពីបទបង្ហាញរបស់វិទ្យាស្ថានជាតិស្ថិតិស្តីពី “សូចនាករតាមដានរួម (JMIs) ឆ្នាំ២០១៧-២០១៨” អំឡុងពេលវគ្គបណ្តុះបណ្តាលខ្លីស្តីពីយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ នៅថ្ងៃទី២៧-២៨ ខែកក្កដា ឆ្នាំ២០១៧។

[៩៦] ដកស្រង់ពីលក្ខខណ្ឌយោងនៃក្រសួងផែនការ គម្រោងបង្កើនសមត្ថភាពវិភាគភាពក្រីក្រ (EPACP) Grant No. TF0A0113 ផ្តល់ថវិកាដោយធនាគារពិភពលោក។

| យុទ្ធសាស្ត្រ/ គោលដៅជាក់លាក់ | សកម្មភាព | ការិយាល័យ ទទួលខុសត្រូវ | លទ្ធផល | អាចត្រូវការ ជំនួយការ បច្ចេកទេស |
|---|---|---|---|---|
| | ៩.៨. សន្ទស្សន៍ថ្លៃផលិតករ[៤៧] | | | |
| | ១០. អភិវឌ្ឍ និងអនុវត្តផែនការជាក់លាក់[៤៨] ដើម្បីកែលម្អភាពក្រីក្រ និងស្ថិតិសង្គមកិច្ច សំខាន់ៗផ្សេងទៀត ដើម្បីកែលម្អភាពទាន់ពេលវេលា និរន្តរភាព ព័ត៌មានលម្អិតភូមិសាស្ត្រ និងគុណភាពទាំងមូលរបស់វា។<br>១០.១. ធ្វើជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០១៩<br>១០.២. អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារ<br>១០.៣. អង្កេតប្រជាសាស្ត្រ និងសុខភាព<br>១០.៤. អង្កេតពិការភាពថ្នាក់ជាតិ<br>១០.៥. អង្កេតចំណាកស្រុកទីប្រជុំជនជនបទ<br>១០.៦. អង្កេតប្រជាជនវ័យចំណាស់<br>១០.៧. អង្កេតថ្នាំជក់ថ្នាក់ជាតិ<br>១០.៨. អំពើហឹង្សាលើរាងកាយកុមារ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការ សម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័ន រាជរដ្ឋាភិបាល | ធ្វើអង្កេតនានា និងជំរឿនទូទៅ ប្រជាជន | បាទ |

**បញ្ហាទី១.** ការរៀបចំសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពបានដំណើរការល្អ (ដូចបានរាយការណ៍ក្នុងកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលស្ថិតិ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧)។ នេះបានរួមបញ្ចូលទាំងការបញ្ជាក់តួនាទីរបស់វិទ្យាស្ថានជាតិស្ថិតិ ដូចខាងក្រោម ៖

- សម្របសម្រួលជាមួយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលដែលជាអ្នកផលិតទិន្នន័យ ដូចមានចែងក្នុងច្បាប់ស្តីពីស្ថិតិ
- យន្តការសម្របសម្រួលស្ថិតិ (ដូចជាក្រុមប្រឹក្សាស្ថិតិ គណៈកម្មាធិការសម្របសម្រួលស្ថិតិ និងមន្ត្រីបង្គោល) ដែលគាំទ្រការបង្កើត និងការផ្សព្វផ្សាយសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
- ផ្តល់ជំនួយបច្ចេកទេស និងសមត្ថកិច្ច ដើម្បីផ្ទៀងផ្ទាត់គុណភាពទិន្នន័យ
- មានមុខងារជាឃ្លាំងផ្ទុកកណ្តាលនៃសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា/សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ការរៀបចំនេះក៏រួមបញ្ចូលការអនុវត្តក្របខ័ណ្ឌថ្នាក់ជាតិផងដែរ។ សកម្មភាពសំខាន់ៗដែលត្រូវបំពេញក្នុងឆ្នាំ ២០១៧/២០១៨ រួមមាន ៖

- បង្កើតមន្ត្រីបង្គោលសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បីសម្របសម្រួលការងារនៃប្រព័ន្ធស្ថិតិជាតិ
- បង្កើតក្រុមការងារបច្ចេកទេសសម្រាប់ការចងក្រង និងការផ្សព្វផ្សាយសូចនាករគោលដៅអភិវឌ្ឍន៍ប្រកប ដោយចីរភាព (TWG-SDGI) និងមន្ត្រីបង្គោលសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បីសម្របសម្រួលការងារនៃប្រព័ន្ធស្ថិតិជាតិ
- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo) ជាប្រចាំ សម្រាប់ទិន្នន័យមូលដ្ឋាននៃសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា/សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងកម្មវិធីផ្សព្វផ្សាយទិន្នន័យសម្រាប់រាយ

[៤៧] គម្រោងសហប្រតិបត្តិការស្ថាប័ន រវាងវិទ្យាស្ថានជាតិស្ថិតិ និងស្ថិតិស៊ុយអែដ ដំណាក់កាល ឆ្នាំ២០១៦-២០១៩ ផ្តល់ថវិកាដោយសហភាពអឺរ៉ុប (EU) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA)។

[៤៨] ដកស្រង់ពីបទបង្ហាញរបស់វិទ្យាស្ថានជាតិស្ថិតិស្តីពី "សូចនាករតាមដានរួម (JMIs) ឆ្នាំ២០១៧-២០១៨" " អំឡុងពេលវគ្គបណ្តុះបណ្តាលខ្លីស្តីពីយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ នៅថ្ងៃទី២៧-២៨ ខែកក្កដា ឆ្នាំ២០១៧។

ការណ៍/ ផ្លាស់ប្ដូរទៅវិញទៅមកនូវទិន្នន័យសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់ថ្នាក់ជាតិ និងអន្តរជាតិ

- កំណត់អត្តសញ្ញាណនៃការកែតម្រូវជាចាំបាច់ដល់ប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo) រួមទាំងការកែប្រែថ្មីរបស់ប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo) ដើម្បីធានារក្សាទុក និងផ្សព្វផ្សាយសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
- ការសហការរបស់វិទ្យាស្ថានជាតិស្ថិតិជាមួយដៃគូអភិវឌ្ឍន៍ស្ដីពីការបង្កើតទិន្នន័យមូលដ្ឋានសមស្រប ដើម្បីរក្សាទុក និងផ្សព្វផ្សាយសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងឧបករណ៍ធ្វើផែនការដ៏មានប្រសិទ្ធភាពបំផុត និងការងារពាក់ព័ន្ធ (ប្រើប្រាស់សេចក្ដីណែនាំយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ និងឧបករណ៍ធ្វើផែនការទិន្នន័យកម្រិតខ្ពស់ (ADAPT) របស់អង្គការភាពជាដៃគូក្នុងស្ថិតិសម្រាប់ការអភិវឌ្ឍក្នុងសតវត្សរ៍ទី២១ (PARIS21) ដែលជាឧបករណ៍ធ្វើផែនការ និងតាមដាន) រួមទាំងការកសាងសមត្ថភាពសម្រាប់ការវាស់វែងសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
- ប្រជុំជាមួយអគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ ដើម្បីពិភាក្សាការធ្វើសមកាលកម្មនៃការងារដែលបានធ្វើលើមូលដ្ឋានីយកម្មនៃសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់រួមបញ្ចូលទៅក្របខ័ណ្ឌសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា/សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
- ប្រជុំបច្ចេកទេសជាមួយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ដើម្បីពិនិត្យឡើងវិញ និងពិភាក្សាការរៀបចំស្ថាប័នសម្រាប់ការអនុវត្តមូលដ្ឋានីយកម្មសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងការបញ្ជាក់នូវ ៖
  - □ តួនាទីនៃក្រុមការងារបច្ចេកទេសសម្រាប់ការចងក្រង និងការផ្សព្វផ្សាយសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (TWG-SDGI) ជាអ្នកធ្វើសេចក្ដីសម្រេចលើការងារបច្ចេកទេសដែលទាក់ទងនឹងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា
  - □ ការទទួលខុសត្រូវរបស់វិទ្យាស្ថានជាតិស្ថិតិ ជាអ្នកថែរក្សាទិន្នន័យមូលដ្ឋាននៃសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្លូវការ និង
  - □ រាយការណ៍អំពីកាតព្វកិច្ចនៃក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលទាក់ទងនឹងសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការបញ្ជូនទិន្នន័យ/ម៉េតាទិន្នន័យទៅវិទ្យាស្ថានជាតិស្ថិតិ សម្រាប់ដាក់បញ្ចូលក្នុងទិន្នន័យមូលដ្ឋានប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo)។

### ៤.១.២ ពង្រឹងច្បាប់ និងក្របខ័ណ្ឌស្ថាប័ន

ក្នុងអំឡុងពេលរហូតដល់ឆ្នាំ២០២៣ រាជរដ្ឋាភិបាលត្រូវវាយតម្លៃថាតើប្រព័ន្ធស្ថិតិជាតិ និងវិទ្យាស្ថានជាតិស្ថិតិពិតជាបានត្រៀមខ្លួន ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការដែលកំពុងកើនឡើងសម្រាប់ធ្វើសេចក្ដីសម្រេចផ្អែកលើជាក់ស្ដែង។ ជាការពិត ច្បាប់ស្ដីពីស្ថិតិ និងអនុក្រឹត្យនានាគឺជាការស្វាគមន៍យ៉ាងខ្លាំងដល់ការអភិវឌ្ឍក្នុងការធ្វើឱ្យប្រសើរឡើងនូវការរៀបចំរចនាសម្ព័ន្ធរបស់ប្រព័ន្ធស្ថិតិជាតិ ដូចជាការបង្កើតក្រុមប្រឹក្សាស្ថិតិ គណៈកម្មាធិការសម្របសម្រួលស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង និងការកែលម្អវិទ្យាស្ថានជាតិស្ថិតិ។

ប៉ុន្តែមានសំណួរមួយចំនួនដូចខាងក្រោម ចោទសួរឡើង ៖

- នៅក្រោមប្រព័ន្ធវិមជ្ឈការ តើវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការមានតួនាទីសម្របសម្រួល និងមានឥទ្ធិពលលើសកម្មភាពស្ថិតិរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលឬទេ?
- តើវាមានសិទ្ធិអំណាច ស្វ័យភាព និងការទទួលខុសត្រូវគ្រប់គ្រាន់ ដើម្បីស្នើសុំ និងចាត់ចែងធនធានដែលចាំបាច់ដល់តម្រូវការស្ថិតិដែលបានចាត់តាំងសម្រាប់ធ្វើការតាមដានវឌ្ឍនភាពនៃផែនការ គោលនយោបាយ និងកម្មវិធីរបស់រដ្ឋាភិបាលឬទេ?

- តើក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិអាចដោះស្រាយកង្វល់ទាំងនេះឬទេ ដែលនឹងត្រូវដោះស្រាយនៅក្នុងវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ជាពិសេសបន្ទាប់ពីការអនុវត្តពេញលេញនូវច្បាប់ស្តីពីស្ថិតិ។ ក្រសួងផែនការគួរតែពិចារណាអំពីស្វ័យភាព និងគណនេយ្យភាពបន្ថែមទៀតរបស់វិទ្យាស្ថានជាតិស្ថិតិទាក់ទងនឹងការគ្រប់គ្រងធនធាន ដោយចាត់ទុកថាជាអ្នកសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិ ដែលត្រូវចូលរួមក្នុងការផ្តល់គុណភាពក្នុងប្រតិបត្តិការស្ថិតិរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

| យុទ្ធសាស្ត្រ/ គោលដៅជាក់លាក់ | សកម្មភាព | ការិយាល័យទទួលខុសត្រូវ | លទ្ធផល | អាចត្រូវការជំនួយការបច្ចេកទេស |
|---|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រ ២. បន្តពង្រឹងច្បាប់ស្ថិតិ ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន រចនាសម្ព័ន្ធចាត់តាំង ឯករាជ្យភាពនៃវិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការ ហិរញ្ញវត្ថុ និងរដ្ឋបាលនៃប្រព័ន្ធស្ថិតិជាតិ ដើម្បីគាំទ្រដល់ការផលិត និងការអភិវឌ្ឍស្ថិតិ។ | | | | |
| • រៀបចំប្រព័ន្ធស្ថិតិជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យ<br>• ផ្តល់នូវស្វ័យភាព និងគណនេយ្យភាពបន្ថែមទៀតក្នុងការគ្រប់គ្រងវិទ្យាស្ថានជាតិស្ថិតិ<br>• បង្កើតអាណត្តិរបស់អង្គភាពស្ថិតិដែលបានចាត់តាំងក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | ១. ពិនិត្យឡើងវិញនូវច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនានា ដើម្បីបន្តពង្រឹងស្វ័យភាព និងគណនេយ្យភាពរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីដឹកនាំប្រព័ន្ធស្ថិតិជាតិ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ | ពិនិត្យឡើងវិញនូវច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យ | បាទ |
| | ២. រៀបចំក្រុមការងារបច្ចេកទេស ដើម្បីគាំទ្រដល់គណៈកម្មាធិការសម្របសម្រួលស្ថិតិ និងវិទ្យាស្ថានជាតិស្ថិតិ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ | រៀបចំក្រុមការងារបច្ចេកទេស | |
| | ៣. ផ្សព្វផ្សាយ និងផ្សាយជាសាធារណៈនូវច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនានា។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ | អនុម័តផែនការទំនាក់ទំនង | បាទ |
| | ៤. ក្រុមប្រឹក្សាស្ថិតិ តាមរយៈគណៈកម្មាធិការសម្របសម្រួលស្ថិតិនឹងធ្វើសនិទានកម្មនូវឋានៈ និងតួនាទីរបស់អង្គភាពស្ថិតិដែលបានចាត់តាំងស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ | ធ្វើសនិទានកម្មស្ថានភាពនៃអង្គភាពស្ថិតិដែលបានចាត់តាំង | |
| | ៥. រៀបចំវិទ្យាស្ថានជាតិស្ថិតិឡើងវិញដើម្បីកែលម្អដំណើរការស្ថិតិទាំងមូល មានដូចជាការប្រមូលទិន្នន័យ ការកែច្នៃទិន្នន័យ ការរក្សាទុក ការផ្សព្វផ្សាយ និងការទទួលបាន។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ | រៀបចំវិទ្យាស្ថានជាតិស្ថិតិឡើងវិញ | បាទ |

### ៤.១.៣ ធ្វើឱ្យប្រសើរឡើងនូវធនធានមនុស្ស

តម្រូវការសំខាន់ជាងគង្វះធនធានមនុស្សធ្វើការនោះ គឺតម្រូវការជំនាញបច្ចេកទេសរបស់វិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល។ ដោយសារអង្គភាពស្ថិតិចម្បងនៅក្នុងប្រព័ន្ធស្ថិតិជាតិ គឺវិទ្យាស្ថានជាតិស្ថិតិ ដែលរក្សានូវអាទិភាពក្នុងការខិតខំប្រឹងប្រែងកសាងសមត្ថភាពទោះជាមានតម្រូវការបន្ថែម ដែលទាំងនេះគួរតែអនុវត្តដោយយកចិត្តទុកដាក់ខ្លាំងទៅលើក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ទាក់ទងនឹងម៉ោងពេលបណ្តុះបណ្តាល សម្ភារៈ និងធនធានមនុស្ស។

ទោះបីជាយ៉ាងណាក៏ដោយ កម្មវិធីកសាងសមត្ថភាពទូលំទូលាយក្នុងប្រព័ន្ធស្ថិតិជាតិត្រូវបានបង្កើតឡើង មិនត្រឹមតែតាមរយៈការបង្រៀន និងសិក្ខាសាលាប៉ុណ្ណោះទេ ប៉ុន្តែក៏មានជាគម្រោងដែលទទួលបានជោគជ័យពីអតីតកាលនៅកម្ពុជា និងប្រទេសដទៃទៀតនៅអាស៊ី ដូចជាការណែនាំ ការផ្សព្វផ្សាយទូលំទូលាយនូវទិន្នន័យ សវនកម្មស្ថិតិ និងការបង្រៀនតាមអនឡាញ។

វិទ្យាស្ថានជាតិស្ថិតិអាចធ្វើការពិនិត្យឡើងវិញ និងរៀបចំប្រព័ន្ធលើកទឹកចិត្ត និងការងារអាជីពសម្រាប់មន្ត្រីរបស់ខ្លួន។ ការងារនេះអាចត្រូវបានអនុវត្តនៅក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

| យុទ្ធសាស្ត្រ/ គោលដៅជាក់លាក់ | សកម្មភាព | ការិយាល័យ ទទួលខុសត្រូវ | លទ្ធផល | អាចត្រូវការ ជំនួយការ បច្ចេកទេស |
|---|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រ ៣. អភិវឌ្ឍ និងអនុវត្តការកសាងសមត្ថភាពមនុស្សក្នុងការរៀបចំជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាល និងកម្មវិធីលើកទឹកចិត្តមន្ត្រីក្នុងប្រព័ន្ធស្ថិតិជាតិ។ | | | | |
| • កែលម្អគោលនយោបាយ និងការគ្រប់គ្រងធនធានមនុស្ស<br>• អភិវឌ្ឍ និងបន្តកម្មវិធីបណ្តុះបណ្តាលទូលំទូលាយក្នុងប្រព័ន្ធស្ថិតិជាតិ | ១. បង្កើនចំនួនមន្ត្រីបច្ចេកទេសឱ្យបានសមស្របសម្រាប់ការចងក្រងសូចនាករសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ការកាត់បន្ថយភាពក្រីក្រ អាស៊ាន និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ | ក្រសួងផែនការ ក្រុមប្រឹក្សាស្ថិតិ | មានអ្នកស្ថិតិបន្ថែមទៀតក្នុងប្រព័ន្ធស្ថិតិជាតិ | បាទ |
| | ២. ផ្តល់ការបណ្តុះបណ្តាលក្នុងផ្នែកស្ថិតិ ដូចបានបញ្ជាក់ក្នុងផ្នែក ២.៣.៤ ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ | វគ្គបណ្តុះបណ្តាល | បាទ |
| | ៣. ក្រសួងផែនការត្រូវផ្តល់នូវស្វ័យភាព និងគណនេយ្យភាពបន្ថែមទៀតដល់វិទ្យាស្ថានជាតិស្ថិតិក្នុងការគ្រប់គ្រងធនធានមនុស្ស។ | ក្រសួងផែនការ ក្រុមប្រឹក្សាស្ថិតិ | | |
| | ៤. ណែនាំត្រួតពិនិត្យការអនុវត្តការងាររបស់មន្ត្រីប្រចាំឆ្នាំ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ | ពិនិត្យការងារមន្ត្រីឡើងវិញប្រចាំឆ្នាំ | |
| | ៥. ណែនាំប្រព័ន្ធមួយសម្រាប់បញ្ជាក់ចំណេះដឹងខាងស្ថិតិ និងការលើកទឹកចិត្តក្នុងការគាំទ្រដល់វិញ្ញាបនប័ត្រ រួមទាំងការងារអាជីព។ | វិទ្យាស្ថានជាតិស្ថិតិ | ប្រព័ន្ធលើកទឹកចិត្ត ការងារអាជីព | បាទ |
| | ៦. រៀបចំ និងអនុវត្តសេចក្តីថ្លែងការណ៍ស្តីពីតម្រូវការអភិវឌ្ឍន៍ និងបណ្តុះបណ្តាលមន្ត្រីរយៈពេលវែង និងកម្មវិធីជាភាសាខ្មែរសម្រាប់ប្រព័ន្ធស្ថិតិជាតិ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | កម្មវិធីអភិវឌ្ឍន៍មន្ត្រីសម្រាប់ប្រព័ន្ធស្ថិតិជាតិ | បាទ |

### ៩.១.៤ ធ្វើសនិទានកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា

កុំព្យូទ័រដែលមានកម្មវិធីផ្សេងៗ ក្រៅពីកម្មវិធី Microsoft មិនបង្កើតប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាឡើយ។ តម្រូវការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្របច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាមិនត្រឹមតែសម្រាប់វិទ្យាស្ថានជាតិស្ថិតិប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ប្រព័ន្ធស្ថិតិជាតិទាំងមូលផងដែរ។ ការទិញទាំងស្រុង និង/ឬជំនួយពីរាជរដ្ឋាភិបាល និង/ឬពីដៃគូអភិវឌ្ឍន៍ត្រូវធ្វើឡើងដោយពិចារណាលើការធានា អាជ្ញាប័ណ្ណ ការថែទាំ ការជួសជុល និងទំនើបកម្ម។

ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាត្រូវតែភ្ជាប់គ្នាជាមួយមាតិកា និងការគ្រប់គ្រងចំណេះដឹង ប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាន ការទាញទិន្នន័យត្រឡប់វិញ និងការរក្សាទុក សុវត្ថិភាព និងឃ្លាំងទិន្នន័យ។

| យុទ្ធសាស្ត្រ/ គោលដៅជាក់លាក់ | សកម្មភាព | ការិយាល័យ ទទួលខុសត្រូវ | លទ្ធផល | អាចត្រូវការជំនួយការបច្ចេកទេស |
|---|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រ ៩. អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រ និងផែនការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដើម្បីផ្តល់នូវសមត្ថភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដោយគាំទ្រគ្រប់ទិដ្ឋភាពទាំងអស់នៃការប្រមូល ការកែច្នៃ ការវិភាគ ការថែរក្សា និងការផ្សព្វផ្សាយស្ថិតិ។ | | | | |
| • ប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាជាយុទ្ធសាស្ត្រជាមួយការកាត់បន្ថយជាអប្បបរមានៃកម្លាំងពលកម្ម | ១. បង្កើត និងអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាសម្រាប់វិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធស្ថិតិជាតិ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ | អនុម័តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាសម្រាប់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា | បាទ |
| | ២. អនុវត្តអនុសាសន៍សម្រាប់ការគ្រប់គ្រងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាតាមផែនការរបស់វិទ្យាស្ថានជាតិស្ថិតិសម្រាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាន (DBMS) ការទាញសំណុំឯកសារត្រឡប់មកវិញ សុវត្ថិភាពព័ត៌មានវិទ្យា និងឃ្លាំងទិន្នន័យ។ | វិទ្យាស្ថានជាតិស្ថិតិ | រៀបចំឡើងវិញនូវការគ្រប់គ្រងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យានៅក្នុងវិទ្យាស្ថានជាតិស្ថិតិ | បាទ |

### ៩.១.៥ បង្កើនការផ្សព្វផ្សាយ និងការគាំទ្រ

ផែនការមេស្ថិតិបានបង្ហាញពីការខិតខំធ្វើឱ្យប្រសើរឡើងនូវការផ្សព្វផ្សាយនៃប្រព័ន្ធស្ថិតិជាតិ ដូចជាការបោះពុម្ពផ្សាយបន្ថែមទៀត ផ្សព្វផ្សាយតាមរយៈវេទិកា និងវេបសាយសម្រាប់អ្នកប្រើប្រាស់ និងមកកាន់មជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិដោយផ្ទាល់។ បើបានរៀបចំសេវាផ្តល់ទិន្នន័យទាំងនេះស្ថិតនៅដាច់ដោយឡែក ចាំបាច់ត្រូវរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រផ្សព្វផ្សាយឱ្យទាន់ពេលវេលាសម្រាប់វិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធស្ថិតិជាតិ។ ផែនការទំនាក់ទំនងក៏ត្រូវរៀបចំក្នុងពេលជាមួយគ្នានឹងយុទ្ធសាស្ត្រផ្សព្វផ្សាយផងដែរ។

ម៉ែត្រសម្រាប់ការប្រើប្រាស់ ការជឿជាក់ និងការទុកចិត្ត និងលទ្ធភាពគួរតែបង្កើតឡើង ដើម្បីវាយតម្លៃការពេញចិត្តរបស់អ្នកប្រើប្រាស់ និងចូលរួមកាន់តែមានប្រសិទ្ធភាពជាមួយភាគីពាក់ព័ន្ធ ប្រព័ន្ធផ្សព្វផ្សាយ វិស័យឯកជន និងសាលារៀន។

| យុទ្ធសាស្ត្រ/ គោលដៅជាក់លាក់ | សកម្មភាព | ការិយាល័យ ទទួលខុសត្រូវ | លទ្ធផល | អាចត្រូវការ ជំនួយការ បច្ចេកទេស |
|---|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រ ៥. អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយ យុទ្ធសាស្ត្រគាំទ្រ និងចំណេះដឹងផ្នែកស្ថិតិ ដើម្បីផ្តល់ការទទួលបានឱ្យកាន់តែប្រសើរឡើងដល់អ្នកប្រើប្រាស់ទាំងអស់ និងបង្កើនសេចក្តីត្រូវការសម្រាប់ស្ថិតិ។ | | | | |
| • ការគាំទ្រដល់ការប្រើប្រាស់ស្ថិតិតាមគោលនយោបាយ និងផែនការ<br>• ផ្សព្វផ្សាយ និងធ្វើអន្តរកម្មប្រកបដោយប្រសិទ្ធភាពទៅអ្នកប្រើប្រាស់ដ៏ទូលំទូលាយ | ១. បង្កើត និងបោះពុម្ពផ្សាយគោលនយោបាយផ្សព្វផ្សាយថ្មីៗរបស់វិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធស្ថិតិជាតិដោយយកចិត្តទុកដាក់ពីគំនិតផ្តួចផ្តើមទិន្នន័យចំហ (Open Data) និងការអនុវត្តប្រព័ន្ធផ្សព្វផ្សាយទិន្នន័យទូទៅ (GDDS)។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ | អនុម័តគោលនយោបាយផ្សព្វផ្សាយ | បាទ |
| | ២. ណែនាំឱ្យឆាប់រហ័សតាមដែលអាចធ្វើបាននូវប្រតិទិនចេញផ្សាយទិន្នន័យជាមុនសម្រាប់ទិន្នន័យសំខាន់ៗ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | ចេញផ្សាយប្រតិទិនសម្រាប់ស្ថិតិផ្លូវការដែលបានចាត់តាំង | |
| | ៣. បង្កើនកម្រិតវេបសាយរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីផ្សព្វផ្សាយអំពីកម្ពុជា និងព័ត៌មានអំពីវិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធស្ថិតិជាតិ។ ផ្តល់បញ្ជាប់ដោយផ្ទាល់ពីវេបសាយវិទ្យាស្ថានជាតិស្ថិតិទៅនឹងទិន្នន័យស្ថិតិដែលមាននៅលើវេបសាយរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលគួរដាក់ស្ថិតិរបស់ខ្លួននៅលើវេបសាយរបស់ខ្លួន។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | ធ្វើទំនើបកម្មវេបសាយរបស់វិទ្យាស្ថានជាតិ | បាទ |
| | ៤. ផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យមានស្រាប់របស់មជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិ និងសេវាកម្មដែលត្រូវផ្តល់ជូន តាមដានកំណត់ត្រាភ្ញៀវ និងសំណូមពរដែលមាន រួមទាំងប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo) និងបណ្ណសារទិន្នន័យជាតិ (NADA)។ | វិទ្យាស្ថានជាតិស្ថិតិ | កែលម្អមជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិ | |
| | ៥. បង្កើត និងអនុវត្តវិធីសាស្ត្រទូលំទូលាយមួយដល់ទំនាក់ទំនង និងការគាំទ្រដែលពាក់ព័ន្ធនឹងការធ្វើផែនការ ការពិគ្រោះយោបល់ និងមតិត្រឡប់ជាមួយអ្នកប្រើប្រាស់ រួមទាំងប្រព័ន្ធផ្សព្វផ្សាយ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | អនុម័តផែនការទំនាក់ទំនង និងការគាំទ្រ | បាទ |
| | ៦. ប្រើប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីទំនាក់ទំនងស្ថិតិ និងការវិភាគ។ | វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | បង្កើនការផ្សព្វផ្សាយតាមបណ្តាញសង្គមបច្ចុប្បន្ន | |

| យុទ្ធសាស្ត្រ/គោលដៅជាក់លាក់ | សកម្មភាព | ការិយាល័យទទួលខុសត្រូវ | លទ្ធផល | អាចត្រូវការជំនួយការបច្ចេកទេស |
|---|---|---|---|---|
| | ៧. លើកទឹកចិត្តដល់ការបង្កើតវេទិកាអ្នកប្រើប្រាស់អនឡាញ ដែលក្នុងនោះអ្នកប្រើប្រាស់អាចផ្លាស់ប្តូរព័ត៌មានអំពីទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ និងធ្វើអន្តរកម្មជាមួយមន្ត្រីបច្ចេកទេស។ | វិទ្យាស្ថានជាតិស្ថិតិ | កំណត់មុខងារវេទិការបស់អ្នកប្រើប្រាស់តាមអនឡាញ | |
| | ៨. ធ្វើអង្កេតតម្រូវការ ប្រើប្រាស់ និងការពេញចិត្តរបស់អ្នកប្រើប្រាស់នៅដើមដំណាក់កាលនៃយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ និងធ្វើរៀងរាល់ ៣-៥ឆ្នាំ ជាបន្តបន្ទាប់។ | វិទ្យាស្ថានជាតិស្ថិតិ | លទ្ធផលអង្កេត | |
| | ៩. ផ្តល់ជំពូកថវិកាសម្រាប់ការផ្សព្វផ្សាយ និងការគាំទ្រ ជាពិសេសក្នុងសកម្មភាពទ្រង់ទ្រាយធំ។ | វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័ន រាជរដ្ឋាភិបាល | ថវិកាសម្រាប់ការផ្សព្វផ្សាយ និងការគាំទ្រ | |

## ៤.១.៦ បង្កើនប្រសិទ្ធភាពការសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ

ច្បាប់ស្តីពីស្ថិតិបានផ្តល់ជូនក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិដែលជាអន្តរស្ថាប័នកម្រិតខ្ពស់អាចជួយពង្រឹងទំនាក់ទំនងរវាងគោលនយោបាយ និងស្ថិតិ និងការសម្របសម្រួលស្ថាប័នស្ថិតិ។ ទោះជាយ៉ាងណាក៏ដោយ ស្ថាប័នទាំងនេះមិនត្រូវបានកោះប្រជុំជាទៀងទាត់យោងទៅតាមច្បាប់ស្តីពីស្ថិតិឡើយ ដែលអាចមានផលប៉ះពាល់ទៅលើប្រព័ន្ធស្ថិតិជាតិមិនមានប្រសិទ្ធភាព។ ដោយពិចារណាលើសារៈសំខាន់ជាយុទ្ធសាស្ត្រនៃតួនាទីរបស់វិទ្យាស្ថានជាតិស្ថិតិ ជាអ្នកសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិ និងឋានៈ និងកម្រិតថ្នាក់របស់ខ្លួនក្នុងការិយាធិបតេយ្យត្រូវធ្វើទំនើបកម្ម និងរៀបចំប្រព័ន្ធស្ថិតិជាតិដើម្បីបំពេញតម្រូវការផ្អែកលើជាក់ស្តែង តាមរយៈការគាំទ្របច្ចេកទេសប្រកបដោយប្រសិទ្ធភាពនៃក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ។ ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិមានសិទ្ធិអំណាចខ្ពស់ក្នុងការប្តេជ្ញាឱ្យក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលធ្វើតាមសេចក្តីណែនាំបច្ចេកទេស និងប្រតិបត្តិសកម្មភាពស្ថិតិដែលរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ តាមរយៈគោលនយោបាយ និងដំណោះស្រាយរបស់ខ្លួន។ រឿងនេះត្រូវបានគេមើលឃើញថាអាចធ្វើទៅបាន ប្រសិនបើឋានៈរបស់វិទ្យាស្ថានជាតិស្ថិតិស្ថិតនៅក្នុងរដ្ឋាភិបាល។

| យុទ្ធសាស្ត្រ/គោលដៅជាក់លាក់ | សកម្មភាព | ការិយាល័យទទួលខុសត្រូវ | លទ្ធផល | អាចត្រូវការជំនួយការបច្ចេកទេស |
|---|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រ ៦. ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិ ដើម្បីលុបបំបាត់ជម្លោះទិន្នន័យ (Data Conflicts) និងផលិតស្ថិតិអាចប្រៀបធៀបបាន ទាន់ពេលវេលាក្នុងប្រព័ន្ធស្ថិតិជាតិប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។ | | | | |
| • ពង្រីកវិសាលភាព និងយន្តការនៃការសម្របសម្រួលនៅក្នុងប្រព័ន្ធស្ថិតិជាតិ | ១. ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិគួរប្រជុំតាមកាលកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ | ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ | |

| | | | | |
|---|---|---|---|---|
| | ២. ធ្វើការវាយតម្លៃ តាមដាន និងលុបបំបាត់ការជាន់គ្នាក្នុងការប្រមូលទិន្នន័យដោយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល តាមរយៈក្រុមការងារបច្ចេកទេស។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ | វាយតម្លៃការជាន់គ្នានៃទិន្នន័យ និងការផ្តល់អនុសាសន៍លើការកំណត់សេរីទិន្នន័យ | បាទ |
| | ៣. បង្កើតអ្នកទំនាក់ទំនងតែមួយសម្រាប់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ដើម្បីផ្តល់បណ្តាញប្រកបដោយប្រសិទ្ធភាពសម្រាប់ការសម្របសម្រួល។ | វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | ចាត់តាំងអ្នកសម្របសម្រួលរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | |
| | ៤. ធ្វើការពិនិត្យពេញលេញឡើងវិញនៃការចែករំលែកព័ត៌មាន និងលទ្ធភាពសម្រាប់ពង្រីកការចែករំលែកទិន្នន័យ និងបច្ចេកវិទ្យាប្រសើរបំផុតសម្រាប់អនុវត្ត និងបង្កើតកិច្ចព្រមព្រៀងផ្លូវការ (អនុស្សរណៈនៃការយោគយល់)។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | អនុស្សរណៈនៃការយោគយល់ស្តីពីការចែករំលែកទិន្នន័យ | |

### ៤.១.៧ ធ្វើសនិទានកម្មផ្សារភ្ជាប់ជាមួយដៃគូអភិវឌ្ឍន៍

ដៃគូអភិវឌ្ឍន៍បានជួយជំរុញវឌ្ឍនភាព និងការផ្លាស់ប្តូរវិទ្យាស្ថានជាតិស្ថិតិ ព្រមទាំងប្រព័ន្ធស្ថិតិជាតិ។ ក្នុងពេលជាមួយគ្នានេះដែរ ពួកគេត្រូវបានលើកជាច្រើនដងនូវហេតុផលបណ្តាលមកពីការបែងចែកធនធានមនុស្សដែលកម្រ និងពេលវេលារបស់មន្ត្រីដែលជាអាទិភាពរបស់ពួកគេមិនសមស្របនឹងផែនការ និងកម្មវិធីរបស់ប្រព័ន្ធស្ថិតិជាតិ។ ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវបង្កើនការរៀបចំសម្របសម្រួលប្រកបដោយប្រសិទ្ធភាពជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីបំពេញសេចក្តីត្រូវការរបស់ពួកគេសម្រាប់ស្ថិតិ ត្រូវការការពង្រឹងមួយចំនួនលើផ្នែកផ្គត់ផ្គង់នៃការកសាងសមត្ថភាពរយៈពេលវែង និងការផ្ទេរបច្ចេកវិទ្យា។

| យុទ្ធសាស្ត្រ/ គោលដៅជាក់លាក់ | សកម្មភាព | ការិយាល័យទទួលខុសត្រូវ | លទ្ធផល | អាចត្រូវការជំនួយការបច្ចេកទេស |
|---|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រ ៧. ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងការងារ និងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីធានានូវការគាំទ្រការព្យាករណ៍ ការបន្ត និងការរួមបញ្ចូលគ្នាទៅនឹងសកម្មភាពអាទិភាពរបស់ប្រព័ន្ធស្ថិតិជាតិ ក៏ដូចជាការផ្ទេរជំនាញពេញលេញ និងចំណេះធ្វើ។ | | | | |
| • សម្រុះសម្រួលតម្រូវការប្រទេសជាមួយដៃគូអភិវឌ្ឍន៍ | ១. រៀបចំដំណើរការច្បាស់លាស់សម្រាប់ការសម្របសម្រួលជំនួយបច្ចេកទេស និងគម្រោងដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍តាមរយៈអនុក្រុមបច្ចេកទេសនៃក្រុមការងារបច្ចេកទេស ផែនការនិងកាត់បន្ថយភាពក្រីក្រ (TWG-PPR) ស្តីពីទិន្នន័យសម្រាប់ការអភិវឌ្ឍ ឬក្រុមការងារបច្ចេកទេសសមស្របដទៃទៀតដែលត្រូវបានបង្កើតដោយក្រុមប្រឹក្សាស្ថិតិ/គណៈកម្មាធិការសម្របសម្រួលស្ថិតិ ដើម្បីបង្កើនប្រសិទ្ធភាពរបស់ខ្លួន និងដោះស្រាយបញ្ហាទិន្នន័យសំខាន់ៗ និងគម្លាតសមត្ថភាព។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ | ក្រុមការងារបច្ចេកទេសស្តីពីកិច្ចសហប្រតិបត្តិការដៃគូអភិវឌ្ឍន៍ | |
| | ២. ស្វែងរកការទទួលបានការប្តេជ្ញាចិត្តយូរអង្វែងសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការព្យាករណ៍ | ក្រុមប្រឹក្សាស្ថិតិ/ | របាយការណ៍ប្រចាំឆ្នាំស្តីពី | |

| | | | | |
|---|---|---|---|---|
| | ហិរញ្ញប្បទាន និងជំនួយដូចបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។ | គណៈកម្មាធិការសម្របសម្រួលស្ថិតិ ក្រសួងផែនការ | ការជួយឧបត្ថម្ភគាំទ្រពីក្រៅប្រទេសដល់ស្ថិតិ | |

### ៩.១.៨ ផ្តល់ហិរញ្ញប្បទានប្រព័ន្ធស្ថិតិជាតិ

ច្បាប់ស្តីពីស្ថិតិបានបង្កើតយន្តការនៃកញ្ចប់ថវិកាសម្រាប់ស្ថិតិ មិនត្រឹមតែនៅក្នុងវិទ្យាស្ថានជាតិស្ថិតិប៉ុណ្ណោះទេ ប៉ុន្តែក៏នៅក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលផងដែរ។ ខណៈដែលមិនមានការធានាពេញលេញពីថវិកាដែលត្រូវបានផ្តល់ឱ្យ កញ្ចប់ថវិកាអាចផ្តល់ការយល់ដឹងដល់ចំណោមអ្នកកាន់កាប់ប្រាក់នៅក្នុងរដ្ឋាភិបាលនូវតម្រូវការតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដែលត្រូវតាមដាន និងណែនាំដោយស្ថិតិមានគុណភាពជាមូលដ្ឋានជាក់ស្តែងសម្រាប់ធ្វើសេចក្តីសម្រេច។ វាគួរតែមានប្រព័ន្ធតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព ដើម្បីបង្ហាញពីការប្រើប្រាស់ដោយសុភវិនិច្ឆ័យនៃធនធានដែលបែងចែកដល់ប្រព័ន្ធស្ថិតិជាតិ។

ធនធានមិនត្រូវបានផ្តល់ឱ្យតាមសំណើថវិការបស់អាជ្ញាធរ និងដៃគូអភិវឌ្ឍន៍ឡើយ។ សំណើនេះគួរតែធ្វើនៅក្នុងបរិបទជាក់ស្តែងតាមការអនុវត្តដែលរាជរដ្ឋាភិបាលបានអនុម័ត ផ្តល់ភាពសំខាន់ និងភាពជឿទុកចិត្តលើផលិតផល និងសេវាកម្ម និងការប្រើប្រាស់ដោយប្រសិទ្ធភាពនូវធនធានកម្រ ដូចបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិនេះ។

| យុទ្ធសាស្ត្រ/ គោលដៅជាក់លាក់ | សកម្មភាព | ការិយាល័យ ទទួលខុសត្រូវ | លទ្ធផល | អាចត្រូវការ ជំនួយការ បច្ចេកទេស |
|---|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រ ៨. ជំរុញស្ថិរភាព និងកំណើននៃការគាំទ្រថវិកាសម្រាប់ប្រព័ន្ធស្ថិតិជាតិពីប្រភពក្នុងស្រុក និងអន្តរជាតិ ដើម្បីអាចធ្វើផែនការ និងអនុវត្តកម្មវិធីស្ថិតិអាទិភាពប្រកបដោយប្រសិទ្ធភាព។ | | | | |
| • អនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីស្ថិតិទាក់ទងនឹងនីតិវិធីកែលម្អសម្រាប់ហិរញ្ញប្បទាន | ១. ធ្វើការអនុម័តផែនការ និងថវិកាស្នើសុំដោយវិទ្យាស្ថានជាតិស្ថិតិ និងមជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិនៅក្នុងបរិបទយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ មុននឹងដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិការបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលនីមួយៗ។ | ក្រុមប្រឹក្សាស្ថិតិ/ គណៈកម្មាធិការសម្របសម្រួលស្ថិតិ | អនុម័តកញ្ចប់ថវិកា | |
| | ២. បង្កើត និងអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃដើម្បីតាមដានប្រភព និងការប្រើប្រាស់មូលនិធិពាក់ព័ន្ធនឹងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។ | វិទ្យាស្ថានជាតិស្ថិតិ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល | ដំណើរការប្រព័ន្ធតាមដាន និងវាយតម្លៃ | បាទ |

## ៤.២ សកម្មភាពអាទិភាព (ឆ្នាំ២០១៩-២០២៣)

កាលវិភាគនៃសកម្មភាពសម្រាប់វិទ្យាស្ថានជាតិស្ថិតិមានច្រើន ជាមួយការផ្តុកជាមុនដែលគួរឱ្យកត់សម្គាល់សម្រាប់ឆ្នាំ២០១៩-២០២៣។ ភាគច្រើននៃជំរឿន និងអង្កេតដែលមានទ្រង់ទ្រាយធំត្រូវបានដំណើរការជាមួយការផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងការផ្តល់ជំនាញបច្ចេកទេស។ តាមពិត ទាំងនេះជាបន្ទុកការងាររបស់វិទ្យា

ស្ថានជាតិស្ថិតិចាប់តាំងពីមុនមក។ ឯកសារទាំងនេះត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ១។ ផែនការអនុវត្តនៃសកម្មភាពរបស់ប្រព័ន្ធស្ថិតិជាតិទាំងមូល ចាប់ពីឆ្នាំ២០១៩-២០២៣ មាននៅក្នុងឧបសម្ព័ន្ធ២។

ទោះជាយ៉ាងណាក៏ដោយ ជាមួយច្បាប់ស្តីពីស្ថិតិ វិទ្យាស្ថានជាតិស្ថិតិត្រូវបានផ្តល់សិទ្ធិឱ្យមានការទទួលខុសត្រូវថ្មីលើស្ថាប័នទាំងមូល។ សម្រាប់ឆ្នាំ២០១៩-២០២៣ គេរំពឹងថានឹងអនុវត្តដូចខាងក្រោម ៖

## ការកំណត់គោលនយោបាយ និងកម្មវិធី

- រៀបចំសេចក្តីណែនាំការអនុវត្តសម្រាប់ម៉េតាទិន្នន័យ (metadata)។
- រៀបចំគោលនយោបាយ និងកម្មវិធីសម្រាប់ស្ថិតិថ្នាក់ក្រោមជាតិ។
- គោលនយោបាយ និងផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា គួរតែជំនួសឱ្យគំនិតទូទៅដែលមានស្រាប់ដែលថាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាគ្រាន់តែជាចំនួនសរុបនៃកុំព្យូទ័រ កម្មវិធី និងសំណុំទិន្នន័យដែលយកបានតាមបុគ្គល។
- ការផ្សព្វផ្សាយមិនគ្រាន់តែរៀបចំរបាយការណ៍ និងការវិភាគលទ្ធផលជំរឿន និងអង្កេតប៉ុណ្ណោះឡើយ។ គោលនយោបាយផ្សព្វផ្សាយត្រូវដាក់បញ្ចូល ដើម្បីបម្រើតម្រូវការទូទៅ និងជាក់លាក់របស់អ្នកប្រើប្រាស់នានាតាមរយៈបណ្តាញសមស្រប និងប្រសើរឡើង (ប្រព័ន្ធផ្សព្វផ្សាយ ប្រតិទិនចេញផ្សាយ បោះពុម្ពផ្សាយ សំណុំឯកសារប្រើប្រាស់ជាសាធារណៈ វេបសាយ និងមជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិ)។

## ការកសាងស្ថាប័ន និងសមត្ថភាពមនុស្ស

- វិទ្យាស្ថានជាតិស្ថិតិគួរតែត្រូវបានផ្តល់ជូនស្វ័យភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីដឹកនាំ និងទ្រទ្រង់ដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះទៅកម្រិតខ្ពស់ជាងអ្វីដែលអនុវត្តនៅក្រោមស្ថានភាពបច្ចុប្បន្នរបស់ខ្លួន។ ការផ្តល់សិទ្ធិស្វ័យភាព និងគណនេយ្យភាពបន្ថែមទៀតដល់វិទ្យាស្ថានជាតិស្ថិតិនឹងតម្រូវឱ្យមានការយល់ព្រមតាមផ្លូវច្បាប់ និង/ឬក្រឹត្យ ហើយច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យត្រូវពិនិត្យឡើងវិញ និងកែសម្រួល បើចាំបាច់។
- ថ្វីបើស្ថិតក្នុងស្ថានភាពបច្ចុប្បន្នរបស់ខ្លួនក៏ដោយ ក៏រចនាសម្ព័ន្ធចាត់តាំងរបស់វិទ្យាស្ថានជាតិស្ថិតិត្រូវការពិចារណាឡើងវិញ (ឧទាហរណ៍ ៖ ការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុ ការផ្សព្វផ្សាយស្ថិតិ ។ល។)។
- ធ្វើការប្តេជ្ញាចិត្តថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ តម្រូវឱ្យជ្រើសរើសមន្ត្រីដែលមានសមត្ថភាពបន្ថែមទៀត ទោះបីជាមន្ត្រីអចិន្ត្រៃយ៍ មន្ត្រីគម្រោងជាប់កិច្ចសន្យាក៏ដោយ។ វិទ្យាស្ថានជាតិស្ថិតិគួរធ្វើការពិនិត្យឡើងវិញអំពីសកម្មភាពការងាររបស់មន្ត្រីប្រចាំឆ្នាំ និងផ្តល់ការលើកទឹកចិត្តដោយផ្អែកលើផលិតភាពការងារ។ កម្មវិធីអភិវឌ្ឍន៍ និងការបណ្តុះបណ្តាលមន្ត្រីរយៈពេលវែងប្រកបដោយប្រសិទ្ធភាព និងនៅនឹងកន្លែងត្រូវបានបង្កើតឡើងសម្រាប់មន្ត្រីទាំងអស់នៃអង្គភាពស្ថិតិដែលបានចាត់តាំង ដោយផ្តោតទៅលើប្រធានបទដែលបានកំណត់។

- ធ្វើបច្ចុប្បន្នកម្មស្ថិតិដែលបានចាត់តាំង។
- ជាអ្នកសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ ប្រព័ន្ធស្ថិតិជាតិគួរតែពិចារណារៀបចំក្រុមការងារបច្ចេកទេសតាមរយៈក្រុមប្រឹក្សាស្ថិតិ/គណៈកម្មាធិការសម្របសម្រួលស្ថិតិ (ដូចជាការបញ្ជ្រាបសូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងសកម្មភាពស្ថិតិ យ៉ាងហោចណាស់មួយផ្នែកសម្រាប់ស្ថិតិសេដ្ឋកិច្ច យ៉ាងហោចណាស់មួយផ្នែកសម្រាប់ស្ថិតិសង្គមកិច្ច យ៉ាងហោចណាស់មួយផ្នែកសម្រាប់ធនធានធម្មជាតិ) ដើម្បីជួយក្នុងយន្តការសម្របសម្រួល និងការរៀបចំ។
- ជាមួយការកើនឡើងនូវតម្រូវការទិន្នន័យ ប្រព័ន្ធស្ថិតិជាតិគួរតែត្រូវបានសម្របសម្រួល និងសកម្មភាពស្ថិតិត្រូវបានពិភាក្សា និងផ្តល់អាទិភាព ដើម្បីលើកកម្ពស់គុណភាព កាត់បន្ថយការជាន់គ្នាដែលមិនចាំបាច់ឱ្យនៅទាបបំផុត និងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ធនធាន។ ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិគួរតែជួបប្រជុំគ្នាជាទៀងទាត់ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ ផែនការ និងកម្មវិធីនានាដែលត្រូវការវាយតម្លៃ និងអនុម័ត។ អ្នកទំនាក់ទំនងគួរត្រូវបានចាត់តាំងនៅក្នុងអង្គភាពស្ថិតិដែលបានចាត់តាំងនីមួយៗ សម្រាប់ទាក់ទង និងធ្វើកិច្ចសហការបានល្អប្រសើរ។ អនុស្សរណៈនៃការយោគយល់គួរត្រូវបានបង្កើត ដើម្បីសម្រួលដល់ទិន្នន័យ ក៏ដូចជាការផ្ទេរបច្ចេកវិទ្យា។
- ការផ្តល់កញ្ចប់ថវិកាក្នុងច្បាប់ស្តីពីស្ថិតិត្រូវតែអនុវត្តឱ្យបានពេញលេញ។ ការផ្លាស់ប្តូរស្ថាប័នដូចបានរៀបរាប់ខាងលើនឹងជួយសម្រួលដល់ការរៀបចំ និងការពិចារណាដោយយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។ ប្រព័ន្ធស្ថិតិជាតិក៏មានភារកិច្ចផងដែរដើម្បីតាមដានប្រភពមូលនិធិ ការប្រើប្រាស់ និងគណនេយ្យភាព តាមរយៈប្រព័ន្ធតាមដាន និងវាយតម្លៃដែលមានស្រាប់។
- ភាគច្រើននៃសកម្មភាពផ្តួចផ្តើមទាំងនេះនឹងត្រូវការជំនួយបច្ចេកទេស និង/ឬហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍។ ក្រុមការងារបច្ចេកទេសគួរត្រូវបានបង្កើតឡើង ដើម្បីធ្វើការពង្រឹងកិច្ចសហប្រតិបត្តិការដៃគូអភិវឌ្ឍន៍លើស្ថិតិ ក្នុងករណីដែលមានស្រាប់ លក្ខខណ្ឌយោងរបស់វាអាចត្រូវបានពង្រីកដើម្បីរួមបញ្ចូលស្ថិតិ និងការគាំទ្រយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។

# ជំពូក ៥ ហិរញ្ញប្បទាន

## ៥.១ ការប៉ាន់ស្មានថវិកា មុនឆ្នាំ២០១៧

ការប៉ាន់ស្មានថវិការអាចទទួលបានពីប្រភពជាច្រើន ៖ ផែនការមេស្ថិតិបានរៀបចំនៅខែតុលា ឆ្នាំ២០០៥ ផែនការមេស្ថិតិ-របាយការណ៍ពាក់កណ្តាលអាណត្តិបានរៀបចំនៅខែវិច្ឆិកា ឆ្នាំ២០១២ និងរបាយការណ៍ប្រចាំឆ្នាំ ២០១៥ របស់ប្រព័ន្ធស្ថិតិជាតិរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ នៅខែធ្នូ ឆ្នាំ២០១៦។ បច្ចុប្បន្ន បញ្ជីសំណួរត្រូវបាន បញ្ជូនទៅក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលទាំងអស់ ដើម្បីទទួលបានព័ត៌មានអំពីសកម្មភាពដែលគ្រោងអនុវត្តក្នុង រយៈពេលពីឆ្នាំ២០១៩-២០២៣ និងតម្រូវឱ្យមានការស្នើសុំហិរញ្ញប្បទាន។

### ៥.១.១ ផែនការមេស្ថិតិ ខែតុលា ឆ្នាំ២០០៥

ការប៉ាន់ស្មានចំណាយរបស់ផែនការមេស្ថិតិត្រូវបានបង្ហាញព័ត៌មានអំពីថវិការបស់ប្រព័ន្ធស្ថិតិជាតិ។ សកម្មភាពដែលបានបង្ហាញជាអាទិភាពនៅក្នុងផែនការមេស្ថិតិ តារាង៣ (ឧបសម្ព័ន្ធ៤) គឺជាមូលដ្ឋាន ប៉ុន្តែជាសកម្មភាពសំខាន់ៗប៉ុណ្ណោះ។ សម្រាប់វិទ្យាស្ថានជាតិស្ថិតិ សកម្មភាពទាំងនេះរួមបញ្ចូលទាំងការចងក្រងគណនេយ្យជាតិ (ប៉ុន្តែមិនចាំបាច់តម្រូវការប្រមូលទិន្នន័យច្រើនឡើយ) សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ សន្ទស្សន៍ថ្លៃអ្នកផលិត និងទំនិញកសិកម្ម សន្ទស្សន៍ផលិតកម្មកសិកម្ម និងឧស្សាហកម្ម និងលក់រាយ ស្ថិតិកម្លាំងពលកម្ម និងសន្ទស្សន៍ចំណាយពលកម្ម និងជំរឿន និងអង្កេតជាច្រើនទៀត។ សម្រាប់ក្រសួងផ្សេងទៀត អាទិភាពត្រូវបានបង្ហាញសម្រាប់ស្ថិតិវិស័យក្រៅប្រទេស និងអង្កេត ស្ថិតិសារពើពន្ធតាមវិស័យ ស្ថិតិផលិតកម្មកសិកម្ម និងអង្កេតជំណាំ បសុសត្វ និងនេសាទ ជំរឿនគ្រឹះស្ថានសិក្សាប្រចាំឆ្នាំ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំដែលពាក់ព័ន្ធ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងសុខាភិបាល ទីផ្សារការងារ និងទេសចរណ៍។ សកម្មភាពអាទិភាពនៅក្នុងតារាងមិនរាប់បញ្ចូលសកម្មភាពតាមក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលឡើយ ក្រៅពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ ធនាគារជាតិនៃកម្ពុជា និងវិទ្យាស្ថានជាតិស្ថិតិ។

គម្លាតហិរញ្ញប្បទានសម្រាប់សកម្មភាពអាទិភាពមាន ៣២,៦ លានដុល្លារអាមេរិក សម្រាប់រយៈពេល ១០ ឆ្នាំនៃផែនការមេស្ថិតិ។ ចំណាយផ្ទាល់សរុបក្នុងរយៈពេលនេះត្រូវបានប៉ាន់ប្រមាណ ៤៤,១ លានដុល្លារអាមេរិក ដូច្នេះ គម្លាតហិរញ្ញប្បទានមានប្រមាណ ៧៤ ភាគរយ នៃតម្រូវការសរុប។ ចំណាយសរុប ៤៤,១ លានដុល្លារអាមេរិក រួមបញ្ចូល ១៣,៨ លានដុល្លារអាមេរិក សម្រាប់ការងារជំរឿន ៖ ជំរឿនប្រជាជន កសិកម្ម និងសេដ្ឋកិច្ច។ វាក៏រួមបញ្ចូល ១២,២ លានដុល្លាអាមេរិក សម្រាប់អង្កេតគ្រួសារ (អំពីចំណូល និងចំណាយ សុខាភិបាល ប្រជាសាស្ត្រ កម្លាំងពលកម្ម និងប្រធានបទដទៃទៀត) និងសហគ្រាស។ សកម្មភាពទាំងនេះបានពឹងផ្អែកលើហិរញ្ញប្បទានពីក្រៅប្រទេសជាសំខាន់។ ថវិកាស្ថិតិរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានប៉ាន់ស្មាន សម្រាប់សកម្មភាពអាទិភាពក្នុងឆ្នាំ ២០០៥ មាន ០,៦ លានដុល្លារអាមេរិក។

ឧបសម្ព័ន្ធ៥ក និង៥ខ បង្ហាញពីហិរញ្ញប្បទានលម្អិតនៃសកម្មភាពទាំងអស់នៅក្នុងប្រព័ន្ធស្ថិតិជាតិ។ ក្នុងរយៈពេល ១០ ឆ្នាំ (ឆ្នាំ២០០៦-២០១៥) ជាមួយការចំណាយផ្ទាល់សរុប ៦២,៦១០ លានដុល្លារអាមេរិក តាមថ្លៃថេរឆ្នាំ២០០៥។

សូមកត់សម្គាល់ថា ថវិកាវិទ្យាស្ថានជាតិស្ថិតិមាន ៣៨,៣៦០ លានដុល្លាអាមេរិក ប្រមាណ ៦១ ភាគរយនៃចំណាយសរុប។

## ៥.១.២ ផែនការមេស្ថិតិ-របាយការណ៍ពាក់កណ្តាលអាណត្តិ ខែវិច្ឆិកា ឆ្នាំ២០១២

អំឡុងពេលពិនិត្យឡើងវិញនូវផែនការមេស្ថិតិ វាមានការលំបាកចំពោះការប៉ាន់ស្មានចំណាយសរុបសម្រាប់ការផលិតស្ថិតិដែលគ្រប់គ្រងដោយដៃគូនៅក្នុងប្រព័ន្ធស្ថិតិជាតិ ក្រៅពីវិទ្យាស្ថានជាតិស្ថិតិ។ អំឡុងពេលពិនិត្យឡើងវិញ ក្នុងគោលបំណងដើម្បីប្រមូលព័ត៌មានបន្ថែមអំពីការចំណាយសម្រាប់ផ្នែកដែលខ្វះនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០១០ និង២០១១ របស់ប្រព័ន្ធស្ថិតិជាតិ។ ក៏ប៉ុន្តែសម្រាប់ក្រសួងពាក់ព័ន្ធមួយចំនួន មានតែទិន្នន័យអំពីចំណាយសម្រាប់ការផលិតស្ថិតិប៉ុណ្ណោះ។

មាតិកានៃតួលេខដែលបានរាយការណ៍ក្នុងរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍បន្តបន្ទាប់មានការខុសគ្នា ដោយរបាយការណ៍ខ្លះរាប់បញ្ចូលប្រាក់បៀវត្សរ៍ និងខ្លះទៀតមិនបានរាប់បញ្ចូលប្រាក់បៀវត្សរ៍ឡើយ ហើយរបាយការណ៍ខ្លះទៀតរាយការណ៍តែប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីចូលរួមក្នុងការផលិតស្ថិតិប៉ុណ្ណោះ។ ការរាយការណ៍ខុសគ្នាក៏ដោយសារតែមិនមានព័ត៌មានជាក់លាក់អំពីសកម្មភាពផ្សេងៗដែលបានអនុវត្តក្នុងការផលិតស្ថិតិ ឬមធ្យោបាយបទដ្ឋាននៃការគណនា និងរាយការណ៍ចំណាយលើប្រាក់បៀវត្សរ៍ ការប្រមូលទិន្នន័យ និងការប្រើប្រាស់ទិន្នន័យរដ្ឋបាល ការវិភាគ និងការផ្សព្វផ្សាយ ។ល។

ដើម្បីទទួលការប៉ាន់ស្មានមួយផ្សេងទៀតលើធនធានហិរញ្ញវត្ថុ ដែលត្រូវការសម្រាប់ស្ថិតិផ្លូវការនៅកម្ពុជា គំរូមួយត្រូវបានប្រើប្រាស់ដោយផ្អែកលើទិន្នន័យចំណាយដែលមានស្រាប់ពីវិទ្យាស្ថានជាតិស្ថិតិ ក្រសួងពាក់ព័ន្ធ និងអង្គភាពដែលបានចាត់តាំងដទៃទៀត និងអង្គភាពរដ្ឋាភិបាលមួយចំនួនផ្សេងទៀតដែលផលិតស្ថិតិ។ គួរប្រើប្រាស់គំរូរាយការណ៍ទិន្នន័យអំពីចំណាយ និងចំនួនមន្ត្រីផលិតស្ថិតិ ដើម្បីគណនាទិន្នន័យអំពីប្រាក់បៀវត្សរ៍។ នៅពេលទិន្នន័យនេះបាត់បង់ ទិន្នន័យពីផែនការមេស្ថិតិបច្ចុប្បន្នត្រូវបានប្រើប្រាស់។

ការចំណាយដែលបានគណនានៅឆ្នាំ២០១១ សម្រាប់ប្រព័ន្ធស្ថិតិជាតិមានប្រមាណ ៨,៥ លានដុល្លារអាមេរិក។ ការផ្តល់មូលនិធិសម្រាប់ទីប្រឹក្សាអន្តរជាតិត្រូវបានរួមបញ្ចូលក្នុងការប៉ាន់ស្មានសម្រាប់ឆ្នាំ២០១១ ហើយផ្នែកនេះនឹងថយចុះប្រមាណ ៥០ ភាគរយ នៅពេលការផ្តល់មូលនិធិរបស់អ្នកផ្តល់ជំនួយត្រូវបានបញ្ចប់។

តួលេខដែលបានគណនាហើយមិនរាប់បញ្ចូល ឬគ្របដណ្តប់ការចំណាយហេដ្ឋារចនាសម្ព័ន្ធឡើយ (ដូចជាការកសាងអគារ អត្ថប្រយោជន៍ កុំព្យូទ័រ ការបណ្តុះបណ្តាល) ការចំណាយមូលធន ឬចំណាយដឹកជញ្ជូន ឬតម្រូវការយានយន្តសម្រាប់សកម្មភាពទាំងនេះ។ មិនរាប់បញ្ចូលការចំណាយគ្រប់គ្រងរបស់មន្ត្រីជាន់ខ្ពស់ ឬការចំណាយផ្សេងៗឡើយ។

ថវិកាវិទ្យាស្ថានជាតិស្ថិតិដែលបានពិនិត្យឡើងវិញមាន ៦,៦ លានដុល្លារអាមេរិក មានជាង ៧៦ ភាគរយនៃថវិកាសរុប។

### ៥.១.៣ របាយការណ៍ប្រព័ន្ធស្ថិតិជាតិប្រចាំឆ្នាំ២០១៥ ដោយវិទ្យាស្ថានជាតិស្ថិតិ ខែធ្នូ ឆ្នាំ២០១៦

ថវិកាប៉ាន់ស្មានបានរាយការណ៍ ឬថវិកាជាក់ស្តែងដែលបានរាយការណ៍ក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៦ ក៏មានបង្ហាញការប៉ាន់ស្មានដោយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលផងដែរ ហើយមានតួលេខខ្ពស់ជាងដែលបានបង្ហាញនៅក្នុងតារាង។ ទោះជាយ៉ាងណាក៏ដោយ ក៏មានចម្លើយជាច្រើនដែលមិនបានឆ្លើយតប ប្រហែលដោយសារមិនមែនជាសំណួរពាក់ព័ន្ធនឹងសកម្មភាពស្ថិតិរបស់ពួកគេនៅក្នុងថវិការបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។ ចំពោះហេតុផលដែលបានលើកឡើងពីមុន ការប៉ាន់ស្មានអាចជាមុខចំណាយខុសគ្នា នៅពេលដែលសេចក្តីណែនាំសម្រាប់ថវិកាហិរញ្ញវត្ថុ និងរបាយការណ៍នៅមិនទាន់បានបង្កើត និងអនុវត្ត។

ការប៉ាន់ស្មានប្រចាំឆ្នាំក៏អាចនាំឱ្យមានការយល់ច្រឡំផងដែរ ដោយសារការធ្វើជំរឿន និងអង្កេតមិនមែនជាការងារតែមួយឆ្នាំ ហើយអាចត្រូវបានធ្វើជារៀងរាល់ឆ្នាំ ជារៀងរាល់ពីរឆ្នាំ ជារៀងរាល់បីឆ្នាំ រៀងរាល់បួនឆ្នាំ ឬរៀងរាល់ដប់ឆ្នាំផងដែរ។

## ៥.២ ការប៉ាន់ស្មានថវិកា ឆ្នាំ២០១៩ - ២០២៣

ការប៉ាន់ស្មានក្នុងឧបសម្ព័ន្ធ៣ គឺផ្អែកលើរបាយការណ៍ប្រទេសស្តីពីការគាំទ្រដល់ស្ថិតិ (CRESS) រៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គការភាពជាដៃគូក្នុងស្ថិតិសម្រាប់ការអភិវឌ្ឍក្នុងសតវត្សរ៍ទី២១ (PARIS21) នៅខែឧសភា ឆ្នាំ២០១៧ និងពីការឆ្លើយតបទៅនឹងបញ្ជីសំណួរដែលបានផ្ញើទៅក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

ទោះជាយ៉ាងណាក៏ដោយ ចំពោះកង្វះខាតការណែនាំច្បាស់លាស់អំពីរបៀបគណនាថវិកាដែលជាព័ត៌មានសំខាន់បំផុតក៏ដោយ ប៉ុន្តែជាទូទៅមកពីក្រសួងពាក់ព័ន្ធ។ ការរៀបចំកញ្ចប់ថវិកាតាមស្ថាប័ន (មាត្រា២១ ច្បាប់ស្តីពីស្ថិតិ) នឹងកែលម្អបានច្រើនដល់ដំណើរការ និងការប៉ាន់ស្មានថវិការបស់សកម្មភាពប្រព័ន្ធស្ថិតិជាតិ។

ថវិកាសរុបរបស់ប្រព័ន្ធស្ថិតិជាតិមានប្រមាណ ៥៨,៨ លានដុល្លារអាមេរិក ពីឆ្នាំ២០១៩-២០២៣។ វិទ្យាស្ថានជាតិស្ថិតិមានប្រមាណ ៧៦,៥ ភាគរយ នៃចំនួនសរុបនេះ។

## ៥.៣ ប្រតិទិននៃសកម្មភាព និងថវិការបស់វិទ្យាស្ថានជាតិស្ថិតិ

ថវិកាប៉ាន់ស្មានសម្រាប់វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០១៩-២០២៣ ត្រូវបានប៉ាន់ស្មាន ៤៤,៧ លានដុល្លារអាមេរិក ជាមួយការបែងចែកតាមឆ្នាំដូចខាងក្រោម ៖

| ឆ្នាំ | ថវិកាប្រចាំឆ្នាំប៉ាន់ស្មាន |
|---|---|
| ២០១៩ | ១៤,៩០៣,៩០០ ដុល្លារអាមេរិក |
| ២០២០ | ៧,១៧៧,៦០០ ដុល្លារអាមេរិក |
| ២០២១ | ៩,០២០,៩០០ ដុល្លារអាមេរិក |
| ២០២២ | ៤,៨១០,៦០០ ដុល្លារអាមេរិក |
| ២០២៣ | ៨,៧៨៦,២០០ ដុល្លារអាមេរិក |

ថវិកាសរុបរបស់ប្រព័ន្ធស្ថិតិជាតិត្រូវបានប៉ាន់ស្មានប្រមាណ ៥៨,៨ លានដុល្លារអាមេរិក ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣។ វិទ្យាស្ថានជាតិស្ថិតិមានប្រមាណ ៧៦,៥ ភាគរយ នៃចំនួនសរុបនេះ។ ការប៉ាន់ស្មានទាំងនេះមាន

នៅក្នុងឧបសម្ព័ន្ធ៣ គឺផ្អែកលើរបាយការណ៍ប្រទេសស្តីពីការគាំទ្រដល់ស្ថិតិ (CRESS) រៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គការភាពជាដៃគូក្នុងស្ថិតិសម្រាប់ការអភិវឌ្ឍក្នុងសតវត្សរ៍ទី២១ (PARIS21) នៅខែឧសភា ឆ្នាំ២០១៧ និងពីចម្លើយក្នុងបញ្ជីសំណួរដែលបានផ្ញើទៅបណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។[៤៩]

ថវិកាប៉ាន់ស្មានសម្រាប់វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០១៩-២០២៣ ប៉ាន់ស្មានប្រមាណ ៤៤,៧ លានដុល្លារអាមេរិក ដោយបានបែងចែកតាមឆ្នាំដូចតទៅ ៖ ឆ្នាំ២០១៩ ប្រមាណ ១៤,៩០៣,៩០០ដុល្លារអាមេរិក ឆ្នាំ២០២០ ប្រមាណ ៧,១៧៧,៦០០ដុល្លារអាមេរិក ឆ្នាំ២០២១ ប្រមាណ ៩,០២០,៩០០ដុល្លារអាមេរិក ឆ្នាំ២០២២ ប្រមាណ ៤,៨១០,៦០០ដុល្លារអាមេរិក និងឆ្នាំ២០២៣ ប្រមាណ ៨,៧៨៦,២០០ ដុល្លារអាមេរិក។

ថវិកាប៉ាន់ស្មានសម្រាប់ការធ្វើជំរឿនប្រជាជនឆ្នាំ២០១៩ មាន ៨,៧លានដុល្លារអាមេរិក និងជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២១ មានប្រមាណ ៤,៥លានដុល្លារអាមេរិក។ ថវិកាជំរឿនប្រជាជនឆ្នាំ២០១៩ មាន ៨,៧លានដុល្លារអាមេរិក រួមមានចំណាយលើសកម្មភាពរៀបចំ ១,៣លានដុល្លារអាមេរិក និងប្រតិបត្តិការជំរឿននៅឆ្នាំ២០១៩ ចំណាយ៧,៤ លានដុល្លារអាមេរិក។

ថវិការអង្កេតរួមមាន ៖ អង្កេតសេដ្ឋកិច្ចសង្គមកិច្ច (ឆ្នាំ២០១៩-២០២៣) ចំណាយ ៤,៧លានដុល្លាអាមេរិក អង្កេតប្រជាសាស្ត្រ និងសុខភាព (ឆ្នាំ២០២០) ចំណាយ ៥,៧លានដុល្លារអាមេរិក អង្កេតចន្លោះជំរឿនកសិកម្ម (ឆ្នាំ ២០១៩) ចំណាយ ១,៧លានដុល្លារអាមេរិក អង្កេតសេដ្ឋកិច្ចប្រចាំឆ្នាំចំណាយ ៦០០ពាន់ដុល្លារអាមេរិក អង្កេតពិការភាពថ្នាក់ជាតិ (ឆ្នាំ២០២១) ចំណាយ ៦៥៣ពាន់ដុល្លារអាមេរិក អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារ (ឆ្នាំ ២០១៩ ២០២១ ២០២៣) ចំណាយ ៩០០ពាន់ដុល្លារអាមេរិក អង្កេតអំពើហឹង្សាលើរាងកាយកុមារ (ឆ្នាំ២០២១) ចំណាយ ៤៥០ពាន់ដុល្លារអាមេរិក អង្កេតប្រជាជនអាយុចាស់ (ឆ្នាំ២០២១) ចំណាយ ៣៩០ពាន់ដុល្លារអាមេរិក និង អង្កេតថ្នាំជក់ទូទៅថ្នាក់ជាតិ (ឆ្នាំ២០១៩) ចំណាយ ៣៦០ពាន់ដុល្លារអាមេរិក។

លើសពីនេះទៀត ថវិកាប្រចាំឆ្នាំប្រមាណ ៤៥០ពាន់ដុល្លារអាមេរិក ត្រូវបានស្នើឡើងសម្រាប់ការកសាងសមត្ថភាពរបស់ប្រព័ន្ធស្ថិតិជាតិស្តីពីការវាស់វែងសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ការតាមដាន ការរាយការណ៍ និងការផ្សព្វផ្សាយ។ សកម្មភាពស្ថិតិ និងការផលិតស្ថិតិដទៃទៀតរបស់វិទ្យាស្ថានជាតិស្ថិតិត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ ៦ ។

**បញ្ហាទី២.** តើរាជរដ្ឋាភិបាលចំណាយគ្រប់គ្រាន់សម្រាប់សកម្មភាពស្ថិតិដែរឬទេ?

ដោយសន្មតថាការប៉ាន់ស្មានក្នុងឧបសម្ព័ន្ធ ៨ មានប្រភព និងបានគណនាសមហេតុផល ដែលបង្ហាញជាក់ស្តែង លើកលែងវិទ្យាស្ថានជាតិស្ថិតិ សកម្មភាពស្ថិតិនៅក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលទទួលបានការបែងចែកតិចជាង ១ ភាគរយ (ជាក់ស្តែងកម្រិតខ្ពស់បំផុតគួរនៅពាក់កណ្តាលនៃមួយភាគរយ) នៃថវិកាសរុប។

រាល់ ១០០,០០ ដុល្លាអាមេរិក បានបែងចែកទៅក្រសួងមួយ តិចជាង ០,២៥ ដុល្លាអាមេរិក សម្រាប់សកម្មភាពស្ថិតិ (និងការតាមដាន និងវាយតម្លៃផ្អែកលើជាក់ស្តែង)។ មិនគ្រប់គ្រាន់...

[៤៩] ការប៉ាន់ស្មានទាំងនេះដែលបានបង្ហាញ និងភាពមិនច្បាស់លាស់ និងកង្វះភាពហ្មត់ចត់ គឺស្ថិតក្នុងចំណោមបញ្ហាជាច្រើនទៀត ដោយសារតែជាទូទៅគ្មានព័ត៌មានជាក់លាក់ដែលអាចរកបានលើសកម្មភាពផ្សេងៗ ដែលបានអនុវត្តនៅក្នុងប្រព័ន្ធស្ថិតិជាតិ (NSS) នៃការផលិតស្ថិតិ ឬវិធីគណនាជាលក្ខណៈស្តង់ដារ និងរបាយការណ៍ចំណាយអំពីបៀវត្សរ៍ ការប្រមូលទិន្នន័យ និងការប្រើប្រាស់ទិន្នន័យរដ្ឋបាល ការវិភាគ និងការផ្សព្វផ្សាយ ។ល។ ការរៀបចំកញ្ចប់ថវិកាសម្រាប់ស្ថាប័ន (មាត្រា ២១ ច្បាប់ស្តីពីស្ថិតិ) នឹងបានល្អប្រសើរនូវដំណើរការថវិកា និងការប៉ាន់ស្មានសកម្មភាពប្រព័ន្ធស្ថិតិជាតិ។

# ជំពូក ៦ និរន្តរភាព

វឌ្ឍនភាពនៃប្រព័ន្ធស្ថិតិជាតិត្រូវមាននិរន្តរភាព និងធ្វើឱ្យប្រសើរឡើងដល់និរន្តរភាពរបស់ខ្លួន ជំពូកនេះនឹងពិនិត្យទៅលើហានិភ័យដែលពាក់ព័ន្ធនឹងការរៀបចំអភិបាលកិច្ច និងកម្មវិធីតាមដាន និងវាយតម្លៃក្នុងអំឡុងពេលអនុវត្តន៍។

## ៦.១ បញ្ហា និងហានិភ័យ

នៅក្នុងផែនការមេស្ថិតិ និងរបាយការណ៍ពាក់កណ្តាលអាណត្តិ មានហានិភ័យមួយចំនួនត្រូវបានកំណត់។ នៅពេលដែលហានិភ័យត្រូវបានកំណត់ និងរៀបចំផែនការទុកជាមុន នោះនឹងទទួលបានឱកាសជោគជ័យកាន់តែច្រើន។ ជាមួយការរកឃើញថ្មីៗនេះ ហានិភ័យដែលទាក់ទងនឹងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិត្រូវបានពិភាក្សាដូចខាងក្រោម។ ជាការពិត វាអាចមានហានិភ័យផ្សេងទៀតដែលមិនទាន់កំណត់បាន។

- ការប្តេជ្ញាចិត្ត និងភាពជាម្ចាស់នៃប្រព័ន្ធស្ថិតិជាតិ ដើម្បីអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិនៅមានកម្រិត។
- សមត្ថភាពនៃការចាត់ចែង និងធនធានមនុស្សក្នុងប្រព័ន្ធស្ថិតិជាតិនៅមានកម្រិត។
- វិធីសាស្ត្ររួមបញ្ចូលគ្នាក្នុងតួនាទីរបស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាក្នុងប្រព័ន្ធស្ថិតិជាតិមិនទាន់សមស្រប។
- ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងប្រព័ន្ធស្ថិតិជាតិ និង/ឬភាគីពាក់ព័ន្ធមិនទាន់បានល្អ។
- រចនាសម្ព័ន្ធ និងដំណើរការមិនគ្រប់គ្រាន់សម្រាប់ទំនាក់ទំនង ការផ្សព្វផ្សាយ និងការគាំទ្រប្រកបដោយប្រសិទ្ធភាព។
- ការគ្រប់គ្រងធនធាននៅមានកម្រិត (ហិរញ្ញវត្ថុ និងភ័ស្តុភារ)។

ហានិភ័យទាំងនេះនៅតែមាន និងគិតថានឹងបន្តកើតមានក្នុងអំឡុងពេលអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។

| ហានិភ័យចម្បង | ឥទ្ធិពលមានសក្តានុពលទៅលើសមិទ្ធផលនៃគោលដៅ (ភាគច្រើន មធ្យម ភាគតិច) | លទ្ធភាពដែលព្រឹត្តិការណ៍នឹងកើតឡើង (ខ្ពស់ មធ្យម ទាប) | វិធានការបន្ថយហានិភ័យ យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ |
|---|---|---|---|
| ការប្តេជ្ញាចិត្ត និងភាពជាម្ចាស់នៃប្រព័ន្ធស្ថិតិជាតិ ដើម្បីអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិនៅមានកម្រិត | **ភាគច្រើន** ៖ ប្រព័ន្ធស្ថិតិជាតិមិនបានជម្រុញឱ្យអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។ | **មធ្យម** ៖ វិទ្យាស្ថានជាតិស្ថិតិបានទទួលស្គាល់តម្រូវការលើកកម្ពស់ទាំងនេះដល់ភាគីពាក់ព័ន្ធនៅគ្រប់កម្រិត។ | ប្រព័ន្ធស្ថិតិជាតិបានចូលរួមយ៉ាងច្រើនក្នុងដំណើរការវាយតម្លៃ និងកំណត់ជាក់លាក់ក្នុងការរៀបចំយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។ យុទ្ធសាស្ត្របញ្ជាក់ពីសកម្មភាព និងតួនាទី និងការទទួលខុសត្រូវរបស់សមាសធាតុនៃប្រព័ន្ធស្ថិតិជាតិ។<br>លេខាធិការដ្ឋានធ្វើការពេញម៉ោងមួយគួរត្រូវបានបង្កើត ដើម្បីគ្រប់គ្រងដំណើរការផ្លាស់ប្តូរ។ ផ្តល់អនុសាសន៍បង្កើតក្រុមការងារបច្ចេកទេសតាមប្រធានបទតាមរយៈក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ ដើម្បីជួយដល់វិទ្យាស្ថានជាតិស្ថិតិត្រួតពិនិត្យការអនុវត្តរបស់ខ្លួនជាប្រចាំ។ |
| សមត្ថភាពនៃការចាត់ចែង និងធនធានមនុស្សក្នុងប្រព័ន្ធស្ថិតិជាតិនៅមានកម្រិត | **ភាគច្រើន** ៖ វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំងមានលទ្ធភាពតិចតួចចូលរួមក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ដោយសារខ្វះស្វ័យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស និងខ្វះបទពិសោធន៍ក្នុងការរៀបចំគោលនយោបាយ និងផែនការស្ថិតិ។ | **មធ្យម** ៖ អគ្គនាយកគួរអនុវត្តសិទ្ធិអំណាចយោងតាមតំណែងរបស់ខ្លួន[៥០]<br>**មធ្យម** ៖ ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិគួរផ្តល់នូវឋានៈ និងបរិយាកាសចាំបាច់ដល់អង្គភាពស្ថិតិដែលបានចាត់តាំង ដើម្បីដើរតួនាទីជាអ្នកអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។ | ពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធ និងសិទ្ធិអំណាចរបស់វិទ្យាស្ថានជាតិស្ថិតិក្នុងកិច្ចសហការជាមួយក្រសួងផែនការ។<br>បង្កើតការគាំទ្រអង្គភាពស្ថិតិដែលបានចាត់តាំងនៅក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល តាមរយៈក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ។ |
| | **ភាគច្រើន** ៖ វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំងមានលទ្ធភាពតិចតួចធ្វើអង្កេតថ្មីពីការរៀបចំរហូតដល់ការវិភាគ ដោយសារខ្វះមន្ត្រីបច្ចេកទេស និងជំនាញ។ | **ខ្ពស់** ៖ យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិតម្រូវឱ្យមានការកើនឡើងខ្លាំងនៅក្នុងបរិមាណ និងគុណភាពនៃមន្ត្រីជំនាញនៅក្នុងប្រព័ន្ធស្ថិតិជាតិ។ | ការកសាងសមត្ថភាពទូលំទូលាយមួយក្នុងប្រព័ន្ធស្ថិតិជាតិត្រូវបានបង្កើត និងអនុវត្តជំនួយបច្ចេកទេស និងការផ្ទេរបច្ចេកវិទ្យាដោយការពិចារណា។ |
| វិធីសាស្ត្ររួមបញ្ចូលគ្នាក្នុងតួនាទីរបស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាក្នុងប្រព័ន្ធស្ថិតិជាតិមិនទាន់សមស្រប | **មធ្យម** ៖ ពុំសូវមានលទ្ធភាពផ្តល់លទ្ធផលមានគុណភាពដោយសារវិធីសាស្ត្រដោយឡែកនៃការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាក្នុងការប្រតិបត្តិ និងការរក្សាទុក។ | **ខ្ពស់** ៖ បញ្ហាអាចគ្រោះថ្នាក់ និងត្រូវដោះស្រាយនៅដំណាក់កាលដំបូងនៃគម្រោង។ | ការវាយតម្លៃ FIDES បានបង្ហាញពីជំហានដែលត្រូវអនុវត្ត។ ទាំងនេះត្រូវតែដោះស្រាយ និង/ឬអនុវត្ត។ |
| ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងប្រព័ន្ធស្ថិតិជាតិ និង/ឬភាគីពាក់ព័ន្ធមិនទាន់បានល្អ | **ភាគច្រើន** ៖ ប្រព័ន្ធស្ថិតិជាតិមានលទ្ធភាពតិចតួចផ្តោតលើសកម្មភាពអាទិភាព និងការអនុវត្តគម្រោង | **មធ្យម** ៖ ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិគួរតែជំរុញកិច្ចសហប្រតិបត្តិការ និងការ | ផ្តល់អនុសាសន៍ឱ្យបង្កើតក្រុមការងារបច្ចេកទេសតាមវិស័យ តាមរយៈក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ ដើម្បីជួយដល់វិទ្យាស្ថានជាតិស្ថិតិត្រួតពិនិត្យការអនុ |

[៥០] ងារស្របទៅនឹងដំណែង។ ច្បាប់ស្តីពីស្ថិតិដែលបានធ្វើបច្ចុប្បន្នកម្មនៅឆ្នាំ២០១៥ អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិត្រូវបានឱ្យងារជា "ប្រធានមន្ត្រីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា" និងបច្ចុប្បន្នជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ។

| ហានិភ័យចម្បង | ឥទ្ធិពលមានសក្តានុពលទៅលើសមិទ្ធិផលនៃគោលដៅ (ភាគច្រើន មធ្យម ភាគតិច) | លទ្ធភាពដែលព្រឹត្តិការណ៍នឹងកើតឡើង (ខ្ពស់ មធ្យម ទាប) | វិធានការបន្ថយហានិភ័យយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ |
|---|---|---|---|
| | | សម្របសម្រួលស្ថាប័ននៅក្នុងប្រព័ន្ធស្ថិតិជាតិ។ | វគ្គយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិជាប្រចាំ។<br>ផ្តល់អនុសាសន៍ឱ្យបង្កើតក្រុមការងារបច្ចេកទេសមួយ បើចាំបាច់ ដើម្បីសម្រះសម្រួលជំនួយអភិវឌ្ឍន៍សម្រាប់យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។ |
| រចនាសម្ព័ន្ធ និងដំណើរការមិនគ្រប់គ្រាន់ សម្រាប់ទំនាក់ទំនង ការផ្សព្វផ្សាយ និងការគាំទ្រប្រកបដោយប្រសិទ្ធភាព | **ភាគច្រើន ៖** ពុំសូវមានលទ្ធភាពលើកកម្ពស់វឌ្ឍនភាពក្នុងការអភិវឌ្ឍកិច្ចដំណើរការទំនាក់ទំនង និងវេបសាយដោយសារខ្វះមន្ត្រីជំនាញ។ | **មធ្យម ៖** វិទ្យាស្ថានជាតិស្ថិតិត្រូវការជំនួយបច្ចេកទេសក្នុងការធ្វើបច្ចុប្បន្នកម្មទីតាំង និងរៀបចំផែនការទំនាក់ទំនង។ | គាំទ្រក្នុងបញ្ហាចាត់ចែង និងណែនាំប្រកបដោយវិជ្ជាជីវៈ តាមរយៈក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ។ |
| | **ភាគច្រើន ៖** ព័ត៌មានស្ថិតិពីបណ្តានាយកដ្ឋានត្រូវការធ្វើបច្ចុប្បន្នកម្មវេបសាយរបស់វិទ្យាស្ថានជាតិស្ថិតិ។ អង្គភាពស្ថិតិដែលបានចាត់តាំងគួរធ្វើបច្ចុប្បន្នកម្មវេបសាយរបស់ខ្លួន។ | **មធ្យម ៖** ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិគួរធានាថាមានការផ្សព្វផ្សាយ និងគោលនយោបាយប្រើប្រាស់ទិន្នន័យសមស្របក្នុងការរកបាន និងទទួលបានទិន្នន័យ។ | គាំទ្រដោយក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិក្នុងការបង្កើតក្រុមការងារពីនាយកដ្ឋាននានា។ |
| ការគ្រប់គ្រងធនធាននៅមានកម្រិត (ហិរញ្ញវត្ថុ និងភស្តុភារ) | **ខ្ពស់ ៖** វិទ្យាស្ថានជាតិស្ថិតិនឹងត្រូវការការផ្តល់មូលនិធិសម្រាប់ការប្រមូលទិន្នន័យនៃសកម្មភាពអាទិភាព។ | យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិមានបំណងជំរុញសេចក្តីត្រូវការក្នុងចំណោមអ្នកផ្តល់មូលនិធិ (រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍) ដើម្បីទិន្នន័យមានគុណភាព តាមរយៈការប្តេជ្ញាចិត្ត និងភាពជាម្ចាស់នៃយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ការសម្របសម្រួល ការផ្សព្វផ្សាយ និងទំនាក់ទំនងក្នុងចំណោមអ្នកផ្គត់ផ្គង់ទិន្នន័យផ្សេងៗ។ ការផ្តោតលើការផ្តល់ និងទំនាក់ទំនងស្ថិតិដល់អ្នកប្រើប្រាស់ក៏ជាកត្តាបន្ធូរបន្ថយមួយ (ទោះបីជាក្នុងរយៈពេលវែង) និងរង់ចាំមើលតម្រូវការស្ថិតិផ្លូវការបន្ថែមទៀត។ | |

## ៦.២ ការរៀបចំអភិបាលកិច្ចសម្រាប់យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ

ចាប់ពីគោលដៅយុទ្ធសាស្ត្ររហូតដល់ផែនការសកម្មភាពទៅការអនុវត្ត តួនាទីរបស់វិទ្យាស្ថានជាតិស្ថិតិដែលនាំមុខក្នុងដំណើរការយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ គឺជាគន្លឹះនាំមកជោគជ័យនៃយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។ វិទ្យាស្ថានជាតិស្ថិតិស្ថិតនៅក្រោមក្រសួងផែនការបានបង្ហាញបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ប៉ុន្តែវាអាចលើសពីសមត្ថភាពរបស់វិទ្យាស្ថានជាតិស្ថិតិ។ ដើម្បីភ្ជាប់ជាផ្លូវការជាមួយអង្គភាពស្ថិតិដែលបានចាត់តាំងនៅក្រោមក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល វាត្រូវឆ្លងកាត់ច្រកតាមរយៈក្រសួងផែនការ ហើយបន្ទាប់មកទៅក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលដែលភ្ជាប់វាទៅអង្គភាពស្ថិតិដែលបានចាត់តាំង។ វាមានភាពត្រឹមត្រូវដែលមន្ត្រីបច្ចេកទេសធ្វើការផ្លាស់ប្តូរក្រៅផ្លូវការនូវកំណត់ត្រា និងទិន្នន័យ ប៉ុន្តែបញ្ហាគោលនយោបាយដូចជាការកំណត់បទដ្ឋាន និងចំណាត់ថ្នាក់ និងការសម្រេចថវិកាត្រូវបានពិភាក្សា និងចរចារនៅថ្នាក់ខ្ពស់។

ច្បាប់ស្តីពីស្ថិតិផ្តល់ឱ្យក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ ដើម្បីដោះស្រាយកិច្ចការគោលនយោបាយ ផែនការ និងវិធីនៅក្នុងប្រព័ន្ធស្ថិតិជាតិ ដូច្នេះវិទ្យាស្ថានជាតិស្ថិតិមានស្ថាប័នកម្រិតខ្ពស់ទាំងនេះដើម្បីជាធនធាន។ គោលការណ៍ចំពោះស្ថាប័នគោលនយោបាយ និងសម្របសម្រួលកម្រិតខ្ពស់ទាំងនេះនឹងក្លាយទៅជាបណ្តាញបច្ចេកទេសមួយមានមុខងាររៀបចំភារកិច្ច និងរបៀបវារៈកិច្ចប្រជុំ និងឯកសារការងារដែលទាំងនេះមិនជួបញឹកញាប់ឡើយ។ វិទ្យាស្ថានជាតិស្ថិតិនឹងត្រូវពិគ្រោះយោបល់ជាទៀងទាត់ជាមួយអង្គភាពស្ថិតិដែលបានចាត់តាំង ដើម្បីទទួលកិច្ចការសំខាន់ៗសម្រាប់ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិធ្វើសកម្មភាព ក្នុងកិច្ចប្រជុំរបស់ពួកគេ។ ការរៀបចំអភិបាលកិច្ចមួយត្រូវបានស្នើសុំ (រូប២) ដែលចាត់ទុកថាមានក្រុមការងារបច្ចេកទេសអន្តរស្ថាប័នសមស្របមួយចំនួន ដែលអ្នកវិភាគ និងអ្នកជំនាញពិភាក្សាគ្នាអំពីបញ្ហា និងដំណោះស្រាយនៅក្នុងប្រព័ន្ធស្ថិតិជាតិ សម្រាប់សម្រេចបញ្ចប់ និងធ្វើសេចក្តីសម្រេចដោយក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ។

សូមកត់សម្គាល់ថា តាមនីតិប្បញ្ញត្តិក្រុមប្រឹក្សាស្ថិតិមានកម្រិតខ្ពស់ជាងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។ ខណៈសមាសភាពនៃសមាជិកភាពមានថ្នាក់ជារដ្ឋលេខាធិការ ក្រុមប្រឹក្សាស្ថិតិគឺជាស្ថាប័នអន្តរក្រសួងមួយដែលទទួលប្រយោជន៍ពីការចូលរួមរបស់ក្រសួងជាច្រើន។ ដូចគ្នានេះក៏អាចនិយាយបានចំពោះគណៈកម្មាធិការសម្របសម្រួលស្ថិតិដែលមានសមាជិកភាពអន្តរក្រសួង។ ប៉ុន្តែការពឹងផ្អែកលើស្ថាប័នដែលមិនបានជួបញឹកញាប់អាចមានការយឺតយ៉ាវក្នុងការបង្កើតគោលនយោបាយ និងការអនុវត្តផែនការ និងកម្មវិធី។ វិទ្យាស្ថានជាតិស្ថិតិជាមួយជំនួយការនៃក្រុមការងារបច្ចេកទេសអាចធានាដល់ការរៀបចំរបៀបវារៈ និងកម្មវិធីការងារបានល្អប្រសើរ សម្រាប់ការធ្វើសេចក្តីសម្រេចប្រកបដោយប្រសិទ្ធភាពដោយស្ថាប័នទាំងនេះ។

ការរៀបចំក៏លើកទឹកចិត្តដល់អន្តរកម្មជាទៀងទាត់របស់ប្រព័ន្ធស្ថិតិជាតិជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីសម្រុះសម្រួលផ្តល់ការគាំទ្រធនធាន និងជំនាញការដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។

រូប១ ៖ ក្របខ័ណ្ឌរចនាសម្ព័ន្ធរបស់ប្រព័ន្ធស្ថិតិជាតិកម្ពុជា




រូប២ ៖ ការរៀបចំសំណើអភិបាលកិច្ចសម្រាប់ការអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ



**បញ្ហាទី៣.** តើប្រព័ន្ធស្ថិតិជាតិឆ្ពោះទៅមជ្ឈការឬទេ?

**ការពិត ៖** ថវិការបស់វិទ្យាស្ថានជាតិស្ថិតិក្នុងរយៈពេលជាច្រើនឆ្នាំមានកម្រិតពី ៦០-៧៥ ភាគរយ នៃថវិកាសរុបរបស់ប្រព័ន្ធស្ថិតិជាតិ តាំងពីឆ្នាំ២០០៦។

**ការពិត ៖** វិទ្យាស្ថានជាតិស្ថិតិមានមន្ត្រី ៦១-៦៦ ភាគរយ នៃមន្ត្រីស្ថិតិសរុបនៅក្នុងប្រព័ន្ធស្ថិតិជាតិ។

**ការពិត ៖** រាជរដ្ឋាភិបាលបែងចែកតែ ០,២៥ ភាគរយ នៃការបែងចែកសរុបឱ្យទៅស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។

ជាបញ្ហាមួយរបស់គោលនយោបាយ និងយុទ្ធសាស្ត្រ តើធនធានបែងចែកដ៏តិចតួចសម្រាប់ការកសាងសមត្ថភាព ដែលអាចមានចំណាយច្រើនជាង និងមិនទូលំទូលាយស្ថិតនៅក្រោមការរៀបចំបច្ចុប្បន្នឬទេ? ប្រហែលជាក្រុមពហុវិស័យ អាចរកឃើញនូវអ្វីដែលអាចរៀបចំឱ្យកាន់តែមានប្រសិទ្ធភាព សម្រាប់ប្រព័ន្ធស្ថិតិជាតិក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។

## ៦.៣ ការតាមដាន និងវាយតម្លៃ

ក្របខ័ណ្ឌសកម្មភាពត្រូវបានរៀបចំ ដើម្បីណែនាំការតាមដាន និងវាយតម្លៃយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិដូចបានបង្ហាញខាងក្រោម។ ចំពោះគោលដៅយុទ្ធសាស្ត្រនីមួយៗ សកម្មភាពត្រូវបានកំណត់ជាមួយលទ្ធផលរំពឹងទុកដែលបានបញ្ជាក់ បង្ហាញភស្តុតាងដោយសូចនាករ និងមធ្យោបាយនៃការផ្ទៀងផ្ទាត់ទាំងនេះ។ លេខាធិការដ្ឋានយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិគួរតែជូនដំណឹងដល់អ្នកអនុវត្តន៍នូវសកម្មភាពនាពេលខាងមុខ និងតាមដានកិច្ចការនេះដោយអនុលោមទៅតាមក្របខ័ណ្ឌដូចបានបង្ហាញខាងក្រោម។

ការវាយតម្លៃផែនការគួរតែប្រព្រឹត្តទៅនៅចុងបញ្ចប់នៃរយៈពេលយុទ្ធសាស្ត្រ។ ពេលវេលាគួរតែត្រូវបានធ្វើសមកាលកម្មជាមួយរបាយការណ៍ជាយុទ្ធសាស្ត្រផ្សេងទៀត (ឧទាហរណ៍ របាយការណ៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឬផែនការចំណាយរដ្ឋាភិបាល)។ របាយការណ៍ពាក់កណ្តាលអាណត្តិគួរតែកើតឡើងក្រោយឆ្នាំ២០២០។ ក៏ត្រូវផ្តល់អនុសាសន៍ដែរ ថាការងារជាមួយយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិថ្មីចាប់ផ្តើមក្នុងឆ្នាំ២០២១ ឬយ៉ាងយូរបំផុតដើមឆ្នាំ២០២២ ដោយផ្អែកលើយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិនេះជាមូលដ្ឋាន និងយកគុណប្រយោជន៍ពីលទ្ធផលនៃរបាយការណ៍ពាក់កណ្តាលអាណត្តិ។

# ក្របខ័ណ្ឌសកម្មភាព (កំណត់ត្រាសកម្មភាព) នៃយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាព | លទ្ធផលរំពឹងទុក | សូចនករលទ្ធផល | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|
| អភិវឌ្ឍ អនុវត្ត និងថែរក្សានូវសំណុំទិន្នន័យស្នូលដែលមានគុណភាពខ្ពស់[៥១] ដោយគ្រប់ស្ថាប័នទាំងអស់នៃប្រព័ន្ធស្ថិតិជាតិ ក្រោមការដឹកនាំរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការស្ថិតិនៃកិច្ចដំណើរការអភិវឌ្ឍន៍ដែលកើតចេញពីការប្តេជ្ញានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការយុទ្ធសាស្ត្រអាស៊ានតាមផ្នែក និងតម្រូវការរបស់អ្នកប្រើប្រាស់ដទៃទៀត។ | ១. រួមបញ្ចូលយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ | ការប្រតិបត្តិរបស់ប្រព័ន្ធស្ថិតិជាតិត្រូវបានភ្ជាប់ទៅនឹងគោលនយោបាយអភិវឌ្ឍន៍។ | ជំពូក/ផ្នែកសំខាន់ៗសម្រាប់ស្ថិតិក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នៅឆ្នាំ២០២០ | ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| | ២. ដឹកនាំការស្វែងរកគ្រប់លទ្ធភាពទាំងអស់សម្រាប់ពង្រីកការប្រើប្រាស់កំណត់ត្រារដ្ឋបាល ប្រព័ន្ធព័ត៌មានគ្រប់គ្រង និងធាតុនៃទិន្នន័យធំទូលាយ (Big Data) ជាប្រភពនៃទិន្នន័យសម្រាប់គោលបំណងស្ថិតិ ដើម្បីបំពេញចន្លោះខ្វះខាត និងជាពិសេសជាប្រភពសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងទិន្នន័យបំបែក (តាមភេទ ក្រុមអាយុ ពិការភាព និងថ្នាក់ក្រោមជាតិ)។ | ស្ថិតិដែលបានចាត់តាំងត្រូវបានពង្រីក ដើម្បីបំពេញចន្លោះខ្វះខាតទិន្នន័យ។ ទិន្នន័យច្រើនទៀតត្រូវបានបំបែកជាពិសេសសម្រាប់សូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ | បន្ថែមការបំបែកទៅសំណុំទិន្នន័យ ចាប់ផ្តើមពីឆ្នាំ២០២០ ធ្វើបច្ចុប្បន្នកម្មគោលនយោបាយស្តីពីស្ថិតិដែលបានចាត់តាំង | ឯកសារគោលនយោបាយការបោះពុម្ពផ្សាយស្ថិតិ ឯកសារប្រើប្រាស់ជាសាធារណៈ |
| | ៣. ធ្វើផែនការវាយតម្លៃ សម្របសម្រួល និងធ្វើឱ្យស្របច្បាប់នូវសំណុំទិន្នន័យពីអង្គការផ្សេងៗ ដូចជាវិទ្យាស្ថានស្រាវជ្រាវ សមាគមវិជ្ជាជីវៈ និងអង្គការមិនមែនរដ្ឋាភិបាល។ | | ការវាយតម្លៃគុណភាពសំណុំទិន្នន័យពីប្រភពមិនមែនរដ្ឋាភិបាល នៅឆ្នាំ២០២២ | របាយការណ៍វាយតម្លៃ |
| | ៤. បង្កើតបញ្ជីរាយឈ្មោះករណីដែលបទដ្ឋាន និងចំណាត់ថ្នាក់អន្តរជាតិមិនត្រូវបានអនុវត្តក្នុងប្រព័ន្ធស្ថិតិជាតិ និងបង្កើតផែនការសម្រាប់ការអនុវត្តរបស់វា។ | គុណភាពស្ថិតិប្រព័ន្ធស្ថិតិជាតិត្រូវបានជំរុញដើម្បីជួយក្នុងការអភិវឌ្ឍ។ | ផែនការអនុវត្តបទដ្ឋាន និងចំណាត់ថ្នាក់អន្តរជាតិ នៅឆ្នាំ២០២២ | បញ្ជីរាយឈ្មោះ ឯកសារផែនការ |
| | ៥. អភិវឌ្ឍ និងយល់ព្រមតាមក្របខ័ណ្ឌធានាគុណភាពទិន្នន័យ។ | | អនុម័តក្របខ័ណ្ឌវាយតម្លៃគុណភាពទិន្នន័យ (DQAF) នៅឆ្នាំ២០២១ | ឯកសារក្របខ័ណ្ឌធានាគុណភាពទិន្នន័យ (DQAF) សៀវភៅណែនាំ DQAF |
| | ៦. ផលិតម៉េតាទិន្នន័យសមស្របសម្រាប់វិស័យទាំងអស់នៃស្ថិតិ និងធ្វើវាឱ្យបានទៅអ្នកប្រើប្រាស់។ | | អនុម័តសេចក្តីណែនាំអនុវត្តន៍សម្រាប់ការផ្តល់ម៉េតាទិន្នន័យ ដើម្បីចេញផ្សាយលទ្ធផល នៅឆ្នាំ២០២០ | សៀវភៅណែនាំម៉េតាទិន្នន័យ |

[៥១] ភាពសំខាន់ ភាពទាន់ពេលវេលា ភាពគួរទុកចិត្តបាន ភាពទទួលបាន។

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាព | លទ្ធផលរំពឹងទុក | សូចនករលទ្ធផល | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|
| | ៧. បង្កើតសេចក្ដីណែនាំគោលនយោបាយច្បាស់លាស់មួយ និងកម្មវិធីសម្រាប់អភិវឌ្ឍន៍ស្ថិតិថ្នាក់ក្រោមជាតិ។ | ការផលិតស្ថិតិសម្រាប់ខេត្ត និងឃុំត្រូវបានកំណត់ជាអាទិភាព ដោយគោលនយោបាយ និងអនុវត្តដោយប្រព័ន្ធស្ថិតិជាតិ។ | អនុម័តគោលនយោបាយ និងកម្មវិធីសម្រាប់ស្ថិតិថ្នាក់ក្រោមជាតិ នៅឆ្នាំ ២០២០ | ឯកសារគោលនយោបាយ និងកម្មវិធី |
| | ៨. បញ្ច្រាបសូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ទៅក្នុងសកម្មភាពស្ថិតិថ្នាក់ជាតិ វិស័យ និងថ្នាក់ក្រោមជាតិ តាមរយៈ អនុក្រុមការងារបច្ចេកទេសផែនការ និងកាត់បន្ថយភាពក្រីក្រ (TWG-PPR) អំពីទិន្នន័យសម្រាប់ការអភិវឌ្ឍ ឬក្រុមការងារបច្ចេកទេសសមស្របដទៃទៀតដែលត្រូវបានបង្កើតដោយក្រុមប្រឹក្សាស្ថិតិ/គណៈកម្មាធិការសម្របសម្រួលស្ថិតិ។ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពត្រូវបានរួមបញ្ចូលគ្នាជាផ្លូវការ និងត្រួតពិនិត្យដោយក្រុមអន្តរស្ថាប័ន។ | បង្កើតក្រុមការងារបច្ចេកទេស ដើម្បីត្រួតពិនិត្យការបញ្ច្រាបសូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅក្នុងសកម្មភាពស្ថិតិ នៅឆ្នាំ ២០២០ | អនុស្សរណៈ/សេចក្ដីសម្រេចបង្កើតក្រុមការងារបច្ចេកទេស |
| | ៩. អភិវឌ្ឍ និងអនុវត្តផែនការជាក់លាក់[៥២] ដើម្បីកែលម្អស្ថិតិសេដ្ឋកិច្ច បរិស្ថាន និងហិរញ្ញវត្ថុ រួមទាំងគណនេយ្យជាតិ ថ្លៃ ជញ្ជីងទូទាត់ និងស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ ដើម្បីធ្វើវាកាន់តែទាន់ពេលវេលា គុណភាពជាងមុន និងភាពសំខាន់ជាងមុន។<br>៩.១. អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាប្រចាំឆ្នាំ<br>៩.២. អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា<br>៩.៣. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថ្នាក់ខេត្តនិងថ្នាក់ជាតិ សាកល្បង[៥៣]<br>៩.៤. សន្ទស្សន៍ថ្លៃផលិតករ[៥៤] | ភាពរកបាននៃស្ថិតិសេដ្ឋកិច្ចមានគុណភាពត្រូវបន្តធ្វើឱ្យប្រសើរឡើង។ | ធ្វើអង្កេតនានា | បោះពុម្ពផ្សាយ (ជាក្រដាស និងអេឡិចត្រូនិក) លទ្ធផលអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា<br>លទ្ធផលអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា<br>លទ្ធផលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថ្នាក់ខេត្ត និងថ្នាក់ជាតិ<br>លទ្ធផលសន្ទស្សន៍ថ្លៃផលិតករ |
| | | | | |

[៥២] ដកស្រង់ពីបទបង្ហាញរបស់វិទ្យាស្ថានជាតិស្ថិតិស្តីពី "សូចនាករតាមដានរួម (JMIs) ឆ្នាំ២០១៧-២០១៨" អំឡុងពេលវគ្គបណ្តុះបណ្តាលខ្លីស្តីពីយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ នៅថ្ងៃទី២៧-២៨ ខែកក្កដា ឆ្នាំ២០១៧។

[៥៣] ដកស្រង់ពីលក្ខខណ្ឌយោងនៃក្រសួងផែនការ គម្រោងបង្កើនសមត្ថភាពវិភាគភាពក្រីក្រ (EPACP) Grant No. TF0A0113 ផ្តល់ថវិកាដោយធនាគារពិភពលោក។

[៥៤] គម្រោងសហប្រតិបត្តិការស្ថាប័ន រវាងវិទ្យាស្ថានជាតិស្ថិតិ និងស្ថិតិស៊ុយអែដ ដំណាក់កាល ឆ្នាំ២០១៦-២០១៩ ផ្តល់ថវិកាដោយសហភាពអឺរ៉ុប (EU) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA)។

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាព | លទ្ធផលរំពឹងទុក | សូចនករលទ្ធផល | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|
| | ១០. អភិវឌ្ឍ និងអនុវត្តផែនការជាក់លាក់[៥៥] ដើម្បីកែលម្អភាពត្រឹមត្រូវ និងស្ថិតិសង្គមកិច្ចសំខាន់ៗផ្សេងទៀត ដើម្បីកែលម្អភាពទាន់ពេលវេលា និរន្តរភាព ព័ត៌មានលម្អិតភូមិសាស្ត្រ និងគុណភាពទាំងមូលរបស់វា។<br>១០.១. ធ្វើជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០១៩<br>១០.២. អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារ<br>១០.៣. អង្កេតប្រជាសាស្ត្រ និងសុខភាព<br>១០.៤. អង្កេតពិការភាពថ្នាក់ជាតិ<br>១០.៥. អង្កេតចំណាកស្រុកទីប្រជុំជនជនបទ<br>១០.៦. អង្កេតប្រជាជនវ័យចំណាស់<br>១០.៧. អង្កេតថ្នាំជក់ថ្នាក់ជាតិ<br>១០.៨. អំពើហិង្សាលើរាងកាយកុមារ | ភាពរកបាននៃស្ថិតិសង្គមកិច្ចមានគុណភាពត្រូវបន្តធ្វើឱ្យប្រសើរឡើង។ | ធ្វើអង្កេតនានា និងជំរឿនប្រជាជន | បោះពុម្ពផ្សាយ (ជាក្រដាស និងអេឡិចត្រូនិក) លទ្ធផលគូសផែនទីនិងការធ្វើសាកល្បងជំរឿនទូទៅប្រជាជនកម្ពុជា<br>លទ្ធផលជំរឿនទូទៅប្រជាជនកម្ពុជា<br>លទ្ធផលអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារ<br>លទ្ធផលអង្កេតប្រជាសាស្ត្រ និងសុខភាព<br>លទ្ធផលអង្កេតពិការភាពថ្នាក់ជាតិ<br>លទ្ធផលអង្កេតចំណាកស្រុកទីប្រជុំជនជនបទ<br>លទ្ធផលអង្កេតប្រជាជនវ័យចំណាស់<br>លទ្ធផលអង្កេតថ្នាំជក់ថ្នាក់ជាតិ<br>លទ្ធផលអំពើហិង្សាលើរាងកាយកុមារ |
| បន្តពង្រឹងច្បាប់ស្ថិតិ ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន រចនាសម្ព័ន្ធចាត់តាំង ឯករាជ្យភាពនៃវិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការ ហិរញ្ញវត្ថុ និងរដ្ឋបាលនៃប្រព័ន្ធស្ថិតិជាតិ ដើម្បីគាំទ្រដល់ការផលិត និងការអភិវឌ្ឍស្ថិតិ។ | ១. ពិនិត្យឡើងវិញនូវច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនានា ដើម្បីបន្តពង្រឹងស្វ័យភាព និងការទទួលខុសត្រូវរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីដឹកនាំប្រព័ន្ធស្ថិតិជាតិ។ | វិទ្យាស្ថានជាតិស្ថិតិត្រូវបានផ្តល់ស្វ័យភាព និងការទទួលខុសត្រូវជាចាំបាច់ ដើម្បីគ្រប់គ្រងការប្រតិបត្តិនៃប្រព័ន្ធស្ថិតិជាតិ។ | រៀបចំវិទ្យាស្ថានជាតិស្ថិតិឡើងវិញនៅឆ្នាំ២០២០ | ឯកសាររៀបចំឡើងវិញ<br>សេចក្តីសម្រេចអនុម័ត |
| | ២. រៀបចំវិទ្យាស្ថានជាតិស្ថិតិឡើងវិញ ដើម្បីកែលម្អដំណើរការស្ថិតិទាំងមូល ដោយអនុវត្តដល់ការប្រមូលទិន្នន័យ ការកែច្នៃទិន្នន័យ ការរក្សាទុក ការផ្សព្វផ្សាយ និងការទទួលបាន។ | | | |
| | ៣. រៀបចំក្រុមការងារបច្ចេកទេស ដើម្បីគាំទ្រដល់គណៈកម្មការធិការសម្របសម្រួលស្ថិតិ និងវិទ្យាស្ថានជាតិស្ថិតិ។ | ការសម្របសម្រួលសកម្មភាពស្ថិតិតាមវិស័យត្រូវបានបង្កើតជាផ្លូវការ។ | រៀបចំក្រុមការងារបច្ចេកទេសនៅឆ្នាំ២០២០ | សេចក្តីសម្រេចបង្កើតក្រុមការងារបច្ចេកទេស |

[៥៥] ដកស្រង់ពីបទបង្ហាញរបស់វិទ្យាស្ថានជាតិស្ថិតិស្តីពី “សូចនាករតាមដានរួម (JMIs) ឆ្នាំ២០១៧-២០១៨” ” អំឡុងពេលវគ្គបណ្តុះបណ្តាលខ្លីស្តីពីយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ នៅថ្ងៃទី២៧-២៨ ខែកក្កដា ឆ្នាំ២០១៧។

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាព | លទ្ធផលរំពឹងទុក | សូចនាករលទ្ធផល | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|
| | ៤. ផ្សព្វផ្សាយ និងផ្សាយជាសាធារណៈនូវច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យនានា។ | ច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យ និងការអនុវត្តត្រូវបានយល់ច្បាស់ដោយភាគីពាក់ព័ន្ធ។ | អនុម័តផែនការទំនាក់ទំនង នៅឆ្នាំ២០២១ | ឯកសារផែនការទំនាក់ទំនង សៀវភៅច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យ |
| | ៥. ក្រុមប្រឹក្សាស្ថិតិ តាមរយៈគណៈកម្មាធិការសម្របសម្រួលស្ថិតិនឹងធ្វើសនិទានកម្មឋានៈ និងតួនាទីរបស់អង្គភាពស្ថិតិដែលបានចាត់តាំងស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យ។ | ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលត្រូវបានណែនាំដោយតួនាទីនៃអង្គភាពស្ថិតិដែលបានចាត់តាំងនៅក្នុងប្រព័ន្ធស្ថិតិជាតិ។ | ធ្វើសនិទានកម្មឋានៈនៃអង្គភាពស្ថិតិដែលបានចាត់តាំង នៅឆ្នាំ២០២១ | ឯកសារផែនការធ្វើសនិទានកម្ម សេចក្តីសម្រេចធ្វើឱ្យអង្គភាពស្ថិតិដែលបានចាត់តាំងស្របច្បាប់ |
| អភិវឌ្ឍ និងអនុវត្តការកសាងសមត្ថភាពមនុស្សក្នុងការរៀបចំជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាល និងកម្មវិធីលើកទឹកចិត្តមន្ត្រីក្នុងប្រព័ន្ធស្ថិតិជាតិ។ | ១. បង្កើនចំនួនមន្ត្រីបច្ចេកទេសឱ្យបានសមស្របសម្រាប់ការចងក្រងសូចនាករសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ការកាត់បន្ថយភាពក្រីក្រ អាស៊ាន និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ | ប្រព័ន្ធស្ថិតិជាតិត្រូវបានផ្តល់មន្ត្រីដែលជាមន្ត្រីមានគុណសម្បត្តិគ្រប់គ្រាន់។ | អ្នកស្ថិតិបន្ថែមទៀត ចាប់ផ្តើមនៅឆ្នាំ ២០២០ | រៀបចំមន្ត្រីរបស់វិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង |
| | ២. ផ្តល់ការបណ្តុះបណ្តាលក្នុងផ្នែកស្ថិតិ ដូចបានបញ្ជាក់ក្នុងផ្នែក ២.៣.៤ ។ | សិក្ខាសាលាបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗត្រូវបានធ្វើឡើង។ | បណ្តុះបណ្តាលបន្ថែមទៀត ពីឆ្នាំ ២០២០ តទៅ | កម្មវិធីបណ្តុះបណ្តាល អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាល |
| | ៣. ក្រសួងផែនការត្រូវផ្តល់នូវស្វ័យភាព និងគណនេយ្យភាពបន្ថែមទៀតដល់វិទ្យាស្ថានជាតិស្ថិតិក្នុងការគ្រប់គ្រងធនធានមនុស្ស។ | វិទ្យាស្ថានជាតិស្ថិតិត្រូវបានផ្តល់នូវស្វ័យភាព និងគណនេយ្យភាពចាំបាច់បន្ថែមទៀត ដើម្បីគ្រប់គ្រងធនធានមនុស្សរបស់ខ្លួន។ | បានរៀបចំអង្គភាពនៅក្នុងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីចូលរួមក្នុងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ | ត្រួតពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធរបស់វិទ្យាស្ថានជាតិស្ថិតិ |
| | ៤. ណែនាំត្រួតពិនិត្យការអនុវត្តការងាររបស់មន្ត្រីប្រចាំឆ្នាំ។ | ធនធានមនុស្សនៃវិទ្យាស្ថានជាតិស្ថិតិត្រូវបានគ្រប់គ្រងតាមរយៈគម្រោងប្រកបដោយភាពច្នៃប្រឌិត។ | ត្រួតពិនិត្យការអនុវត្តការងារប្រចាំឆ្នាំ នៅឆ្នាំ២០២០ | សៀវភៅណែនាំការអនុវត្តការងារ របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ |
| | ៥. ណែនាំប្រព័ន្ធមួយសម្រាប់បញ្ជាក់ចំណេះដឹងខាងស្ថិតិ និងការលើកទឹកចិត្តក្នុងការគាំទ្រដល់វិញ្ញាបនប័ត្រ រួមទាំងការងារអាជីព។ | | វិញ្ញាបនប័ត្រក្នុងប្រព័ន្ធ ការងារអាជីព នៅឆ្នាំ២០២២ | សេចក្តីណែនាំវិញ្ញាបនប័ត្រក្នុងប្រព័ន្ធ សេចក្តីណែនាំការងារអាជីព |
| | ៦. រៀបចំ និងអនុវត្តសេចក្តីថ្លែងការណ៍ស្តីពីតម្រូវការអភិវឌ្ឍន៍ និងបណ្តុះបណ្តាលមន្ត្រីរយៈពេលវែង និងកម្មវិធីជាភាសាខ្មែរសម្រាប់ប្រព័ន្ធស្ថិតិជាតិ។ | ការបណ្តុះបណ្តាលសម្រាប់អ្នកពាក់ព័ន្ធនឹងស្ថិតិ ត្រូវបានរៀបចំផែនការ និងអនុវត្តន៍។ | កម្មវិធីអភិវឌ្ឍន៍មន្ត្រីសម្រាប់ប្រព័ន្ធស្ថិតិជាតិ នៅឆ្នាំ២០២០ | ឯកសារវិភាគតម្រូវការបណ្តុះបណ្តាល ឯកសារកម្មវិធីអភិវឌ្ឍន៍មន្ត្រី |
| អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រ និងផែនការបច្ចេកវិទ្យាគមនាគមន៍ | ១. បង្កើត និងអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនៃ | ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាត្រូវ | អនុម័តគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា និង | ឯកសារគោលនយោបាយបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា |

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាព | លទ្ធផលរំពឹងទុក | សូចនករលទ្ធផល | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|
| និងព័ត៌មានវិទ្យា ដើម្បីផ្តល់នូវសមត្ថភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ដោយគាំទ្រគ្រប់ទិដ្ឋភាពទាំងអស់នៃការប្រមូល ការកែច្នៃ ការវិភាគ ការថែរក្សា និងការផ្សព្វផ្សាយស្ថិតិ។ | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាសម្រាប់វិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធស្ថិតិជាតិ។ | បានគ្រប់គ្រង ដើម្បីលើកកម្ពស់ការសិក្សា និងការគ្រប់គ្រងចំណេះដឹងនៅក្នុងប្រព័ន្ធស្ថិតិជាតិ។ | ផែនការយុទ្ធសាស្ត្រសម្រាប់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា នៅឆ្នាំ២០២០ | ឯកសារផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា |
| | ២. អនុវត្តអនុសាសន៍សម្រាប់ការគ្រប់គ្រងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យាតាមផែនការរបស់វិទ្យាស្ថានជាតិស្ថិតិសម្រាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា ប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាន (DBMS) ការទាញសំណុំឯកសារត្រឡប់មកវិញ សុវត្ថិភាពព័ត៌មានវិទ្យា និងឃ្លាំងទិន្នន័យ។ | | រៀបចំឡើងវិញនូវការគ្រប់គ្រងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យានៅវិទ្យាស្ថានជាតិស្ថិតិ នៅឆ្នាំ២០២២ | សៀវភៅណែនាំប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាន<br>ការទាញសំណុំឯកសារត្រឡប់មកវិញ<br>សៀវភៅណែនាំសុវត្ថិភាពទិន្នន័យ<br>សេចក្តីណែនាំឃ្លាំងទិន្នន័យ |
| អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយ យុទ្ធសាស្ត្រគាំទ្រ និងចំណេះដឹងផ្នែកស្ថិតិ ដើម្បីផ្តល់ការទទួលបានឱ្យកាន់តែប្រសើរឡើងដល់អ្នកប្រើប្រាស់ទាំងអស់ និងបង្កើនសេចក្តីត្រូវការសម្រាប់ស្ថិតិ។ | ១. បង្កើត និងបោះពុម្ពផ្សាយគោលនយោបាយផ្សព្វផ្សាយថ្មីៗរបស់វិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធស្ថិតិជាតិដោយយកចិត្តទុកដាក់ពីគំនិតផ្តួចផ្តើមទិន្នន័យចំហ (Open Data) និងការអនុវត្តប្រព័ន្ធផ្សព្វផ្សាយទិន្នន័យទូទៅ (GDDS)។ | គោលនយោបាយផ្សព្វផ្សាយត្រូវបានធ្វើបច្ចុប្បន្នកម្ម ដើម្បីបញ្ចូលគំនិតផ្តួចផ្តើមទិន្នន័យថ្មី។ | អនុម័តគោលនយោបាយផ្សព្វផ្សាយ នៅឆ្នាំ២០២០ | ឯកសារគោលនយោបាយ |
| | ២. ណែនាំឱ្យឆាប់រហ័សតាមដែលអាចធ្វើបាននូវប្រតិទិនចេញផ្សាយទិន្នន័យជាមុនសម្រាប់ទិន្នន័យសំខាន់ៗ។ | អ្នកប្រើប្រាស់ត្រូវបានយល់ដឹងនៅពេលស្ថិតិថ្មីការត្រូវបានចេញផ្សាយដោយតម្លាភាព និងភាពជឿជាក់។ | ចេញផ្សាយប្រតិទិនសម្រាប់ស្ថិតិដែលបានចាត់តាំង នៅឆ្នាំ២០២០ | ចេញផ្សាយប្រតិទិន |
| | ៣. បង្កើនកម្រិតគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីផ្សព្វផ្សាយអំពីកម្ពុជា និងព័ត៌មានអំពីវិទ្យាស្ថានជាតិស្ថិតិ និងប្រព័ន្ធស្ថិតិជាតិ។ ផ្តល់បញ្ជាប់ដោយផ្ទាល់ពីគេហទំព័រវិទ្យាស្ថានជាតិស្ថិតិទៅនឹងទិន្នន័យស្ថិតិដែលមាននៅលើគេហទំព័ររបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល។ ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលគួរដាក់ស្ថិតិរបស់ខ្លួននៅលើគេហទំព័ររបស់ខ្លួន។ | លក្ខណៈពិសេសគេហទំព័រត្រូវបានបន្ថែម ដើម្បីឱ្យអ្នកប្រើប្រាស់ងាយស្រួលប្រើ។ | បង្កើនកម្រិតគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ នៅឆ្នាំ២០២០ | គេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ<br>គេហទំព័ររបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល |

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាព | លទ្ធផលរំពឹងទុក | សូចនករលទ្ធផល | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|
| | ៤. ផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យមានស្រាប់របស់មជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិ និងសេវាកម្មដែលត្រូវផ្តល់ជូន តាមដានកំណត់ត្រាភ្ញៀវ និងសំណូមពរដែលមាន រួមទាំងប្រព័ន្ធព័ត៌មានកម្ពុជា (CAMInfo) និងប័ណ្ណសារទិន្នន័យជាតិ (NADA)។ | អ្នកប្រើប្រាស់ជូនកាលត្រូវបានជូនដំណឹងអំពីបណ្តាញផ្សព្វផ្សាយបន្ថែមដែលមានស្រាប់។ | កែលម្អមជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិ នៅឆ្នាំ២០២០ | ធ្វើឱ្យកាន់តែប្រសើរឡើងនូវមធ្យោបាយរបស់មជ្ឈមណ្ឌលក្នុងការគ្រប់គ្រងទិន្នន័យ |
| | ៥. បង្កើត និងអនុវត្តវិធីសាស្ត្រទូលំទូលាយមួយ ដល់ទំនាក់ទំនង និងការគាំទ្រដែលពាក់ព័ន្ធនឹងការធ្វើផែនការ ការពិគ្រោះយោបល់ និងមតិត្រឡប់ជាមួយអ្នកប្រើប្រាស់ រួមទាំងប្រព័ន្ធផ្សព្វផ្សាយ។ | ទំនាក់ទំនង និងគាំទ្រផលិតផល និងសេវាកម្មរបស់ប្រព័ន្ធស្ថិតិជាតិ ទៅកាន់អ្នកពាក់ព័ន្ធផ្សេងៗត្រូវបានគ្រោងទុក។ | អនុម័តផែនការទំនាក់ទំនង និងការគាំទ្រ នៅឆ្នាំ២០២១ | ឯកសារផែនការ |
| | ៦. ប្រើប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីទំនាក់ទំនងស្ថិតិ និងការវិភាគ។ | អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមអាចត្រូវបានធ្វើបច្ចុប្បន្នកម្មលើផលិតផល និងសេវាកម្មរបស់ប្រព័ន្ធស្ថិតិជាតិ។ | បង្កើនវត្តមានប្រព័ន្ធផ្សព្វផ្សាយសង្គម នៅឆ្នាំ២០២១ | ធ្វើប្រព័ន្ធផ្សព្វផ្សាយសង្គម |
| | ៧. លើកទឹកចិត្តដល់ការបង្កើតវេទិកាអ្នកប្រើប្រាស់អនឡាញ ដែលក្នុងនោះអ្នកប្រើប្រាស់អាចផ្លាស់ប្តូរព័ត៌មានអំពីទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ និងធ្វើអន្តរកម្មជាមួយមន្ត្រីបច្ចេកទេស។ | អ្នកប្រើប្រាស់អនឡាញអាចត្រូវបានធ្វើបច្ចុប្បន្នកម្ម តាមរយៈការផ្ញើសារអំពីផលិតផល និងសេវាកម្មរបស់ប្រព័ន្ធស្ថិតិជាតិ | ដំណើរការវេទិកាអ្នកប្រើប្រាស់អនឡាញ នៅឆ្នាំ២០២២ | បណ្តាញផ្ញើសារ សំណុំឯកសារអ្នកប្រើប្រាស់ |
| | ៨. ធ្វើអង្កេតតម្រូវការប្រើប្រាស់ និងការពេញចិត្តរបស់អ្នកប្រើប្រាស់ នៅដើមដំណាក់កាលនៃយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ និងធ្វើរៀងរាល់ ៣-៥ឆ្នាំ ជាបន្តបន្ទាប់។ | បទពិសោធន៍របស់អ្នកប្រើប្រាស់ជាមួយប្រព័ន្ធស្ថិតិជាតិត្រូវបានវាស់វែង និងយល់ដឹងកាន់តែប្រសើរដោយអ្នកផ្គត់ផ្គង់ទិន្នន័យ។ | លទ្ធផលអង្កេត ៣ ខែ បន្ទាប់ពីការប្រមូលទិន្នន័យ | លទ្ធផលអង្កេត |
| | ៩. ផ្តល់ជំពូកថវិកាសម្រាប់ការផ្សព្វផ្សាយ និងការគាំទ្រ ជាពិសេសក្នុងសកម្មភាពទ្រង់ទ្រាយធំ។ | ការផ្តល់មូលនិធិត្រូវបានធានាសម្រាប់ការផ្សព្វផ្សាយស្ថិតិសំខាន់ៗពីជំរឿន និងអង្កេតនានា។ | អនុម័តជំពូកថវិកាសម្រាប់ការផ្សព្វផ្សាយ និងការគាំទ្រ | ឯកសារថវិកា |

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាព | លទ្ធផលរំពឹងទុក | សូចនករលទ្ធផល | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|
| ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលនៃប្រព័ន្ធស្ថិតិជាតិ ដើម្បីលុបបំបាត់ជម្លោះទិន្នន័យ (Data Conflicts) និងផលិតស្ថិតិអាចប្រៀបធៀបបាន ទាន់ពេលវេលា ក្នុងប្រព័ន្ធស្ថិតិជាតិប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។ | ១. ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិគួរប្រជុំតាមកាលកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ។ | គោលនយោបាយ និងកម្មវិធីជាច្រើនទៀតត្រូវបានបង្កើតឡើង វាយតម្លៃ និងអនុវត្តជាមួយការកើនឡើងនៃចំនួនកិច្ចប្រជុំ។ | កិច្ចប្រជុំដែលបានចូលរួមកាន់តែច្រើនរបស់ក្រុមប្រឹក្សាស្ថិតិ និងគណៈកម្មាធិការសម្របសម្រួលស្ថិតិ | សេចក្តីជូនដំណឹង និងកំណត់ហេតុកិច្ចប្រជុំ |
| | ២. ធ្វើការវាយតម្លៃ តាមដាន និងលុបបំបាត់ការជាន់គ្នាក្នុងការប្រមូលទិន្នន័យដោយក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលតាមរយៈក្រុមការងារបច្ចេកទេស។ | ការជាន់គ្នានៃទិន្នន័យដែលមិនចាំបាច់ត្រូវបានចៀសវាង និងការផលិតទិន្នន័យត្រូវបានកំណត់អាទិភាព។ | វាយតម្លៃការជាន់គ្នានៃទិន្នន័យ និងផ្តល់អនុសាសន៍ស្តីពីការកំណត់សេរី នៅឆ្នាំ២០២០ | របាយការណ៍វាយតម្លៃ សេចក្តីសម្រេចស្តីពីស្ថិតិដែលបានចាត់តាំង |
| | ៣.បង្កើតអ្នកទំនាក់ទំនងតែមួយសម្រាប់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ដើម្បីផ្តល់បណ្តាញប្រកបដោយប្រសិទ្ធភាពសម្រាប់ការសម្របសម្រួល។ | លំហូរនៃការទំនាក់ទំនងផ្លូវការ និងក្រៅផ្លូវការត្រូវបានកែលម្អ និងសម្រួលការសម្របសម្រួលក្នុងប្រព័ន្ធ | បានតែងតាំងអ្នកសម្របសម្រួលរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល នៅឆ្នាំ២០២០ | បញ្ជីរាយនាមអ្នកសម្របសម្រួលរបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល |
| | ៤. ធ្វើការពិនិត្យពេញលេញឡើងវិញនៃការចែករំលែកព័ត៌មាន និងលទ្ធភាពសម្រាប់ពង្រីកការចែករំលែកទិន្នន័យ និងបច្ចេកវិទ្យាប្រសើរបំផុតសម្រាប់អនុវត្ត និងបង្កើតកិច្ចព្រមព្រៀងផ្លូវការ (អនុស្សរណៈនៃការយោគយល់)។ | ការចែករំលែកទិន្នន័យនៅក្នុងប្រព័ន្ធស្ថិតិជាតិត្រូវបានបង្កើតជាស្ថាប័ន។ | អនុស្សរណៈស្តីពីការចែករំលែកទិន្នន័យ នៅឆ្នាំ២០២០ | អនុស្សរណៈ |
| ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងការងារ និងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីធានានូវការគាំទ្រការព្យាករណ៍ ការបន្ត និងការរួមបញ្ចូលគ្នាទៅនឹងសកម្មភាពអាទិភាពរបស់ប្រព័ន្ធស្ថិតិជាតិ ក៏ដូចជាការផ្ទេរជំនាញពេញលេញ និងចំណេះធ្វើ។ | ១. រៀបចំដំណើរការច្បាស់លាស់សម្រាប់ការសម្របសម្រួលជំនួយបច្ចេកទេស និងគម្រោងដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍តាមរយៈអនុក្រុមបច្ចេកទេសនៃក្រុមការងារបច្ចេកទេស ផែនការ និងកាត់បន្ថយភាពក្រីក្រ (TWG-PPR) ស្តីពីទិន្នន័យសម្រាប់ការអភិវឌ្ឍ ឬក្រុមការងារបច្ចេកទេសសមស្របដទៃទៀត ដែលត្រូវបានបង្កើតដោយក្រុមប្រឹក្សាស្ថិតិ/គណៈកម្មាធិការសម្របសម្រួលស្ថិតិ ដើម្បីបង្កើនប្រសិទ្ធភាពរបស់ខ្លួន និងដោះស្រាយបញ្ហាទិន្នន័យសំខាន់ៗ និងគម្លាតសមត្ថភាព។ | របៀបវារៈនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសត្រូវបានពិភាក្សា និងផ្តល់អាទិភាពដល់ប្រព័ន្ធដ៏ទូលំទូលាយ។ | ក្រុមការងារបច្ចេកទេសស្តីពីកិច្ចសហប្រតិបត្តការដៃគូអភិវឌ្ឍន៍ នៅឆ្នាំ ២០២០ | ដំណើរការក្រុមការងារបច្ចេកទេស |

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាព | លទ្ធផលរំពឹងទុក | សូចនករលទ្ធផល | មធ្យោបាយផ្ទៀងផ្ទាត់ |
|---|---|---|---|---|
| | ២. ស្វែងរកការទទួលបានការប្តេជ្ញាចិត្តយូរអង្វែងសម្រាប់ធ្វើឱ្យប្រសើរឡើងនូវការព្យាករណ៍ហិរញ្ញប្បទាន និងជំនួយដូចបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។ | | របាយការណ៍ប្រចាំឆ្នាំស្តីពីការគាំទ្រក្រៅប្រទេសដល់ស្ថិតិ នៅឆ្នាំ២០២០ | របាយការណ៍ប្រចាំឆ្នាំ |
| ជំរុញស្ថិរភាព និងកំណើននៃការគាំទ្រថវិកាសម្រាប់ប្រព័ន្ធស្ថិតិជាតិពីប្រភពក្នុងស្រុក និងអន្តរជាតិ ដើម្បីអាចធ្វើផែនការ និងអនុវត្តកម្មវិធីស្ថិតិអាទិភាពប្រកបដោយប្រសិទ្ធភាព។ | ១. ធ្វើការអនុម័តផែនការ និងថវិកាស្នើសុំដោយវិទ្យាស្ថានជាតិស្ថិតិ និងមជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិនៅក្នុងបរិបទយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ មុននឹងដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិការបស់ក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលនីមួយៗ។ | កញ្ចប់ថវិកាត្រូវបានរៀបចំ ពិភាក្សា វាយតម្លៃ និងដាក់ជាអាទិភាព។ | អនុម័តកញ្ចប់ថវិកា នៅឆ្នាំ២០២០ | ឯកសារថវិកា |
| | ២. បង្កើត និងអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃដើម្បីតាមដានប្រភព និងការប្រើប្រាស់មូលនិធិពាក់ព័ន្ធនឹងយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។ | ប្រភព និងការប្រើប្រាស់មូលនិធិត្រូវបានតាមដាននៅក្នុងបរិបទយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ។ | កិច្ចដំណើរការប្រព័ន្ធតាមដាន និងវាយតម្លៃ នៅឆ្នាំ២០២០ | របាយការណ៍តាមដាន និងវាយតម្លៃ |

# ឯកសារយោង


សៀវភៅណែនាំស្តីពីការរៀបចំយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ (NSDS) (សេចក្តីណែនាំលេខ ២.៣ យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ) PARIS21 (ខែមេសា ឆ្នាំ២០១៧)។

គម្រោងកិច្ចសហប្រតិបត្តិការស្ថាប័នរវាងវិទ្យាស្ថានជាតិស្ថិតិកម្ពុជា និងស្ថិតិស៊ុយអែត (SCB) របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ខែកក្កដា-ធ្នូ ឆ្នាំ២០១៦ (ខែកុម្ភៈ ឆ្នាំ២០១៧)។

របាយការណ៍ប្រចាំឆ្នាំ ២០១៥ ៖ ប្រព័ន្ធស្ថិតិជាតិនៅកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ខែធ្នូ ឆ្នាំ២០១៦)។

ប្រព័ន្ធស្ថិតិសហគមន៍អាស៊ាន (ACSS) ក្រមអនុវត្តន៍ គណៈកម្មាធិការប្រព័ន្ធស្ថិតិសហគមន៍អាស៊ាន (ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២)។

ច្បាប់ស្តីពីស្ថិតិកម្ពុជា ឆ្នាំ ២០១៥ (បកប្រែមិនផ្លូវការ) វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ (ខែកុម្ភៈ ឆ្នាំ២០១៦)។

របាយការណ៍ប្រទេសស្តីពីការគាំទ្រដល់ស្ថិតិកម្ពុជា (CRESS) PARIS21/វិទ្យាស្ថានជាតិស្ថិតិ (ខែឧសភា ឆ្នាំ២០១៧)។

ផែនទីបង្ហាញផ្លូវនៃយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ PARIS21 (ខែកុម្ភៈ ឆ្នាំ២០១៦)។

យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី៣ (ខែកញ្ញា ឆ្នាំ២០១៣)។

របាយការណ៍វេទិកាថ្នាក់ជាតិស្តីពីការរៀបចំយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ឆ្នាំ២០១៧-២០២៣ ក្រសួងផែនការ (ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦)។

របាយការណ៍ស្តីពីវេទិកាថ្នាក់ជាតិជាន់ខ្ពស់ស្តីពីការគាំទ្រសម្រាប់ស្ថិតិ PARIS21/វិទ្យាស្ថានជាតិស្ថិតិ (ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៣)។

ផែនការមេស្ថិតិកម្ពុជា ឆ្នាំ២០០៨ - ២០១៥ វិទ្យាស្ថានជាតិស្ថិតិ (ខែតុលា ឆ្នាំ២០០៥)។

ផែនការមេស្ថិតិកម្ពុជា របាយការណ៍ពាក់កណ្តាលអាណត្តិ វិទ្យាស្ថានជាតិស្ថិតិ (ខែវិច្ឆិកា ឆ្នាំ២០១២)។

អនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង (បកប្រែមិនផ្លូវការ) រាជរដ្ឋាភិបាលកម្ពុជា (ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០)។

អនុក្រឹត្យស្តីពីការបង្កើតនាយកដ្ឋានមួយចំនួន ចំណុះវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ រាជរដ្ឋាភិបាលកម្ពុជា (ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩)។

អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ (បកប្រែមិនផ្លូវការ) រាជរដ្ឋាភិបាលកម្ពុជា (ថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧)។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤ - ២០១៨ (ខែកក្កដា ឆ្នាំ២០១៤)។

## ឧបសម្ព័ន្ធ ១ ៖

## ការវិភាគសូចនាករ សម្រាប់ជំរឿន និង អង្កេត ឆ្នាំ២០១៩ - ២០២៣

# ការវិភាគសូចនាករ សម្រាប់ជំរឿន និង អង្កេត ឆ្នាំ២០១៩ - ២០២៣

| ឆ្នាំ | ដំណាក់កាលគោលនយោបាយសំខាន់ៗ | | | ជំរឿន | អង្កេត | | ឆ្នាំ |
|---|---|---|---|---|---|---|---|
| ២០១៩ | | | | ជំរឿនទូទៅប្រជាជន ឆ្នាំ២០១៩ | | អង្កេតចន្លោះជំរឿនកសិកម្ម | ២០១៩ |
| ២០២០ | | របាយការណ៍គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | បន្តតាមដានសូចនាករសម្រាប់<br>- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ<br>- គោលដៅអភិវឌ្ឍន៍កបដោយចីរភាព<br>- អាស៊ាន | រៀបចំជំរឿនសេដ្ឋកិច្ច | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ជាមួយផ្នែកស្នូល និងទម្រង់វិលជុំ<br><br>អង្កេតដទៃទៀត ៖<br>អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារ<br>ពិការភាពថ្នាក់ជាតិ<br>អង្កេតចំណាកស្រុកទីប្រជុំជនជនបទ<br>អង្កេតប្រជាជនវ័យចំណាស់<br>អង្កេតថ្នាំជក់ថ្នាក់ជាតិ<br>អំពើហិង្សាលើរាងកាយកុមារ<br>អង្កេតសេដ្ឋកិច្ច<br>អង្កេតផ្នែកមិនរៀបរយ និងសេដ្ឋកិច្ចមិនបានពិនិត្យ | អង្កេតប្រជាសាស្ត្រ និង សុខភាព | ២០២០ |
| ២០២១ | | | | ជំរឿនសេដ្ឋកិច្ច | | | ២០២១ |
| ២០២២ | រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | | | រៀបចំជំរឿនកសិកម្ម | | | ២០២២ |
| ២០២៣ | | | | ជំរឿនកសិកម្ម | | | ២០២៣ |

# ឧបសម្ព័ន្ធ ២ ៖ ផែនការអនុវត្តន៍ ឆ្នាំ២០១៩ - ២០២៣

## ផែនការអនុវត្តន៍ ឆ្នាំ២០១៩ - ២០២៣

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាព | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| អភិវឌ្ឍ អនុវត្ត និងថែរក្សានូវសំណុំទិន្នន័យស្ថិតិដែលមានគុណភាពខ្ពស់[៥៦] ដោយគ្រប់ស្ថាប័នទាំងអស់នៃប្រព័ន្ធស្ថិតិជាតិក្រោមការដឹកនាំរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីឆ្លើយតបគ្រប់គ្រាន់ទៅនឹងតម្រូវការស្ថិតិនៃកិច្ចដំណើរការអភិវឌ្ឍន៍ដែលកើតចេញពីការប្តេជ្ញានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការយុទ្ធសាស្ត្រអាស៊ានតាមផ្នែក និងតម្រូវការរបស់អ្នកប្រើប្រាស់ដទៃទៀត។ | ១. រួមបញ្ចូលយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ | ● | | | | |
| | ២. ដឹកនាំការស្វែងរកគ្រប់លទ្ធភាពទាំងអស់សម្រាប់ពង្រីកការប្រើប្រាស់កំណត់ត្រារដ្ឋបាល ប្រព័ន្ធព័ត៌មានគ្រប់គ្រង និងធាតុនៃទិន្នន័យទូលាយ (Big Data) ជាប្រភពនៃទិន្នន័យសម្រាប់គោលបំណងស្ថិតិ ដើម្បីបំពេញចន្លោះខ្វះខាត និងជាពិសេសជាប្រភពសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងទិន្នន័យបំបែក (តាមភេទ ក្រុមអាយុ ពិការភាព និងថ្នាក់ក្រោមជាតិ)។ | ● | ● | ● | ● | ● |
| | ៣. ធ្វើផែនការវាយតម្លៃ សម្របសម្រួល និងធ្វើឱ្យស្របច្បាប់នូវសំណុំទិន្នន័យពីអង្គការផ្សេងៗ ដូចជាវិទ្យាស្ថានស្រាវជ្រាវ សមាគមវិជ្ជាជីវៈ និងអង្គការមិនមែនរដ្ឋាភិបាល។ | ● | ● | ● | | |
| | ៤. បង្កើតបញ្ជីវាយឈ្មោះករណីដែលបទដ្ឋាន និងចំណាត់ថ្នាក់អន្តរជាតិមិនត្រូវបានអនុវត្តក្នុងប្រព័ន្ធស្ថិតិជាតិ និងបង្កើតផែនការសម្រាប់ការអនុវត្តរបស់វា។ | ● | ● | ● | | |
| | ៥. អភិវឌ្ឍ និងយល់ព្រមតាមក្របខ័ណ្ឌធានាគុណភាពទិន្នន័យ។ | ● | ● | | | |
| | ៦. ផលិតម៉េតាទិន្នន័យសមស្របសម្រាប់វិស័យទាំងអស់នៃស្ថិតិ និងធ្វើវាឱ្យបានទៅដល់អ្នកប្រើប្រាស់។ | ● | ● | ● | ● | ● |
| | ៧. បង្កើតសេចក្តីណែនាំគោលនយោបាយច្បាស់លាស់មួយ និងកម្មវិធីសម្រាប់អភិវឌ្ឍន៍ស្ថិតិថ្នាក់ក្រោមជាតិ។ | ● | | | | |
| | ៨. បញ្ជ្រាបសូចនាករផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ទៅក្នុងសកម្មភាពស្ថិតិថ្នាក់ជាតិ វិស័យ និងថ្នាក់ក្រោមជាតិតាមរយៈ អនុក្រុមការងារបច្ចេកទេសផែនការ និងកាត់បន្ថយភាពក្រីក្រ (TWG-PPR) អំពីទិន្នន័យសម្រាប់ការអភិវឌ្ឍ ឬក្រុមការងារបច្ចេកទេសសមស្របដទៃទៀតដែលត្រូវបានបង្កើតដោយក្រុមប្រឹក្សាស្ថិតិ/គណៈកម្មាធិការសម្របសម្រួលស្ថិតិ។ | ● | | | | |
| | ៩. អភិវឌ្ឍ និងអនុវត្តផែនការជាក់លាក់[៥៧] ដើម្បីកែលម្អស្ថិតិសេដ្ឋកិច្ច បរិស្ថាន និងហិរញ្ញវត្ថុ រួមទាំងគណនេយ្យជាតិ ថ្លៃ ជញ្ជីងទូទាត់ និងស្ថិតិពាណិជ្ជកម្មទំនិញអន្តរជាតិ ដើម្បីធ្វើវាកាន់តែទាន់ពេលវេលា គុណភាពជាងមុន និងភាពសំខាន់ជាងមុន។<br>៩.១. អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាប្រចាំឆ្នាំ<br>៩.២. អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា<br>៩.៣. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថ្នាក់ខេត្តនិងថ្នាក់ជាតិសាកល្បង[៥៨] | ● | ● | ● | ● | ● |

[៥៦] ភាពសំខាន់ ភាពទាន់ពេលវេលា ភាពគួរទុកចិត្តបាន ភាពទទួលបាន។

[៥៧] ដកស្រង់ពីបទបង្ហាញរបស់វិទ្យាស្ថានជាតិស្ថិតិស្តីពី “សូចនាករតាមដានរួម (JMIs) ឆ្នាំ២០១៧-២០១៨” អំឡុងពេលវគ្គបណ្តុះបណ្តាលខ្លីស្តីពីយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ នៅថ្ងៃទី២៧-២៨ ខែកក្កដា ឆ្នាំ២០១៧។

[៥៨] ដកស្រង់ពីលក្ខខណ្ឌយោងនៃក្រសួងផែនការ គម្រោងបង្កើនសមត្ថភាពវិភាគភាពក្រីក្រ (EPACP) Grant No. TF0A0113 ផ្តល់ថវិកាដោយធនាគារពិភពលោក។

| គោលដៅយុទ្ធសាស្ត្រ | សកម្មភាព | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| | ៩.៤. សន្ទស្សន៍ថ្លៃផលិតករ[៥៩] | | | | | |
| | ១០. អភិវឌ្ឍ និងអនុវត្តផែនការជាក់លាក់[៦០] ដើម្បីកែលម្អភាពក្រីក្រ និងស្ថិតិសង្គមកិច្ចសំខាន់ៗផ្សេងទៀត ដើម្បីកែលម្អភាពទាន់ពេលវេលា និរន្តរភាព ព័ត៌មានលម្អិតភូមិសាស្ត្រ និងគុណភាពទាំងមូលរបស់វា។<br>១០.១. ធ្វើជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០១៩<br>១០.២. អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារ<br>១០.៣. អង្កេតប្រជាសាស្ត្រ និងសុខភាព<br>១០.៤. អង្កេតពិការភាពថ្នាក់ជាតិ<br>១០.៥. អង្កេតចំណាកស្រុកទីប្រជុំជនជនបទ<br>១០.៦. អង្កេតប្រជាជនវ័យចំណាស់<br>១០.៧. អង្កេតថ្នាំជក់ថ្នាក់ជាតិ<br>១០.៨. អំពើហិង្សាលើរាងកាយកុមារ | ● | ● | ● | ● | ● |
| | ១១. អភិវឌ្ឍ និងអនុវត្តក្រុមសង្កេតការភពផែនដី | ● | ● | ● | ● | ● |
